# ព្រះ

# ត្រៃបិដកបាលី

និង

សេចក្តីប្រែជាភាសាខ្មែរ

# សុត្តន្តបិដក

ខុទ្ទកនិកាយ ឥតិវុត្តកៈ

ទុតិយភាគ

# ៥៣

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស ២៥០០

ឯកសារគម្ពីរព្រះត្រៃបិដកស្កាននេះ
ត្រូវបានថតចេញពីច្បាប់គម្ពីរព្រះត្រៃបិដកជប៉ុន ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ៩១ ដល់ ភាគ១១០
ត្រូវបានរៀបចំធ្វើឡើងដោយ គេហទំព័រ៥000ឆ្នាំ បូជា
ចំពោះព្រះពុទ្ធសាសនា សម្រាប់ជាធម្មទាន ៗ

ផ្តល់សៀវភៅគម្ពីរព្រះត្រៃបិដកសម្រាប់ការងារ
ដោយ ឧបាសិកា កាំង ហ្គិចណៃ ៗ

គ្រប់គ្រងគម្រោង (ទូទៅ និងផ្នែកបច្ចេកទេស)
ដោយ ឧបាសក ស្រុង-ចាន់ណា ៗ

ត្រួតពិនិត្យឡើងវិញ
ដោយ ចន-ស្រីស្រស់ ៗ

ថតស្កានដោយ
ប្អូនប្រុស ម៉ាន់ សាវ៉េត

www.5000-years.org

ក្រោមការឧបត្ថម្ភយ៉ាងក្រៃលែងអំពី៖

- ឧបាសិកា កាំង ហ៊ុចណៃ (ភ្នំពេញ)
- ឧបាសក ផុត លីស្រ៊ុង និង ឧបាសិកា លី សុខា ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក សន ចន និង ឧបាសិកា អ៊ូច សាវៀង ព្រមទាំងបុត្រ (បាត់ដំបង)
- ឧបាសក ជា ស៊ីវត្ថានា និងឧបាសិកា ឃុន សូនីម៉ា ព្រមទាំងបុត្រី ជា សុមេធាធីតា (ស.រ.អ)
- លោក ជឹម-ជា និងលោកស្រី រតនី ស្រីមុំ (ភ្នំពេញ)
- ឧបាសក ផែង យឿន (កូរ៉េ)
- លោក ស៊ុក ចាន់សេរី (បន្ទាយមានជ័យ)
- ឧបាសិកា យ៉ា វ៉ារី (បន្ទាយមានជ័យ)
- ប្អូនស្រី យ៉ា សុភ: (បន្ទាយមានជ័យ)
- ឧបាសិកា កោ សេង (ភ្នំពេញ)
- លោកស្រី ប៉ាន សុគន្ធានីន និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក ស្រ៊ុង ចាន់ណា និង ឧបាសិកា ចន ស្រីស្រស់
ព្រមទាំងបុត្រ ចាន់ណា សុធារនីរាជ, ចាន់ណា សុធារនិរោធ (ភ្នំពេញ)
- លោកស្រី ស្រ៊ុង ចាន់រស្មី និង ស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- កញ្ញា ស្រ៊ុង ចាន់រតនា (ភ្នំពេញ)
- លោក ស្រ៊ុង យូហេង (ភ្នំពេញ)
- លោក នង សុផល (កូរ៉េ)
- ប្អូនស្រី សុខ អេង (កំពង់ចាម)
- កញ្ញា ចន កក្កដា (បាត់ដំបង)
- លោកស្រី ចន សត្យា និងលោក ទួត សេរីសីក ព្រមទាំងបុត្រ (ភ្នំពេញ)
- លោក ចន រចនា (បាត់ដំបង)
- កញ្ញា ស៊ៃ សុផារី (បាត់ដំបង)
- កញ្ញា យឿម សុផានី (បាត់ដំបង)
- លោក ម៉ៅ គន្ធា និងលោកស្រី ធៀង សេដ្ឋា (បាត់ដំបង)
- លោក សៅ សារ៉ុម (បាត់ដំបង)
- ព្រះតេជព្រះគុណ ជុំ សារ: (ព្រះចៅអធិការវត្ត សម សាន្ត ខេត្តបាត់ដំបង)
- ឧបាសិកា វ៉ាន់ លុយ និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- លោកស្រី ហួ ច័ន្ទសុវណ្ណ និងស្វាមី ព្រមទាំងបុត្រ (ស.រ.អ)

# ព្រះ
# ត្រៃបិដកបាលី
## និង
## សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
## ខុទ្ទកនិកាយ ឥតិវុត្តកៈ
# ទុតិយភាគ
# ៥៣



ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៥០១

## ឧទ្ទិសកថា

យើងខ្ញុំ សូមផ្ចង់ស្មារតីសូត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។
ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។
ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានសូត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

# អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន " ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យនៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណាប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណាប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្តានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវអន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្តីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើឃោរឃៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្តេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

**អ្នកតំណាងចាត់ការ** The Rev. Seikyo Muchaku

**ប្រធានការិយាល័យ** The Rev. Eiitsu Shinohara

**អ្នកចាត់ការ**

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# 『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

世話人代表　無着　成恭
事務局長　篠原　鋭一

世話人　松永　然道　有馬　実成
伊藤　佳通　渡井　奎一
杉谷　義純　茂田　真澄
前田　利勝　中島　教之
永　六輔

# Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

**TRIPITAKA PUBLISHING SUPPORT COMMITTEE**
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# 『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

世話人代表　無着　成恭
事務局長　篠原　鋭一

世話人　松永　然道　有馬　実成
伊藤　佳通　渡井　奎一
杉谷　義純　茂田　真澄
前田　利勝　中島　教之
永　六輔

# សុត្តន្តបិដក

## ខុទ្ទកនិកាយ ឥតិវុត្តកៈ

## ទុតិយភាគ

៥៣

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស ឥតិវុត្តកស្ស

# ទុតិយោ ភាគោ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## ឯកនិបាតស្ស បឋមវគ្គោ

(១) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ឯកធម្មំ ភិក្ខវេ បជហថ អហំ វោ បាដិភោគោ អនាគាមិតាយ ។ កតមំ ឯកធម្មំ ។ លោភំ ភិក្ខវេ ឯកធម្មំ បជហថ អហំ វោ បាដិភោគោ អនាគាមិតាយាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

យេន លោភេន លុទ្ធាសេ សត្តា គច្ឆន្តិ ទុគ្គតឹ
តំ លោភំ សម្មទញ្ញាយ បជហន្តិ វិបស្សិនោ
បហាយ ន បុនាយន្តិ ឥមំ លោកំ កុទាចនន្តិ ។

# សុត្តន្តបិដក

# ខុទ្ទកនិកាយ ឥតិវុត្តកៈ

# ទុតិយភាគ

---

*សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ អង្គនោះ ។*

## ឯកនិបាត បឋមវគ្គ

[១] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ ចេញ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយ ជាអនាគាមី ។ ធម៌ ១ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ គឺលោភៈ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយ ជាអនាគាមី ។ លុះព្រះមានព្រះភាគទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សត្វទាំងឡាយ លោភហើយ ព្រោះលោភៈណា តែងទៅ
កាន់ទុគ្គតិ សត្វទាំងឡាយអ្នកឃើញច្បាស់ ដឹងដោយបញ្ញា
ដ៏ប្រពៃហើយ រមែងលះបង់លោភៈនោះបាន លុះលះបង់បាន
ហើយ មិនត្រឡប់មកកាន់លោកនេះទៀត ក្នុងកាលណាឡើយ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

បឋមំ[១] ។

(២) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ឯកធម្មំ ភិក្ខវេ បជហថ អហំ វោ បាដិភោគោ អនាគាមិតាយ ។ កតមំ ឯកធម្មំ ។ ទោសំ ភិក្ខវេ ឯកធម្មំ បជហថ អហំ វោ បាដិភោគោ អនាគាមិតាយាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

យេន ទោសេន ទុដ្ឋាសេ សត្តា គច្ឆន្តិ ទុគ្គតឹ
តំ ទោសំ សម្មទញ្ញាយ បជហន្តិ វិបស្សិនោ
បហាយ ន បុនាយន្តិ ឥមំ លោកំ កុទាចនន្តិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ទុតិយំ[២] ។

---

១ ឱ, ម. បឋមន្តិ ឥត្ថិ ។ ២ ឱ.ម. ទុតិយន្តិ ឥត្ថិ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ។ សូត្រទី ១ ។

(២) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ ចេញ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយ ជាអនាគាមី ។ ធម៌ ១ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ គឺទោសៈ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយជាអនាគាមី ។ លុះព្រះមានព្រះភាគ ទ្រង់បំដែងសេចក្តីនុះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សត្វទាំងឡាយ ប្រទូស្តហើយ ព្រោះទោសៈណា តែងទៅកាន់ទុគ្គតិ សត្វទាំងឡាយអ្នកឃើញច្បាស់ ដឹងដោយបញ្ញាដ៏ប្រពៃហើយ រមែងលះបង់ទោសៈនោះបាន លុះលះបង់បានហើយ មិនត្រឡប់មកកាន់លោកនេះទៀត ក្នុងកាលណាឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ២ ។

(៣) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ឯកធម្មំ ភិក្ខវេ បជហថ អហំ វោ បាដិភោគោ អនាគាមិតាយ ។ កតមំ ឯកធម្មំ ។ មោហំ ភិក្ខវេ ឯកធម្មំ បជហថ អហំ វោ បាដិភោគោ អនាគាមិតាយាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

យេន មោហេន មូឡ្ហាសេ សត្តា គច្ឆន្តិ ទុគ្គតឹ
តំ មោហំ សម្មទញ្ញាយ បជហន្តិ វិបស្សិនោ
បហាយ ន បុនាយន្តិ ឥមំ លោកំ កុទាចនន្តិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

តតិយំ[១] ។

(៤) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ឯកធម្មំ ភិក្ខវេ បជហថ អហំ វោ បាដិភោគោ អនាគាមិតាយ ។ កតមំ ឯកធម្មំ ។ កោធំ ភិក្ខវេ ឯកធម្មំ បជហថ អហំ វោ បាដិភោគោ អនាគាមិតាយាតិ ។

---

១ ឱ.ម. តតិយន្តិ នត្ថិ ។

(៣) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ ចេញ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយជាអនាគាមី ។ ធម៌ ១ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយ ចូរលះបង់ធម៌ ១ គឺមោហៈ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយជាអនាគាមី ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តី+នុះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សត្វទាំងឡាយ វង្វេងហើយ ព្រោះមោហៈណា តែងទៅកាន់ទុគ្គតិ សត្វទាំងឡាយ អ្នកឃើញច្បាស់ ដឹងដោយបញ្ញាដ៏ប្រពៃហើយ រមែងលះបង់មោហៈនោះបាន លុះលះបង់បានហើយ មិនត្រឡប់មកកាន់លោកនេះទៀត ក្នុងកាលណាឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រ ទី ៣ ។

(៤) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ ចេញ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយជាអនាគាមី ។ ធម៌១ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរលះបង់ធម៌ ១ គឺសេចក្តីក្រោធ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយជាអនាគាមី ។

ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

យេន កោធេន កុទ្ធាសេ សត្តា គច្ឆន្តិ ទុគ្គតឹ
តំ កោធំ សម្មទញ្ញាយ បជហន្តិ វិបស្សិនោ
បហាយ ន បុនាយន្តិ ឥមំ លោកំ កុទាចនន្តិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ចតុត្ថំ(១) ។

(៥) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។

ឯកធម្មំ ភិក្ខវេ បជហថ អហំ វោ បាដិភោគោ អនាគាមិតាយ ។ កតមំ ឯកធម្មំ ។ មក្ខំ ភិក្ខវេ ឯកធម្មំ បជហថ អហំ វោ បាដិភោគោ អនាគាមិតាយាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

១ ឱ.ម. បតុត្ថិ ឆត្ថី ។

លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្ដីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សត្វទាំងឡាយ ក្រោធហើយ ព្រោះសេចក្ដីក្រោធណា តែងទៅកាន់ទុគ្គតិ សត្វទាំងឡាយអ្នកឃើញច្បាស់ ដឹងដោយបញ្ញាដ៏ប្រពៃហើយ រមែងលះបង់សេចក្ដីក្រោធនោះបាន លុះលះបង់បានហើយ មិនត្រឡប់មកកាន់លោកនេះទៀត ក្នុងកាលណាឡើយ ។

ខ្ញុំបានស្ដាប់មកថា សេចក្ដីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៤ ។

(៥) ខ្ញុំបានស្ដាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ ចេញ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយជាអនាគាមី ។ ធម៌ ១ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ គឺសេចក្ដីលុបគុណ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយជាអនាគាមី ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្ដីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

យេន មក្ខេន មក្ខិតាសេ(១) សត្តា គច្ឆន្តិ ទុគ្គតឹ
តំ មក្ខំ សម្មទញ្ញាយ បជហន្តិ វិបស្សិនោ
បហាយ ន បុនាយន្តិ ឥមំ លោកំ កុទាចនន្តិ ។
អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។
បញ្ចមំ(២) ។

(៦) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ឯកធម្មំ ភិក្ខវេ បជហថ អហំ វោ ពាដិភោគោ អនាគាមិតាយ ។ កតមំ ឯកធម្មំ ។ មានំ ភិក្ខវេ ឯកធម្មំ បជហថ អហំ វោ ពាដិភោគោ អនាគាមិតាយាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

យេន មានេន មត្តាសេ សត្តា គច្ឆន្តិ ទុគ្គតឹ
តំ មានំ សម្មទញ្ញាយ បជហន្តិ វិបស្សិនោ
បហាយ ន បុនាយន្តិ ឥមំ លោកំ កុទាចនន្តិ ។

---

១ ឱ.ម. មក្ខសេ ។ ២ ឱ.ម. បញ្ចមន្តិ នត្ថិ ។

សត្វទាំងឡាយ លុបគុណហើយ ព្រោះសេចក្តីលុបគុណ
ណា តែងទៅកាន់ទុគ្គតិ សត្វទាំងឡាយ អ្នកឃើញច្បាស់
ដឹងដោយបញ្ញាដ៏ប្រពៃហើយ រមែងលះបង់សេចក្តីលុប
គុណនោះបាន លុះលះបង់បានហើយ រមែងមិនត្រឡប់
មកកាន់លោកនេះទៀត ក្នុងកាលណាឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បាន ត្រាស់ទុកហើយ ។ សូត្រ ទី ៥ ។

(៦) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ ចេញ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយ ជាអនាគាមី ។ ធម៌ ១ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ គឺ មានះ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយ ជាអនាគាមី ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សត្វទាំងឡាយ ប្រកាន់ហើយ ព្រោះមានះណា តែង
ទៅកាន់ទុគ្គតិ សត្វទាំងឡាយអ្នកឃើញច្បាស់ ដឹងដោយបញ្ញា
ដ៏ប្រពៃហើយ រមែងលះបង់មានះនោះបាន លុះលះបង់បាន
ហើយ មិនត្រឡប់មកកាន់លោកនេះទៀត ក្នុងកាលណាឡើយ ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ឥតិវុត្តកំ

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ឆដ្ឋំ(១) ។

(៧) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ សព្វំ ភិក្ខវេ អនភិជានំ អបរិជានំ តត្ថ ចិត្តំ អវិរាជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ សព្វញ្ច ខោ ភិក្ខវេ អភិជានំ បរិជានំ តត្ថ ចិត្តំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

យោ សព្វំ សព្វតោ ញត្វា សព្វត្ថេសុ ន រជ្ជតិ
ស វេ សព្វំ បរិញ្ញា សោ សព្វំ ទុក្ខំ ឧបច្ចគាតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

សត្តមំ(២) ។

១ ម. យ. ឆដ្ឋំ សុត្តំ ។ ២ ម. យ. សព្វបរិញ្ញាសុត្តំ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បាន ត្រាស់ទុកហើយ ។ សូត្រទី ៦ ។

(៧) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹងច្បាស់ មិនកំណត់ដឹង នូវហេតុទាំងពួង មិនញុំាងចិត្តឲ្យនឿយណាយ មិនលះបង់ នូវហេតុទាំងនោះ មិនគួរដើម្បីអស់ទុក្ខបានឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹងច្បាស់ កំណត់ដឹង នូវហេតុទាំងពួង ញុំាងចិត្តឲ្យនឿយណាយ លះបង់នូវហេតុទាំងនោះបាន ទើបគួរដើម្បីអស់ទុក្ខ ។

លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលណាដឹងហេតុទាំងពួង ដោយអាការទាំងពួង មិនត្រេកអរ
ក្នុងផល (សកលកាយ) ទាំងពួង បុគ្គលនោះឯងកំណត់ដឹងហេតុ
ទាំងពួង បុគ្គលនោះ ទើបកន្លងទុក្ខទាំងពួងបាន ដោយពិត ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបាន ត្រាស់ទុកហើយ ។ សូត្រទី ៧ ។

ឥតិវុត្តកេ ឯកនិបាតស្ស បឋមវគ្គស្ស អដ្ឋមសុត្តំ

(៨) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ មានំ ភិក្ខវេ អនភិជានំ អបរិជានំ តត្ថ ចិត្តំ អវិរាជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ មានញ្ច ខោ ភិក្ខវេ អភិជានំ បរិជានំ តត្ថ ចិត្តំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

មានុបេតា អយំ បជា មានគន្ថា ភវេ រតា
មានំ អបរិជានន្តា អាគន្តារោ(១) បុនព្ភវំ
យេ ច មានំ បហន្ត្វាន(២) វិមុត្តា មានសង្ខយេ
តេ មានគន្ថាភិភុនោ សព្វំ ទុក្ខំ ឧបច្ចគុំ(៣) ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

អដ្ឋមំ(៤) ។

---

១ ឱ.ម. អគន្តារោ ។ ២ ឱ. បហត្វាន ។ ៣ ឱ. សព្វទុក្ខំ ឧបច្ចគុន្តិ ។ ម. សព្វទុក្ខមុបច្ចគុន្តិ ។

៤ ឱ.ម. អដ្ឋមន្តិ នត្ថិ ។

(៨) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹងច្បាស់ មិនកំណត់ដឹង នូវមានះ មិនញុំាងចិត្ត ឲ្យនឿយណាយ មិនលះបង់នូវមានះនោះ មិនគួរ ដើម្បីអស់ទុក្ខបានឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹងច្បាស់ កំណត់ដឹងនូវមានះ ញុំាងចិត្តឲ្យនឿយណាយ លះបង់នូវមានះនោះបាន ទើបគួរ ដើម្បីអស់ទុក្ខ ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ពួកសត្វនេះ ជាអ្នកប្រកបដោយមានះ ត្រូវមានះពាក់ស្រែះហើយ
ត្រេកអរក្នុងភព កាលមិនកំណត់ដឹងមានះ តែងមកកាន់ភពថ្មីទៀត
បំណែកពួកសត្វណា លះបង់មានះបានហើយ ផុតស្រឡះហើយ
ព្រោះអស់មានះ សត្វទាំងនោះគ្របសង្កត់នូវគ្រឿងពាក់ស្រែះ គឺ
មានះបានហើយ កន្លងបង់នូវគ្រឿងពាក់ស្រែះទាំងពួងបាន ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនុ៎ះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៨ ។

(៩) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ លោភំ ភិក្ខវេ អនភិជានំ អបរិជានំ តត្ថ ចិត្តំ អវិរាជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ លោភញ្ច ខោ ភិក្ខវេ អភិជានំ បរិជានំ តត្ថ ចិត្តំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

យេន លោភេន លុទ្ធាសេ សត្តា គច្ឆន្តិ ទុគ្គតឹ
តំ លោភំ សម្មទញ្ញាយ បជហន្តិ វិបស្សិនោ
បហាយ ន បុនាយន្តិ ឥមំ លោកំ កុទាចនន្តិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

នវមំ[១] ។

---

១ ឱ.ម. នវមន្ត សត្ត ។

សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តកៈ

(៩) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាល មិនដឹងច្បាស់ មិនកំណត់ដឹងនូវលោភៈ មិនញុំាងចិត្តឲ្យនឿយណាយ មិនលះបង់នូវលោភៈនោះ មិនគួរ ដើម្បីអស់ទុក្ខបានឡើយ ម្នាលភិក្ខុ ទាំងឡាយ បុគ្គលកាលដឹងច្បាស់ កំណត់ដឹងនូវលោភៈ ញុំាងចិត្តឲ្យ នឿយណាយ លះបង់ នូវលោភៈនោះបាន ទើបគួរ ដើម្បីអស់ទុក្ខ ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់ គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សត្វទាំងឡាយ ជាប់ហើយ ព្រោះលោភៈណា តែងទៅ កាន់ទុគ្គតិ សត្វទាំងឡាយ អ្នកឃើញច្បាស់ ដឹងដោយបញ្ញា ដ៏ប្រពៃហើយ រមែងលះបង់លោភៈនោះបាន លុះលះបង់បាន ហើយ មិនត្រឡប់មកកាន់លោកនេះទៀត ក្នុងកាលណាឡើយ ។ ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រ ទី ៩ ។

## ឥតិវុត្តកេ ឯកនិបាតស្ស បឋមវគ្គស្ស ទសមសុត្តំ

[១០] វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ទោសំ ភិក្ខវេ អនភិជានំ អបរិជានំ តត្ថ ចិត្តំ អវិរា-ជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ ។ ទោសញ្ច ខោ ភិក្ខវេ អភិជានំ បរិជានំ តត្ថ ចិត្តំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

យេន ទោសេន ទុដ្ឋាសេ សត្តា គច្ឆន្តិ ទុគ្គតឹ
តំ ទោសំ សម្មទញ្ញាយ បជហន្តិ វិបស្សិនោ
បហាយ ន បុនាយន្តិ ឥមំ លោកំ កុទាចនន្តិ ។
អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។
ទសមំ(១) ។

### បាដិភោគវគ្គោ បឋមោ ។

តស្សុទ្ទានំ

រាគទោសា អថ មោហោ
កោធមក្ខា មានំ សព្វំ
មានតោ រាគទោសា បុន ទ្វេ
បកាសិតា វគ្គមាហុ(២) បឋមន្តិ ។

១ ឱ. ម. ទសមត្តំ គត្តំ ។ ២ ឱ. ម. វគ្គមាហុ ។

(១០) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹងច្បាស់ មិនកំណត់ដឹងនូវទោសៈ មិនញុំាងចិត្តឲ្យនឿយណាយ មិនលះបង់នូវទោសៈនោះ មិនគួរដើម្បីនឹងអស់ទុក្ខបានឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹងច្បាស់ កំណត់ដឹងនូវទោសៈ ញុំាងចិត្តឲ្យនឿយណាយ លះបង់នូវទោសៈនោះបាន ទើបគួរដើម្បីអស់ទុក្ខ ។ លុះព្រះមានព្រះភាគទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សត្វទាំងឡាយ ប្រទូស្តហើយ ព្រោះទោសៈណា តែងទៅ
កាន់ទុគ្គតិ សត្វទាំងឡាយអ្នកឃើញច្បាស់ ដឹងដោយបញ្ញាដ៏
ប្រពៃហើយ រមែងលះបង់ទោសៈនោះបាន លុះលះបង់បាន
ហើយ មិនត្រឡប់មកកាន់លោកនេះទៀត ក្នុងកាលណាឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រ ទី ១០ ។

ចប់ បាដិភោគវគ្គ ទី ១ ។

## ឧទ្ទាននៃបាដិភោគវគ្គនោះគឺ

និយាយអំពីរាគៈ ១ ទោសៈ ១ មោហៈ ១ សេចក្តីក្រោធ ១
សេចក្តីលុបគុណ ១ មានះ ១ ហេតុទាំងពួង ១ មានះ ១ រាគៈ
ទោសៈ ២ទៀត អ្នកប្រាជ្ញទាំងឡាយពោលថាជាបឋមវគ្គ ។

# ឥតិវុត្តកេ ឯកនិបាតស្ស ទុតិយោ វគ្គោ

(១១) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ លោភំ ភិក្ខវេ អនភិជានំ អបរិជានំ តត្ថ ចិត្តំ អវិរាជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ លោភញ្ច ខោ ភិក្ខវេ អភិជានំ បរិជានំ តត្ថ ចិត្តំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

យេន លោភេន លុទ្ធាសេ សត្តា គច្ឆន្តិ ទុគ្គតឹ
តំ លោភំ សម្មទញ្ញាយ បជហន្តិ វិបស្សិនោ
បហាយ ន បុនាយន្តិ ឥមំ លោកំ កុទាចនន្តិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។ បឋមំ[១] ។

(១២) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ទោសំ ភិក្ខវេ អនភិជានំ អបរិជានំ តត្ថ ចិត្តំ អវិរាជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ

១ ឱ.ម. បឋមន្តិ នត្ថិ ។

# ឥតិវុត្តកៈ ឯកនិបាត ទុតិយវគ្គ

(១១) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹងច្បាស់ មិនកំណត់ដឹងនូវមោហៈ មិនញុំាងចិត្តឲ្យនឿយណាយ មិនលះបង់នូវមោហៈនោះ មិនគួរដើម្បីនឹងអស់ទុក្ខបានឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹងច្បាស់ កំណត់ដឹងនូវមោហៈ ញុំាងចិត្តឲ្យនឿយណាយ លះបង់នូវមោហៈនោះបាន ទើបគួរនឹងអស់ទុក្ខ ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សត្វទាំងឡាយ វង្វេងហើយ ព្រោះមោហៈណា តែងទៅ
កាន់ទុគ្គតិ សត្វទាំងឡាយអ្នកឃើញច្បាស់ ដឹងដោយបញ្ញាដ៏
ប្រពៃហើយ រមែងលះបង់មោហៈនោះបាន លុះលះបង់បាន
ហើយ មិនត្រឡប់មកកាន់លោកនេះទៀត ក្នុងកាលណាឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ១ ។

(១២) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹងច្បាស់ មិនកំណត់ដឹងនូវសេចក្តីក្រោធ មិនញុំាងចិត្តឲ្យនឿយណាយ មិនលះបង់ នូវសេចក្តីក្រោធនោះ មិនគួរ ដើម្បីនឹងអស់ទុក្ខបានឡើយ

ឥតិវុត្តកេ ឯកនិបាតស្ស ទុតិយវគ្គស្ស តតិយសុត្តំ

កោធញ្ច ខោ ភិក្ខវេ អភិជានំ បរិជានំ តត្ថ ចិត្តំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

យេន កោធេន កុទ្ធាសេ សត្តា គច្ឆន្តិ ទុគ្គតឹ
តំ កោធំ សម្មទញ្ញាយ បជហន្តិ វិបស្សិនោ
បហាយ ន បុនាយន្តិ ឥមំ លោកំ កុទាចនន្តិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ទុតិយំ(១) ។

(១៣) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ មក្ខំ ភិក្ខវេ អនភិជានំ អបរិជានំ តត្ថ ចិត្តំ អវិរាជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ មក្ខញ្ច ខោ ភិក្ខវេ អភិជានំ បរិជានំ តត្ថ ចិត្តំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

---

១ ឱ. ម. ទុតិយាត្តិ ឧត្តិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹងច្បាស់ កំណត់ដឹងនូវសេចក្តីក្រោធ ញុំាងចិត្តឲ្យនឿយណាយ លះបង់នូវសេចក្តីក្រោធនោះបាន ទើបគួរ ដើម្បីនឹងអស់ទុក្ខ ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សត្វទាំងឡាយ ក្រោធហើយ ព្រោះសេចក្តីក្រោធណា តែង
ទៅកាន់ទុគ្គតិ សត្វទាំងឡាយ អ្នកឃើញច្បាស់ ដឹងដោយ
បញ្ញាដ៏ប្រពៃហើយ លះបង់សេចក្តីក្រោធនោះ លុះលះបង់បាន
ហើយ មិនត្រឡប់មកកាន់លោកនេះទៀត ក្នុងកាលណាឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ២ ។

(១៣) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹងច្បាស់ មិនកំណត់ដឹងនូវសេចក្តីលុបគុណ មិនញុំាងចិត្តឲ្យនឿយណាយ មិនលះបង់នូវសេចក្តីលុបគុណនោះ មិនគួរ ដើម្បីនឹងអស់ទុក្ខបានឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹងច្បាស់ កំណត់ដឹងនូវសេចក្តីលុបគុណ ទាំងញុំាងចិត្តឲ្យនឿយណាយ លះបង់សេចក្តីលុបគុណនោះបាន ទើបគួរ ដើម្បីនឹងអស់ទុក្ខ ។ លុះព្រះមានព្រះភាគសំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

យេន មោហេន មូឡ្ហាសេ សត្តា គច្ឆន្តិ ទុគ្គតឹ
តំ មោហំ សម្មទញ្ញាយ បជហន្តិ វិបស្សិនោ
បហាយ ន បុនាយន្តិ ឥមំ លោកំ កុទាចនន្តិ ។
អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

តតិយំ[១] ។

(១៤) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ នាហំ ភិក្ខវេ អញ្ញំ ឯកនីវរណម្បិ សមនុបស្សាមិ យេន នីវរណេន និវុតា បជា ទីឃរត្តំ សន្ធាវន្តិ សំសរន្តិ យថយិទំ ភិក្ខវេ អវិជ្ជានីវរណំ អវិជ្ជានីវរណេន ហិ ភិក្ខវេ និវុតា បជា ទីឃរត្តំ សន្ធាវន្តិ សំសរន្តីតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

នត្ថញ្ញោ ឯកធម្មោបិ[២] យេនេវំ និវុតា បជា
សំសរន្តិ អហោរត្តំ យថា មោហេន អាវុតា
យេ ច មោហំ បហន្ត្វាន តមោក្ខន្ធំ បទាលយុំ
ន តេ បុន សំសរន្តិ ហេតុ តេសំ ន វិជ្ជតីតិ ។

---

១ ឱ.ម. តតិយន្តិ នត្ថិ ។ ២ ម. ឯកធម្មោវ យេនេវ ។

សត្វទាំងឡាយ លុបគុណហើយ ព្រោះសេចក្ដីលុបគុណណា តែងទៅកាន់ទុគ្គតិ សត្វទាំងឡាយ អ្នកឃើញច្បាស់ ដឹងដោយបញ្ញាដ៏ប្រពៃហើយ រមែងលះបង់សេចក្ដីលុបគុណនោះបាន លុះលះបង់បានហើយ មិនត្រឡប់មកកាន់លោកនេះទៀត ក្នុងកាលណាឡើយ ។ ខ្ញុំបានស្ដាប់មកហើយថា សេចក្ដីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៣ ។

(១៤) ខ្ញុំបានស្ដាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វត្រូវនីវរណៈណា រួបរឹតហើយ តែងអន្ទោលទៅ តែងត្រាច់ទៅ អស់កាលត្រីវែង ម្នាលភិក្ខុទាំងឡាយ តថាគត មិនឃើញនីវរណៈដទៃនោះ សូម្បីតែនីវរណៈមួយ ដូចអវិជ្ជានីវរណៈនេះឡើយ ម្នាលភិក្ខុទាំងឡាយ ហេតុតែពួកសត្វ ត្រូវអវិជ្ជានីវរណៈ រួបរឹតហើយ ទើបបានអន្ទោលទៅត្រាច់ទៅ អស់កាលត្រីវែង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្ដីនុះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ពួកសត្វត្រូវមោហៈដែលជាធម៌ឯក មិនមានធម៌ដទៃដូច រួបរឹតបិទបាំងហ៊ានេះហើយ តែងអន្ទោលទៅអស់ថ្ងៃនិងយប់ដ៏វែង ចំណែកសត្វទាំងឡាយណា លះបង់មោហៈ ទំលាយគំនរនៃងងឹតហើយ សត្វទាំងនោះនឹងមិនអន្ទោលទៅទៀត ព្រោះហេតុរបស់សត្វទាំងនោះមិនមាន ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ចតុត្ថំ(១) ។

(១៥) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ នាហំ ភិក្ខវេ អញ្ញំ ឯកសំយោជនម្បិ សមនុបស្សាមិ យេនេវំ សំយោជនេន សំយុត្តា សត្តា ទីឃរត្តំ សន្ធាវន្តិ សំសរន្តិ យថយិទំ ភិក្ខវេ តណ្ហាសំយោជនំ តណ្ហាសំយោជនេន ហិ ភិក្ខវេ សំយុត្តា សត្តា ទីឃរត្តំ សន្ធាវន្តិ សំសរន្តីតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

តណ្ហាទុតិយោ បុរិសោ ទីឃមទ្ធាន សំសរំ
ឥត្ថម្ភាវញ្ញថាភាវំ(២) សំសារំ នាតិវត្តតិ
ឯតមាទីនវំ ញត្វា តណ្ហំ ទុក្ខស្ស សម្ភវំ
វីតតណ្ហោ អនាទានោ សតោ ភិក្ខុ បរិព្វជេតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

បញ្ចមំ(៣) ។

---

១ ឱ.ម. ចតុត្ថំ នត្ថិ ។ ២ ឱ.ម. ឥត្ថភាវញ្ញថាភាវំ ។ ៣ ឱ.ម. បញ្ចមំ នត្ថិ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រ ទី៧ ។

(១៨) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ សត្វដែលប្រកបដោយសំយោជនៈណាហើយ តែងអន្ទោលទៅ ត្រាច់ទៅ អស់រាត្រីដ៏វែង ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសំយោជនៈដទៃនោះ សូម្បីតែសំយោជនៈមួយ ដូចជាតណ្ហាសំយោជនៈនេះឡើយ ម្នាលភិក្ខុទាំងឡាយ ហេតុតែសត្វទាំងឡាយ ដែលប្រកបដោយតណ្ហាសំយោជនៈហើយ ទើបបានអន្ទោលទៅ ត្រាច់ទៅ អស់រាត្រីវែង ។ លុះព្រះមានព្រះភាគទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុរសមានតណ្ហាជាគំរប់ពីរ កាលអន្ទោលទៅ កាន់សង្សារ
អស់កាលដ៏វែង រមែងមិនកន្លងនូវសង្សារវដ្ត ដែលមានសភាព
យ៉ាងនេះ និងយ៉ាងដទៃបានឡើយ ភិក្ខុដឹងនូវតណ្ហានេះ ថា
ជាទោស ជាដែនកើតនៃទុក្ខហើយ ជាអ្នកប្រាសចាកតណ្ហា មិន
មានសេចក្តីប្រកាន់ ជាអ្នកមានសតិ គប្បីវៀរបង់ចោលចេញ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រ ទី៨ ។

(១៦) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ សេក្ខស្ស ភិក្ខវេ ភិក្ខុនោ អប្បត្តមានសស្ស អនុត្តរំ យោគក្ខេមំ បត្ថយមានស្ស វិហរតោ អជ្ឈត្តិកំ អង្គន្តិ ករិត្វា ន អញ្ញំ ឯកង្គម្បិ សមនុបស្សាមិ ឯវំ ពហុការំ(១) យថយិទំ ភិក្ខវេ យោនិសោ មនសិការោ យោនិសោ ភិក្ខវេ ភិក្ខុ មនសិការោន្តោ អកុសលំ បជហតិ កុសលំ ភាវេតីតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

យោនិសោ មនសិការោ ធម្មោ សេក្ខស្ស ភិក្ខុនោ
នត្ថញ្ញោ ឯវំ ពហុការោ(២) ឧត្តមត្ថស្ស បត្តិយា
យោនិសោ បទហំ ភិក្ខុ ខយំ ទុក្ខស្ស បាបុណេតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ឆដ្ឋំ(៣) ។

---

១ ឱ. ពហូបការំ ។ ម. ពហុបការំ ។ ២ ឱ. ពហូបការោ ។ ម. ពហុបការោ ។

(១៦) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុជាសេក្ខៈ មិនទាន់សម្រេចអរហត្តផលនៅឡើយ ហើយប្រាថ្នាធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ ម្នាលភិក្ខុទាំងឡាយ តថាគតធ្វើបច្ច័យខាងក្នុងឲ្យជាហេតុ ហើយមិនឃើញហេតុដទៃ សូម្បីតែហេតុមួយ ដែលមានឧបការៈច្រើនយ៉ាងនេះ ដូចជាយោនិសោមនសិការៈឡើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលធ្វើទុកក្នុងចិត្ត ដោយឧបាយហើយ ទើបលះបង់អកុសល ចំរើនកុសលបាន ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

យោនិសោមនសិការៈ ជាធម៌របស់ភិក្ខុជាសេក្ខៈ
ធម៌ដទៃ ដែលមានឧបការៈច្រើន ដើម្បីសម្រេច
ប្រយោជន៍ដ៏ឧត្តមដូច្នោះមិនមានឡើយ កាលភិក្ខុ
ផ្គងចិត្ត ដោយឧបាយ ទើបដល់នូវការអស់ទុក្ខបាន ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៦ ។

ឥតិវុត្តកេ ឯកនិបាតស្ស ទុតិយវគ្គស្ស សត្តមសុត្តំ

(១៧) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ សេក្ខស្ស ភិក្ខវេ ភិក្ខុនោ អប្បត្តមានសស្ស(១) អនុត្តរំ យោគក្ខេមំ បត្ថយមានស្ស វិហរតោ ពាហិរំ អង្គន្តិ ករិត្វា ន អញ្ញំ ឯកង្គម្បិ សមនុបស្សាមិ ឯវំ ពហុការំ យទិទំ ភិក្ខវេ កល្យាណមិត្តតា ។ កល្យាណមិត្តោ ភិក្ខវេ ភិក្ខុ អកុសលំ បជហតិ កុសលំ ភាវេតីតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

កល្យាណមិត្តោ យោ ភិក្ខុ សប្បតិស្សោ សគារវោ
ករំ មិត្តាន វចនំ(២) សម្បជានោ បតិស្សតោ
បាបុណេ អនុបុព្វេន សព្វសំយោជនក្ខយន្តិ ។
អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

សត្តមំ(៣) ។

---

១ ឱ.ម. អប្បត្តមានសស្ស ។ ២ ឱ.ម. មិត្តានំ វចនំ ។ ៣ ឱ.ម. សត្តមន្តិ នត្ថិ ។

(១៧) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុជាសេក្ខៈ មិនទាន់សម្រេចអរហត្តផលនៅឡើយ ហើយប្រាថ្នាធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ ម្នាលភិក្ខុទាំងឡាយ តថាគតធ្វើបច្ច័យខាងក្រៅឲ្យជាហេតុ ហើយមិនឃើញហេតុដទៃ សូម្បីតែហេតុមួយ ដែលមានឧបការៈច្រើន យ៉ាងនេះ ឲ្យដូចជាភាពនៃបុគ្គលមានកល្យាណមិត្តនេះឡើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានកល្យាណមិត្ត ទើបលះបង់អកុសល ចំរើនកុសលបាន ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ភិក្ខុណា មានកល្យាណមិត្ត មានសេចក្តីកោតក្រែង
ប្រកបដោយសេចក្តីគោរព ធ្វើតាមពាក្យរបស់កល្យាណមិត្ត
ជាអ្នកមានសេចក្តីដឹងខ្លួន មានស្មារតី ភិក្ខុនោះ ទើបគួរដល់
នូវកិរិយាអស់សំយោជនៈទាំងពួង ដោយលំដាប់បាន ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៧ ។

(១៨) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ឯកធម្មោ ភិក្ខវេ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ ពហុជនាហិតាយ ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ។ កតមោ ឯកធម្មោ ។ សង្ឃភេទោ ។ សង្ឃេ ខោ បន ភិក្ខវេ ភិន្នេ អញ្ញមញ្ញំ ភណ្ឌនានិ ចេវ ហោន្តិ អញ្ញមញ្ញំ បរិភាសា ច ហោន្តិ អញ្ញមញ្ញំ បរិក្ខេបា ច ហោន្តិ អញ្ញមញ្ញំ បរិច្ចជនា ច ហោន្តិ តត្ថ អប្បសន្នា ចេវ នប្បសីទន្តិ បសន្នានញ្ច ឯកច្ចានំ អញ្ញថត្តំ ហោតីតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

អាបាយិកោ នេរយិកោ កប្បដ្ឋោ សង្ឃភេទកោ
វគ្គារាមោ អធម្មដ្ឋោ យោគក្ខេមា ធំសតិ(១)
សង្ឃំ សមគ្គំ ភេត្វាន(២) កប្បំ និរយម្ហិ បច្ចតីតិ ។
អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

អដ្ឋមំ(៣) ។

---

១ ឱ.ម. យោគក្ខេមា វិធំសតិ ។ ២ ឱ.ម. ភិត្វាន ។ ៣ ឱ.ម. អដ្ឋមត្តិ ឆដ្ឋំ

(១៨) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ៗ ម្នាលភិក្ខុទាំងឡាយ ធម៌ ១ កាលកើតឡើង ក្នុងលោក តែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីមិនចំរើនដល់ជនច្រើន ដើម្បីជាទុក្ខដល់ទេវតានិងមនុស្សទាំងឡាយ ៗ ធម៌ ១ តើដូចម្តេច ៗ គឺសង្ឃភេទ (ការបំបែកសង្ឃ)។ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃបែកគ្នាហើយ ការឈ្លោះប្រកែកគ្នានឹងគ្នា ក៏កើតមាន ការប្រទេចផ្តាសាគ្នានឹងគ្នា ក៏កើតមាន ការបោកបោះពាក្យសំដីដល់គ្នានឹងគ្នា ក៏កើតមាន ការលះបង់គ្នានឹងគ្នា ក៏កើតមាន ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាក្នុងសង្ឃនោះ ក៏មិនជ្រះថ្លា ជនពួកខ្លះដែលជ្រះថ្លាស្រាប់ហើយ ក៏ងាកទៅជាយ៉ាងដទៃវិញ ៗ លុះព្រះមានព្រះភាគទ្រង់សំដែងសេចក្តីនុ៎ះហើយ ៗ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលជាអ្នកបំបែកសង្ឃ ត្រេកអរក្នុងពួក មិនឋិតក្នុងធម៌
តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក តាំងនៅអស់មួយកប្ប
រមែងសាបសូន្យចាកធម៌ជាទីក្សេមចាកយោគៈ បុគ្គលបំបែក
សង្ឃដែលព្រមព្រៀងគ្នាហើយ តែងឆេះក្នុងនរកអស់មួយកប្ប ៗ

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ៗ សូត្រទី ៨ ។

## ឥតិវុត្តកេ ឯកនិបាតស្ស ទុតិយវគ្គស្ស នវមសុត្តំ

(១៩) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ឯកធម្មោ ភិក្ខវេ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ ពហុជនហិតាយ ពហុជនសុខាយ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ កតមោ ឯកធម្មោ ។ សង្ឃស្ស សាមគ្គី ។ សង្ឃេ ខោ បន ភិក្ខវេ សមគ្គេ ន ចេវ អញ្ញមញ្ញំ ភណ្ឌនានិ ហោន្តិ ន ច អញ្ញមញ្ញំ បរិភាសា ហោន្តិ ន ច អញ្ញមញ្ញំ បរិក្ខេបា ហោន្តិ ន ច អញ្ញមញ្ញំ បរិច្ចជនា ហោន្តិ តត្ថ អប្បសន្នា ចេវ បសីទន្តិ បសន្នានញ្ច ភិយ្យោភាវោ ហោតីតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

សុខា សង្ឃស្ស សាមគ្គី សមគ្គានញ្ចនុគ្គហោ
សមគ្គរតោ ធម្មដ្ឋោ យោគក្ខេមា ន ធំសតិ
សង្ឃំ សមគ្គំ កត្វាន កប្បំ សគ្គម្ហិ មោទតីតិ ។

ឥតិវុត្តកៈ ឯកនិបាត ទុតិយវគ្គ សូត្រទី ៩

(១៩) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១ កាលកើតឡើង ក្នុងលោក តែងកើតឡើង ដើម្បីជាប្រយោជន៍ ដល់ជនច្រើន ដើម្បីជាសុខ ដល់ជនច្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីចំរើន ដល់ជនច្រើន ដើម្បីជាសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ ធម៌ ១ តើដូចម្តេច ។ គឺសេចក្តីព្រមព្រៀងរបស់សង្ឃ ។ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃព្រមព្រៀងគ្នាហើយ ការឈ្លោះប្រកែកគ្នានឹងគ្នា ក៏មិនកើតមាន ការប្រទេចផ្តាសាគ្នានឹងគ្នា ក៏មិនកើតមាន ការបោកបោះពាក្យសំដីដល់គ្នានឹងគ្នា ក៏មិនកើតមាន ការលះបង់គ្នានឹងគ្នា ក៏មិនកើតមាន ជនទាំងឡាយដែលមិនជ្រះថ្លា ក្នុងសង្ឃនោះ ក៏រមែងជ្រះថ្លា ពួកជនដែលជ្រះថ្លាស្រាប់ហើយ ក៏រឹតតែជ្រះថ្លាឡើង ។ លុះព្រះមានព្រះភាគទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សេចក្តីព្រមព្រៀង នៃសង្ឃ ជាហេតុនាំសេចក្តីសុខមកឲ្យ
ការអនុគ្រោះបុគ្គលទាំងឡាយ ដែលមានសេចក្តីព្រមព្រៀង
គ្នា (ជាហេតុនាំសេចក្តីសុខមកឲ្យ) បុគ្គលត្រេកអរ ក្នុងជន
ដែលព្រមព្រៀងគ្នា តាំងនៅក្នុងធម៌ រមែងមិនសាបសូន្យ
ចាកធម៌ជាទីក្សេមចាកយោគៈ បុគ្គលធ្វើសង្ឃ ឲ្យព្រមព្រៀង
គ្នា រមែងរីករាយ ក្នុងឋានសួគ៌ អស់ ១ កប្ប ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតំ ។ ទសមំ(១) ។

[២០] វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ឥធាហំ ភិក្ខវេ ឯកច្ចំ បុគ្គលំ បទុដ្ឋចិត្តំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ឥមម្ហិ ចាយំ សមយេ បុគ្គលោ កាលំ ករេយ្យ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ តំ កិស្ស ហេតុ ។ ចិត្តំ ហិស្ស ភិក្ខវេ បទុដ្ឋំ ។ ចេតោបទោសហេតុ បន ភិក្ខវេ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតិំ វិនិបាតំ និរយំ ឧបបជ្ជន្តីតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

បទុដ្ឋចិត្តំ ញត្វាន ឯកច្ចំ ឥធ បុគ្គលំ
ឯតមត្ថំ(២) ព្យាកាសិ ពុទ្ធោ ភិក្ខូន សន្តិកេ
ឥមម្ហិ ចាយំ សមយេ កាលំ កយិរាថ បុគ្គលោ
និរយំ ឧបបជ្ជេយ្យ ចិត្តំ ហិស្ស បទូសិតំ
យថា ហរិត្វា និក្ខិបេយ្យ ឯវមេវ តថាវិធោ
ចេតោបទោសហេតូហិ សត្តា គច្ឆន្តិ ទុគ្គតិន្តិ ។

១ ឱ.ម. ទសមន្តិ នត្ថិ ។ ២ ឱ.ម. ឯតមត្ថញ្ច ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ ត្រាស់ទុកហើយ ។ សូត្រទី ៤ ។

(២០) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគត កំណត់ចិត្តដោយចិត្តហើយ ដឹងច្បាស់ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលមានចិត្តប្រទូស្តយ៉ាងនេះថា បើបុគ្គលនេះ ធ្វើមរណកាលទៅ ក្នុងសម័យនេះ មុខជាទៅកើតក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះបុគ្គលនោះ មានចិត្តប្រទូស្ត ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ហេតុតែមានចិត្តប្រទូស្ត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាតនិងនរក ៕ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ព្រះពុទ្ធទ្រង់ជ្រាបបុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលមានចិត្ត
ប្រទូស្ត ទើបទ្រង់ព្យាករសេចក្តីនុ៎ះ ក្នុងសំណាក់ភិក្ខុទាំងឡាយ
ថា បើបុគ្គលនេះ ធ្វើមរណកាលទៅ ក្នុងសម័យនេះ មុខជា
ទៅកើត ក្នុងនរក ព្រោះតែបុគ្គលនោះ មានចិត្តប្រទូស្ត
បុគ្គលបែបនោះ ដូចជាគេនាំយកទៅទំលាក់យ៉ាងនេះឯង សត្វ
ទាំងឡាយ រមែងទៅកាន់ទុគ្គតិ ព្រោះហេតុតែមានចិត្តប្រទូស្ត ។

ឥតិវុត្តកេ ឯកនិបាតស្ស ទុតិយវគ្គស្ស ឧទ្ទានំ

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។ ទសមំ[១] ។

ទុតិយវគ្គោ ។

តស្សុទ្ទានំ

ទោសោ កោធោ អថ មក្ខោ មោហោ កាមា សេក្ខា ទុវេ
ភេទមោទា បុគ្គលោ ច វគ្គមាហុ ទុតិយន្តិ វុច្ចតិ ។

១ ឱ.ម. ទសមន្តិ នត្ថិ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រ ទី១០ ។

ចប់ ទុតិយវគ្គ ។

## ឧទ្ទាននៃទុតិយវគ្គនោះគឺ

និយាយអំពីមោហៈ១ សេចក្តីក្រោធ ១ សេចក្តីលុបគុណគេ ១ សេចក្តីវង្វេង១ កាម១ សេក្ខៈមាន២លើក ការបំបែក១ សេចក្តីត្រេកអរ១ បុគ្គល១ លោកហៅថាជាវគ្គទី ២ ។

---

# ឥតិវុត្តកេ ឯកនិបាតស្ស តតិយវគ្គោ

(២១) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ឥធាហំ ភិក្ខវេ ឯកច្ចំ បុគ្គលំ បសន្នចិត្តំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ឥមម្ហិ(១) ចាយំ សមយេ បុគ្គលោ កាលំ ករេយ្យ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ តំ កិស្ស ហេតុ ។ ចិត្តំ ហិស្ស ភិក្ខវេ បសន្នំ ។ ចេតោបសាទហេតុ ខោ បន ភិក្ខវេ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

បសន្នចិត្តំ ញត្វាន ឯកច្ចំ ឥធ បុគ្គលំ
ឯតមត្ថំ(២) ព្យាកាសិ ពុទ្ធោ ភិក្ខូន សន្តិកេ
ឥមម្ហិ ចាយំ សមយេ កាលំ កយិរាថ បុគ្គលោ
សុគតឹ ឧបបជ្ជេយ្យ ចិត្តំ ហិស្ស បសាទិតំ(៣)
យថា ហរិត្វា និក្ខិបេយ្យ ឯវមេវ តថាវិធោ
ចេតោបសាទហេតុ ហិ សត្តា គច្ឆន្តិ សុគតឹ ។
អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ទសមំ(៤) ។

១ ម. ឥមស្មិំ ។ ២ ឱ. ឯតមត្ថញ្ច ។ ៣ ឱ. បសាទិកំ ។ ៤ ឱ.ម. បឋមន្តិ ឆដ្ឋំ ។

# ឥតិវុត្តកៈ ឯកនិបាត តតិយវគ្គ

(២១) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគត កំណត់ដឹងចិត្ត ដោយចិត្ត ដឹងច្បាស់ បុគ្គលពួកខ្លះក្នុងលោកនេះ ដែលមានចិត្តជ្រះថ្លាហើយយ៉ាងនេះថា បើបុគ្គលនេះ ធ្វើមរណកាលទៅ ក្នុងសម័យនេះ នឹងទៅកើតក្នុងឋានសួគ៌ ដូចជាគេនាំយកទៅដាក់ទុក ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះបុគ្គលនោះមានចិត្តជ្រះថ្លា ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ហេតុតែមានចិត្តជ្រះថ្លាយ៉ាងនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតឯសុគតិសួគ៌ទេវលោក ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ព្រះពុទ្ធទ្រង់ជ្រាបបុគ្គលពួកខ្លះ ដែលមានចិត្តជ្រះថ្លា ក្នុងលោក
នេះ ទើបទ្រង់ពោលសេចក្តីនុ៎ះ ក្នុងសំណាក់ភិក្ខុទាំងឡាយ ថា
បើបុគ្គលនេះ ធ្វើមរណកាលទៅ ក្នុងសម័យនេះ នឹងទៅកើត
ក្នុងសុគតិ ព្រោះបុគ្គលនោះមានចិត្តជ្រះថ្លា បុគ្គលបែបនោះ
ដូចជាគេនាំយកទៅដាក់ទុក ( ក្នុងសួគ៌ ) យ៉ាងនេះឯង សត្វ
ទាំងឡាយ រមែងទៅកាន់សុគតិ ព្រោះហេតុតែមានចិត្តជ្រះថ្លា ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ១ ។

(២២) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ មា ភិក្ខវេ បុញ្ញានំ ភាយិត្ថ សុខស្សេតំ ភិក្ខវេ អធិវចនំ ឥដ្ឋស្ស កន្តស្ស បិយស្ស មនាបស្ស យទិទំ បុញ្ញានិ ។ អភិជានាមិ ខោ បនាហំ ភិក្ខវេ ទីឃរត្តំ កតានំ បុញ្ញានំ ទីឃរត្តំ ឥដ្ឋំ កន្តំ បិយំ មនាបំ វិបាកំ បច្ចនុភូតំ ។ សត្ត វស្សានិ មេត្តចិត្តំ ភាវេត្វា សត្ត សំវដ្ដវិវដ្ដកប្បេ នយិមំ លោកំ បុនាគមាសឹ សំវដ្ដមានេ សុទំ ភិក្ខវេ កប្បេ អាភស្សរូបគោ ហោមិ វិវដ្ដមានេ កប្បេ សុញ្ញំ ព្រហ្មវិមានំ ឧបបជ្ជាមិ ។ តត្រ សុទំ ភិក្ខវេ ព្រហ្មា ហោមិ មហាព្រហ្មា អភិភូ អនភិភូតោ អញ្ញទត្ថុទសោ វសវត្តី ។ ឆត្តឹសក្ខត្តុំ ខោ បនាហំ ភិក្ខវេ សក្កោ អហោសឹ ទេវានមិន្ទោ អនេកសតក្ខត្តុំ រាជា អហោសឹ ចក្កវត្តិ ធម្មិកោ ធម្មរាជា ចាតុរន្តោ វិជិតាវី ជនបទត្ថាវរិយប្បត្តោ សត្តរតនសមន្នាគតោ កោ បន វាទោ បទេសរជ្ជស្ស ។

(២២) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំខ្លាចបុណ្យឡើយ ម្នាលភិក្ខុទាំងឡាយ ព្រោះពាក្យថា បុណ្យនេះជាឈ្មោះនៃសេចក្តីសុខដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីស្រឡាញ់ ជាទីពេញចិត្ត។ ម្នាលភិក្ខុទាំងឡាយ តថាគតស្គាល់ច្បាស់ ផលនៃបុណ្យ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីស្រឡាញ់ ជាទីពេញចិត្ត ដែលតថាគតបានហើយ អស់កាលជាអង្វែង ដែលតថាគតធ្វើហើយ អស់កាលជាអង្វែង ។ តថាគតបានចំរើនមេត្តាចិត្ត អស់ ៧ ឆ្នាំ មិនបានមកកាន់លោកនេះទៀត អស់ ៧ សំវដ្តវិវដ្តកប្ប ម្នាលភិក្ខុទាំងឡាយ ដំណើរថា កាលកប្បវិនាស តថាគតបានទៅកើត ក្នុងអាភស្សរព្រហ្ម កាលកប្បចំរើន តថាគតបានចូលទៅកាន់ព្រហ្មវិមាន ដែលសូន្យទទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងទីនោះ តថាគតជាព្រហ្ម ជាមហាព្រហ្ម គ្របសង្កត់សត្វដទៃបាន សត្វដទៃមិនអាចគ្របសង្កត់តថាគតបានទេ តថាគតអាចញុំាងអំណាច ឲ្យប្រព្រឹត្តទៅបាន ដោយពិត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត តថាគតបានកើតជាព្រះឥន្ទ្រ ជាធំជាងទេវតាទាំងឡាយ៣៦ដង បានជាស្តេចចក្រពត្តិ ធម្មិក-ធម្មរាជ ជាឥស្សរៈលើផែនដី ដែលមានសមុទ្រទាំង ៤ ជាទីបំផុត ជាស្តេចឈ្នះសង្គ្រាម មានជនបទ ដល់នូវការមាំមួន បរិបូណ៌ដោយរតនៈទាំង ៧ ប្រការ អស់ច្រើនរយដង ទឹងបាច់ពោលទៅថ្វី ដល់ប្រទេសរាជ្យ ។

តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ កិស្ស[១] នុ ខោ មេ ឥទំ កម្មស្ស ផលំ កិស្ស[២] កម្មស្ស វិបាកោ យេនាហំ ឯតរហិ ឯវំមហិទ្ធិកោ ឯវំមហានុភាវោតិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ តិណ្ណំ ខោ មេ ឥទំ កម្មានំ ផលំ តិណ្ណំ កម្មានំ វិបាកោ យេនាហំ ឯតរហិ ឯវំមហិទ្ធិកោ ឯវំមហានុភាវោ សេយ្យថីទំ ទានស្ស ទមស្ស សញ្ញមស្សាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

បុញ្ញមេវ សោ សិក្ខេយ្យ អាយតគ្គំ សុខុទ្រយំ[៣]
ទានញ្ច សមចរិយញ្ច មេត្តចិត្តញ្ច ភាវយេ
ឯតេ ធម្មេ ភាវយិត្វា តយោ សុខសមុទ្ទយេ
អព្យាបជ្ឈំ សុខំ លោកំ បណ្ឌិតោ ឧបបជ្ជតីតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។ ទុតិយំ[៤] ។

---

១-២ ម. កស្ស ។ ៣ ឱ.ម. សុខិន្ទ្រិយំ ។ ៤ ឱ.ម. ទុតិយត្តំ ឆដ្ឋំ ។

ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្ដីត្រិះរិះថា នេះជាផលកម្មរបស់អាត្មាអញ ដូចម្ដេចហ្ន៎ នេះជាវិបាកនៃកម្មដូចម្ដេច ដែលនាំឲ្យអាត្មាអញមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ក្នុងកាលឥឡូវនេះ ៗ

ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្ដីត្រិះរិះថា នេះជាផលកម្មទាំងឡាយ ៣ យ៉ាង របស់អាត្មាអញ នេះជាវិបាក នៃកម្មទាំងឡាយ ៣ យ៉ាង ដែលនាំឲ្យអាត្មាអញមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ក្នុងកាលឥឡូវនេះ គឺផលទាន១ ការទូន្មានឥន្ទ្រិយ ១ ការសង្រួម ១ ៗ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្ដីនុ៎ះហើយ ៗ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

កុលបុត្រអ្នកប្រាថ្នាប្រយោជន៍ គួរសិក្សា គឺថា គប្បីសេពនូវបុណ្យ ដែលមានផលបរិបូណ៌ មានវិបាកជាសុខ គួរបំរើនទាន ១ ការប្រព្រឹត្តិស្មើ គឺសីល ១ មេត្តាចិត្ត ១ លុះបំរើនធម៌ទាំង៣នេះ ដែលមានអានិសង្សជាសុខហើយ រមែងចូលទៅកាន់លោកជាសុខ[១] ឥតមានទុក្ខ ៗ

ខ្ញុំបានស្ដាប់មកហើយថា សេចក្ដីនេះ ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ៗ សូត្រ ទី ២ ៗ

---

១ សុខក្នុងទីនេះបានដល់សុខដែលកើតអំពីឈានសមាបត្តិ។

ឥតិវុត្តកេ ឯកនិបាតស្ស តតិយវគ្គស្ស តតិយសុត្តំ

(៦៣) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ឯកធម្មោ ភិក្ខវេ ភាវិតោ ពហុលីកតោ ឧភោ អត្ថេ សមធិគយ្ហ តិដ្ឋតិ ទិដ្ឋធម្មិកញ្ចេវ អត្ថំ សម្បរាយិកញ្ច ។ កតមោ ឯកធម្មោ ។ អប្បមាទោ កុសលេសុ ធម្មេសុ ។ អយំ ខោ ភិក្ខវេ ឯកធម្មោ ភាវិតោ ពហុលីកតោ ឧភោ អត្ថេ សមធិគយ្ហ តិដ្ឋតិ ទិដ្ឋធម្មិកញ្ចេវ អត្ថំ សម្បរាយិកញ្ចាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

អប្បមាទំ បសំសន្តិ បុញ្ញកិរិយាសុ បណ្ឌិតា
អប្បមត្តោ ឧភោ អត្ថេ អធិគណ្ហាតិ បណ្ឌិតោ
ទិដ្ឋេ ធម្មេ ច យោ អត្ថោ យោ ចត្ថោ សម្បរាយិកោ
អត្ថាភិសមយា ធីរោ បណ្ឌិតោតិ បវុច្ចតីតិ ។
អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។
តតិយំ(១) ។

---

១ ឱ.ម. តតិយគ្តិ នត្ថិ ។

(២៣) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យរឿយ ៗ ហើយ រមែងបានប្រយោជន៍ទាំង ២ គឺ ប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ប្រយោជន៍ក្នុងបរលោក ១ ។ ធម៌ ១ តើដូចម្តេច ។ គឺសេចក្តីមិនប្រមាទ ក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ ១ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យរឿយ ៗ ហើយ រមែងបានប្រយោជន៍ទាំង ២ គឺប្រយោជន៍ ក្នុងបច្ចុប្បន្ន ១ ប្រយោជន៍ក្នុងបរលោក ១ ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បណ្ឌិតទាំងឡាយ តែងសរសើរសេចក្តីមិនប្រមាទក្នុងបុញ្ញកិរិយាវត្ថុ
ទាំងឡាយ បណ្ឌិតមិនប្រមាទហើយ រមែងបានប្រយោជន៍ទាំង ២
គឺប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ប្រយោជន៍ក្នុងបរលោក ១ អ្នកមាន
ប្រាជ្ញា ព្រោះបានប្រយោជន៍ទាំង ២ ទើបហៅថាជាបណ្ឌិត ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រ ទី ៣ ។

(២៤) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ឯកបុគ្គលស្ស ភិក្ខវេ កប្បំ សន្ធាវតោ សំសរតោ សិយា ឯវំ មហា អដ្ឋិកង្កលោ អដ្ឋិបុញ្ជោ អដ្ឋិរាសិ យថាយំ វេបុល្លបព្វតោ សចេ សំហារកោ អស្ស សម្ភតញ្ច ន វិនស្សេយ្យាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

ឯកស្សេកេន កប្បេន បុគ្គលស្សដ្ឋិសញ្ចយោ
សិយា បព្វតសមោ រាសិ ឥតិ វុត្តំ មហេសិនា
សោ ខោ បនាយំ អក្ខាតោ វេបុល្លោ បព្វតោ មហា
ឧត្តរោ គិជ្ឈកូដស្ស មគធានំ គិរិព្វជេ
យតោ ច អរិយសច្ចានិ សម្មប្បញ្ញាយ បស្សតិ
ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្កមំ
អរិយញ្ចដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ
ស សត្តក្ខត្តុំ បរមំ(១) សន្ធាវិត្វាន បុគ្គលោ
ទុក្ខស្សន្តករោ ហោតិ សព្វសំយោជនក្ខយាតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ចតុត្ថំ(២) ។

---

១ ម. បរមំ ។ ២ ឱ.ម. បុគ្គលំ ឆត្តំ ។

(២៤) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលម្នាក់ ស្ទុះទៅ អន្ទោលទៅ អស់កប្ប បំណែកឆ្អឹង ពំនូកឆ្អឹង គំនរឆ្អឹងជាច្រើន បើបុគ្គលប្រមូលនាំមកដាក់ទុក (១កន្លែង) ហើយរក្សាទុក មិនឲ្យវិនាស ខ្ចាត់ខ្ចាយទៅ ឆ្អឹងទាំងដូចជាភ្នំវេបុល្លនេះដូច្នោះឯង ។ លុះព្រះមានព្រះភាគ សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ព្រះសម្មាសម្ពុទ្ធ ព្រះអង្គស្វែងរកគុណដ៏ធំ ទ្រង់ត្រាស់ដូច្នេះ
ថា គំនរឆ្អឹង បុគ្គលម្នាក់ៗក្នុងមួយកប្បជាគំនរប៉ុនភ្នំ ឯភ្នំនោះ
ឯង ដែលព្រះសម្មាសម្ពុទ្ធត្រាស់ថា ភ្នំវេបុល្ល ជាភ្នំធំ ជាភ្នំខ្ពស់
ជាងភ្នំគិជ្ឈកូដ ក្បែរក្រុងគិរិព្វជៈ គឺរាជគ្រឹះរបស់ពួកជនអ្នក
ស្រុកមគធៈ កាលណាបើបុគ្គលឃើញអរិយសច្ចទាំងឡាយ
ដោយបញ្ញាដ៏ប្រពៃ គឺទុក្ខ ១ ហេតុដែលនាំឲ្យកើតទុក្ខ ១
ការកន្លងបង់ទុក្ខ ១ មគ្គប្រកបដោយអង្គ៨ដ៏ប្រសើរ ដែល
ជាទីញុំាងសត្វឲ្យទៅកាន់ទីរលត់ទុក្ខ ១ លុះបុគ្គលនោះ
អន្ទោលទៅអស់ ៧ ជាតិ ជាយ៉ាងក្រៃលែង ទើបធ្វើនូវ
ទីបំផុតនៃទុក្ខបាន ព្រោះអស់សំយោជនៈទាំងពួង ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៤ ។

## ឥតិវុត្តកេ ឯកនិបាតស្ស តតិយវគ្គស្ស បញ្ចមសុត្តំ

(២៥) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ឯកធម្មំ អតីតស្ស ភិក្ខវេ បុរិសបុគ្គលស្ស នាហំ តស្ស កិញ្ចិ បាបកម្មំ អករណីយន្តិ វទាមិ ។ កតមំ ឯកធម្មំ ។ យទិទំ ភិក្ខវេ សម្បជានមុសាវាទោតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

ឯកធម្មំ អតីតស្ស មុសាវាទិស្ស ជន្តុនោ
វិតិណ្ណបរលោកស្ស នត្ថិ បាបំ អការិយន្តិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។
បញ្ចមំ(១) ។

(២៦) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ឯវញ្ចេ ភិក្ខវេ សត្តា ជានេយ្យុំ ទានសំវិភាគស្ស វិបាកំ យថាហំ ជានាមិ ន អទត្វា ភុញ្ជេយ្យុំ ន ច នេសំ មច្ឆេរមលំ ចិត្តំ បរិយាទាយ តិដ្ឋេយ្យ ។ យោបិ នេសំ អស្ស ចរិមោ អាលោបោ ចរិមំ កពលំ តតោបិ ន អសំវិភជិត្វា ភុញ្ជេយ្យុំ សចេ នេសំ បដិគ្គាហកា អស្សុ ។

---

១ ឱ.ម. បញ្ចមត្ថី នត្ថិ ។

(២៥) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គល ដែលកន្លងធម៌ ១ ហើយ តថាគតមិនដែលពោលថា បុរសបុគ្គលនោះ មិនគប្បីធ្វើបាបកម្មបន្តិចបន្តួច ដូច្នេះឡើយ ។ ធម៌ ១ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១ នេះ គឺសម្បជានមុសាវាទ (ការពោលពាក្យកុហកទាំងដឹងខ្លួន) ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះ ហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សត្វដែលកន្លងធម៌ ១ គឺអ្នកពោលពាក្យកុហក មានបរលោក
កន្លងបង់ហើយ មិនគប្បីធ្វើអំពើបាប មិនមានឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បាន ត្រាស់ទុកហើយ ។ សូត្រ ទី ៥ ។

(២៦) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បើពួកសត្វដឹងផលនៃ ការចែកទាន ដូចជាតថាគតដឹងដូច្នោះ បើមិនទាន់ឲ្យទានទេ ក៏មិនហ៊ាន បរិភោគឡើយ មួយទៀត មន្ទិលគឺសេចក្តីកំណាញ់របស់សត្វទាំងនោះ ក៏ មិនគ្របសង្កត់ចិត្តបានឡើយ ។ ពោះបើពំនូតបាយជាដម្បូង ដុំបាយជាដម្បូង ឯណា របស់សត្វទាំងឡាយនោះ សត្វទាំងឡាយមិនបានចែកអំពីពំនូត បាយនោះ ក៏មិនបរិភោគឡើយ បើសត្វទាំងនោះមានបដិគ្គាហកបុគ្គល ។

យស្មា ច ខោ ភិក្ខវេ សត្តា ន ឯវំ ជានន្តិ ទានសំវិភាគស្ស វិបាកំ យថាហំ ជានាមិ តស្មា អទត្វា ភុញ្ជន្តិ មច្ឆេរមលញ្ច នេសំ ចិត្តំ បរិយា-ទាយ តិដ្ឋតីតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

ឯវញ្ចេ សត្តា ជានេយ្យុំ យថាវុត្តំ មហេសិនា
វិបាកំ សំវិភាគស្ស យថា ហោតិ មហប្ផលំ
វិនេយ្យ[១] មច្ឆេរមលំ វិប្បសន្នេន ចេតសា
ទជ្ជុំ កាលេន អរិយេសុ យត្ថ ទិន្នំ មហប្ផលំ
អន្នញ្ច ទត្វាន ពហុនោ ទក្ខិណេយ្យេសុ ទក្ខិណំ
ឥតោ ចុតា មនុស្សត្តា សគ្គំ គច្ឆន្តិ ទាយកា
តេ ច សគ្គគតា តត្ថ មោទន្តិ កាមកាមិនោ
វិបាកំ សំវិភាគស្ស អនុភោន្តិ អមច្ឆរា ។

---

១ ឱ.ម. វិនេយ្យុំ

ម្នាលភិក្ខុទាំងឡាយ តថាគតដឹងផលនៃការឲ្យ និងការចែករំលែក យ៉ាងណា សត្វទាំងឡាយ មិនដឹងយ៉ាងនោះទេ ព្រោះហេតុណា ហេតុនោះ សត្វទាំងឡាយមិនបានឲ្យទានហើយ ទើបហ៊ានបរិភោគ មួយទៀត មន្ទិលគឺសេចក្តីកំណាញ់ ក៏តែងគ្របសង្កត់ចិត្តសត្វទាំងឡាយ នោះ ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បើសត្វទាំងឡាយ គប្បីដឹងផល នៃការចែករំលែក ថាមាន ផលច្រើន ដូចព្រះពុទ្ធទ្រង់ស្វែងរកគុណដ៏ធំត្រាស់ទុកហើយ យ៉ាងនេះ សត្វទាំងឡាយ មានចិត្តជ្រះថ្លា គប្បីបន្ទោបង់ មន្ទិល គឺសេចក្តីកំណាញ់ចេញ បានដែលគេឲ្យហើយ ដល់ព្រះអរិយៈទាំងឡាយណា រមែងមានផលច្រើន បុគ្គល ទាំងឡាយ គួរឲ្យទានដល់ព្រះអរិយៈទាំងនោះ ក្នុងកាលដ៏គួរ មួយទៀត ជនច្រើននាក់ ឲ្យហើយជាទក្ខិណាទាន ដល់ ទក្ខិណេយ្យបុគ្គលទាំងឡាយ ទាយកទាំងឡាយ លុះច្យុតអំពី អត្តភាពជាមនុស្សនេះហើយ រមែងទៅកាន់ឋានសួគ៌ ទាយក ទាំងនោះ លុះទៅកាន់ឋានសួគ៌ ជាអ្នកមានបំណងក្នុងកាម រមែងរីករាយ ក្នុងឋានសួគ៌នោះ សត្វទាំងឡាយ មិន កំណាញ់ រមែងសោយផល នៃការចែករំលែក ។

ឥតិវុត្តកេ ឯកនិបាតស្ស តតិយវគ្គស្ស សត្តមសុត្តំ

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ឆដ្ឋំ[(១)] ។

(២៧) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ យានិ កានិចិ ភិក្ខវេ ឱបធិកានិ បុញ្ញកិរិយាវត្ថូនិ សព្វានិ តានិ មេត្តាយ ចេតោវិមុត្តិយា កលំ នាគ្ឃន្តិ សោឡសឹ មេត្តាយេវ តានិ ចេតោវិមុត្តិ អធិគ្គហេត្វា ភាសតេ ច តបតេ ច វិរោចតេ[(២)] ច ។ សេយ្យថាបិ ភិក្ខវេ យា កាចិ តារករូបានំ បភា សព្វា តា ចន្ទប្បភាយ[(៣)] កលំ នាគ្ឃន្តិ សោឡសឹ ចន្ទប្បភា យេវ តានិ អធិគ្គហេត្វា ភាសតេ ច តបតេ ច វិរោចតេ ច ឯវមេវ ខោ ភិក្ខវេ យានិ កានិចិ ឱបធិកានិ បុញ្ញកិរិយាវត្ថូនិ សព្វានិ តានិ មេត្តាយ ចេតោវិមុត្តិយា កលំ នាគ្ឃន្តិ សោឡសឹ មេត្តាយេវ តានិ ចេតោវិមុត្តិ អធិគ្គហេត្វា ភាសតេ ច តបតេ ច វិរោចតេ ច ។

---

១ ឱម. ឆដ្ឋិ ឧត្តិ ។ ២ ឱ,ម. វិរោចតិ ។ ៣ ឱ.ឌ ចន្ទិយា បភាយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បាន ត្រាស់ទុកហើយ ។ សូត្រទី ៦ ។

(៦៧) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុញ្ញកិរិយាវត្ថុទាំងឡាយ ដែលឲ្យផលក្នុងបដិសន្ធិកាលទីឯបវត្តិកាល ឯណាទីមួយ បុញ្ញកិរិយាវត្ថុទាំងអស់នោះ មិនដល់មួយចំណិតនៃមេត្តាចេតោវិមុត្តិ ដែលបុគ្គលចែកឲ្យជាចំណែក ១៦ ។ ផងឡើយ មេត្តាចេតោវិមុត្តិ តែងគ្របសង្កត់បុញ្ញកិរិយាវត្ថុទាំងនោះ ភ្លឺស្វាងរុងរឿង ។ ម្នាលភិក្ខុទាំងឡាយ ដូចពន្លឺពួកផ្កាយ ឯណាទីមួយ ពន្លឺពួកផ្កាយទាំងអស់នោះ មិនដល់មួយចំណិតពន្លឺព្រះចន្ទ ដែលបុគ្គលចែកជាចំណែក ១៦ ។ ផងឡើយ ពន្លឺព្រះចន្ទ តែងគ្របសង្កត់ពន្លឺផ្កាយទាំងអម្បាលនោះ ភ្លឺស្វាងរុងរឿង ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ បុញ្ញកិរិយាវត្ថុទាំងឡាយ ដែលឲ្យផលក្នុងបដិសន្ធិកាលទីឯបវត្តិកាលឯណាទីមួយ បុញ្ញកិរិយាវត្ថុទាំងអស់នោះ មិនដល់មួយចំណិតនៃមេត្តាចេតោវិមុត្តិ ដែលចែកឲ្យជាចំណែក១៦ ។ ផង មេត្តាចេតោវិមុត្តិ តែងគ្របសង្កត់បុញ្ញកិរិយាវត្ថុទាំងនោះ ភ្លឺស្វាងរុងរឿង ក៏ដូច្នោះឯង ។

សេយ្យថាបិ ភិក្ខវេ វស្សានំ បច្ឆិមេ មាសេ សរទសមយេ វិទ្ធេ(១) វិគតវលាហកេ ទេវេ(២) អាទិច្ចោ នភំ អព្ភុស្សក្កមានោ សព្វំ អាកាសំ(៣) តមគតំ អភិហច្ច(៤) ភាសតេ ច តបតេ ច វិរោចតេ ច ឯវមេវ ខោ ភិក្ខវេ យានិ កានិចិ ឱបធិកានិ បុញ្ញកិរិយវត្ថូនិ សព្វានិ តានិ មេត្តាយ ចេតោវិមុត្តិយា កលំ នាគ្ឃន្តិ សោឡសឹ មេត្តាយេវ តានិ ចេតោវិមុត្តិ អធិគ្គហេត្វា ភាសតេ ច តបតេ ច វិរោចតេ ច ។ សេយ្យថាបិ ភិក្ខវេ រត្តិយា បច្ចូសសមយំ ឱសធិតារកា ភាសតេ ច តបតេ ច វិរោចតេ ច ឯវមេវ ខោ ភិក្ខវេ យានិ កានិចិ ឱបធិកានិ បុញ្ញកិរិយវត្ថូនិ សព្វានិ តានិ មេត្តាយ ចេតោវិមុត្តិយា កលំ នាគ្ឃន្តិ សោឡសឹ មេត្តាយេវ តានិ ចេតោវិមុត្តិ អធិគ្គហេត្វា ភាសតេ ច តបតេ ច វិរោចតេ ចាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

---

១ ឱ. វិសុទ្ធេ ។ ២ ឱ.ម. នភេ ។ ៣ ឱ.ម. អាកាសគតំ ។ ៤ ឱ.ម. អភិវិហច្ច ។

ម្នាលភិក្ខុទាំងឡាយ ដូចមេឃដែលស្រឡះ ប្រាសចាកពពក ក្នុងសរទសម័យ ក្នុងខែជាខាងចុងនៃរដូវភ្លៀង ព្រះអាទិត្យ ក៏រះត្រដួចត្រដឹមក្នុងពពក កំចាត់បង់ងងឹតឰដ៏អាកាសទាំងអស់ ភ្លឺស្វាងរុងរឿង ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ បុញ្ញកិរិយាវត្ថុទាំងឡាយ ដែលឲ្យផលក្នុងបដិសន្ធិកាលនឹងបវត្តិកាល ឯណានីមួយ បុញ្ញកិរិយាវត្ថុទាំងអស់នោះ មិនដល់មួយចំណិតនៃមេត្តាចេតោវិមុត្តិ ដែលបុគ្គលចែកឲ្យជាចំណែក ១៦ ។ ផងឡើយ មេត្តាចេតោវិមុត្តិ តែងគ្របសង្កត់បុញ្ញកិរិយាវត្ថុទាំងនោះ ភ្លឺស្វាងរុងរឿង ដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ ដូចផ្កាយព្រឹក ភ្លឺស្វាងរុងរឿង ក្នុងបច្ចូសសម័យនៃរាត្រី ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ បុញ្ញកិរិយាវត្ថុទាំងឡាយ ដែលឲ្យផល ក្នុងបដិសន្ធិកាលនឹងបវត្តិកាល ឯណានីមួយ បុញ្ញកិរិយាវត្ថុទាំងអស់នោះ មិនដល់មួយចំណិតនៃមេត្តាចេតោវិមុត្តិ ដែលចែកឲ្យជាចំណែក ១៦ ។ ផងឡើយ មេត្តាចេតោវិមុត្តិ តែងគ្របសង្កត់បុញ្ញកិរិយាវត្ថុទាំងនោះ ភ្លឺស្វាងរុងរឿង ដូច្នោះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ឥតិវុត្តកេ ឯកនិបាតស្ស តតិយវគ្គស្ស សត្តមសុត្តំ

យោ ច មេត្តំ ភាវយតិ អប្បមាណំ បដិស្សតោ
តនូ សំយោជនា ហោន្តិ បស្សតោ ឧបធិក្ខយំ
ឯកម្បិ ចេ បាណមទុដ្ឋចិត្តោ
មេត្តាយតិ កុសលោ តេន ហោតិ
សព្វេ ច បាណេ មនសានុកម្បំ
បហូតមរិយោ បករោតិ បុញ្ញំ
(១) យេ សត្តសណ្ឌំ បឋវឹ វិជិត្វា
រាជីសយោ យជមានានុបរិយគា (២)
( អស្សមេធំ (៣) បុរិសមេធំ
សម្មាបាសំ វាជបេយ្យំ (៤) និរគ្គឡំ )
មេត្តស្ស ចិត្តស្ស សុភាវិតស្ស
កលម្បិ តេ នានុភវន្តិ សោឡសឹ
( ចន្ទប្បភា តារគណាវ សព្វេ )

---

១ ម. យោ ។ ២ ម. ដមានានុបរិយគា ។ ៣ ម. សស្សមេធំ ។ ៤ ម. វាចាបេយ្យំ ។

បុគ្គលណា មានស្មារតី ចំរើនមេត្តា មិនមានប្រមាណ បដិឃ-សំយោជនៈទាំងឡាយ របស់បុគ្គលនោះអ្នកឃើញកិរិយាអស់ទៅនៃកិលេស រមែងស្តួចស្តើង បើបុគ្គលមានចិត្តមិនប្រទូស្តសត្វ សូម្បីតែសត្វមួយ ចំរើនមេត្តា ជាបុគ្គលឈ្លាសវៃ ដោយមេត្តានោះ មួយទៀត ព្រះអរិយៈកាលអនុគ្រោះសត្វទាំងអស់ដោយចិត្តហើយ ឈ្មោះថាធ្វើបុណ្យច្រើន ជនទាំងឡាយណាឈ្នះផែនដីធំដេរដាសទៅដោយសត្វ ជនទាំងឡាយនោះ ជាធម្មិករាជ ប្រហែលដោយឥសី ហើយញុំាងការបូជាឲ្យប្រព្រឹត្តទៅ(គឺទ្រង់ឈ្លាសវៃក្នុងការទំនុកបម្រុងធញ្ញាហារ គឺស្រែស្រូវឲ្យសម្បូណ៌ក្នុងព្រះរាជអាណាចក្រ១ ទ្រង់ឈ្លាសវៃក្នុងការស-ង្គ្រោះរាជបុរស១ ទ្រង់ប្រកបឧបាយចងចិត្តមនុស្សឲ្យចូលចិត្ត១ ទ្រង់មានព្រះបន្ទូលផ្អែមល្ហែម១ ជាហេតុឲ្យស្រុកទេសរាបទាបសាន្តត្រាណគ្មានចោរ ទាល់តែមិនបាច់ដាក់គន្លឹះទាក់សោទ្វារផ្ទះ១) ការបូជាទាំងឡាយនោះ មិនដល់មួយចំណិត នៃបុគ្គលអ្នកចំរើនមេត្តាចិត្ត ដែលចែកឲ្យជាចំណែក ១៦ ៗ ផងឡើយ (ដូចពួកផ្កាយទាំងអស់ មិនដល់មួយចំណិតនៃពន្លឺព្រះចន្ទ្រ)

យោ ន ហន្តិ ន ឃាតេតិ ន ជិនាតិ ន ជាបយេ

មេត្តំសោ សព្វភូតេសុ វេរំ តស្ស ន កេនចីតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

សត្តមំ[១] ។

តតិយវគ្គោ ។

តស្សុទ្ទានំ

ចិត្តំ ឈាយី ឧភោ អត្ថេ[២] ពុញ្ជំ វេបុល្លបព្វតំ

សម្បជានមុសាវាទោ ទានញ្ច មេត្តភាវញ្ច[៣]

សត្តមានិ ច សុត្តានិ បុរិមានិ ច វីសតិ

ឯកធម្មេសុ សុត្តន្តា សត្តវីសតិ សង្គហាតិ ។

ឯកនិបាតោ និដ្ឋិតោ[៤] ។

---

១ ឱ.ម. សត្តមន្តិ នត្ថិ ។ ២ ម. អត្ថា ។ ៣ ម. មេត្តភាវញ្ច ។ ៤ ឱ. ឥតោ បរំ ទ្វេ ធម្មេ អនុក្កមិតិ ឈាប ទិស្សតិ ។

បុគ្គលណាមិនសម្លាប់សត្វដោយខ្លួនឯង មិនប្រើគេឲ្យសម្លាប់ មិនផ្ចាញ់ផ្ចាល ដោយខ្លួនឯង មិនប្រើគេឲ្យផ្ចាញ់ផ្ចាល ជាអ្នកមានចំណែកនៃមេត្តា ក្នុងសត្វទាំងឡាយទាំងពួង ពៀរមិនមានដល់បុគ្គលនោះ ដោយហេតុណាមួយឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៧ ។

ចប់ តតិយវគ្គ ។

## ឧទ្ទាននៃតតិយវគ្គនោះគឺ

និយាយអំពីចិត្ត ១ ចំរើនឈាន ១ ប្រយោជន៍ទាំងពីរ ១ គំនរឆ្អឹងដូចជាភ្នំវេបុល្ល ១ សម្បជានមុសាវាទ ១ ទាន ១ ការចំរើនមេត្តា ១ ព្រះសូត្រទាំងឡាយក្នុងធម៌មួយ ៗ គឺ ព្រះសូត្រ (ខាងចុង) ៧ សូត្រ ព្រះសូត្រខាងដើម ២០ សូត្រ សង្គ្រោះជាសូត្រ ២៧ សូត្រ ។

ចប់ ឯកនិបាត ។

# ឥតិវុត្តកេ ទុកនិបាតស្ស បឋមវគ្គោ

(២៨) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ទ្វីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ ទិដ្ឋេវ ធម្មេ ទុក្ខំ វិហរតិ សវិឃាតំ សឧបាយាសំ សបរិឡាហំ កាយស្ស ភេទា បរម្មរណា ទុគ្គតិ បាដិកង្ខា ។ កតមេហិ ទ្វីហិ ។ ឥន្ទ្រិយេសុ អគុត្តទ្វារតាយ ច ភោជនេ អមត្តញ្ញុតាយ ច ។ ឥមេហិ ខោ ភិក្ខវេ ទ្វីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ទិដ្ឋេវ ធម្មេ ទុក្ខំ វិហរតិ សវិឃាតំ សឧបាយាសំ សបរិឡាហំ កាយស្ស ភេទា បរម្មរណា ទុគ្គតិ បាដិកង្ខាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

ចក្ខុសោតញ្ច ឃានញ្ច ជិវ្ហា កាយោ តថា មនោ
ឯតានិ យស្ស ទ្វារានិ អគុត្តានិធ ភិក្ខុនោ
ភោជនម្ហិ អមត្តញ្ញូ ឥន្ទ្រិយេសុ អសំវុតោ
កាយទុក្ខំ ចេតោទុក្ខំ ទុក្ខំ សោ អធិគច្ឆតិ
ឌយ្ហមានេន កាយេន ឌយ្ហមានេន ចេតសា
ទិវា វា យទិ វា រត្តិំ ទុក្ខំ វិហរតិ តាទិសោតិ ។

(២៧) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ២ រមែងនៅជាទុក្ខ ប្រកបដោយសេចក្តីថ្នាំងថ្នាក់ ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្រវល់ក្រវាយ ក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ ប្រាកដជាទៅកាន់ទុគ្គតិ ។ ភិក្ខុប្រកបដោយធម៌ ២ តើដូចម្តេច ។ គឺភាពជាអ្នកមិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ១ ភាពជាអ្នកមិនដឹងប្រមាណក្នុងភោជន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ២ នេះឯង រមែងនៅជាទុក្ខ ប្រកបដោយសេចក្តីថ្នាំងថ្នាក់ ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្រវល់ក្រវាយ ក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ ប្រាកដជាទៅកាន់ទុគ្គតិ ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះ+ហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ភិក្ខុណា ក្នុងសាសនានេះ មិនបានគ្រប់គ្រងទ្វារអម្បាលនេះគឺ ចក្ខុ ១ សោតៈ ១ ឃានៈ ១ ជិវ្ហា ១ កាយ ១ មនៈ ១ ជាអ្នកមិនដឹងប្រមាណក្នុងភោជន មិនសង្រួមក្នុងឥន្ទ្រិយទាំងឡាយ ភិក្ខុនោះតែងបានទទួលសេចក្តីទុក្ខ គឺទុក្ខក្នុងកាយផង ទុក្ខក្នុងចិត្តផង ភិក្ខុបែបនោះ មានកាយក្តៅក្រហាយ មានចិត្តក្តៅក្រហាយ តែងនៅជាទុក្ខទាំងថ្ងៃទាំងយប់ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។ បឋមំ(១) ។

[២៩] វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ទ្វីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ ទិដ្ឋេវ ធម្មេ សុខំ វិហរតិ អវិឃាតំ អនុបាយាសំ អបរិឡាហំ កាយស្ស ភេទា បរម្មរណា សុគតិ បាដិកង្ខា ។ កតមេហិ ទ្វីហិ ។ ឥន្ទ្រិយេសុ គុត្តទ្វារតាយ ច ភោជនេ មត្តញ្ញុតាយ ច ។ ឥមេហិ ខោ ភិក្ខវេ ទ្វីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ទិដ្ឋេវ ធម្មេ សុខំ វិហរតិ អវិឃាតំ អនុបាយាសំ អបរិឡាហំ កាយស្ស ភេទា បរម្មរណា សុគតិ បាដិកង្ខាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

ចក្ខុ សោតញ្ច ឃានញ្ច ជិវ្ហា កាយោ អថោ មនោ
ឯតានិ យស្ស ទ្វារានិ សុគុត្តានីធ ភិក្ខុនោ
ភោជនម្ហិ ច មត្តញ្ញូ ឥន្ទ្រិយេសុ ច សំវុតោ
កាយសុខំ ចេតោសុខំ សុខំ សោ អធិគច្ឆតិ
អឌយ្ហមានេន កាយេន អឌយ្ហមានេន ចេតសា
ទិវា វា យទិ វា រត្តិំ សុខំ វិហរតិ តាទិសោតិ ។

១ ឱ. ម. បឋមត្តិកត្តំ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ១ ។

(២៩) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ២ រមែងនៅជាសុខ មិនថ្នាំងថ្នាក់ មិនចង្អៀតចង្អល់ មិនក្រវល់ក្រវាយ ក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ ប្រាកដជាទៅកាន់សុគតិ ។ ភិក្ខុប្រកបដោយធម៌ ២ តើដូចម្តេច ។ គឺភាពជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ១ ភាពជាអ្នកដឹងប្រមាណក្នុងភោជន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ២ នេះឯង រមែងនៅជាសុខ មិនថ្នាំងថ្នាក់ មិនចង្អៀតចង្អល់ មិនក្រវល់ក្រវាយ ក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ ប្រាកដជាទៅកាន់សុគតិ ។ លុះព្រះមានព្រះភាគទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ភិក្ខុណា ក្នុងសាសនានេះ បានគ្រប់គ្រងទ្វារទាំងឡាយនេះគឺ
ចក្ខុ ១ សោតៈ ១ ឃានៈ ១ ជិវ្ហា ១ កាយ ១ មនៈ ១
ល្អហើយ ជាអ្នកដឹងប្រមាណក្នុងភោជន សង្រួមក្នុងឥន្ទ្រិយ
ទាំងឡាយ ភិក្ខុនោះតែងបានសេចក្តីសុខ គឺសុខក្នុងកាយផង
សុខក្នុងចិត្តផង ភិក្ខុបែបនោះ មានកាយមិនក្តៅក្រហាយ
មានចិត្តមិនក្តៅក្រហាយ រមែងនៅជាសុខ ទាំងថ្ងៃទាំងយប់ ។

## ឥតិវុត្តកេ ទុកនិបាតស្ស បឋមវគ្គស្ស តតិយសុត្តំ

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។ ទុតិយំ[១] ។

(៣០) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ទ្វេមេ ភិក្ខវេ ធម្មា តបនីយា ។ កតមេ ទ្វេ ។ ឥធ ភិក្ខវេ ឯកច្ចោ អកតកល្យាណោ ហោតិ អកតកុសលោ អកតភីរុត្តាណោ កតបាបោ កតលុទ្ទោ[២] កតកិព្ពិសោ សោ អកតំ មេ កល្យាណន្តិបិ តប្បតិ កតំ មេ បាបន្តិបិ តប្បតិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មា តបនីយាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

កាយទុច្ចរិតំ កត្វា វចីទុច្ចរិតានិ ច[៣]
មនោទុច្ចរិតំ កត្វា យញ្ចញ្ញំ ទោសសញ្ហិតំ[៤]
អកត្វា កុសលំ កម្មំ កត្វានាកុសលំ ពហុំ
កាយស្ស ភេទា ទុប្បញ្ញោ និរយំ សោ ឧបបជ្ជតីតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។ តតិយំ[៥] ។

---

១ ឱ.ម. ទុតិយន្តិ ទន្តិ ។ ២ ឱ. កតត្ថុទ្ទោ ។ ៣ ម.ប ។ ៤ ឱ. ទោសសញ្ញិតំ ។
៥ ឱ.ម. តតិយន្តិ ទត្តិ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បាន ត្រាស់ទុកហើយ ។ សូត្រ ទី ២ ។

(៣០) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌នាំឲ្យក្តៅនេះ មាន២ ។ ធម៌នាំឲ្យក្តៅ២តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ មិនបានធ្វើសេចក្តីល្អ មិនបានធ្វើកុសល មិនបានធ្វើទីពឹងអាស្រ័យ ធ្វើតែអំពើបាប ធ្វើតែអំពើរឹងរូស ធ្វើតែអំពើអាក្រក់ បុគ្គលនោះ តែងក្តៅក្រហាយ ដោយគិតថា អាត្មាអញមិនបានធ្វើអំពើល្អផង តែងក្តៅក្រហាយ ដោយគិតថា អាត្មាអញ ធ្វើតែអំពើអាក្រក់ផង ។ ម្នាលភិក្ខុទាំងឡាយ ធម៌នាំឲ្យក្តៅមាន២នេះឯង ។ លុះព្រះមានព្រះភាគសំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលណា ធ្វើកាយទុច្ចរិត វចីទុច្ចរិត ឬធ្វើមនោទុច្ចរិត ឬក៏អំពើ
ណាមួយដទៃទៀត ដែលប្រកបដោយទោស មិនបានធ្វើ
កុសលកម្ម ធ្វើតែអកុសលជាច្រើន បុគ្គលអ្នកឥតបញ្ញានោះ
លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងចូលទៅកាន់នរក ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បាន ត្រាស់ទុកហើយ ។ សូត្រ ទី ៣ ។

(៣១) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ទ្វេមេ ភិក្ខវេ ធម្មា អតបនីយា ។ កតមេ ទ្វេ ។ ឥធ ភិក្ខវេ ឯកច្ចោ កតកល្យាណោ ហោតិ កតកុសលោ កតភីរុត្តាណោ អកតបាបោ អកតលុទ្ទោ[១] អកតកិព្ពិសោ សោ កតំ មេ កល្យាណន្តិបិ ន តប្បតិ អកតំ មេ បាបន្តិបិ ន តប្បតិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មា អតបនីយាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

កាយទុច្ចរិតំ ហិត្វា វចីទុច្ចរិតានិ ច
មនោទុច្ចរិតំ ហិត្វា យញ្ចញ្ញំ ទោសសញ្ហិតំ ។
អកត្វា អកុសលំ កម្មំ កត្វាន កុសលំ ពហុំ
កាយស្ស ភេទា សប្បញ្ញោ សគ្គំ សោ ឧបបជ្ជតីតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ចតុត្ថំ[២] ។

---

១ ម៊ី. អកតត្ថុទ្ទោ ។ ២ ឱ.ម. បតុត្ថិ ឆដ្ឋំ ។

(៣១) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌នាំមិនឲ្យក្តៅក្រហាយនេះ មាន ២ ។ ធម៌នាំមិនឲ្យក្តៅក្រហាយ ២ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ បានធ្វើសេចក្តីល្អទុកហើយ បានធ្វើកុសលទុកហើយ បានធ្វើសេចក្តីពឹងពាក់ទុកហើយ មិនបានធ្វើបាប មិនបានធ្វើសេចក្តីរឹងរូស មិនបានធ្វើសេចក្តីអាក្រក់ បុគ្គលនោះ តែងមិនក្តៅក្រហាយ ដោយគិតថា អាត្មាអញ បានធ្វើសេចក្តីល្អទុកហើយផង តែងមិនក្តៅក្រហាយ ដោយគិតថា អាត្មាអញ មិនបានធ្វើសេចក្តីអាក្រក់ទុកហើយផង ។ ម្នាលភិក្ខុទាំងឡាយ ធម៌នាំមិនឲ្យក្តៅក្រហាយ មាន ២ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលណា លះបង់កាយទុច្ចរិត វចីទុច្ចរិត ឬលះបង់មនោទុច្ចរិត ឬ
អំពើណាមួយដទៃទៀត ដែលប្រកបដោយទោស មិនធ្វើអកុសល.
កម្ម ធ្វើតែកុសលកម្មជាច្រើន បុគ្គលនោះ ជាអ្នកប្រកបដោយបញ្ញា
លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងចូលទៅកាន់ស្ថានសួគ៌ ។

ខ្ញុំបានស្តាប់មក ហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៤ ។

(៣២) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ទ្វីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បុគ្គលោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ ទ្វីហិ ។ បាបកេន ច សីលេន បាបិកាយ ច ទិដ្ឋិយា ។ ឥមេហិ ខោ ភិក្ខវេ ទ្វីហិ ធម្មេហិ សមន្នាគតោ បុគ្គលោ យថាភតំ និក្ខិត្តោ ឯវំ និរយេតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

បាបកេន ច សីលេន បាបិកាយ ច ទិដ្ឋិយា
ឯតេហិ ទ្វីហិ ធម្មេហិ យោ សមន្នាគតោ នរោ
កាយស្ស ភេទា ទុប្បញ្ញោ និរយំ សោ ឧបបជ្ជតីតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

បញ្ចមំ[1] ។

---

១ ឱ. ម. បញ្ចមន្តិ នត្ថិ ។

(៣៦) ខ្ញុំបានស្តាប់មកហើយថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ២ រមែងទៅកើត ក្នុងនរក ដូចគេនាំយកទៅទំលាក់ ។ ប្រកបដោយធម៌ ២ តើ ដូចម្តេច ។ គឺប្រកបដោយសីលលាមក ១ ប្រកបដោយទិដ្ឋិលាមក ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ២ នេះឯង រមែងទៅកើត ក្នុងនរក ដូចគេនាំយកទៅទំលាក់ ។ លុះព្រះមានព្រះភាគទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ជនណា ប្រកបដោយធម៌ ២ យ៉ាងនេះ គឺដោយសីល
លាមក ១ ដោយទិដ្ឋិលាមក ១ ជនអ្នកឥតបញ្ញានោះ
លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងចូលទៅ កាន់នរក ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រ ទី ៨ ។

(៣៣) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ទ្វីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បុគ្គលោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ ទ្វីហិ ។ ភទ្ទកេន ច សីលេន ភទ្ទិកាយ ច ទិដ្ឋិយា ។ ឥមេហិ ខោ ភិក្ខវេ ទ្វីហិ ធម្មេហិ សមន្នាគតោ បុគ្គលោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

ភទ្ទកេន ច សីលេន ភទ្ទិកាយ ច ទិដ្ឋិយា
ឯតេហិ ទ្វីហិ ធម្មេហិ យោ សមន្នាគតោ នរោ
កាយស្ស ភេទា សប្បញ្ញោ សគ្គំ សោ ឧបបជ្ជតីតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ឆដ្ឋំ[១] ។

---

១ ឱ. ម. ឆដ្ឋិទ្ធិ ឥទ្ធិ ។

(៣៣) ខ្ញុំបានស្តាប់មកហើយថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ២ រមែងទៅកើតក្នុងស្ថានសួគ៌ ដូចគេនាំយកទៅដំកល់ទុក ។ ប្រកបដោយធម៌ ២ តើដូចម្តេច ។ គឺប្រកបដោយសីលចំរើន ១ ប្រកបដោយទិដ្ឋិចំរើន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌២ នេះឯង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចគេនាំយកទៅដំកល់ទុក ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះក្នុងសូត្រនោះថា

ជនណា ប្រកបដោយធម៌ ២ នេះ គឺដោយសីលល្អ ១

ដោយទិដ្ឋិល្អ ១ ជនអ្នកប្រកបដោយបញ្ញានោះ លុះ

បែកធ្លាយកាយស្លាប់ទៅ រមែងចូលទៅកាន់ស្ថានសួគ៌ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បាន

ត្រាស់ទុកហើយ ។ សូត្រ ទី ៦ ។

(៣៨) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ អនាតាបី ភិក្ខវេ ភិក្ខុ អនោត្តប្បី អភព្វោ សម្ពោធាយ អភព្វោ និព្វានាយ អភព្វោ អនុត្តរស្ស យោគក្ខេមស្ស អធិគមាយ អាតាបី ខោ ភិក្ខវេ ភិក្ខុ ឱត្តប្បី ភព្វោ សម្ពោធាយ ភព្វោ និព្វានាយ ភព្វោ អនុត្តរស្ស យោគក្ខេមស្ស អធិគមាយាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

អនាតាបី អនោត្តប្បី កុសីតោ ហីនវីរិយោ
យោ ថីនមិទ្ធពហុលោ អហិរីកោ អនាទរោ
អភព្វោ តាទិសោ ភិក្ខុ ផុដ្ឋុំ សម្ពោធិមុត្តមំ
យោ ច សតិមា និបកោ ឈាយី
អាតាបី ឱត្តប្បី ច អប្បមត្តោ
សញ្ញោជនំ ជាតិជរាយ ឆេត្វា
ឥធេវ សម្ពោធិមនុត្តរំ ផុសេតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។ សត្តមំ(១) ។

១ ឱម. សត្តមត្តី ឥត្ថិ ។

(៣៤) ខ្ញុំបានស្តាប់មកហើយថា ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនមានព្យាយាមជាគ្រឿងដុតកំដៅកិលេស មិនមានសេចក្តីខ្លាចបាប មិនគួរដើម្បីត្រាស់ដឹង មិនគួរដើម្បីរំលត់ មិនគួរដើម្បីបាននូវធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរឡើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានសេចក្តីខ្លាចបាប ទើបគួរដើម្បីត្រាស់ដឹង គួរដើម្បីរំលត់ គួរដើម្បីបាននូវធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ ៗ លុះព្រះមានព្រះភាគទ្រង់សំដែងសេចក្តីនុ៎ះហើយ ៗ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ភិក្ខុណា មិនមានព្យាយាមដុតកំដៅកិលេស មិនមានសេចក្តី
ខ្លាចបាប ជាអ្នកខ្ជិលច្រអូស មានព្យាយាមថោកថយ ច្រើនដោយ
ថីនមិទ្ធៈ មិនមានសេចក្តីអៀនខ្មាស មិនមានសេចក្តីអើពើ ភិក្ខុនោះ
មិនគួរដើម្បីបាននូវសេចក្តីត្រាស់ដឹងដ៏ឧត្តមឡើយ ភិក្ខុណាជាអ្នក
មានស្មារតី មានបញ្ញាជាគ្រឿងរក្សាខ្លួន មានឈាន មានព្យាយាម
ជាគ្រឿងដុតកំដៅកិលេស មានសេចក្តីខ្លាចបាប មិនប្រមាទ
ផ្តាច់បង់នូវគ្រឿងប្រកប នៃជាតិជរាបាន ភិក្ខុនោះទើបគួរ ដើម្បី
បាននូវសេចក្តីត្រាស់ដឹងដ៏ឧត្តម ក្នុងលោកនេះ ៗ

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ៗ សូត្រទី ៧ ។

(៣៥) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ នយិទំ ភិក្ខវេ ព្រហ្មចរិយំ វុស្សតិ ជនកុហនត្ថំ ន[១] ជនលបនត្ថំ ន[១] លាភសក្ការសិលោកានិសំសត្ថំ ន[១] ឥតិ មំ ជនោ ជានាតូតិ ។ អថខោ ឥទំ ភិក្ខវេ ព្រហ្មចរិយំ វុស្សតិ សំវរត្ថញ្ចេវ បហានត្ថញ្ចាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

សំវរត្ថំ បហានត្ថំ ព្រហ្មចរិយំ អនីតិហំ
អទេសយិ សោ ភគវា និព្វានោគធគាមិនំ
ឯស មគ្គោ មហត្តេហិ[២] អនុយាតោ មហេសិភិ[៣]
យេ យេ តំ បដិបជ្ជន្តិ យថា ពុទ្ធេន ទេសិតំ
ទុក្ខស្សន្តំ ករិស្សន្តិ សត្ថុសាសនការិនោតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។ អដ្ឋមំ[៤] ។

---

១ ឱ.ម. ឥសព្វោ នត្ថិ ។ ២ ខ. មហេត្តេហិ ។ ម. មហន្តេហិ ។ ៣ ខ.ម. មហេសិនោ ។
៤ ខ.ម. អដ្ឋមត្ថិ នត្ថិ ។

(៣៥) ខ្ញុំបានស្តាប់មកហើយថា ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយៗ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រព្រឹត្តព្រហ្មចរិយៈនេះ មិនមែន ដើម្បីកុហកនូវជន មិនមែន ដើម្បីរួសរាយបំពោះជន មិនមែន ដើម្បីអានិសង្សគឺលាភសក្ការៈនឹងសេចក្តីសរសើរទេ មិនប្រព្រឹត្តព្រហ្មចរិយៈ ដោយគិតថា មហាជនចូរស្គាល់នូវអាត្មាអញដូច្នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ តាមពិតនោះ បុគ្គលប្រព្រឹត្តព្រហ្មចរិយៈនេះ ដើម្បីសង្រួមផង ដើម្បីលះបង់ផង ។ លុះព្រះមានព្រះភាគទ្រង់សំដែងសេចក្តីនុះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ព្រះមានព្រះភាគ ព្រះអង្គនោះ ទ្រង់បានសំដែងនូវព្រហ្មចរិយៈ
ដែលមិនអាងតាមពាក្យគេថា ទីប្រព្រឹត្តទៅ ដើម្បីចុះស៊ប់
កាន់ព្រះនិព្វាន ដើម្បីសង្រួម ដើម្បីលះបង់ នេះជាផ្លូវ
ដែលព្រះសម្មាសម្ពុទ្ធទាំងឡាយ ទ្រង់មានព្រះអធ្យាស្រ័យដ៏ធំ
ស្វែងរកនូវគុណដ៏ធំ ទ្រង់ប្រតិបត្តិមកហើយ ជនទាំងឡាយណា
ដើរតាមផ្លូវ ដែលព្រះពុទ្ធបានសំដែងហើយនោះ ឈ្មោះថា
ធ្វើតាមពាក្យប្រដៅនៃព្រះសាស្តា នឹងធ្វើនូវទីបំផុតនៃទុក្ខបាន ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រ ទី ៨ ។

### ឥតិវុត្តកេ ទុកនិបាតស្ស បឋមវគ្គស្ស នវមសុត្តំ

[៣៦] វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ នយិទំ ភិក្ខវេ ព្រហ្មចរិយំ វុស្សតិ ជនកុហនត្ថំ[១] ន ជនលបនត្ថំ[១] ន លាភសក្ការសិលោកានិសំសត្ថំ ន[១] ឥតិ មំ ជនោ ជានាតូតិ ។ អថខោ ឥទំ ភិក្ខវេ ព្រហ្មចរិយំ វុស្សតិ អភិញ្ញត្ថញ្ចេវ បរិញ្ញត្ថញ្ចាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

អភិញ្ញត្ថំ បរិញ្ញត្ថំ ព្រហ្មចរិយំ អនីតិហំ
អទេសយិ សោ ភគវា និព្វានោគធគាមិនំ
ឯស មគ្គោ មហន្តេហិ អនុយាតោ មហេសិភិ
យេ យេ តំ បដិបជ្ជន្តិ យថា ពុទ្ធេន ទេសិតំ
ទុក្ខស្សន្តំ ករិស្សន្តិ សត្ថុសាសនការិនោតិ ។
អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

នវមំ[២] ។

---

១ ឱ.ម. ឥសត្ថោ ឥត្ថិ ។ ២ ឱ.ម. នវមត្ថិ ឥត្ថិ ។

ឥតិវុត្តកៈ ទុកនិបាត បឋមវគ្គ សូត្រទី ៩

(៣៦) ខ្ញុំបានស្តាប់មកហើយថា ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រព្រឹត្តព្រហ្មចរិយៈនេះ មិនមែនដើម្បីកុហកនូវជន មិនមែនដើម្បីស្លេកយបំពោះជន មិនមែនដើម្បីអានិសង្ស គឺលាភសក្ការៈ ទាំងសេចក្តីសរសើរទេ មិនប្រព្រឹត្តព្រហ្មចរិយៈដោយគិតថា មហាជន ចូរស្គាល់នូវអាត្មាអញដូច្នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ តាមពិតនោះ បុគ្គលប្រព្រឹត្តព្រហ្មចរិយៈនេះ ដើម្បីដឹងផង ដើម្បីកំណត់ដឹងផង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់បានសំដែងព្រហ្មចរិយៈ
ដែលមិនអាងតាមពាក្យគេថា ទីប្រព្រឹត្តទៅ ដើម្បីចុះស៊ប់
កាន់ព្រះនិព្វាន ដើម្បីដឹង ដើម្បីកំណត់ដឹង នេះជាផ្លូវ
ដែលព្រះសម្មាសម្ពុទ្ធទាំងឡាយ ទ្រង់មានព្រះអធ្យាស្រ័យធំ
ស្វែងរកនូវគុណដ៏ធំទ្រង់ប្រតិបត្តិមកហើយ ជនទាំងឡាយណា
ដើរតាមផ្លូវដែលព្រះពុទ្ធ ទ្រង់សំដែងហើយនោះ ឈ្មោះថា
ធ្វើតាមពាក្យប្រដៅនៃព្រះសាស្តា នឹងធ្វើនូវទីបំផុតនៃទុក្ខបាន ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រ ទី ៩ ។

(៣៧) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ទ្វីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ ទិដ្ឋេវ ធម្មេ សុខសោមនស្សពហុលោ វិហរតិ យោនិសោ អារទ្ធោ ហោតិ អាសវានំ ខយាយាតិ ។ កតមេហិ ទ្វីហិ ។ សំវេជនីយេសុ ឋានេសុ សំវេជនេន សំវិគ្គស្ស ច យោនិសោ បធានេន ។ ឥមេហិ ខោ ភិក្ខវេ ទ្វីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ទិដ្ឋេវ ធម្មេ សុខសោមនស្សពហុលោ វិហរតិ យោនិសោ អារទ្ធោ ហោតិ អាសវានំ ខយាយាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

សំវេជនីយេសុ ឋានេសុ សំវិជ្ជេថេវ បណ្ឌិតោ
អាតាបី និបកោ ភិក្ខុ បញ្ញាយ សមវេក្ខិយ
ឯវំ វិហារី អាតាបី សន្តវុត្តិ អនុទ្ធតោ
ចេតោសមថមនុយុត្តោ ខយំ ទុក្ខស្ស បាបុណេតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។ នវមំ(១) ។

១ ឱ.ម. ទសមន្តិ ។

(៣៧) ខ្ញុំបានស្តាប់មកហើយថា ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌២ រមែងច្រើនដោយសេចក្តីសុខនឹងសោមនស្ស ជាអ្នកប្រារព្ធ ដើម្បីអស់អាសវៈទាំងឡាយ ដោយឧបាយនៃបញ្ញា ក្នុងបច្ចុប្បន្ន ។ ប្រកបដោយធម៌ ២ តើដូចម្តេច ។ គឺប្រកបដោយសេចក្តីសំវេគ ក្នុងទីទាំងឡាយដែលជាទីតាំងនៃសេចក្តីសំវេគ១ ប្រកបដោយសេចក្តីព្យាយាម ដោយឧបាយនៃសេចក្តីសំវេគ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ២នេះឯង រមែងច្រើនដោយសេចក្តីសុខនឹងសោមនស្ស ជាអ្នកប្រារព្ធ ដើម្បីអស់អាសវៈទាំងឡាយ ដោយឧបាយនៃបញ្ញាក្នុងបច្ចុប្បន្ន ។ លុះព្រះមានព្រះភាគសំដែងសេចក្តីនេះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ភិក្ខុជាបណ្ឌិត មានព្យាយាម ជាគ្រឿងដុតកំដៅកិលេស
មានបញ្ញាជាគ្រឿងរក្សាខ្លួន គប្បីសំវេគក្នុងទីជាទីតាំងនៃ
សេចក្តីសំវេគទាំងឡាយ គប្បីពិចារណា ដោយបញ្ញា
ភិក្ខុមានធម៌ជាគ្រឿងនៅយ៉ាងនេះ មានព្យាយាមជាគ្រឿង
ដុតកំដៅកិលេស ប្រព្រឹត្តស្ងប់ មិនរាយមាយ ប្រកបរឿយ ៗ
នូវចេតោសមថៈហើយ គប្បីដល់នូវកិរិយាអស់ទៅនៃទុក្ខបាន ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ១០ ។

ចប់ បឋមវគ្គ ។

# តស្សុទ្ទានំ

ទ្វេ ភិក្ខុ តបនីយា-

តបនីយា បរត្តេហិ(១)

អាតាបី ច កុហនា ច

សោមនស្សេន តេ ទសាតិ ។

---

១ ម. បរត្តេតិ ។

## ឧទ្ទាននៃបឋមវគ្គនោះគឺ

និយាយអំពីភិក្ខុប្រកបដោយធម៌ ២ មាន ២ លើក ធម៌ ដុតកំដៅ ១ ធម៌ មិនបានដុតកំដៅ ១ ប្រយោជន៍ក្នុងបរលោក មាន ២ លើក ភិក្ខុមានព្យាយាមជាគ្រឿងដុតកំដៅកិលេស ១ ភិក្ខុប្រព្រឹត្តព្រហ្មចរិយៈ មិនមែន ដើម្បីកុហក មាន ២ លើក ភិក្ខុប្រកបដោយធម៌ ២ យ៉ាង រមែងមានសេចក្តីសុខនឹងសោមនស្ស ១ ទាំងអម្បាលនោះ ត្រូវជា ១០ ។

# ឥតិវុត្តកេ ទុកនិបាតស្ស ទុតិយវគ្គោ

(៣៨) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តថាគតំ ភិក្ខវេ អរហន្តំ សម្មាសម្ពុទ្ធំ ទ្វេ វិតក្កា ពហុលំ សមុទាចរន្តិ ខេមោ ច វិតក្កោ វិវេកោ[១] ច ។ អព្យាបជ្ឈារាមោ ភិក្ខវេ តថាគតោ អព្យាបជ្ឈរតោ តមេនំ ភិក្ខវេ តថាគតំ អព្យាបជ្ឈារាមំ អព្យាបជ្ឈរតំ ឯសេវ វិតក្កោ ពហុលំ សមុទាចរតិ ឥមាយាហំ ឥរិយាយ ន កិញ្ចិ ព្យាពាធេមិ តសំ វា ថាវរំ វាតិ ។ បវិវេការាមោ ភិក្ខវេ តថាគតោ បវិវេករតោ តមេនំ ភិក្ខវេ តថាគតំ បវិវេការាមំ បវិវេករតំ ឯសេវ វិតក្កោ ពហុលំ សមុទាចរតិ យំ អកុសលំ តំ បហីនន្តិ ។ តស្មាតិហ ភិក្ខវេ តុម្ហេបិ អព្យាបជ្ឈារាមា វិហរថ អព្យាបជ្ឈរតា តេសំ វោ ភិក្ខវេ តុម្ហាកំ អព្យាបជ្ឈារាមានំ វិហរតំ អព្យាបជ្ឈរតានំ ឯសេវ វិតក្កោ ពហុលំ សមុទាចរិស្សតិ

១ ឱ.ឞ. បវិវេកោ ។

# ឥតិវុត្តកៈ ទុកនិបាត ទុតិយវគ្គ

(៣៨) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ វិតក្កៈមាន ២ យ៉ាងគឺ ខេមវិតក្កៈ (វិតក្កៈប្រកបដោយករុណាជាដើម) ១ វិវេកវិតក្កៈ (វិតក្កៈប្រកបដោយវិវេក) ១ តែងផុសផុលឡើងជាច្រើន ចំពោះព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ជាអ្នករីករាយក្នុងសេចក្តីមិនព្យាបាទ ត្រេកអរហើយក្នុងសេចក្តីមិនព្យាបាទ ម្នាលភិក្ខុទាំងឡាយ វិតក្កៈនេះឯង តែងផុសផុលឡើងជាច្រើន ចំពោះព្រះតថាគតនោះ ដែលជាអ្នករីករាយ ក្នុងសេចក្តីមិនព្យាបាទ ត្រេកអរក្នុងសេចក្តីមិនព្យាបាទថា តថាគតមិនបានបៀតបៀនសត្វណាមួយ ដែលនៅតក់ស្លុត ឬដែលនឹងធឹង ដោយសេចក្តីប្រព្រឹត្ត (កាយប្រយោគ ឬវចីប្រយោគ) នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគត ជាអ្នករីករាយក្នុងវិវេក ត្រេកអរក្នុងវិវេក ម្នាលភិក្ខុទាំងឡាយ វិតក្កៈនេះឯង តែងផុសផុលឡើងជាច្រើន ចំពោះព្រះតថាគតនោះ ដែលជាអ្នករីករាយ ក្នុងវិវេក ត្រេកអរ ក្នុងវិវេកថា អកុសលនោះ តថាគតបានលះអស់ហើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយ គួររីករាយក្នុងសេចក្តីមិនព្យាបាទ ត្រេកអរ ក្នុងសេចក្តីមិនព្យាបាទចុះ ម្នាលភិក្ខុទាំងឡាយ វិតក្កៈនេះឯង នឹងផុសផុលឡើងជាច្រើន ចំពោះអ្នកទាំងឡាយនោះ ដែលរីករាយ ក្នុងសេចក្តីមិនព្យាបាទ ត្រេកអរ ក្នុងសេចក្តីមិនព្យាបាទថា

ឥតិវុត្តកេ ទុកនិបាតស្ស ទុតិយវគ្គស្ស បឋមសុត្តំ

ឥមាយ មយំ ឥរិយាយ ន កិញ្ចិ ព្យាពាធេម តសំ វា ថាវរំ វាតិ ។ បវិវេការាមា ភិក្ខវេ វិហរថ បវិវេករតា តេសំ វោ ភិក្ខវេ តុម្ហាកំ បវិវេការាមានំ វិហរតំ បវិវេករតានំ ឯសេវ វិតក្កោ ពហុលំ សមុទាចរិស្សតិ កឹ អកុសលំ កឹ អប្បហីនំ កឹ បជហាមាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

តថាគតំ ពុទ្ធំ អសយ្ហសាហិនំ[(១)]
ទ្វេ[(២)] វិតក្កា សមុទាចរន្តិ នំ
ខេមោ វិតក្កោ បឋមោ ឧទីរិតោ
តតោ វិវេកោ ទុតិយោ បកាសិតោ ។
តមោនុទំ បារគតំ មហេសឹ
តំ បត្តិបត្តំ វសិមំ អនាសវំ
វិសន្តរំ[(៣)] តណ្ហក្ខយេ វិមុត្តំ
តំ វេ មុនឹ អន្តិមទេហធារឹ
មារជហំ[(៤)] ព្រូមិ ជរាយ បារគុំ ។

---

១ ម. បសយ្ហសាហិនំ ។ ២ ឱ.ម. ទុវេ ។ ៣ ម. វិសត្តំ ។ ៤ ឱ. មានំជហំ ។ ម. មានជហំ ។

យើងទាំងឡាយ មិនបៀតបៀនសត្វណាមួយ ដែលតក់ស្លុត ឬដែលនឹងធឹង ដោយសេចក្ដីប្រព្រឹត្តិនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូររីករាយ ក្នុងវិវេក ចូរត្រេកអរ ក្នុងវិវេកចុះ ម្នាលភិក្ខុទាំងឡាយ វិតក្កៈនេះឯង នឹងផុសផុលឡើងជាច្រើន ចំពោះអ្នកទាំងឡាយនោះដែលរីករាយក្នុងវិវេក ត្រេកអរក្នុងវិវេកថា អ្វីជាអកុសល អ្វីដែលយើងមិនទាន់លះបង់ យើងលះបង់អ្វី ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្ដីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

វិតក្កៈ ២ យ៉ាង គឺ ខេមវិតក្កៈទី ១ ដែលព្រះអង្គទ្រង់សំដែង
ហើយ តអំពីនោះ វិវេកវិតក្កៈទី ២ ដែលព្រះអង្គទ្រង់
ប្រកាសហើយ តែងផុសផុលឡើង ចំពោះព្រះតថាគត
ជាព្រះពុទ្ធ ដែលបុគ្គលដទៃគ្របសង្កត់មិនបាន ។ តថាគត
ហៅបុគ្គលអ្នកបន្ទោបង់នូវងងឹត ដល់នូវត្រើយ ស្វែងរក
នូវគុណដ៏ធំ ដល់នូវសេចក្ដីត្រាស់ដឹង ស្ងាត់ (ក្នុងឈាន)
មិនមានអាសវៈ ឆ្លងនូវពិសត្តិកិលេស រួចស្រឡះហើយ
ព្រោះការអស់តណ្ហានោះឯង ថាជាអ្នកប្រាជ្ញ ទ្រទ្រង់នូវ
កាយជាទីបំផុត កំចាត់បង់នូវមារ ដល់នូវត្រើយនៃជរា ។

សេលេ យថា បព្វតមុទ្ធនិដ្ឋិតោ
យថាបិ បស្សេ ជនតំ សមន្តតោ
តថូបមំ ធម្មមយំ សុមេធោ
បាសាទមារុយ្ហ សមន្តចក្ខុ
សោកាវតិណ្ណំ ជនតមបេតសោកោ[១]
អវេក្ខតិ ជាតិជរាភិភូតន្តិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។ បឋមំ[២] ។

(៣៩) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស ទ្វេ ធម្មទេសនា បរិយាយេន ភវន្តិ ។ កតមា ទ្វេ ។ បាបំ បាបកតោ បស្សថាតិ អយំ បឋមា ធម្មទេសនា ។ បាបំ បាបកតោ ទិស្វា តត្ថ និព្វិន្ទថ វិរជ្ជថ វិមុច្ចថាតិ អយំ ទុតិយា ធម្មទេសនា ។ តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស ឥមា ទ្វេ ធម្មទេសនា បរិយាយេន ភវន្តិ[៣] ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

---

១ ឱ. ជនតំ អបេតសោកោ ។ ២ ឱ.ម. បឋមន្តិ នត្ថិ ។ ៣ ឱ.ម. ភវន្តីតិ ។

បុគ្គលឈរលើកំពូលភ្នំ ជាវិការៈនៃថ្មសុទ្ធ គប្បីឃើញនូវប្រជុំជន ដោយជុំវិញ មានឧបមា ដូចម្តេចមិញ លោកអ្នកមានបញ្ញាល្អ មានចក្ខុជុំវិញ មានសេចក្តីសោកទៅប្រាសហើយ គប្បីឡើងកាន់ប្រាសាទជាវិការៈនៃធម៌ រមែងឃើញនូវប្រជុំជន ដែលមានសេចក្តីសោកមិនទាន់ធ្លង់ហើយ មានជាតិនិងជរាគ្របសង្កត់ហើយ ក៏មានឧបមេយ្យដូច្នោះដែរ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រ ទី ១ ។

(៣៩) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រះធម្មទេសនារបស់ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ មាន ២ យ៉ាង ដោយបរិយាយ ។ ធម្មទេសនា ២ យ៉ាង តើដូចម្តេច ។ គឺអ្នកទាំងឡាយ ចូរឃើញនូវបាបថាជាបាប នេះជាធម្មទេសនាទី ១ លុះអ្នកទាំងឡាយ ឃើញនូវបាបថាជាបាបហើយ ចូរនឿយណាយ ចូរជិនឆ្អន់ ចូរផុតស្រឡះចាកបាបនោះ នេះឯងជាធម្មទេសនាទី ២ ។ ម្នាលភិក្ខុទាំងឡាយ ធម្មទេសនារបស់ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ មាន ២ យ៉ាងនេះឯង ដោយបរិយាយ ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

តថាគតស្ស ពុទ្ធស្ស សព្វភូតានុកម្បិនោ
បរិយាយវចនំ បស្ស ទ្វេ ច ធម្មា បកាសិតា
បាបកំ បស្សថ ចេកំ តត្ថ ចាបិ[១] វិរជ្ជថ
តតោ វិរត្តចិត្តាសេ ទុក្ខស្សន្តំ ករិស្សថាតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ទុតិយំ[២] ។

(៤០) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ អវិជ្ជា ភិក្ខវេ បុព្វង្គមា អកុសលានំ ធម្មានំ សមាបត្តិយា អន្វទេវ អហិរិកំ អនោត្តប្បំ ។ វិជ្ជា ច ខោ ភិក្ខវេ បុព្វង្គមា កុសលានំ ធម្មានំ សមាបត្តិយា អន្វទេវ ហិរោត្តប្បន្តិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

---

១ ឱ.ម. វាបិ ។ ២ ឱ.ម. ទុតិយន្តិ នត្ថិ ។

អ្នកចូរឃើញនូវព្រះវាចា ដោយបរិយាយ នៃព្រះតថាគត ជាព្រះពុទ្ធ ដែលទ្រង់មានសេចក្តីអនុគ្រោះ ដល់សព្វសត្វ ផង នូវធម្មទេសនា ២ យ៉ាង ដែលព្រះតថាគត ប្រកាស ហើយផង អ្នកទាំងឡាយ ជាអ្នកឈ្លាស ចូរឃើញនូវ អំពើបាប អ្នកទាំងឡាយ ចូរលះបង់នូវបាបក្នុងបាបនោះ គឺអំពីនោះទៅ ចូរអ្នកទាំងឡាយ មានចិត្តប្រាសចាក សេចក្តីត្រេកអរហើយ នឹងធ្វើនូវទីបំផុតនៃទុក្ខបាន ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បាន ត្រាស់ទុកហើយ ។ សូត្រទី ២ ។

(៤០) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អវិជ្ជា ជាប្រធាន ដើម្បីចួបប្រទះនូវអកុសលធម៌ទាំងឡាយ អហិរិកៈ នឹងអនោត្តប្បៈ កើត តាមក្រោយ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកឯវិជ្ជា ជាប្រធាន ដើម្បី ចួបប្រទះនូវកុសលធម៌ទាំងឡាយ ហិរិនឹងឱត្តប្បៈ កើតតាមក្រោយ ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុះហើយ ។ ទ្រង់ត្រាស់ គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

យា កាចិមា ទុគ្គតិយោ អស្មឹ លោកេ បរម្ហិ ច

អវិជ្ជាមូលកា សព្វា ឥច្ឆាលោភសមុស្សយា

យតោ ច ហោតិ បាបិច្ឆោ អហិរិកោ អនាទរោ

តតោ បាបំ បសវតិ អបាយំ តេន គច្ឆតិ ។

តស្មា ឆន្ទញ្ច លោភញ្ច អវិជ្ជញ្ច វិរាជយំ

វិជ្ជំ ឧប្បាទយំ ភិក្ខុ សព្វា ទុគ្គតិយោ ជហេតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

តតិយំ[១] ។

(៤១) វុត្តំ ហេតំ[២] ភគវតា វុត្តមរហតាតិ មេ សុតំ ។ តេ ភិក្ខវេ សត្តា សុបរិហីនា យេ អរិយាយ បញ្ញាយ បរិហីនា តេ ទិដ្ឋេ ចេវ ធម្មេ ទុក្ខំ វិហរន្តិ សវិឃាតំ សឧបាយាសំ សបរិឡាហំ កាយស្ស ភេទា បរម្មរណា ទុគ្គតិ បាដិកង្ខា ។

---

១ ឱ.ម. តតិយន្តិ នត្ថិ ។ ២ ឱ.ម. ឯត្ថ ហិតេ បឋមភាណវារន្តិ ទិស្សតិ ។

ទុគ្គតិទាំងឡាយណាមួយ ទាំងក្នុងលោកនេះ ទាំងក្នុងបរលោក ទុគ្គតិទាំងអស់នោះ មានអវិជ្ជា ជាឫស មានសេចក្តីប្រាថ្នា និងសេចក្តីលោភ ជាគ្រឿងដុះដាលឡើង បុគ្គលមានសេចក្តីប្រាថ្នាលាមក មានសេចក្តីមិនខ្មាសបាប ទាំងមានសេចក្តីមិនអើពើ ក្នុងកាលណាហើយ តែងទទួលនូវផលបាប ទៅកាន់អបាយ ព្រោះបាបនោះ ក្នុងកាលនោះ ៗ ព្រោះហេតុនោះ ភិក្ខុគប្បីញុំាងឆន្ទៈ លោភៈ និងអវិជ្ជា ឲ្យវិនាសទៅផង ញុំាងវិជ្ជាឲ្យកើតឡើងផង ទើបលះបង់នូវទុគ្គតិទាំងពួងបាន ៗ ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ៗ សូត្រទី ៣ ។

(៨១) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ៗ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយណា សាបសូន្យចាកបញ្ញាដ៏ប្រសើរហើយ សត្វទាំងឡាយនោះ ឈ្មោះថា សាបសូន្យអស់រលីង សត្វទាំងឡាយនោះ រមែងនៅជាទុក្ខ ប្រកបដោយសេចក្តីថ្នាំងថ្នាក់ ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ ប្រាកដជាទៅកាន់ទុគ្គតិ ៗ

ឥតិវុត្តកេ ទុកនិបាតស្ស ទុតិយវគ្គស្ស ចតុត្ថសុត្តំ

តេ ភិក្ខវេ សត្តា អបរិហីនា យេ អរិយាយ បញ្ញាយ អបរិហីនា តេ ទិដ្ឋេវ ធម្មេ សុខំ វិហរន្តិ អវិឃាតំ អនុបាយាសំ អបរិឡាហំ កាយស្ស ភេទា បរម្មរណា សុគតិ បាដិកង្ខាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

បញ្ញាយ បរិហានេន បស្ស លោកំ សទេវកំ
និវិដ្ឋំ នាមរូបស្មឹ ឥទំ សច្ចន្តិ មញ្ញតិ ។
បញ្ញា ហិ សេដ្ឋា លោកស្មឹ យាយំ និព្វេធគាមិនី
សា ច[១] សម្មា បជានាតិ ជាតិភវបរិក្ខយំ
តេសំ ទេវា មនុស្សា ច សម្ពុទ្ធានំ សតីមតំ
បិហយន្តិ ហាសបញ្ញានំ[២] សរីរន្តិមធារិនំ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ចតុត្ថំ[៣] ។

---

១ ឱ. យា ច ។ ម. យាយ ។ ២ ឱ. សបញ្ញានំ ។ ៣ ឱ. ម. ចតុត្ថត្ថិទត្ថិ ។

ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយណា មិនសាបសូន្យចាកបញ្ញាដ៏ប្រសើរ ហើយ សត្វទាំងឡាយនោះ ឈ្មោះថាមិនសាបសូន្យ សត្វទាំងឡាយនោះ តែងនៅជាសុខ មិនប្រកបដោយសេចក្តីថ្នាំងថ្នាក់ មិនប្រកបដោយសេចក្តីចង្អៀតចង្អល់ មិនប្រកបដោយសេចក្តីក្តៅក្រហាយ ក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ ប្រាកដជាទៅកាន់សុគតិ ។ លុះព្រះមានព្រះភាគទ្រង់សំដែងសេចក្តីនុះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

អ្នកចូរមើលនូវសត្វលោក ព្រមទាំងទេវលោក ដែលជាប់នៅ
ក្នុងនាមនិងរូប រមែងសំគាល់ថា នេះជារបស់ពិត ព្រោះ
សាបសូន្យចាកបញ្ញាដ៏ប្រសើរ ។ បញ្ញាជាគ្រឿងប្រព្រឹត្តទៅ
ដើម្បីចាក់ធ្លុះនេះឯង ប្រសើរបំផុតក្នុងលោក ព្រោះបញ្ញានោះដឹង
ច្បាស់នូវកិរិយាអស់ជាតិនិងភព ដោយប្រពៃ ទេវតានិងមនុស្ស
ទាំងឡាយ តែងស្រឡាញ់នូវព្រះសម្ពុទ្ធទាំងឡាយនោះ ដែល
មានស្មារតី មានបញ្ញាជាគ្រឿងរីករាយ ទ្រទ្រង់នូវរាងកាយជាទីបំផុត ។
ខ្ញុំបាទស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បាន

ត្រាស់ទុកហើយ ។ សូត្រ ទី ៤ ។

(៤២) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ទ្វេមេ ភិក្ខវេ សុក្កា ធម្មា លោកំ បាលេន្តិ ។ កតមេ ទ្វេ ។ ហិរី ច ឱត្តប្បញ្ច ។ ឥមេ ចេ ភិក្ខវេ ទ្វេ សុក្កា ធម្មា លោកំ ន បាលេយ្យុំ នយិធ បញ្ញាយេថ មាតាតិ វា មាតុច្ឆាតិ វា មាតុលានីតិ វា អាចរិយភរិយាតិ វា គរូនំ ទារាតិ វា សម្ភេទំ លោកោ អគមិស្ស យថា អជេឡកា កុក្កុដសូករា សោណសិង្គាលា ។ យស្មា ច ខោ ភិក្ខវេ ឥមេ ទ្វេ សុក្កា ធម្មា លោកំ បាលេន្តិ តស្មា បញ្ញាយេថ មាតាតិ វា មាតុច្ឆាតិ វា មាតុលានីតិ វា អាចរិយភរិយាតិ វា គរូនំ ទារាតិ វាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

យេសំ ចេ ហិរិឱត្តប្បំ សព្វទា ច ន វិជ្ជតិ
វោក្កន្តា សុក្កមូលា តេ ជាតិមរណគាមិនោ ។
យេសញ្ច ហិរិឱត្តប្បំ សទា សម្មា ឧបដ្ឋិតា
វិរូឡ្ហព្រហ្មចរិយា តេ សន្តោ ខីណបុនព្ភវាតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

បញ្ញាសំ(១) ។

១ ឱ.ម. បញ្ចមវគ្គិ ទុតិ ។

(៤២) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ស ២ នេះ តែងរក្សានូវលោក ។ ធម៌ស ២ តើដូចម្តេច ។ គឺហិរិ ១ ឱត្តប្បៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បើធម៌ស ២ នេះ មិនគប្បីរក្សានូវលោកទេ ពាក្យថា មាតាក្តី ម្តាយមីងក្តី ម្តាយធំក្តី ប្រពន្ធរបស់អាចារ្យក្តី ប្រពន្ធរបស់គ្រូក្តី មិនប្រាកដ ក្នុងលោកនេះបានឡើយ លោកនឹងដល់នូវការប្រឡូកប្របល់គ្នា ដូចជាសត្វពពែ កែះ មាន់ ជ្រូក ឆ្កែ និងចចកដូច្នោះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែធម៌ស ២ នេះ តែងរក្សានូវលោក បានជាពាក្យថា មាតាក្តី ម្តាយមីងក្តី ម្តាយធំក្តី ប្រពន្ធរបស់អាចារ្យក្តី ប្រពន្ធរបស់គ្រូក្តី ទើបប្រាកដបាន ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បើហិរិនិងឱត្តប្បៈ មិនមានដល់សត្វទាំងឡាយណា សព្វកាលទេ
សត្វទាំងឡាយនោះ ជាអ្នកឃ្លាតចាកឫសគល់នៃធម៌ស មានដំណើរ
ទៅកាន់ជាតិនិងមរណៈ ។ ចំណែកសត្វទាំងឡាយណា ដំកល់ទុក
នូវហិរិនិងឱត្តប្បៈដោយប្រពៃ សព្វកាល សត្វទាំងឡាយនោះ ជាអ្នក
មានព្រហ្មចរិយៈចំរើនហើយ ជាអ្នកស្ងប់ អស់ភពតទៅទៀតហើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៤ ។

(៨៣) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ អត្ថិ ភិក្ខវេ អជាតំ អភូតំ អកតំ អសង្ខតំ នោ ចេតំ ភិក្ខវេ អភវិស្ស អជាតំ អភូតំ អកតំ អសង្ខតំ នយិធ ជាតស្ស ភូតស្ស កតស្ស សង្ខតស្ស និស្សរណំ បញ្ញាយេថ ។ យស្មា ច ខោ ភិក្ខវេ អត្ថិ អជាតំ អភូតំ អកតំ អសង្ខតំ តស្មា ជាតស្ស ភូតស្ស កតស្ស សង្ខតស្ស និស្សរណំ បញ្ញាយេថាតិ[១] ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

ជាតំ ភូតំ សមុប្បន្នំ កតំ សង្ខតមទ្ធុវំ
ជរាមរណសង្ខតំ រោគនិឌ្ឌំ[២] បភង្គុណំ
អាហារនេត្តិប្បភវំ នាលំ តទភិនន្ទិតុំ
តស្ស និស្សរណំ សន្តំ អតក្កាវចរំ ធុវំ
អជាតំ អសមុប្បន្នំ អសោកំ វិរជំ បទំ

១ ម. បញ្ញាយតីតិ ។ ២ ឱ.ម. រោគនីឡំ ។

(៤៣) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាតដែលមិនកើត មិនមាន មិនបានធ្វើ ដែលបច្ច័យមិនតាក់តែងហើយ តែងមាន ម្នាលភិក្ខុទាំងឡាយ បើធម្មជាត ដែលមិនកើត មិនមាន មិនធ្វើ ដែលបច្ច័យ មិនតាក់តែង នឹងមិនបានមានហើយ ការរលាស់ចេញចាកធម្មជាត ដែលកើត ដែលមាន ដែលបានធ្វើ ដែលបច្ច័យតាក់តែង ក៏រមែងមិនប្រាកដក្នុងលោកនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែធម្មជាត ដែលមិនកើត មិនមាន មិនបានធ្វើ ដែលបច្ច័យមិនតាក់តែងហើយ តែងមាន បានជា ការរលាស់ចេញចាកធម្មជាត ដែលកើត ដែលមាន ដែលបានធ្វើ ដែលបច្ច័យតាក់តែងហើយ ទើបប្រាកដឡើងបាន ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលមិនគួរត្រេកអរនឹងកាយនោះ ដែលកើត ដែលមាន ដែល
កើតព្រម ដែលបានធ្វើ ដែលបច្ច័យតាក់តែងហើយ ជារបស់មិន
ទៀង ជារបស់ដែលជរានឹងមរណៈតាក់តែងហើយ ជាទីនៅនៃរោគ
ជារបស់ពុករលួយ មានអាហារនិងតណ្ហាជាប្រភព (ជាដែនកើត)

និរោធោ ទុក្ខធម្មានំ សង្ខារូបសមោ សុខោតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ឆដ្ឋំ[១] ។

[៤៤] វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ទ្វេមា ភិក្ខវេ និព្វានធាតុយោ ។ កតមា ទ្វេ ។ សឧបាទិសេសា ច និព្វានធាតុ អនុបាទិសេសា ច និព្វានធាតុ ។ ឥធ ភិក្ខវេ ភិក្ខុ អរហំ ហោតិ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសំយោជនោ សម្មទញ្ញា វិមុត្តោ តស្ស តិដ្ឋន្តេវ បញ្ចិន្ទ្រិយានិ យេសំ អវិឃាតត្តា មនាបា-មនាបំ បច្ចនុភោតិ សុខទុក្ខំ បដិសំវេទយតិ[២] ។

---

១ ឱ ម. ឆដ្ឋិតិ ខត្តំ ។ ២ ឱ. បដិសំវេទិយតិ ។ ម. បដិសំវេទេតិ ។

ឯព្រះនិព្វានជាគ្រឿងរលាស់ចេញនូវកាយនោះ ទើបជារបស់ស្ងប់ មិនជារបស់ប្រព្រឹត្តទៅតាមសេចក្តីត្រិះ ជារបស់ទៀង ជារបស់មិនកើត មិនកើតព្រម មិនមានសោក ប្រាសចាកសេចក្តីគ្រេកអរ ការរលត់នូវហេតុនៃទុក្ខទាំងឡាយ ការរម្ងាប់នូវសង្ខារ ជាគុណនាំមកនូវសេចក្តីសុខ ។ ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាប់ទុកហើយ ។ សូត្រទី ៦ ។

(៤៤) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ និព្វានធាតុនេះមាន ២ ។ និព្វានធាតុ ២ តើដូចម្តេច ។ គឺសឧបាទិសេសនិព្វានធាតុ ១ អនុបាទិសេសនិព្វានធាតុ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសឧបាទិសេសនិព្វានធាតុ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអរហន្តខីណាស្រព មានព្រហ្មចរិយៈប្រព្រឹត្តរួចហើយ មានសោឡសកិច្ច បានធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ ដោយលំដាប់ មានសំយោជន ក្នុងភពអស់ហើយ ផុតស្រឡះហើយ ព្រោះដឹងច្បាស់ដោយប្រពៃ ប៉ុន្តែឥន្ទ្រិយទាំង ៥ របស់អរហន្តខីណាស្រពនោះ តាំងនៅដដែល អរហន្តខីណាស្រពនោះ នៅសោយអារម្មណ៍ ដែលពេញចិត្ត នឹងមិនពេញចិត្ត សោយសុខនឹងទុក្ខ ព្រោះឥន្ទ្រិយទាំង ៥ នោះ មិនមានសេចក្តីថ្នាំងថ្នាក់ទេ ។

ឥតិវុត្តកេ ទុកនិបាតស្ស ទុតិយវគ្គស្ស សត្តមសុត្តំ

តស្ស យោ រាគក្ខយោ ទោសក្ខយោ មោហក្ខយោ អយំ វុច្ចតិ ភិក្ខវេ សឧបាទិសេសា និព្វានធាតុ ។ កតមា ច ភិក្ខវេ អនុបាទិសេសា និព្វានធាតុ ។ ឥធ ភិក្ខវេ ភិក្ខុ អរហំ ហោតិ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសំយោជនោ សម្មទញ្ញា វិមុត្តោ ។ តស្ស ឥធេវ ភិក្ខវេ សព្វវេទយិតានិ អនភិនន្ទិតានិ សីតិភវិស្សន្តិ អយំ វុច្ចតិ ភិក្ខវេ អនុបាទិសេសា និព្វានធាតុ ។ ឥមា ខោ ភិក្ខវេ ទ្វេ និព្វានធាតុយោតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

ទ្វេ ឥមា ចក្ខុមតា បកាសិតា
និព្វានធាតូ អនិស្សិតេន តាទិនា
ឯកា ហិ ធាតុ ឥធ ទិដ្ឋធម្មិកា
សឧបាទិសេសា ភវនេត្តិសង្ខយា
អនុបាទិសេសា បន សម្បរាយិកា
យម្ហិ និរុជ្ឈន្តិ ភវានិ សព្វសោ ។

ការអស់រាគៈ អស់ទោសៈ អស់មោហៈណា របស់ព្រះអរហន្តនោះ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សឧបាទិសេសនិព្វានធាតុ ។ ម្នាលភិក្ខុទាំងឡាយ អនុបាទិសេសនិព្វានធាតុ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអរហន្តខីណាស្រព មានព្រហ្មចរិយៈប្រព្រឹត្តរួចហើយ មានសោឡសកិច្ច ធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ ដោយលំដាប់ មានសំយោជនៈក្នុងភពអស់ហើយ ផុតស្រឡះហើយ ព្រោះដឹងច្បាស់ដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ ការសោយនូវអារម្មណ៍ទាំងពួង មានសុខវេទនាជាដើម ការមិនត្រេកអរ ដោយកិលេស មានតណ្ហាជាដើម របស់ព្រះអរហន្តនោះ នឹងស្ងប់រម្ងាប់ ឥតកម្រើក ក្នុងអត្តភាពនេះឯង ម្នាលភិក្ខុទាំងឡាយ នេះហៅថា អនុបាទិសេសនិព្វានធាតុ ។ ម្នាលភិក្ខុទាំងឡាយ និព្វានធាតុមាន ២ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

និព្វានធាតុ ២ នេះ ព្រះសម្មាសម្ពុទ្ធទ្រង់មានចក្ខុ ព្រះអង្គមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) មិនញាប់ញ័រ (ដោយលោកធម៌) ទ្រង់ប្រកាសហើយថា ធាតុមួយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ននេះ ជាទីអស់ទៅនៃតណ្ហាក្នុងភព ជាសឧបាទិសេសៈ ចំណែកធាតុ ដែលប្រព្រឹត្តទៅក្នុងបរលោក រលត់ភពទាំងឡាយដោយសព្វគ្រប់ ជាអនុបាទិសេសៈ ។

យេ ឯតទញ្ញាយ បទំ អសង្ខតំ

វិមុត្តចិត្តា ភវនេត្តិសង្ខយា

តេ ធម្មសារាធិគមក្ខយេ(១) រតា

បហំសុ តេ សព្វភវានិ តាទិនោតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។ សត្តមំ(២) ។

[៤៥] វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ បដិសល្លានារាមា ភិក្ខវេ វិហរថ បដិសល្លានរតា អជ្ឈត្តំ ចេតោសមថមនុយុត្តា អនិរាកតជ្ឈានា(៣) វិបស្សនាយ សមន្នាគតា ព្រូហេតា(៤) សុញ្ញាគារានំ ។ បដិសល្លានារាមានំ ភិក្ខវេ វិហរតំ បដិសល្លានរតានំ អជ្ឈត្តំ ចេតោសមថមនុយុត្តានំ អនិរាកតជ្ឈានានំ វិបស្សនាយ សមន្នាគតានំ ព្រូហេតានំ សុញ្ញាគារានំ ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

១ ឱ.ម. ធម្មសារាធិគមាខយេ ។ ២ ឱ.ម. សត្តមន្តិ នត្ថិ ។ ៣ ឱ.ម. អនិរាកតជ្ឈានំ ។
៤ ព្រូហេតារោតិ អដ្ឋកថាយំ ទិស្សតិ ។

អរហន្តទាំងឡាយណា មានចិត្តផុតស្រឡះហើយ អស់តណ្ហាក្នុងភពហើយ ព្រោះដឹងព្រះនិព្វាននេះ ដែលបច្ច័យមិនតាក់តែងហើយ អរហន្តទាំងនោះ ត្រេកអរក្នុងការអស់ទៅ ព្រោះបានធម៌មានខ្លឹម អរហន្តទាំងនោះ មិនបានញាប់ញ័រដោយលោកធម៌ បានលះបង់នូវភពទាំងអស់ហើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៧ ។

(៤៥) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូររីករាយក្នុងទីស្ងាត់ ត្រេកអរក្នុងទីស្ងាត់ ប្រកបរឿយៗ នូវចេតោសមថៈក្នុងខាងក្នុង កុំសាបសូន្យចាកឈាន ប្រកបព្រមដោយវិបស្សនា ចំរើនសុញ្ញាគារស្ថាន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ រីករាយក្នុងទីស្ងាត់ ត្រេកអរក្នុងទីស្ងាត់ ប្រកបរឿយៗ នូវចេតោសមថៈក្នុងខាងក្នុង មិនសាបសូន្យចាកឈាន ប្រកបដោយវិបស្សនា ចំរើនសុញ្ញាគារស្ថានហើយ បណ្តាផលទាំងឡាយពីរ ផលណាមួយ គង់នឹងបានប្រាកដ គឺបានសម្រេចអរហត្ត ក្នុងបច្ចុប្បន្ន ពុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់នៅ ក៏គង់បានសម្រេចភាពជាអនាគាមី ។ លុះព្រះមានព្រះភាគទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

យេ សន្តចិត្តា និបកា សតិមន្តោ ច ឈាយិនោ
សម្មា ធម្មំ វិបស្សន្តិ កាមេសុ អនបេក្ខិនោ
អប្បមាទរតា សន្តា បមាទេ ភយទស្សិនោ
អភព្វា បរិហានាយ និព្វានស្សេវ សន្តិកេតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។
អដ្ឋមំ(១) ។

(៤៦) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ សិក្ខានិសំសា ភិក្ខវេ វិហរថ បញ្ញុត្តរា វិមុត្តិសារា សតាធិបតេយ្យា ។ សិក្ខានិសំសានំ ភិក្ខវេ វិហរតំ បញ្ញុត្តរានំ វិមុត្តិសារានំ សតាធិបតេយ្យានំ ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

១ ឱ.ម. អដ្ឋមន្តិ នត្ថិ ។

ជនទាំងឡាយណា ជាអ្នកមានចិត្តស្ងប់ មានបញ្ញា មានស្មារតី មានឈាន ពិចារណាឃើញធម៌ដោយប្រពៃ មិនមានសេចក្ដីអាល័យក្នុងកាមទាំងឡាយ ត្រេកអរក្នុងសេចក្ដីមិនប្រមាទ ជាអ្នកស្ងប់រម្ងាប់ ឃើញភ័យក្នុងសេចក្ដីប្រមាទ ជនទាំងឡាយនោះ មិនគួរដើម្បីនឹងសាបសូន្យ (បិតនៅ) ក្នុងទីជិតនៃព្រះនិព្វាន ។

ខ្ញុំបានស្ដាប់មកហើយថា សេចក្ដីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៨ ។

(៤៦) ខ្ញុំបានស្ដាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរជាបុគ្គលមានសិក្ខាជាអានិសង្ស មានបញ្ញាជាកំពូល មានវិមុត្តិជាខ្លឹម មានសតិ ជាអធិបតី ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ មានសិក្ខាជាអានិសង្ស មានបញ្ញាជាកំពូល មានវិមុត្តិជាខ្លឹម មានសតិ ជាអធិបតីហើយ បណ្ដាផលទាំងឡាយពីរ ផលណាមួយ គង់នឹងបានប្រាកដ គឺបានសម្រេចអរហត្តក្នុងបច្ចុប្បន្ន ពុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់នៅ ក៏គង់បានសម្រេចភាពជាអនាគាមី ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្ដីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បរិបុណ្ណសេក្ខំ អបហានធម្មំ
បញ្ញុត្តរំ ជាតិខយន្តទស្សឹ
តំ វេ មុនឹ អន្តិមទេហធារឹ
មានញ្ជហំ ព្រូមិ ជរាយ បារគុំ ។
តស្មា សទា ឈានរតា សមាហិតា
អាតាបិនោ ជាតិខយន្តទស្សិនោ
មារំ សសេនំ អភិភុយ្យ ភិក្ខវោ
ភវថ ជាតិមរណស្ស បារគាតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។ ឆដ្ឋំ[១] ។

(៤៧) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ជាគរោ ចស្ស ភិក្ខវេ ភិក្ខុ វិហរេយ្យ សតោ សម្បជានោ សមាហិតោ បមុទិតោ វិប្បសន្នោ ច តត្ថ កាលវិបស្សី ច កុសលេសុ ធម្មេសុ ។ ជាគរស្ស ភិក្ខវេ ភិក្ខុនោ វិហរតោ សតិមតោ[២] សម្បជានស្ស សមាហិតស្ស បមុទិតស្ស វិប្បសន្នស្ស តត្ថ កាលវិបស្សិនោ កុសលេសុ ធម្មេសុ ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ

---

១ ឱ. ម. នវមន្តិ ឆក្កំ ។ ២ ឱ. ឬ. សតស្ស ។

គឺថាគេហៅនូវបុគ្គល ដែលមានការសិក្សាបរិបូណ៌ មានធម៌មិនបានលះបង់ មានបញ្ញាដ៏ឧត្តម បានឃើញព្រះនិព្វាន ជាទីអស់ទៅនៃជាតិនោះឯង ថាជាមុនី ទ្រទ្រង់នូវកាយជាទីបំផុត កំចាត់បង់មារ (មានកិលេសមារជាដើម) បានដល់ត្រើយនៃជរា ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរត្រេកអរក្នុងឈាន មានចិត្តដ៏តម្កល់មាំ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ឃើញព្រះនិព្វានជាទីអស់ទៅនៃជាតិ គ្របសង្កត់នូវមារព្រមទាំងសេនា សព្វកាល ដល់ត្រើយនៃជាតិ និងមរណៈ ។ ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៩ ។

(៤៧) ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីជាអ្នកភ្ញាក់រឭក មានសតិ មានសម្បជញ្ញៈ មានចិត្តដ៏តម្កល់មាំ មានចិត្តទន់ មានសេចក្តីជ្រះថ្លា ដោះនការឃើញ ក្នុងកាលគួរ ក្នុងកុសលធម៌ទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុ ជាអ្នកភ្ញាក់រឭក មានសតិ មានសម្បជញ្ញៈ មានចិត្តដ៏តម្កល់មាំ មានចិត្តទន់ មានសេចក្តីជ្រះថ្លា មានការឃើញ ក្នុងកាលគួរ ក្នុងកុសលធម៌ទាំងនោះហើយ បណ្តាផលទាំងឡាយពីរ ផលណាមួយ គង់បានប្រាកដគឺបានសម្រេច

ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតាតិ ។
ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

ជាគរន្តា សុណាថេតំ យេ សុត្តា តេ បពុជ្ឈថ
សុត្តា ជាគរិតំ សេយ្យោ នត្ថិ ជាគរតោ ភយំ ។

យោ ជាគរោ ច សតិមា សម្បជានោ
សមាហិតោ មុទិតោ វិប្បសន្នោ ច
កាលេន សោ សម្មា ធម្មំ បរិវីមំសមានោ
ឯកោទិភូតោ វិហនេ តមំ សោ ។

តស្មា ហវេ ជាគរិយំ ភជេថ
អាតាបី ភិក្ខុ និបកោ ឈានលាភី
សំយោជនំ ជាតិជរាយ ឆេត្វា
ឥធេវ សម្ពោធិមនុត្តរំ ផុសេតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។
ទសមំ(១) ។

---

១ ឱ. ម. ទសមន្តិ នត្ថិ ។

អរហត្ត ក្នុងបច្ចុប្បន្ន ពុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់នៅ ក៏គង់បានសម្រេចភាពជាអនាគាមី ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

អ្នកទាំងឡាយ ចូរភ្ញាក់រឭកឡើង ចាំស្តាប់ពាក្យនុ៎ះ ជនទាំងឡាយ
ណា ជាអ្នកដេកលក់ហើយ ជនទាំងឡាយនោះ ចូរភ្ញាក់ឡើង
កិរិយាភ្ញាក់ចាកការលក់ ជាការប្រសើរ ព្រោះភ័យមិនមានដល់
បុគ្គលអ្នកភ្ញាក់ឡើយ ។ បុគ្គលណា ជាអ្នកភ្ញាក់រឭក មានសតិ
មានសម្បជញ្ញៈ មានចិត្តដំកល់មាំ មានចិត្តទន់ មានចិត្តជ្រះថ្លា
បុគ្គលនោះ កាលពិចារណាឃើញធម៌ប្រពៃ តាមកាលគួរហើយ
បុគ្គលនោះ ជាបុគ្គលប្រសើរឯក កំចាត់បង់នូវងងឹតគឺអវិជ្ជាបាន ។
ព្រោះហេតុនោះ អ្នកទាំងឡាយ គួរសេពគប់នូវជាគរិយធម៌
ភិក្ខុអ្នកមានព្យាយាម ជាគ្រឿងដុតកំដៅកិលេស មានបញ្ញា
បានឈាន ផ្តាច់បង់ នូវសំយោជនៈ នៃជាតិ និងជរាហើយ
រមែងបានសម្ពោធិញ្ញាណដ៏ប្រសើរ ក្នុងលោកនេះឯង ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ១០ ។

(៤៨) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ទ្វេមេ ភិក្ខវេ អាបាយិកា នេរយិកា ឥទមប្បហាយ ។ កតមេ ទ្វេ ។ យោ អព្រហ្មចារី ព្រហ្មចារិប្បដិញ្ញោ យោ ច បរិសុទ្ធំ បរិសុទ្ធំ ព្រហ្មចរិយំ ចរន្តំ អមូលកេន អព្រហ្មចរិយេន អនុទ្ធំសេតិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ អាបាយិកា នេរយិកា ឥទមប្បហាយាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

អភូតវាទី និរយំ ឧបេតិ
យោ ចាបិ(១) កត្វា ន ករោមិ ចាហ
ឧភោបិ តេ បេច្ច សមា ភវន្តិ
និហីនកម្មា មនុជា បរត្ថ ។

កាសាវកណ្ឋា ពហវោ បាបធម្មា អសញ្ញតា
បាបា បាបេហិ កម្មេហិ និរយំ តេ ឧបបជ្ជរេ
សេយ្យោ អយោគុឡោ ភុត្តោ តត្តោ អគ្គិសិខូបមោ
យញ្ចេ ភុញ្ជេយ្យ ទុស្សីលោ រដ្ឋបិណ្ឌំ អសញ្ញតោតិ ។

១ ឱ. វាបិ ។

(៤៨) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកនេះ បើមិនទាន់លះបង់ នូវបាបសមាចារៈនេះទេ មុខជានឹងទៅកើតក្នុងអបាយ កើតក្នុងនរកមិនខាន ។ បុគ្គល ២ ពួក តើដូចម្តេច ។ គឺបុគ្គលដែលមិនមែនជាព្រហ្មចារីហើយប្តេជ្ញាខ្លួនជាព្រហ្មចារី ១ បុគ្គលដែលកំចាត់បង់អ្នកប្រព្រឹត្តព្រហ្មចរិយៈដ៏បរិសុទ្ធបរិបូណ៌ ដោយអព្រហ្មចរិយធម៌ មិនមានមូល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកនេះឯង បើមិនលះបង់នូវបាបសមាចារៈនេះទេ មុខជានឹងទៅកើតក្នុងអបាយ កើតក្នុងនរក មិនខាន ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលអ្នកនិយាយកុហក និងបុគ្គលដែលធ្វើបាប ហើយពោលថាខ្ញុំ មិនធ្វើទេ រមែងទៅកើតក្នុងនរក បុគ្គលទាំង ២ ពួកនោះ ជាសត្វ មានកម្មលាមក លះលោកនេះហើយ រមែងមានទោសស្មើគ្នាក្នុង បរលោក ។ បុគ្គលទាំងឡាយច្រើននាក់ មានកព័ន្ធព័ទ្ធដោយសំពត់ កាសាវៈ ប៉ុន្តែជាបុគ្គលមានធម៌លាមក មិនសង្រួម បុគ្គលបាបទាំង នោះនឹងទៅកើតក្នុងនរក ដោយកម្មទាំងឡាយលាមក បុគ្គលបរិភោគ ដុំដែកក្តៅ មានរងើកភ្លើងជាឧបមា ប្រសើរជាង បុគ្គលទ្រុស្តសីល មិនសង្រួម បរិភោគដុំបាយ របស់អ្នកដែន មិនប្រសើរឡើយ ។

## ឥតិវុត្តកេ ទុកនិបាតស្ស ទុតិយវគ្គស្ស ទ្វាទសមសុត្តំ

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ឯកាទសមំ[១] ។

(៤៩) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ទ្វីហិ ភិក្ខវេ ទិដ្ឋិគតេហិ បរិយុដ្ឋិតា ទេវមនុស្សា ឱលីយន្តិ ឯកេ អតិធាវន្តិ ឯកេ ចក្ខុមន្តោ ច បស្សន្តិ ។ កថញ្ច ភិក្ខវេ ឱលីយន្តិ ឯកេ ។ ភវារាមា ភិក្ខវេ ទេវមនុស្សា ភវរតា ភវសម្មុទិតា តេសំ ភវនិរោធាយ ធម្មេ ទេសិយមានេ ចិត្តំ ន បក្ខន្ទតិ ន បសីទតិ ន សន្តិដ្ឋតិ នាធិមុច្ចតិ ឯវំ[២] ភិក្ខវេ ឱលីយន្តិ ឯកេ ។ កថញ្ច ភិក្ខវេ អតិធាវន្តិ ឯកេ ។ ភវេនេវ ខោ បនេកេ អដ្ដិយមានា ហរាយមានា ជិគុច្ឆមានា វិភវំ អភិនន្ទន្តិ យតោ កិរ ភោ អយំ អត្តា កាយស្ស ភេទា បរម្មរណា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណា ឯតំ សន្តំ ឯតំ បណីតំ ឯតំ យថាវន្តិ[៣]

---

១ ឱ.ម. ឯកាទសមន្តិ នត្ថិ ។ ២ ឱ. ឯវំ ខោ ។ ៣ ម. យាថាវន្តិ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បាន ត្រាស់ទុកហើយ ។ សូត្រ ទី ១១ ។

(៤៩) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ទេវតានិងមនុស្ស ទាំងឡាយ ត្រូវទិដ្ឋិទាំង ២ រួបរឹតហើយ ពួក ១ រមែងជាប់នៅ ពួក ១ រមែងស្ទុះទៅ ចំណែកឯពួកបុគ្គលមានចក្ខុ រមែងឃើញ ។ ម្នាលភិក្ខុ ទាំងឡាយ បុគ្គលពួក ១ រមែងជាប់នៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំង ឡាយ ទេវតានិងមនុស្សទាំងឡាយ ជាអ្នករីករាយ ក្នុងភព ត្រេកអរ ក្នុងភព ស្រើបស្រាលក្នុងភព កាលតថាគតសំដែងធម៌ ដើម្បីរលត់ ភព ចិត្តរបស់ទេវតា និងមនុស្សទាំងឡាយនោះ ក៏មិនស្ទុះទៅ មិន ជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ម្នាលភិក្ខុទាំងឡាយ ទេវតានិងមនុស្ស ទាំងឡាយពួក ១ រមែងជាប់នៅ យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ទេវតានិងមនុស្សទាំងឡាយ ពួក ១ រមែងស្ទុះទៅ តើដូចម្តេច ។ ទេវតា និងមនុស្សទាំងឡាយពួក ១ កាលជិនឆ្អន់ នឿយណាយ ស្អប់ខ្ពើមភព រមែងត្រេកអរចំពោះការប្រាសចាកភពថា ម្នាលអ្នកដ៏ចំរើន បានឮថា អត្តភាពនេះ លុះបែកធ្លាយកន្លងកាយស្លាប់ទៅ រមែងដាច់សូន្យ វិនាសទៅ មិនកើតទៅក្នុងខាងមុខទៀត ព្រោះហេតុណា នេះជាធម្មជាត ស្ងប់ម្ងាប់ នេះជាធម្មជាត ដ៏ឧត្តម នេះជាធម្មជាត ដ៏ពិត

ឯវំ ខោ ភិក្ខវេ អតិធាវន្តិ ឯកេ ។ កថញ្ច ភិក្ខវេ ចក្ខុមន្តោ ច បស្សន្តិ ។ ឥធ ភិក្ខុ ភូតំ ភូតតោ បស្សតិ ភូតំ ភូតតោ ទិស្វា ភូតស្ស និព្ពិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ឯវំ ខោ ភិក្ខវេ ចក្ខុមន្តោ ច បស្សន្តីតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

យោ[១] ភូតំ ភូតតោ ទិស្វា ភូតស្ស ច អតិក្កមំ
យថាភូតំ[២] វិមុច្ចតិ ភវតណ្ហាបរិក្ខយា
ស ចេ[៣] ភូតំ បរិញ្ញោ សោ វីតតណ្ហោ ភវាភវេ
ភូតស្ស វិភវា ភិក្ខុ នាគច្ឆតិ[៤] បុនព្ភវន្តិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។
ទ្វាទសមំ[៥] ។

ទុតិយវគ្គោ ។

---

១ ឱ. យេ ។ ២ ឱ.ម. យថាភូតេ អដ្ឋកថាយម្បិ ទិស្សតិ ។ ៣ ម. ស វេ ។ ៤ ឱ. ភិក្ខុ នាគច្ឆតិ ។ ៥ ឱ.ម. ទ្វាទសមត្តិ ឆត្តិ ។

ម្នាលភិក្ខុទាំងឡាយ ទេវតានិងមនុស្សទាំងឡាយពួក ១ រមែងស្ទុះទៅយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះចំណែកបុគ្គលអ្នកមានចក្ខុ រមែងឃើញតើដូចម្តេច ។ ភិក្ខុក្នុងសាសនា នេះ ឃើញនូវខន្ធបញ្ចកៈ ដោយសភាវៈពិត លុះឃើញនូវខន្ធបញ្ចកៈ ដោយសភាវៈពិតហើយ ជាអ្នកប្រតិបត្តិ ដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់នូវខន្ធបញ្ចកៈ ម្នាលភិក្ខុទាំងឡាយ ចំណែកបុគ្គលមានចក្ខុ រមែងឃើញយ៉ាងនេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

អរិយសាវកណា ឃើញនូវខន្ធបញ្ចកៈ ដោយសភាវៈពិតផង
នូវការប្រព្រឹត្តិកន្លងនៃខន្ធបញ្ចកៈផង រមែងចុះចិត្តស៊ប់ ក្នុង
ព្រះនិព្វាន ដោយសភាវៈពិត ព្រោះអស់តណ្ហា ក្នុងភព
ប្រសិនបើ អរិយសាវកនោះ កំណត់ដឹងនូវខន្ធបញ្ចកៈ ប្រាស
ចាកតណ្ហា ក្នុងភពតូចភពធំហើយ ភិក្ខុទាំងឡាយ សូន្យ
ចាកខន្ធបញ្ចកៈហើយ រមែងមិនបានមកកាន់ភពថ្មីទៀត ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ១២ ។

ចប់ ទុតិយវគ្គ ។

### ឥតិវុត្តកេ ទុកនិបាតស្ស ទុតិយវគ្គស្ស ឧទ្ទានំ

## តស្សុទ្ទានំ

ទ្វេ ឥន្ទ្រិយា ទ្វេ តបនិយា  សីលេន អបរេ ទុវេ
អនោត្តប្បី កុហនា ទ្វេ ច  សំវេជនីយេន តេ ទស
វិតក្កា ទេសនា វិជ្ជា  បញ្ញា ធម្មេន បញ្ចមំ
អជាតំ ធាតុ សល្លានំ  សិក្ខា ជាគរិយេន ច
អបាយ ទិដ្ឋិយាយេវ(១)  ពាវីសតិ បកាសិតាតិ ។

ទុកនិបាតោ និដ្ឋិតោ ។

---

១ ឱ.ម. ទិដ្ឋិយា ចេវ ។

## ឧទ្ទាននៃទុតិយវគ្គនោះគឺ

និយាយអំពីឥន្ទ្រិយមានពីរលើក តបនិយធម៌មានពីរលើក សីលនឹងរឿងដទៃទៀត មានពីរលើក អំពីមិនមានឱត្តប្បៈ ១ រឿងកុហក មានពីរលើក សំវេជនីយ ១ ត្រូវជា ១០ អំពីវិតក្កៈ ១ ទេសនា ១ វិជ្ជា ១ បញ្ញា ១ នឹងធម៌ ១ ត្រូវជា ៥ អំពីអជាតធម៌ ១ ធាតុ ១ ទីសម្ងំ ១ សិក្ខា ១ ជាគរិយធម៌ ១ អបាយ ១ ទិដ្ឋិ ១ ត្រូវជា ២២ ដែលលោកបានប្រកាសទុកហើយ ៗ

ចប់ ទុកនិបាត ។

# ឥតិវុត្តកេ តិកនិបាតស្ស បឋមវគ្គោ

(៥០) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តីណិមានិ ភិក្ខវេ អកុសលមូលានិ ។ កតមានិ តីណិ ។ លោភោ អកុសលមូលំ ទោសោ អកុសលមូលំ មោហោ អកុសលមូលំ ។ ឥមានិ ខោ ភិក្ខវេ តីណិ អកុសលមូលានីតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

លោភោ ទោសោ ច មោហោ ច បុរិសំ បាបចេតសំ
ហឹសន្តិ អត្តសម្ភូតា តចសារំវ សម្ផលន្តិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។ បឋមំ[១] ។

(៥១) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តិស្សោ ឥមា ភិក្ខវេ ធាតុយោ ។ កតមា តិស្សោ ។ រូបធាតុ អរូបធាតុ និរោធធាតុ ។ ឥមា ខោ ភិក្ខវេ តិស្សោ ធាតុយោតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

រូបធាតុបរិញ្ញាយ អរូបេសុ អសណ្ឋិតា
និរោធេ យេ វិមុច្ចន្តិ តេ ជនា មច្ចុហាយិនោ ។

---

១ ឱ.ម. បឋមន្តិ ឥត្តិ ។

# ឥតិវុត្តកៈ តិកនិបាត បឋមវគ្គ

(៨០) ខ្ញុំបានស្ដាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អកុសលមូលនេះមាន៣ ។ អកុសលមូល ៣ តើដូចម្ដេច ។ គឺលោភៈ ជាអកុសលមូល ១ ទោសៈ ជាអកុសលមូល ១ មោហៈ ជាអកុសលមូល ១ ។ ម្នាលភិក្ខុទាំងឡាយ អកុសលមូលមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្ដីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

លោភៈ ទោសៈ មោហៈ ដែលកើតអំពីខ្លួន តែងបៀតបៀននូវបុរស
មានចិត្តលាមក ដូចជាបុស្សីមានផ្លែ តែងបៀតបៀននូវដើមរបស់វា ។

ខ្ញុំបានស្ដាប់មកហើយថា សេចក្ដីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រ ទី ១ ។

(៨១) ខ្ញុំបានស្ដាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ធាតុនេះ មាន ៣ ។ ធាតុ ៣ តើដូចម្ដេច ។ គឺរូបធាតុ ១ អរូបធាតុ ១ និរោធធាតុ ១ ។ ម្នាលភិក្ខុទាំងឡាយ ធាតុមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគទ្រង់សំដែងសេចក្ដីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ជនទាំងឡាយណា កំណត់ដឹងក្នុងរូបធាតុ មិនតាំងនៅក្នុងអរូបធាតុ
ចុះចិត្តស៊ប់ក្នុងនិរោធ ជនទាំងនោះ ឈ្មោះថាញុំាងមច្ចុឲ្យសាបសូន្យ ។

កាយេន អមតំ ធាតុំ ផុស្សយិត្វា និរូបធឹ
ឧបធិប្បដិនិស្សគ្គំ សច្ឆិកត្វា អនាសវោ
ទេសេតិ សម្មាសម្ពុទ្ធោ អសោកំ វិរជំ បទន្តិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ទុតិយំ(១) ។

(៥២) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តិស្សោ ឥមា ភិក្ខវេ វេទនា ។ កតមា តិស្សោ ។ សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។ ឥមា ខោ ភិក្ខវេ តិស្សោ វេទនាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

សមាហិតោ សម្បជានោ សតោ ពុទ្ធស្ស សាវកោ
វេទនា ច បជានាតិ វេទនានញ្ច សម្ភវំ
យត្ថ ចេតា និរុជ្ឈន្តិ មគ្គញ្ច ខយគាមិនំ
វេទនានំ ខយា ភិក្ខុ និច្ឆាតោ បរិនិព្វុតោតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

តតិយំ(២) ។

---

១ ឱ. ម. ទុតិយន្តិ និដ្ឋិ ។ ២ ឱ. ម. តតិយន្តិ និដ្ឋិ ។

ព្រះសម្មាសម្ពុទ្ធ ដែលមិនមានអាសវៈ បានពាល់ត្រូវ
នូវអមតធាតុ ដែលមិនមានឧបធិ ដោយនាមកាយ
ធ្វើឲ្យជាក់ច្បាស់ នូវព្រះនិព្វានដែលជាទីលះបង់ឧបធិ ទ្រង់
សំដែងព្រះនិព្វាន ដែលមិនមានសោក មិនមានតម្រេក ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រ ទី ២ ។

(៥២) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ វេទនានេះមាន ៣ ។ វេទនា ៣ តើដូចម្តេច ។ គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ វេទនាមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សាវ័កនៃព្រះពុទ្ធ មានចិត្តដំកល់មាំ មានសម្បជញ្ញៈ មានសតិ
ដឹងច្បាស់នូវវេទនាទាំងឡាយផង នូវទីកើតនៃវេទនាទាំងឡាយ
ផង វេទនាទាំងនោះ រលត់ទៅ ក្នុងទីណា ក៏ដឹងច្បាស់នូវ
ទីនោះផង នូវមគ្គជាដំណើរទៅកាន់ទីអស់ទៅ នៃវេទនាផង
ភិក្ខុអស់តណ្ហា តែងបរិនិព្វាន ព្រោះអស់វេទនាទាំងឡាយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រ ទី ៣ ។

[៥៣] វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តិស្សោ ឥមា ភិក្ខវេ វេទនា ។ កតមា តិស្សោ ។ សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។ សុខា ភិក្ខវេ វេទនា ទុក្ខតោ ទដ្ឋព្វា ទុក្ខា វេទនា សល្លតោ ទដ្ឋព្វា អទុក្ខមសុខា វេទនា អនិច្ចតោ ទដ្ឋព្វា ។ យតោ ច ខោ ភិក្ខវេ ភិក្ខុនោ សុខា វេទនា ទុក្ខតោ ទិដ្ឋា ហោតិ ទុក្ខា វេទនា សល្លតោ ទិដ្ឋា ហោតិ អទុក្ខមសុខា វេទនា អនិច្ចតោ ទិដ្ឋា ហោតិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អរិយោ សម្មទ្ទសោ អច្ឆេច្ឆិ(១) តណ្ហំ វិវត្តយិ សំយោជនំ សម្មា មានាភិសមយា អន្តមកាសិ ទុក្ខស្សាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

យោ សុខំ ទុក្ខតោ ទក្ខិ ទុក្ខមទ្ទក្ខិ សល្លតោ
អទុក្ខមសុខំ សន្តំ អទក្ខិ នំ អនិច្ចតោ
ស វេ សម្មទ្ទសោ ភិក្ខុ យតោ តត្ថ វិមុច្ចតិ
អភិញ្ញាវោសិតោ សន្តោ ស វេ យោគាតិគោ មុនីតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ចតុត្ថំ(២) ។

---

១ ឱ. អច្ឆេជ្ឈិ ។ ម. អច្ឆិជ្ជិ ។ ២ ឱ ម. ចតុត្ថន្តិ នត្ថិ ។

(៥៣) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ៗ ម្នាលភិក្ខុទាំងឡាយ វេទនានេះ មាន ៣ ៗ វេទនា ៣ តើដូចម្តេច ៗ គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខ-វេទនា ១ ៗ ម្នាលភិក្ខុទាំងឡាយ បុគ្គលគប្បីឃើញនូវសុខវេទនា ថាជាទុក្ខ គប្បីឃើញនូវទុក្ខវេទនា ថាជាប្រួញ គប្បីឃើញនូវអទុក្ខមសុខវេទនា ថាជារបស់មិនទៀង ៗ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុ ឃើញសុខវេទនា ថាជាទុក្ខ ឃើញទុក្ខវេទនា ថាជាប្រួញ ឃើញអទុក្ខមសុខវេទនា ថាជារបស់មិនទៀងហើយ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុប្រសើរ ឃើញត្រូវ ផ្តាច់បង់តណ្ហា ដោះស្រាយសំយោជនៈ ធ្វើនូវទីបំផុតនៃទុក្ខបាន ព្រោះយល់ច្បាស់នូវមានះ ដោយប្រពៃ ៗ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ៗ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ភិក្ខុណា បានឃើញសុខវេទនា ថាជាទុក្ខ បានឃើញទុក្ខវេទនាថា ជាប្រួញ បានឃើញអទុក្ខមសុខវេទនា ជាទីស្ងប់នោះ ថាជារបស់មិនទៀង ភិក្ខុនោះឯង ឃើញ (វេទនាទាំង ៣) ដោយប្រពៃ រមែងរួចស្រឡះក្នុងវេទនា ដោយការបង្រួមកាយ វាចា ចិត្ត ភិក្ខុនោះឯងមានព្រហ្មចរិយៈប្រព្រឹត្តរួចហើយ ព្រោះត្រាស់ដឹង ជាអ្នកស្ងប់រម្ងាប់ ជាមុនីកន្លងផុតនូវយោគៈ ៗ

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ៗ សូត្រ ទី ៤ ។

(៥៤) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តិស្សោ ឥមា ភិក្ខវេ ឯសនា ។ កតមា តិស្សោ ។ កាមេសនា ភវេសនា ព្រហ្មចរិយេសនា ។ ឥមា ខោ ភិក្ខវេ តិស្សោ ឯសនាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

សមាហិតោ សម្បជានោ សតោ ពុទ្ធស្ស សាវកោ
ឯសនា ច បជានាតិ ឯសនានញ្ច សម្ភវំ
យត្ថ ចេតា និរុជ្ឈន្តិ មគ្គញ្ច ខយគាមិនំ
ឯសនានំ ខយា ភិក្ខុ និច្ឆាតោ បរិនិព្វុតោតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។ បញ្ចមំ[1] ។

(៥៥) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តិស្សោ ឥមា ភិក្ខវេ ឯសនា ។ កតមា តិស្សោ ។ កាមេសនា ភវេសនា ព្រហ្មចរិយេសនា ។

---

១ ឱ. ម. បញ្ចមន្តិ នត្ថិ ។

(៥៤) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ៗ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកនេះ មាន ៣ ៗ ការស្វែងរក ៣ តើដូចម្តេច ៗ គឺការស្វែងរកកាម ១ ការស្វែងរកភព ១ ការស្វែងរកព្រហ្មចរិយៈ ១ ៗ ម្នាលភិក្ខុទាំងឡាយ ការស្វែងរក មាន ៣ នេះឯង ៗ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ៗ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សាវកនៃព្រះពុទ្ធ មានចិត្តដំកល់មាំ មានសម្បជញ្ញៈ មាន
សតិ ដឹងច្បាស់នូវការស្វែងរកទាំងឡាយផង នូវទីកើតនៃ
ការស្វែងរកទាំងឡាយផង ការស្វែងរកទាំងនុ៎ះ រលត់ទៅ
ក្នុងទីណា ក៏ដឹងច្បាស់នូវទីនោះផង នូវមគ្គជាដំណើរទៅ
កាន់ទីអស់ទៅ នៃការស្វែងរកផង ភិក្ខុអស់ទៅនៃតណ្ហា
តែងបរិនិព្វាន ព្រោះអស់ទៅនៃការស្វែងរកទាំងឡាយ ៗ

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បាន ត្រាស់ទុកហើយ ៗ សូត្រ ទី ៥ ។

(៥៥) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ៗ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកនេះ មាន ៣ ៗ ការស្វែងរក ៣ តើដូចម្តេច ៗ គឺការស្វែងរកកាម ១ ការស្វែងរកភព ១ ការស្វែងរកព្រហ្មចរិយៈ ១ ៗ

ឥមា ខោ ភិក្ខវេ តិស្សោ ឯសនាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

កាមេសនា ភវេសនា ព្រហ្មចរិយេសនា សហ
ឥតិ សច្ចបរាមាសោ ទិដ្ឋិដ្ឋានា សមុស្សយា
សព្ពរាគវិរត្តស្ស តណ្ហក្ខយវិមុត្តិនោ(១)
ឯសនា បដិនិស្សដ្ឋា ទិដ្ឋិដ្ឋានា(២) សមូហតា
ឯសនានំ ខយា ភិក្ខុ និរាសោ អកថង្កថីតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។
ឆដ្ឋំ(៣) ។

(៥៦) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តយោមេ ភិក្ខវេ អាសវា ។ កតមេ តយោ ។ កាមាសវោ ភវាសវោ អវិជ្ជាសវោ ។ ឥមេ ខោ ភិក្ខវេ តយោ អាសវាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

---

១ ម. តណ្ហក្ខយវិមុត្តិយា ។ ២ ម. ទិដ្ឋិសតា ។ ៣ ឱ.ម. ឆដ្ឋិ ឥតិ ។

ម្នាលភិក្ខុទាំងឡាយ ការស្វែងរកមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ការស្វែងរកកាម ការស្វែងរកភព នឹងការស្វែងរកព្រហ្មចរិយៈ
ដែលជាទីស្ទាបអង្អែល ថាជារបស់ពិត ជាទីតាំងនៃទិដ្ឋិ
ជាទីដុះដាលនៃកិលេស ការស្វែងរករបស់ភិក្ខុ អ្នកប្រាស
ចាកសេចក្តីត្រេកអរទាំងពួង ផុតស្រឡះ ព្រោះអស់តណ្ហា
បានលះបង់ហើយ ទាំងហេតុជាទីតាំងនៃទិដ្ឋិ ក៏បានដក
ចោលហើយ ភិក្ខុមិនមានសេចក្តីប្រាថ្នា មិនមានសេចក្តី
ងឿងឆ្ងល់ ព្រោះអស់ទៅនៃការស្វែងរកទាំងឡាយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៦ ។

(៥៦) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈនេះ មាន ៣ ។ អាសវៈ ៣ តើដូចម្តេច ។ គឺកាមាសវៈ ១ ភវាសវៈ ១ អវិជ្ជាសវៈ ១ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគទ្រង់សំដែងសេចក្តីនេះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សមាហិតោ សម្បជានោ សតោ ពុទ្ធស្ស សាវកោ
អាសវេ ច បជានាតិ អាសវានញ្ច សម្ភវំ
យត្ថ ចេតោ(១) និរុជ្ឈន្តិ មគ្គញ្ច ខយគាមិនំ
អាសវានំ ខយា ភិក្ខុ និច្ឆាតោ បរិនិព្វុតោតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។ សត្តមំ(២) ។

[៨៧] វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តយោមេ ភិក្ខវេ អាសវា ។ កតមេ តយោ ។ កាមាសវោ ភវាសវោ អវិជ្ជាសវោ ។ ឥមេ ខោ ភិក្ខវេ តយោ អាសវាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

យស្ស កាមាសវោ ខីណោ អវិជ្ជា ច វិរាជិតា
ភវាសវោ បរិក្ខីណោ វិប្បមុត្តោ និរូបធិ
ធារេតិ អន្តិមំ ទេហំ ជេត្វា មារំ សវាហនន្តិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។ អដ្ឋមំ(៣) ។

---

១ ចេតេតិ យុត្តតរំ ។ ២ ឱ.ម. សត្តមន្តិ នត្ថិ ។ ៣ ឱ.ម. អដ្ឋមន្តិ នត្ថិ ។

សាវ័កនៃព្រះពុទ្ធ មានចិត្តដំកល់មាំ មានសម្បជញ្ញៈ មានសតិ ដឹងច្បាស់នូវអាសវៈទាំងឡាយផង នូវទីកើតនៃអាសវៈទាំងឡាយផង អាសវៈទាំងនោះ រលត់ទៅក្នុងទីណា ក៏ដឹងច្បាស់នូវទីនោះផង នូវមគ្គជាដំណើរទៅកាន់ទីអស់ទៅនៃអាសវៈផង ភិក្ខុមិនមានសេចក្តីប្រាថ្នា តែងបរិនិព្វាន ព្រោះអស់អាសវៈទាំងឡាយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៧ ។

(៩៧) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈនេះមាន ៣ ។ អាសវៈ ៣ តើដូចម្តេច ។ គឺកាមាសវៈ ១ ភវាសវៈ ១ អវិជ្ជាសវៈ ១ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលណា មានកាមាសវៈអស់ហើយ មានអវិជ្ជាសវៈអស់ហើយ
មានភវាសវៈអស់ហើយ មានចិត្តផុតស្រឡះហើយ មិនមានឧបធិ
បុគ្គលនោះ ឈ្នះមារព្រមទាំងពាហនៈទ្រទ្រង់នូវកាយជាទីបំផុត ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៨ ។

(៥៨) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តិស្សោ ឥមា ភិក្ខវេ តណ្ហា ។ កតមា តិស្សោ ។ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។ ឥមា ខោ ភិក្ខវេ តិស្សោ តណ្ហាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

តណ្ហាយោគេន សំយុត្តា រត្តចិត្តា ភវាភវេ
តេ យោគយុត្តា មារស្ស អយោគក្ខេមិនោ ជនា
សត្តា គច្ឆន្តិ សំសារំ ជាតិមរណគាមិនោ
យេ ច តណ្ហំ បហន្ត្វាន វីតតណ្ហា(១) ភវាភវេ
តេ វេ បារគតា(២) លោកេ យេ បត្តា អាសវក្ខយន្តិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

នវមំ(៣) ។

---

១ ម. និត្តណ្ហា ប ។ ២ ឱ ម. តេ បារំ គតា ។ ៣ ឱ ម. នវមន្តិ ឆដ្ឋំ ។

(៥៨) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ តណ្ហានេះមាន ៣ ។ តណ្ហា ៣ តើដូចម្តេច ។ គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ ម្នាលភិក្ខុទាំងឡាយ តណ្ហាមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ជនទាំងឡាយប្រកបហើយ ព្រោះប្រកបដោយតណ្ហា មាន
ចិត្តត្រេកអរ ក្នុងភពតូចនិងភពធំ ជនទាំងនោះ ឈ្មោះថា
ប្រកបដោយយោគៈ ពោលគឺអន្ទាក់នៃមារ មិនក្សេមចាកយោគៈ
សត្វទាំងឡាយ នៅមានដំណើរ ទៅកាន់ជាតិនិងមរណៈ
តែងទៅកាន់សង្សារ ចំណែកពួកសត្វណា លះបង់តណ្ហាបាន
ហើយ សត្វទាំងនោះឈ្មោះថា ប្រាសចាកតណ្ហា ក្នុងភពតូច
និងភពធំ ពួកសត្វណា បានដល់នូវការអស់អាសវៈក្នុងលោក
សត្វទាំងនោះឯង ឈ្មោះថា បានដល់នូវត្រើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រ ទី ៥ ។

## ឥតិវុត្តកេ តិកនិបាតស្ស បឋមវគ្គស្ស ទសមសុត្តំ

(៥៩) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អតិក្កម្ម មារធេយ្យំ អាទិច្ចោវ វិរោចតិ ។ កតមេហិ តីហិ ។ ឥធ ភិក្ខវេ ភិក្ខុ អសេក្ខេន សីលក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន សមាធិក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន បញ្ញាក្ខន្ធេន សមន្នាគតោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អតិក្កម្ម មារធេយ្យំ អាទិច្ចោវ វិរោចតីតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

សីលសមាធិបញ្ញា[១] ច យស្ស ឯតេ សុភាវិតា
អតិក្កម្ម មារធេយ្យំ អាទិច្ចោវ វិរោចតីតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ទសមំ[២] ។

បឋមវគ្គោ ។

---

១ ឱ.ម. សីលំ សមាធិបញ្ញា ។ ២ ឱ.ម. ទសមត្តិ ឆត្ថិ ។

ឥតិវុត្តកៈ តិកនិបាត បឋមវគ្គ សូត្រ ទី ១០

(៥៩) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ រមែងកន្លងនូវវិស័យនៃមារ រុងរឿង ដូចព្រះអាទិត្យ ៗ ប្រកបដោយធម៌ ៣ តើដូចម្តេច ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ប្រកបដោយសីលក្ខន្ធ ជាអសេក្ខៈ ១ ប្រកបដោយសមាធិក្ខន្ធ ជាអសេក្ខៈ ១ ប្រកបដោយបញ្ញាខន្ធ ជាអសេក្ខៈ ១ ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ នេះឯង រមែងកន្លងនូវវិស័យនៃមារ រុងរឿង ដូចព្រះអាទិត្យ ៗ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ៗ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សីល សមាធិ និងបញ្ញា ទាំងអម្បាលនុ៎ះ
ដែលបុគ្គលណា បានអប់រំល្អហើយ បុគ្គលនោះ
រមែងកន្លងនូវវិស័យនៃមារ រុងរឿង ដូចព្រះអាទិត្យ ៗ

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ៗ សូត្រ ទី ១០ ។

ចប់ បឋមវគ្គ ។

## តស្សុទ្ទានំ

មូលធាតុ អថ វេទនា ទ្វេ

ឯសនា ច ទ្វេ អាសវា ទ្វេ

តណ្ហាតោ អថ[១] មារធេយ្យតោ

វគ្គមាហុ បឋមន្តិ ឧត្តមន្តិ ។

---

១ ឱ ម. ឯត្ថន្តរេ បសខ្ខោ អត្ថិ ។

សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តកៈ

## ឧទ្ទាននៃបឋមវគ្គនោះគឺ

និយាយអំពីមូល ១ ធាតុ ១ វេទនាពីរលើក

ការស្វែងរក ពីរលើក អាសវៈ ពីរលើក

តណ្ហា ១ វិស័យនៃមារ ១ លោកពោល

ថា បឋមវគ្គ ជាវគ្គដ៏ឧត្តម ។

---

# ឥតិវុត្តកេ តិកនិបាតស្ស ទុតិយវគ្គោ

(៦០) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តីណិមានិ ភិក្ខវេ បុញ្ញកិរិយវត្ថូនិ ។ កតមានិ តីណិ ។ ទានមយំ បុញ្ញកិរិយវត្ថុ សីលមយំ បុញ្ញកិរិយវត្ថុ ភាវនាមយំ បុញ្ញកិរិយវត្ថុ ។ ឥមានិ ខោ ភិក្ខវេ តីណិ បុញ្ញកិរិយវត្ថូនីតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

បុញ្ញមេវ សោ សិក្ខេយ្យ អាយតគ្គំ សុខិន្ទ្រិយំ
ទានញ្ច សមចរិយញ្ច មេត្តចិត្តញ្ច ភាវយេ
ឯតេ ធម្មេ ភាវយិត្វា តយោ សុខសមុទ្ទយេ
អព្យាបជ្ឈំ សុខំ លោកំ បណ្ឌិតោ ឧបបជ្ជតីតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។ បឋមំ[១] ។

(៦១) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តីណិមានិ ភិក្ខវេ ចក្ខូនិ ។ កតមានិ តីណិ ។ មំសចក្ខុ ទិព្វចក្ខុ បញ្ញាចក្ខុ ។ ឥមានិ ខោ ភិក្ខវេ តីណិ ចក្ខូនីតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

---

១ ឱម. បឋមន្តិ នត្ថិ ។

# ឥតិវុត្តកៈ តិកនិបាត ទុតិយវគ្គ

(៦០) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុញ្ញកិរិយាវត្ថុនេះ មាន ៣ ។ បុញ្ញកិរិយាវត្ថុ ៣ តើដូចម្តេច ។ គឺទានមយបុញ្ញកិរិយាវត្ថុ ១ សីលមយបុញ្ញកិរិយាវត្ថុ ១ ភាវនាមយបុញ្ញកិរិយាវត្ថុ ១ ។ ម្នាលភិក្ខុទាំងឡាយ បុញ្ញកិរិយាវត្ថុ មាន ៣ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

កុលបុត្រអ្នកប្រាថ្នាប្រយោជន៍ គួរសិក្សានូវបុណ្យ ដែល
មានផលបរិបូណ៌ មានវិបាកជាសុខ គឺគួរបំពេញទានផង
ការប្រព្រឹត្តិស្មើ គឺសីលផង មេត្តាចិត្តផង លុះបំពេញធម៌
ទាំង ៣ នេះ ដែលមានអានិសង្សជាសុខហើយ រមែង
ចូលទៅកាន់លោក ដែលជាសុខ ឥតមានការបៀតបៀន ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ១ ។

(៦១) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុនេះ មាន ៣ ។ ចក្ខុ ៣ តើដូចម្តេច ។ គឺមំសចក្ខុ ១ ទិព្វចក្ខុ ១ បញ្ញាចក្ខុ ១ ។

មំសចក្ខុ ទិព្វចក្ខុ   បញ្ញាចក្ខុ អនុត្តរំ
ឯតានិ តីណិ ចក្ខូនិ   អក្ខាសិ បុរិសុត្តមោ
មំសចក្ខុស្ស ឧប្បាទោ   មគ្គោ ទិព្វស្ស ចក្ខុនោ
យតោ ញាណំ ឧទបាទិ   បញ្ញាចក្ខុ អនុត្តរំ
តស្ស ចក្ខុស្ស បដិលាភា   សព្វទុក្ខា វិមុច្ចតីតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ទុតិយំ[១] ។

[៦២] វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តីណិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កតមានិ តីណិ ។ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ អញ្ញិន្ទ្រិយំ អញ្ញាតាវិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ តីណិ ឥន្ទ្រិយានីតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

---

១ ឱ. ម. ទុតិយន្តិ នត្ថិ ។

ម្នាលភិក្ខុទាំងឡាយ ចក្ខុមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុរសឧត្តម បាននោលនូវចក្ខុ ៣ នេះ គឺមំសចក្ខុ ១ ទិព្វចក្ខុ ១ បញ្ញាចក្ខុ ដ៏ប្រសើរបំផុត ១ ការកើតឡើងនៃមំសចក្ខុ ជាឧបាយនៃទិព្វចក្ខុ កាលដែលញាណគឺបញ្ញាចក្ខុដ៏ឧត្តម កើតឡើងហើយ បុគ្គល រមែងរួចស្រឡះចាកទុក្ខទាំងពួង ព្រោះបាននូវចក្ខុនោះ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រ ទី ២ ។

(៦២) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះ មាន៣ ។ ឥន្ទ្រិយ ៣ តើដូចម្តេច ។ គឺអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ[1] ១ អញ្ញិន្ទ្រិយ[2] ១ អញ្ញាតាវិន្ទ្រិយ[3] ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ មាន ៣ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

---

១ ឥន្ទ្រិយដែលកើតឡើង ដល់អ្នកប្រតិបត្តិថា អាត្មាអញនឹងដឹងនូវចតុស្សច្ចធម៌ ដែលអាត្មាអញមិនទាន់ដឹង មិនទាន់សម្រេច ក្នុងសំសារវដ្ត បានដល់សោតាបត្តិមគ្គប្បញ្ញា ។

២ ឥន្ទ្រិយរបស់អរិយបុគ្គលតាំងអំពីសោតាបត្តិផលដល់អរហត្តមគ្គ ។ ៣ ឥន្ទ្រិយរបស់ព្រះខីណាស្រព ដែលមានញាណកិច្ច សម្រេចហើយក្នុងសច្ចៈទាំង ៤ ។

ឥតិវុត្តកេ តិកនិបាតស្ស ទុតិយវគ្គស្ស ចតុត្ថសុត្តំ

សេក្ខស្ស សិក្ខមានស្ស ឧជុមគ្គានុសារិនោ
ខយស្មឹ បឋមំ ញាណំ តតោ អញ្ញា អនន្តរា
តតោ អញ្ញា វិមុត្តស្ស ញាណំ វេ[១] ហោតិ តាទិនោ
អកុប្បា មេ វិមុត្តីតិ ភវសំយោជនក្ខយា
ស វេ[២] ឥន្ទ្រិយសម្បន្នោ សន្តោ សន្តិបទេ រតោ
ធារេតិ អន្តិមំ ទេហំ ជេត្វា មារំ សវាហនន្តិ ។
អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។
តតិយំ[៣] ។

(៦៣) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តយោមេ ភិក្ខវេ អទ្ធា ។ កតមេ តយោ ។ អតីតោ អទ្ធា អនាគតោ អទ្ធា បច្ចុប្បន្នោ អទ្ធា ។ ឥមេ ខោ ភិក្ខវេ តយោ អទ្ធាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

---

១ ម. បេ ។ ២ ឱ.ម. សវេ ។ ៣ ឱ.ម. តតិយត្ថិ នត្ថិ ។

ញាណជាបឋម ក្នុងកិរិយាអស់ទៅ កើតឡើងដល់សេក្ខបុគ្គល អ្នកកំពុងសិក្សា អ្នករលឹករឿយៗ នូវផ្លូវដ៏ត្រង់ លំដាប់ពីនោះមក អរហត្តក៏កើតឡើង លំដាប់អំពីអរហត្តផលនោះមក បច្ចវេក្ខណញ្ញាណ ក៏កើតឡើង ដល់ព្រះខីណាស្រព ដែលដល់នូវតាទិលក្ខណៈ រួចស្រឡះហើយ ព្រោះអស់ទៅនៃភវសំយោជនៈថា វិមុត្តិរបស់អាត្មាអញ មិនកំរើក បើបុគ្គលប្រកបដោយឥន្ទ្រិយជាអ្នកស្ងប់ម្ងាប់ ត្រេកអរ ក្នុងព្រះនិព្វានជាទីស្ងប់ ឈ្នះនូវមារព្រមទាំងពាហនៈហើយ រមែងទ្រទ្រង់នូវរាងកាយជាទីបំផុត ។ ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រ ទី ៣ ។

(៦៣) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលនេះមាន ៣ ។ កាល ៣ តើដូចម្តេច ។ គឺ អតីតកាល ១ អនាគតកាល ១ បច្ចុប្បន្នកាល ១ ។ ម្នាលភិក្ខុទាំងឡាយ កាលមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

អក្ខេយ្យសញ្ញិនោ សត្តា អក្ខេយ្យស្មឹ បតិដ្ឋិតា
អក្ខេយ្យំ អបរិញ្ញាយ យោគមាយន្តិ មច្ចុនោ
អក្ខេយ្យំ(១) បរិញ្ញាយ អក្ខាតារំ ន មញ្ញតិ
ផុដ្ឋោ វិមោក្ខោ មនសា សន្តិបទមនុត្តរំ
ស វេ(២) អក្ខេយ្យសម្បន្នោ សន្តោ សន្តិបទេ រតោ
សង្ខាយ សេវី ធម្មដ្ឋោ សង្ខ្យំ នោបេតិ វេទគូតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ចតុត្ថំ ។

(៦៤) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តីណិមានិ ភិក្ខវេ ទុច្ចរិតានិ ។ កតមានិ តីណិ ។ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ ។ ឥមានិ ខោ ភិក្ខវេ តីណិ ទុច្ចរិតានីតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

១ ឱ. អក្ខេយ្យញ្ច ។ ម អក្ខេយ្យប ។ ២ ម. សវេ ។

សត្វទាំងឡាយ មានសេចក្តីសំគាល់ ក្នុងកិរិយាពោលថាសត្វ ថាបុគ្គលជាដើម តាំងនៅក្នុងកិរិយាពោល ដោយអំណាចនៃតណ្ហានិងទិដ្ឋិ លុះមិនកំណត់ដឹងនូវកិរិយាពោល ដោយបរិញ្ញាទាំង ៣ យ៉ាង ក្នុងធម៌ដែលប្រកបដោយភូមិ ៣ ហើយរមែងមកកាន់ទីប្រកបដោយមរណៈ ព្រះខីណាស្រព រមែងមិនសំគាល់ គឺមិនជឿនូវបុគ្គលអ្នកប្រាប់ ព្រោះកំណត់ដឹងនូវពាក្យពោល វិមោក្ខ គឺព្រះនិព្វានជាទីរម្ងាប់ដ៏ប្រសើរ ឈ្មោះថាលោកបានសម្រេចហើយដោយចិត្ត ព្រះខីណាស្រពនោះឯង ដល់ព្រមដោយការពោល ជាអ្នកស្ងប់រម្ងាប់ ត្រេកអរក្នុងព្រះនិព្វានជាទីស្ងប់ ពិចារណាហើយទើបសេព តាំងនៅក្នុងនិព្វានធម៌ ដល់នូវវេទ រមែងមិនដល់នូវការរាប់ថា (ជាមនុស្សឬទេវតា) ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៤ ។

(៦៤) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ទុច្ចរិតនេះមាន ៣ ។ ទុច្ចរិត ៣ តើដូចម្តេច ។ គឺកាយទុច្ចរិត ១ វចីទុច្ចរិត ១ មនោទុច្ចរិត ១ ។ ម្នាលភិក្ខុទាំងឡាយ ទុច្ចរិតមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ឥតិវុត្តកេ តិកនិបាតស្ស ទុតិយវគ្គស្ស ឆដ្ឋសុត្តំ

កាយទុច្ចរិតំ កត្វា វចីទុច្ចរិតានិ ច
មនោទុច្ចរិតំ កត្វា យញ្ចញ្ញំ ទោសសំហិតំ
អកត្វា កុសលំ កម្មំ កត្វានាកុសលំ ពហុំ
កាយស្ស ភេទា ទុប្បញ្ញោ និរយំ សោ ឧបបជ្ជតីតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។ បញ្ចមំ(១) ។

(៦៨) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តីណិមានិ ភិក្ខវេ សុចរិតានិ ។ កតមានិ តីណិ ។ កាយសុចរិតំ វចីសុចរិតំ មនោសុចរិតំ ។ ឥមានិ ខោ ភិក្ខវេ តីណិ សុចរិតានីតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

កាយទុច្ចរិតំ ហិត្វា វចីទុច្ចរិតានិ ច
មនោទុច្ចរិតំ ហិត្វា យញ្ចញ្ញំ ទោសសំហិតំ
អកត្វា អកុសលំ កម្មំ កត្វាន កុសលំ ពហុំ
កាយស្ស ភេទា សប្បញ្ញោ សគ្គំ សោ ឧបបជ្ជតីតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។ ឆដ្ឋំ(២) ។

---

១ ឱ. ម. បញ្ចមត្ថិ ទត្តិ ។ ២ ឱ. ម. ឆដ្ឋត្ថិ ទត្តិ ។

បុគ្គលធ្វើកាយទុច្ចរិតផង វចីទុច្ចរិតផង ធ្វើមនោទុច្ចរិតផង នូវអំពើណាមួយដែលប្រកបដោយទោសផង មិនធ្វើនូវអំពើជាកុសល ធ្វើតែអំពើជាអកុសលដ៏ច្រើន បុគ្គលឥតប្រាជ្ញានោះ លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៨ ។

(៦៨) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ សុចរិតនេះមាន ៣ ។ សុចរិត ៣ តើអ្វីខ្លះ ។ គឺកាយសុចរិត ១ វចីសុចរិត១ មនោសុចរិត ១ ។ ម្នាលភិក្ខុទាំងឡាយ សុចរិតមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលណា លះនូវកាយទុច្ចរិតផង នូវវចីទុច្ចរិតផង លះនូវមនោទុច្ចរិតផង នូវអំពើណាមួយ ដែលប្រកបដោយទោសផង មិនធ្វើអកុសលកម្ម ធ្វើតែកុសលកម្មដ៏ច្រើន បុគ្គលប្រកបដោយប្រាជ្ញានោះ លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងឋានសួគ៌ ។

[៦៦] វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តីណិមានិ ភិក្ខវេ សោចេយ្យានិ ។ កតមានិ តីណិ ។ កាយសោចេយ្យំ វចីសោចេយ្យំ មនោសោចេយ្យំ ។ ឥមានិ ខោ ភិក្ខវេ តីណិ សោចេយ្យានីតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

កាយសុចឹ[១] វាចាសុចឹ[២] ចេតោសុចិមនាសវំ
សុចឹ[៣] សោចេយ្យសម្បន្នំ អាហុ សព្វប្បហាយិនន្តិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

សត្តមំ[៤] ។

[៦៧] វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តីណិមានិ ភិក្ខវេ មោនេយ្យានិ ។ កតមានិ តីណិ ។

---

១-២-៣ ម. សុចិ ។ ៤ ឱ. ម. សត្តមត្ថំ ឥត្ថិ ។

ខ្ញុំបានស្ដាប់មកហើយថា សេចក្ដីនេះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ។ សូត្រទី ៦ ។

(៦៦) ខ្ញុំបានស្ដាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ សោចេយ្យៈ (សេចក្ដីស្អាត) នេះ មាន ៣ ។ សោចេយ្យៈ ៣ តើអ្វីខ្លះ ។ គឺ កាយសោចេយ្យៈ ១ វចីសោចេយ្យៈ ១ មនោសោចេយ្យៈ ១ ។ ម្នាលភិក្ខុទាំងឡាយ សោចេយ្យៈ មាន ៣ នេះឯង ។ លុះព្រះមានព្រះភាគទ្រង់សំដែងសេចក្ដីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

(ពួកព្រះអរិយៈមានព្រះពុទ្ធជាដើម) តែងហៅនូវបុគ្គលអ្នក
ស្អាតកាយ ស្អាតវាចា ស្អាតចិត្ត មិនមានអាសវៈ លះបង់នូវ
ទុច្ចរិតទាំងពួង ថាជាអ្នកស្អាត បរិបូណ៌ដោយសេចក្ដីស្អាត ។

ខ្ញុំបានស្ដាប់មកហើយថា សេចក្ដីនេះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ។ សូត្រទី ៧ ។

(៦៧) ខ្ញុំបានស្ដាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ មោនេយ្យៈ (ការស្ងប់ស្ងៀម) នេះ មាន ៣ ។ មោនេយ្យៈ ៣ តើអ្វីខ្លះ ។

កាយមោនេយ្យំ វចីមោនេយ្យំ មនោមោនេយ្យំ ។

ឥមានិ ខោ ភិក្ខវេ តីណិ មោនេយ្យានីតិ ។ ឯតមត្ថំ

ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

កាយមុនឹ(១) វាចាមុនឹ(២) មនោមុនិមនាសវំ

មុនឹ(៣) មោនេយ្យសម្បន្នំ អាហុ និន្ហាតបាបកន្តិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

អដ្ឋមំ(៤) ។

---

១-២-៣ ឱ. ម. មុនិ ។ ៤ ឱ. ម. អដ្ឋមន្តិ ខត្តិ ។

តិកាយមោនេយ្យៈ(១) ១ វចីមោនេយ្យៈ(២) ១ មនោមោនេយ្យៈ(៣) ១ ។ ម្នាលភិក្ខុទាំងឡាយ មោនេយ្យៈ មាន ៣ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

(ពួកព្រះអរិយៈមានព្រះពុទ្ធជាដើម) តែងហៅនូវបុគ្គល
អ្នកស្ងប់ស្ងៀមកាយ ស្ងប់ស្ងៀមវាចា ស្ងប់ស្ងៀមចិត្ត
មិនមានអាសវៈ អ្នកលាងមន្ទិលដំណាមក ហោលហើយ
ថាជាអ្នកស្ងប់ស្ងៀម បរិបូណ៌ដោយការស្ងប់ស្ងៀម ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយ ។ សូត្រ ទី ៨ ។

---

១ ការលះនូវកាយទុច្ចរិត ៣ ហៅថា កាយមោនេយ្យៈ កាយសុចរិត ៣ យ៉ាង ក៏ហៅថា កាយមោនេយ្យៈ ការដឹងអារម្មណ៍ដោយកាយ ហៅថា កាយមោនេយ្យៈ ការកំណត់ដឹងដោយកាយ ហៅថា កាយមោនេយ្យៈ មគ្គប្រកបដោយការកំណត់ដឹងដោយកាយ ហៅថា កាយ-មោនេយ្យៈ ការលះនូវឆន្ទរាគក្នុងកាយ ហៅថា កាយមោនេយ្យៈ ចតុត្ថជ្ឈានសមាបត្តិ ដែលរលត់កាយសង្ខារ ហៅថា កាយមោនេយ្យ ។ ២-៣ វចីមោនេយ្យ មនោមោនេយ្យ សេចក្តីដូចគ្នានឹងកាយមោនេយ្យ ។ អដ្ឋកថា ។

(៦៨) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ យស្ស កស្សចិ ភិក្ខវេ រាគោ អប្បហីនោ ទោសោ អប្បហីនោ មោហោ អប្បហីនោ អយំ វុច្ចតិ ភិក្ខវេ ពទ្ធោ មារស្ស បដិមុក្កស្ស មារៈបាសោ យថាកាមករណីយោ ច បាបិមតោ ។ យស្ស កស្សចិ ភិក្ខវេ រាគោ បហីនោ ទោសោ បហីនោ មោហោ បហីនោ អយំ វុច្ចតិ ភិក្ខវេ អពទ្ធោ មារស្ស ឱមុក្កស្ស មារបាសោ ន យថាកាមករណីយោ ច បាបិមតោតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

យស្ស រាគោ ច ទោសោ ច អវិជ្ជា ច វិរាជិតា
តំ ភាវិតត្តញ្ញតរំ ព្រហ្មភូតំ តថាគតំ
ពុទ្ធំ វេរភយាតីតំ អាហុ សព្វប្បហាយិនន្តិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។ នវមំ(១) ។

---

១ ឱ. ម. នវមន្តិ នត្ថិ ។

(៦៨) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ មិនបានលះរាគៈ មិនបានលះទោសៈ មិនបានលះមោហៈទេ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ ហៅថា ជាអ្នកត្រូវមារចងបានផង ត្រូវអន្ទាក់មារបញ្ចូលហើយផង ជាអ្នកត្រូវមារមានចិត្តបាបធ្វើបានតាមប្រាថ្នាផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ បានលះរាគៈ លះទោសៈ លះមោហៈ ហើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ ហៅថា ជាអ្នកមិនត្រូវមារចងបានផង អន្ទាក់របស់មារក៏ផ្ទោះចេញផង មារមានចិត្តបាបធ្វើមិនបានតាមប្រាថ្នាផង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលណា ឃ្លាតចេញចាករាគៈផង ទោសៈផង អវិជ្ជាផង
ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម តែងហៅ នូវ
បុគ្គល អ្នកមានខ្លួនចំរើនហើយ លះបង់នូវកិលេស
ទាំងពួងនោះថា ជាអរហន្ត ជាព្រហ្ម ជាព្រះតថាគត
ជាព្រះពុទ្ធ អ្នកកន្លងបង់ នូវពៀរនិងភ័យ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ។ សូត្រ ទី៩ ។

(៦៩) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ យស្ស កស្សចិ ភិក្ខវេ ភិក្ខុស្ស វា ភិក្ខុនិយា វា រាគោ អប្បហីនោ ទោសោ អប្បហីនោ មោហោ អប្បហីនោ អយំ វុច្ចតិ ភិក្ខវេ ន អតរិ សមុទ្ទំ សឧម្មឹ សវីចឹ សាវដ្ដំ សគហំ សរក្ខសំ ។ យស្ស កស្សចិ ភិក្ខវេ ភិក្ខុស្ស វា ភិក្ខុនិយា វា រាគោ បហីនោ ទោសោ បហីនោ មោហោ បហីនោ អយំ វុច្ចតិ ភិក្ខវេ(១) អតរិ សមុទ្ទំ សឧម្មឹ សវីចឹ សាវដ្ដំ សគហំ សរក្ខសំ តិណ្ណោ បារគតោ ថលេ តិដ្ឋតិ ព្រាហ្មណោតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

---

១ ម. ភិក្ខវេ តិណ្ណោ ។

[៦៩] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ទោះជាភិក្ខុក្តី ភិក្ខុនីក្តី មិនបានលះរាគៈ មិនបានលះទោសៈ មិនបានលះមោហៈទេ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ ហៅថា មិនបានឆ្លងនូវសមុទ្រ (គឺសំសារ) ដែលប្រកបដោយរលកធំ ប្រកបដោយរលកតូច (គឺសេចក្តីក្រោធនិងឧបាយាសៈ) ប្រកបដោយអាវដ្តៈ (គឺកាមគុណ ៥) ប្រកបដោយការចាប់ ទាំងប្រកបដោយអារក្ខទឹក (គឺវិសភាគបុគ្គលដែលប្រាកដស្មើដោយមករកាចនិង(ត្រីកាច) ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ទោះជាភិក្ខុក្តី ភិក្ខុនីក្តី បានលះរាគៈ លះទោសៈ លះមោហៈ ហើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ ហៅថា បានឆ្លងសមុទ្រ ដែលប្រកបដោយរលកធំ ប្រកបដោយរលកតូច ប្រកបដោយអាវដ្តៈ ប្រកបដោយការចាប់ ទាំងប្រកបដោយអារក្ខទឹក បានឈ្មោះថា ខីណាសវព្រាហ្មណ៍ បានឆ្លងទៅកាន់ត្រើយខាងនាយ ហើយឋិតនៅលើគោក(គឺព្រះនិព្វាន) ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

យស្ស រាគោ ច ទោសោ ច អវិជ្ជា ច វិរាជិតា

សោ ឥមំ សមុទ្ទំ សគហំ សរក្ខសំ

សឩម្មិភយំ[១] ទុត្តរំ អច្ចតារិ[២]

សង្គាតិគោ មច្ចុជហោ និរូបធិ

បហាសិ ទុក្ខំ អបុនព្ភវាយ

អត្ថង្គតោ សោ ន បមាណមេតិ

អមោហយិ មច្ចុរាជន្តិ ព្រូមីតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ទសមំ[៣] ។

ទុតិយវគ្គោ ។

## តស្សុទ្ទានំ

បុញ្ញំ ចក្ខុ អថិន្ទ្រិយា

អទ្ធា ចរិតំ ទុវេ សុចិ

មុនេ អជ រាគ ទុវេ

បុន វគ្គមាហុ ទុតិយមុត្តមន្តិ ។

---

១ ឱ. ឩមិភយំ ។ ប. សូមិភយំ ។ ២ ឱ. ទុត្តរមច្ចតារិ ។ ម. ទុត្តរមច្ចហារិ ។

៣ ឱ.ម. ទសមន្តិ ទត្តិ ។

បុគ្គលណា ឃ្លាតចាករាគៈផង ទោសៈផង អវិជ្ជាផង បុគ្គលនោះ ឈ្មោះថា បានឆ្លងនូវសមុទ្រនេះ ដែលប្រកបដោយត្រីចាប់ ប្រកបដោយត្រីរាក្ខស ទាំងប្រកបដោយរលកដ៏គួរខ្លាច ដែលឆ្លងបានដោយកម្រ ជាអ្នកកន្លងនូវកិលេសជាគ្រឿងជាប់ចំពាក់ លះបង់មច្ចុ មិនមានឧបធិ បានលះបង់ទុក្ខ ដើម្បីមិនទៅកើត ក្នុងភពថ្មីទៀត បុគ្គលនោះ ឈ្មោះថា សម្រេចប្រយោជន៍ គឺព្រះនិព្វាន រមែងមិនដល់ នូវការរាប់ដោយ ( នាមនិងគោត្ត ) ឡើយ តថាគតពោលថា បុគ្គលនោះ បានញុំាងមច្ចុរាជឲ្យវង្វេង ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ។ សូត្រទី ១០ ។

ចប់វគ្គទី ២ ។

## ឧទ្ទាននៃទុតិយវគ្គនោះគឺ

និយាយអំពីបុញ្ញកិរិយាវត្ថុ ១ ចក្ខុ ១
ឥន្ទ្រិយ ១ កាល ១ ចរិត ២ លើក
សេចក្តីស្អាត ១ ការស្ងប់ស្ងៀម ១ រាគៈ ២ លើក
លោកពោលនូវវគ្គទីពីរ ជាវគ្គដ៏ឧត្តម ។

# ឥតិវុត្តកេ តិកនិបាតស្ស តតិយវគ្គោ

(៧០) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ទិដ្ឋា មយា ភិក្ខវេ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា តំ ខោ បនាហំ ភិក្ខវេ នាញ្ញស្ស សមណស្ស វា ព្រាហ្មណស្ស វា សុត្វា វទាមិ ទិដ្ឋា មយា ភិក្ខវេ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា អបិច ភិក្ខវេ យទេវ សាមំ ញាតំ សាមំ ទិដ្ឋំ សាមំ វិទិតំ តទេវាហំ វទាមិ ទិដ្ឋា មយា ភិក្ខវេ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នាតិ ។

# ឥតិវុត្តកៈ តិកនិបាត តតិយវគ្គ

(៧០) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញពួកសត្វ ដែលប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលពួកព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ សមាទាននូវអំពើជាមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយពងកាយស្លាប់ទៅ តែងកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនឮសេចក្តីនោះ (អំពីសំណាក់) នៃសមណៈ ឬព្រាហ្មណ៍ដទៃហើយពោលទេ ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញ ពួកសត្វដែលប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលពួកព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ សមាទាននូវអំពើជាមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយពងកាយ ស្លាប់ទៅ តែងកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ម្នាលភិក្ខុទាំងឡាយ លុះតែហេតុណាដែលតថាគត ដឹងដោយខ្លួនឯង ឃើញដោយខ្លួនឯង ជ្រាបច្បាស់ដោយខ្លួនឯង ទើបតថាគតពោល នូវហេតុនោះថា ម្នាលភិក្ខុទាំងឡាយ តថាគត បានឃើញពួកសត្វ ដែលប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលពួកព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ សមាទាននូវអំពើជាមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយពងកាយស្លាប់ទៅ តែងកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។

ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

មិច្ឆាមនំ បណិធាយ  មិច្ឆាវាចំ អភាសិយ
មិច្ឆាកម្មានិ កត្វាន  កាយេន ឥធ បុគ្គលោ
អប្បស្សុតោ អបុញ្ញករោ  អប្បស្មឹ ឥធ ជីវិតេ
កាយស្ស ភេទា ទុប្បញ្ញោ  និរយំ សោ ឧបបជ្ជតីតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។
បឋមំ[១] ។

(៧៨) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ទិដ្ឋា មយា ភិក្ខវេ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នា តំ ខោ បនាហំ ភិក្ខវេ នាញ្ញស្ស សមណស្ស វា ព្រាហ្មណស្ស វា សុត្វា វទាមិ ទិដ្ឋា មយា ភិក្ខវេ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា

១ ឱ.ម. បឋមន្តិ ឥត្ថិ ។

លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្ដីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលក្នុងលោកនេះ ជាអ្នកស្ដាប់តិច មិនបានធ្វើបុណ្យ
ដំកល់ចិត្តខុសពោលវាចាខុស ធ្វើការងារខុសដោយកាយ
បុគ្គលនោះជាអ្នកឥតប្រាជ្ញា លុះបែកធ្លាយរាងកាយស្លាប់ទៅ
ព្រោះជីវិតក្នុងមនុស្សលោកនេះតិចណាស់ រមែងកើតក្នុងនរក ។

ខ្ញុំបានស្ដាប់មកហើយថា សេចក្ដីនេះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយ ។ សូត្រទី ១ ។

(៧១) ខ្ញុំបានស្ដាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញពួកសត្វដែលប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលពួកព្រះអរិយៈ ជាសម្មាទិដ្ឋិ សមាទានទូវអំពើជាសម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិ សួគ៌ ទេវលោក ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនឮសេចក្ដីនោះ(អំពីសំណាក់) នៃសមណៈ ឬព្រាហ្មណ៍ដទៃ ហើយពោលទេ ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញពួកសត្វ ដែលប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលពួកព្រះអរិយៈ ជាសម្មាទិដ្ឋិ សមាទានទូវអំពើជាសម្មាទិដ្ឋិ

## ឥតិវុត្តកេ តិកនិបាតស្ស តតិយវគ្គស្ស ទុតិយសុត្តំ

តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នា អបិ ច យេនេវ ភិក្ខវេ សាមំ ញាតំ សាមំ ទិដ្ឋំ សាមំ វិទិតំ តមេវាហំ វទាមិ ទិដ្ឋា មយា ភិក្ខវេ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

សម្មាមនំ បណិធាយ សម្មាវាចំ អភាសិយ
សម្មាកម្មានិ កត្វាន កាយេន ឥធ បុគ្គលោ
ពហុស្សុតោ បុញ្ញការោ អប្បស្មឹ ឥធ ជីវិតេ
កាយស្ស ភេទា សប្បញ្ញោ សគ្គំ សោ ឧបបជ្ជតីតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ទុតិយំ[១] ។

---

១ ឱ. ម. ទុតិយន្តិ ឥត្ថំ ។

សត្វទាំងនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ តែងកើតក្នុងសុគតិ សួគ៌ ទេវលោក ម្នាលភិក្ខុទាំងឡាយ លុះតែហេតុណាដែលតថាគត បានដឹងដោយខ្លួនឯង បានឃើញដោយខ្លួនឯង ជ្រាបច្បាស់ដោយខ្លួនឯងពិតមែន ទើបតថាគត ពោលនូវហេតុនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញពួកសត្វ ដែលប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលពួកព្រះអរិយៈ ជាសម្មាទិដ្ឋិ សមាទាននូវអំពើជាសម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ តែងកើតក្នុងសុគតិ សួគ៌ ទេវលោក ។ លុះព្រះមានព្រះភាគទ្រង់សំដែងសេចក្ដីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលក្នុងលោកនេះ ជាពហុស្សុត បានធ្វើបុណ្យ តម្កល់ចិត្តត្រូវ
ពោលវាចាត្រូវ ធ្វើការងារត្រូវដោយកាយ បុគ្គលនោះប្រកប
ដោយបញ្ញា លុះបែកធ្លាយរាងកាយ ស្លាប់ទៅ ព្រោះជីវិត
ក្នុងមនុស្សលោកនេះតិចណាស់ រមែងទៅកើតក្នុងឋានសួគ៌ ។

ខ្ញុំបានស្ដាប់មកហើយថា សេចក្ដីនេះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ។ សូត្រ ទី ២ ។

(៧២) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តិស្សោ ឥមា ភិក្ខវេ និស្សរណិយា ធាតុយោ ។ កតមា តិស្សោ ។ កាមានមេតំ និស្សរណំ យទិទំ នេក្ខម្មំ រូបានមេតំ និស្សរណំ យទិទំ អារុប្បំ យំ ខោ បន កិញ្ចិ ភូតំ សង្ខតំ បដិច្ចសមុប្បន្នំ និរោធោ តស្ស និស្សរណំ[១] ។ ឥមា ខោ ភិក្ខវេ តិស្សោ និស្សរណិយា ធាតុយោតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

កាមនិស្សរណំ ញត្វា រូបានញ្ច អតិក្កមំ[២]
សព្វសង្ខារសមថំ ផុសំ អាតាបិ សព្វទា
ស វេ សម្មទ្ទសោ ភិក្ខុ យតោ តត្ថ វិមុច្ចតិ
អភិញ្ញាវោសិតោ សន្តោ ស វេ យោគាតិគោ មុនីតិ ។

---

១ ម. និរោធស្ស និស្សរណន្តិ ទិស្សតិ ។ ២ ឱ.ម. អតិក្កមំ ។

(៧២) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ធាតុជាគ្រឿងរលាស់ចេញនេះ មាន ៣ ។ ធាតុ ជាគ្រឿងរលាស់ចេញ ៣ តើអ្វីខ្លះ ។ ការរលាស់ចេញចាកកាមទាំងឡាយនេះ បានដល់នេក្ខម្មៈ គឺបឋមជ្ឈាន ១ ការរលាស់ចេញចាករូបធម៌ទាំងឡាយនេះ បានដល់អរូបជ្ឈាន ១ ធម្មជាតណាមួយ ដែលកើតហើយ ដែលបច្ច័យតាក់តែងហើយ ដែលកើតឡើងព្រោះអាស្រ័យហេតុ ការរលត់គឺព្រះនិព្វានជាគ្រឿងរលាស់ចេញចាកធម្មជាតនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ ធាតុជាគ្រឿងរលាស់ចេញ មាន ៣ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

(ភិក្ខុណា) ដឹងនូវការរលាស់ចេញចាកកាមផង ដឹងនូវ
ឧបាយជាគ្រឿងកន្លងរូបធម៌ទាំងឡាយផង កាលពាល់ត្រូវ
ព្រះនិព្វាន ជាទីរម្ងាប់នូវសង្ខារទាំងពួង ជាអ្នកមានព្យាយាម
ជាគ្រឿងដុតកំដៅកិលេស សព្វ ៗ កាល ភិក្ខុនោះ ឈ្មោះថា
ជាអ្នកឃើញដោយប្រពៃ ជាអ្នកសង្រួម រមែងចុះចិត្តស៊ប់
ក្នុងព្រះនិព្វាន ជាទីរម្ងាប់នូវសង្ខារទាំងពួងនោះ ភិក្ខុនោះ ជា
អ្នកមានព្រហ្មចរិយធម៌នៅរួចហើយ ជាអ្នកស្ងប់រម្ងាប់ ព្រោះ
ដឹងច្បាស់ ឈ្មោះថា អ្នកប្រាជ្ញ អ្នកប្រព្រឹត្តកន្លងនូវយោគៈ ។

## សុត្តន្តបិដកេ តិកនិបាតស្ស តតិយវគ្គស្ស បឋមសុត្តំ

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

តតិយំ (១) ។

(៧៣) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ រូបេហិ ភិក្ខវេ អរូបា សន្តតរា អរូបេហិ និរោធោ សន្តតរោតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

យេ ច រូបូបគា សត្តា យេ ច អរូបដ្ឋាយិនោ
និរោធំ អប្បជានន្តា អាគន្តារោ បុនព្ភវំ ។
យេ ច រូបេ បរិញ្ញាយ អរូបេសុ អសណ្ឋិតា
និរោធេ យេ វិមុច្ចន្តិ តេ ជនា មច្ចុហាយិនោ ។
កាយេន អមតំ ធាតុំ ផុសយិត្វា និរូបធិ (២)
ឧបធិប្បដិនិស្សគ្គំ សច្ឆិកត្វា អនាសវោ
ទេសេតិ សម្មាសម្ពុទ្ធោ អសោកំ វិរជំ បទន្តិ (៣) ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ចតុត្ថំ (៤) ។

---

១ ឱ. ម. តតិយន្តំ នត្ថិ ។ ២ ឱ.ម. និរូបធឹ ។ ៣ ម. បដន្តិ ។ ៤ ឱ. ម. បឋមន្តំ នត្ថិ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ។ សូត្រ ទី ៣ ។

[៧៣] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អរូបជ្ឈានជាធម្មជាតល្អិតជាងរូបជ្ឈានទាំងឡាយ និរោធជាសភាពល្អិតលើសជាងអរូបជ្ឈានទាំងឡាយ ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ពួកសត្វណា ដែលទៅកាន់រូបភពក្តី ពួកសត្វណា ដែលតាំងនៅក្នុងអរូបភពក្តី (សត្វទាំងនោះ) មិនដឹងច្បាស់នូវនិរោធ ជាអ្នកមកកាន់ភពថ្មីទៀត ។ ពួកជនណា កំណត់ដឹងនូវរូបភពទាំងឡាយក្តី មិនតាំងនៅក្នុងអរូបភពទាំងឡាយក្តី ហើយចុះចិត្តស៊ប់ ក្នុងនិរោធ ពួកជននោះ ឈ្មោះថា អ្នកមានមច្ចុសាបសូន្យហើយ ។ ព្រះសម្មាសម្ពុទ្ធ ព្រះអង្គបាននូវអមតធាតុ ដោយនាមកាយ ព្រះអង្គមិនមានឧបធិ បានធ្វើឲ្យជាក់ច្បាស់នូវធម៌ ជាគ្រឿងរលាស់ចេញចាកឧបធិ ព្រះអង្គមិនមានអាសវៈ ទ្រង់សំដែងនូវបទដែលមិនមានសោក មិនមានធូលី ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានទ្រង់ត្រាស់ទុកហើយ ។ សូត្រ ទី ៤ ។

(៧៤) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តយោមេ ភិក្ខវេ បុត្តា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ អតិជាតោ អនុជាតោ អវជាតោតិ ។ កថញ្ច ភិក្ខវេ បុត្តោ អតិជាតោ ហោតិ ។ ឥធ ភិក្ខវេ បុត្តស្ស មាតាបិតរោ ហោន្តិ ន ពុទ្ធំ សរណំ គតា ន ធម្មំ សរណំ គតា ន សង្ឃំ សរណំ គតា បាណាតិបាតា អប្បដិវិរតា អទិន្នាទានា អប្បដិវិរតា កាមេសុ មិច្ឆាចារា អប្បដិវិរតា មុសាវាទា អប្បដិវិរតា សុរាមេរយមជ្ជប្បមាទដ្ឋានា អប្បដិវិរតា ទុស្សីលា បាបធម្មា បុត្តោ ច នេសំ ហោតិ ពុទ្ធំ សរណំ គតោ ធម្មំ សរណំ គតោ សង្ឃំ សរណំ គតោ បាណាតិបាតា បដិវិរតោ អទិន្នាទានា បដិវិរតោ កាមេសុ មិច្ឆាចារា បដិវិរតោ មុសាវាទា បដិវិរតោ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ សីលវា កល្យាណធម្មោ ឯវំ ខោ ភិក្ខវេ បុត្តោ អតិជាតោ ហោតិ ។ កថញ្ច ភិក្ខវេ បុត្តោ អនុជាតោ ហោតិ ។ ឥធ ភិក្ខវេ បុត្តស្ស មាតាបិតរោ ហោន្តិ

(៧៤) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុត្ត ៣ នេះ រមែងមានប្រាកដ ក្នុងលោក ។ បុត្ត ៣ តើអ្វីខ្លះ ។ គឺអតិជាតបុត្ត ១ អនុជាតបុត្ត ១• អវជាតបុត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ អតិជាតបុត្តតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតាបិតារបស់បុត្ត ក្នុងលោកនេះ ជាអ្នកមិនដល់ព្រះពុទ្ធជាទីពឹង មិនដល់ព្រះធម៌ជាទីពឹង មិនដល់ព្រះសង្ឃជាទីពឹង មិនវៀរចាកបាណាតិបាត មិនវៀរចាកអទិន្នាទាន មិនវៀរចាកកាមេសុមិច្ឆាចារ មិនវៀរចាកមុសាវាទ មិនវៀរចាកសុរាមេរយៈមជ្ជប្បមាទដ្ឋាន ជាបុគ្គលទ្រុស្តសីល ជាអ្នកមានធម៌ដ៏លាមក ទើបឯកូនរបស់មាតាបិតាទាំងនោះ ជាអ្នកដល់ព្រះពុទ្ធជាទីពឹង ដល់ព្រះធម៌ជាទីពឹង ដល់ព្រះសង្ឃជាទីពឹង វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ជាអ្នកមានសីល មានកល្យាណធម៌ ម្នាលភិក្ខុទាំងឡាយ កូនយ៉ាងនេះឯង ឈ្មោះថាអតិជាតបុត្ត ។ ម្នាលភិក្ខុទាំងឡាយ អនុជាតបុត្តតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតាបិតារបស់បុត្ត ក្នុងលោកនេះ

ពុទ្ធំ សរណំ គតា ធម្មំ សរណំ គតា សង្ឃំ សរណំ គតា បាណាតិបាតា បដិវិរតា អទិន្នាទានា បដិវិរតា កាមេសុ មិច្ឆាចារា បដិវិរតា មុសាវាទា បដិវិរតា សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតា សីលវន្តោ កល្យាណធម្មា បុត្តោ ច នេសំ ហោតិ ពុទ្ធំ សរណំ គតោ ធម្មំ សរណំ គតោ សង្ឃំ សរណំ គតោ បាណាតិបាតា បដិវិរតោ អទិន្នាទានា បដិវិរតោ កាមេសុ មិច្ឆាចារា បដិវិរតោ មុសាវាទា បដិវិរតោ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ សីលវា កល្យាណធម្មោ ឯវំ ខោ ភិក្ខវេ បុត្តោ អនុជាតោ ហោតិ ។

កថញ្ច ភិក្ខវេ បុត្តោ អវជាតោ ហោតិ ។

ឥធ ភិក្ខវេ បុត្តស្ស មាតាបិតរោ ហោន្តិ ពុទ្ធំ សរណំ គតា ធម្មំ សរណំ គតា សង្ឃំ សរណំ គតា បាណាតិបាតា បដិវិរតា អទិន្នាទានា បដិវិរតា កាមេសុ មិច្ឆាចារា បដិវិរតា មុសាវាទា បដិវិរតា សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតា សីលវន្តោ កល្យាណធម្មា បុត្តោ ច នេសំ ហោតិ ន ពុទ្ធំ សរណំ គតោ ន ធម្មំ សរណំ គតោ ន សង្ឃំ សរណំ គតោ

ដល់ព្រះពុទ្ធជាទីរពឹង ដល់ព្រះធម៌ជាទីរពឹង ដល់ព្រះសង្ឃជាទីរពឹង វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ជាអ្នកមានសីល មានកល្យាណធម៌ ទើបឯកូនរបស់មាតាបិតាទាំងនោះ ដល់ព្រះពុទ្ធជាទីរពឹង ដល់ព្រះធម៌ជាទីរពឹង ដល់ព្រះសង្ឃជាទីរពឹង វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ជាអ្នកមានសីល មានកល្យាណធម៌ដែរ ម្នាលភិក្ខុទាំងឡាយ កូនយ៉ាងនេះឯង ឈ្មោះថា អនុជាតបុត្ត ។ ម្នាលភិក្ខុទាំងឡាយ អវជាតបុត្ត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតាបិតារបស់បុត្ត ក្នុងលោកនេះ ដល់ព្រះពុទ្ធជាទីរពឹង ដល់ព្រះធម៌ជាទីរពឹង ដល់ព្រះសង្ឃជាទីរពឹង វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ជាអ្នកមានសីល មានកល្យាណធម៌ ទើបកូនរបស់មាតាបិតាទាំងនោះ មិនដល់ព្រះពុទ្ធជាទីរពឹង មិនដល់ព្រះធម៌ជាទីរពឹង មិនដល់ព្រះសង្ឃជាទីរពឹង

បាណាតិបាតា អប្បដិវិរតោ អទិន្នាទានា អប្បដិវិរតោ
កាមេសុ មិច្ឆាចារា អប្បដិវិរតោ មុសាវាទា អប្ប-
ដិវិរតោ សុរាមេរយមជ្ជប្បមាទដ្ឋានា អប្បដិវិរតោ
ទុស្សីលោ បាបធម្មោ ឯវំ ខោ ភិក្ខវេ បុត្តោ
អវជាតោ ហោតិ ។ ឥមេ ខោ ភិក្ខវេ តយោ
បុត្តា សន្តោ សំវិជ្ជមានា លោកស្មិំ ។ ឯតមត្ថំ
ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

អតិជាតំ អនុជាតំ បុត្តមិច្ឆន្តិ បណ្ឌិតា
អវជាតំ ន ឥច្ឆន្តិ យោ ហោតិ កុលគន្ធនោ(១) ។
ឯតេ ខោ បុត្តា លោកស្មិំ យេ ច(២) ភវន្តិ ឧបាសកា
សទ្ធា សីលេន សម្បន្នា វទញ្ញូ វីតមច្ឆរា
ចន្ទោ អព្ភឃនា មុត្តោ បរិសាសុ វិរោចរេតិ ។
អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។
បញ្ចមំ(៣) ។

---

១ កុលគន្ធនោតិបិ បាឋោ ។ ២ ឱ. ម. ចសទ្ទោ នត្ថិ ។ ៣ ឱ. ម. បញ្ចមន្តិ នត្ថិ ។

មិនវៀរចាកបាណាតិបាត មិនវៀរចាកអទិន្នាទាន មិនវៀរចាកកាមេសុមិច្ឆាចារ មិនវៀរចាកមុសាវាទ មិនវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ជាអ្នកទ្រុស្តសីល មានធម៌លាមក ម្នាលភិក្ខុទាំងឡាយ កូនយ៉ាងនេះឯង ឈ្មោះថា អវជាតបុត្ត ។ ម្នាលភិក្ខុទាំងឡាយ កូន ៣ នេះ រមែងមាន ប្រាកដក្នុងលោក ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បណ្ឌិតទាំងឡាយ តែងប្រាថ្នាអតិជាតបុត្ត នឹងអនុជាតបុត្ត
មិនប្រាថ្នាអវជាតបុត្ត ដែលជាកូនផ្តាច់បង់ត្រកូលឡើយ ។
កូនទាំងនេះឯង តែងមានក្នុងលោក ម្យ៉ាងទៀត កូនទាំងឡាយ
ណា ជាឧបាសក (កូនទាំងនោះ) ឈ្មោះថាជាអ្នកបរិបូណ៌
ដោយសទ្ធា នឹងសីល ជាអ្នកដឹងពាក្យពេចន៍ ជាអ្នកប្រាស
ចាកសេចក្តីកំណាញ់ រមែងរុងរឿងក្នុងពួកបរិស័ទ ដូចជា
ព្រះចន្ទ្រ ដែលផុតស្រឡះហើយ ចាកដុំនៃពពក ដូច្នោះ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បាន ត្រាស់ទុកហើយ ។ សូត្រទី ៥ ។

ឥតិវុត្តកេ តិកនិបាតស្ស តតិយវគ្គស្ស ឆដ្ឋសុត្តំ

(៧៨) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តយោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ អវុដ្ឋិកសមោ បទេសវស្សី សព្វត្ថាភិវស្សី ។ កថញ្ច ភិក្ខវេ បុគ្គលោ អវុដ្ឋិកសមោ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សព្វេសញ្ញេវ ន ទាតា ហោតិ សមណព្រាហ្មណកបណទ្ធិកវណិព្វកយាចកានំ អន្នំ បានំ វត្ថំ យានំ មាលាគន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ ឯវំ ខោ ភិក្ខវេ បុគ្គលោ អវុដ្ឋិកសមោ ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ បទេសវស្សី ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ឯកច្ចានំ ទាតា ហោតិ ឯកច្ចានំ ន ទាតា (១) សមណព្រាហ្មណ-កបណទ្ធិកវណិព្វកយាចកានំ អន្នំ បានំ វត្ថំ យានំ មាលាគន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ

---

១ ឱ.ម. ឯត្តក្តរេ ហោតីតិ អត្ថិ ។

(៧៤) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមានប្រាកដ ក្នុងលោក ។ បុគ្គល ៣ ពួក តើដូចម្តេចខ្លះ ។ គឺ បុគ្គលស្មើដោយមេឃមិនបង្អុរភ្លៀងចុះ ១ បុគ្គលស្មើដោយមេឃដែលបង្អុរភ្លៀងចុះត្រង់ប្រទេសមួយៗ ១ បុគ្គលស្មើដោយមេឃដែលបង្អុរភ្លៀងចុះសព្វប្រទេស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលស្មើដោយមេឃមិនបង្អុរភ្លៀងចុះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមិនដែលឲ្យបាយ ទឹក សំពត់ យានជំនិះ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ និងគ្រឿងសម្រាប់ប្រទីប ដល់ពួកសមណៈ ព្រាហ្មណ៍ អ្នកកំព្រា អ្នកដំណើរ និងអ្នកពណ៌នាហើយសូម និងយាចកទាំងពួង ដល់ម្តងឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលស្មើដោយមេឃមិនបង្អុរភ្លៀងចុះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលស្មើដោយមេឃបង្អុរភ្លៀងចុះ ត្រង់ប្រទេសមួយៗ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកឲ្យបាយ ទឹក សំពត់ យានជំនិះ ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ និងគ្រឿងសម្រាប់ប្រទីប ដល់ពួកសមណៈ ព្រាហ្មណ៍ អ្នកកំព្រា អ្នកដំណើរ អ្នកពណ៌នាហើយសូម និងយាចកពួកខ្លះ មិនឲ្យបានដល់សមណៈ ព្រាហ្មណ៍ពួកខ្លះ

ឯវំ ខោ ភិក្ខវេ បុគ្គលោ បទេសវស្សី ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ សព្វត្ថាភិវស្សី ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សព្វេសំ ទេតិ សមណព្រាហ្មណកបណទ្ធិកវណិព្វកយាចកានំ អន្នំ បានំ វត្ថំ យានំ មាលាគន្ធំ វិលេបនំ សេយ្យាវសថបទីបេយ្យំ ឯវំ ខោ ភិក្ខវេ បុគ្គលោ សព្វត្ថាភិវស្សី ហោតិ ។ ឥមេ ខោ ភិក្ខវេ តយោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

ន សមណេ ន ព្រាហ្មណេ ន កបណទ្ធិកេ ន វណិព្វកេ
លទ្ធាន សំវិភាជេតិ អន្នំ បានញ្ច ភោជនំ
តំ វេ អវុដ្ឋិកសមោតិ អាហុ នំ បុរិសាធមំ[១] ។
ឯកច្ចានំ ន ទទាតិ ឯកច្ចានំ បវេច្ឆតិ
តំ វេ បទេសវស្សីតិ អាហុ មេធាវិនោ ជនា ។

---

១ ម. បុរិសាធម្មំ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលស្មើដោយមេឃ បង្អុរភ្លៀងចុះត្រង់ប្រទេសមួយៗ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលស្មើដោយមេឃ បង្អុរភ្លៀងចុះសព្វប្រទេស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ តែងឲ្យបាយ ទឹក សំពត់ យានជំនិះ ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ នឹងគ្រឿងសម្រាប់ប្រទីប ដល់សមណៈ ព្រាហ្មណ៍ អ្នកកំព្រា អ្នកដំណើរ អ្នកពណិនាហើយសូម នឹងយាចកទាំងពួង ម្នាលភិក្ខុទាំងឡាយ បុគ្គលស្មើដោយមេឃ បង្អុរភ្លៀងចុះសព្វប្រទេស យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះឯង តែងមានប្រាកដ ក្នុងលោក ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនេះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលណា បាននូវសមណៈ បាននូវព្រាហ្មណ៍ បាននូវអ្នក
កំព្រា អ្នកដំណើរ ទាំងបាននូវជនអ្នកពណិនាហើយសូម
ទាំងឡាយ ហើយមិនចាត់ចែងនូវបាយ ទឹក ភោជនបណ្ឌិត
ទាំងឡាយ តែងហៅនូវបុគ្គលដ៏លាមកនោះឯងថា ដូចជា
មេឃ ដែលមិនបង្អុរភ្លៀងចុះ ដូច្នោះ ។ បុគ្គលណា មិន
ឲ្យទាន ដល់សមណៈពួកខ្លះ ឲ្យទានដល់សមណៈពួកខ្លះ ពួក
ជនអ្នកមានប្រាជ្ញា តែងហៅ បុគ្គលនោះឯងថា ដូចជា
មេឃដែលបង្អុរភ្លៀងចុះ ក្នុងប្រទេសមួយ ១ ដូច្នោះ ។

ឥតិវុត្តកេ តិកនិបាតស្ស តតិយវគ្គស្ស សត្តមសុត្តំ

សុភិក្ខវាចោ បុរិសោ សព្វភូតានុកម្បកោ
អាមោទមានោ បកិរេតិ ទេថ ទេថាតិ ភាសតិ
យថាបិ មេឃោ ថនយិត្វា គជ្ជយិត្វា បវស្សតិ
ថលំ និន្នញ្ច បូរេតិ អភិសន្ទន្តោវ(១) វារិនា
ឯវមេវ ឥធេកច្ចោ បុគ្គលោ ហោតិ តាទិសោ
ធម្មេន សំហរិត្វាន ឧដ្ឋានាធិគតំ ធនំ
តប្បេតិ អន្នបានេន សម្មា បត្តេ វនិព្វកេតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។
ឆដ្ឋំ(២) ។

(៧៦) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តីណិមានិ ភិក្ខវេ សុខានិ បត្ថយមានោ សីលំ រក្ខេយ្យ បណ្ឌិតោ ។ កតមានិ តីណិ ។ បសំសា មេ អាគច្ឆតូតិ សីលំ រក្ខេយ្យ បណ្ឌិតោ ភោគា មេ ឧប្បជ្ជន្តូតិ សីលំ រក្ខេយ្យ បណ្ឌិតោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សាមីតិ សីលំ រក្ខេយ្យ បណ្ឌិតោ ។

---

១ ម. វ ។ ២ ឱ.ម ឆដ្ឋិតិ ឥត្ថិ ។

បុរស មានវាចានាំឲ្យបានបាយដោយងាយ មានសេចក្តីអនុគ្រោះសព្វសត្វ មានចិត្តរីករាយ តែងចាត់ចែង (ទេយ្យធម៌) ពោលថា អ្នកទាំងឡាយចូរឲ្យ អ្នកទាំងឡាយចូរឲ្យ ប្រៀបដូច មហាមេឃគ្រហឹម គ្រោមហើយបង្អុរភ្លៀងចុះ ធ្វើទីទួល និងទីទាប បង្ហូរឲ្យពេញដោយទឹក យ៉ាងណាមិញ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសភាពដូច្នោះ បានប្រមូលមក នូវទ្រព្យដែលកើតដោយសេចក្តីព្យាយាមតាមផ្លូវធម៌ ក៏ដប់លៀង ពួកជនអ្នកពណិនាហើយសូម ដែលមកដល់ដោយល្អ ដោយបាយទឹក ក៏យ៉ាងនោះដែរ ៗ ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ៗ សូត្រ ទី ៦ ។

(៧៦) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ៗ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតកាលប្រាថ្នាសេចក្តីសុខ ៣ យ៉ាងនេះ គួរតែរក្សាសីល ៗ សេចក្តីសុខ ៣ យ៉ាង តើដូចម្តេចខ្លះ ៗ គឺបណ្ឌិតគប្បីរក្សាសីល ដោយបំណងថា សូមឲ្យសេចក្តីសរសើរ មកដល់អាត្មាអញ ១ បណ្ឌិតគប្បីរក្សាសីល ដោយបំណងថា សូមឲ្យភោគៈទាំងឡាយ កើតឡើងដល់អាត្មាអញ ១ បណ្ឌិតគប្បីរក្សាសីល ដោយបំណងថា អាត្មាអញលុះដល់បែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតឯសុគតិ សួគ៌ ទេវលោក ១ ៗ

ឥមានិ ខោ ភិក្ខវេ តីណិ សុខានិ បត្ថយមានោ សីលំ រក្ខេយ្យ បណ្ឌិតោតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

សីលំ រក្ខេយ្យ មេធាវី បត្ថយានោ តយោ សុខេ
បសំសំ វិត្តលាភញ្ច បេច្ច សគ្គេ បមោទនំ ។
អករោន្តោបិ ចេ បាបំ ករោន្តមុបសេវតិ
សង្កិយោ ហោតិ បាបស្មឹ អវណ្ណោ ចស្ស រូហតិ ។
យាទិសំ កុរុតេ មិត្តំ យាទិសំ ចូបសេវតិ
ស វេ តាទិសកោ ហោតិ សហវាសោ ហិ តាទិសោ ។
សេវមានោ សេវមានំ សម្ផុដ្ឋោ សម្ផុសំ បរំ
សរោ ទិទ្ធោ កលាបំវ អលិត្តមុបលិម្បតិ ។
ឧបលេបភយា ធីរោ នេវ បាបសខា សិយា ។

ម្នាលភិក្ខុទាំងឡាយ បណ្ឌិតកាលប្រាថ្នាសេចក្ដីសុខ ៣ យ៉ាង នេះឯង គួរតែរក្សាសីល ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្ដីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បណ្ឌិតកាលប្រាថ្នា នូវសេចក្ដីសុខ ៣ យ៉ាង គឺសេចក្ដីសរសើរ១ ការបានទ្រព្យ១ ការលះលោកនេះហើយរីករាយក្នុងស្ថានសួគ៌១ គួរតែរក្សាសីល ។ កាលបើបុគ្គលមិនធ្វើបាបទេ តែទៅសេពគប់នឹងបុគ្គលធ្វើបាប បុគ្គលនោះត្រូវអ្នកផងរង្កៀសព្រោះអំពើអាក្រក់ផង កំណិះដំនៀលរមែងចំរើនឡើងដល់បុគ្គលនោះផង ។ បុគ្គលយកបុគ្គលបែបណាជាមិត្រផង សេពគប់នូវមិត្តបែបណាផង បុគ្គលនោះឯង នឹងប្រាកដស្មើដោយមិត្រនោះៗ ព្រោះការនៅរួម នឹងក្លាយទៅជាបែបគ្នានោះពិត ។ បុគ្គលបាប កាលបើបុគ្គលស្អាតដទៃមកសេពគប់ហើយ បុគ្គលបាបត្រូវបុគ្គលស្អាត (នោះ)មកគប់ប្រសព្វហើយ រមែងប្រឡាក់ នូវបុគ្គលអ្នកមកគប់ប្រសព្វ (នោះ) ដែលគេមិនបានប្រឡាក់ (ដោយបាបធម៌) ផង ដូចព្រួញ ដែលគេលាបថ្នាំពិស កាលប្រឡាក់នូវបំពង់ព្រួញដូច្នោះឯង ។ អ្នកប្រាជ្ញ ព្រោះខ្លាចការប្រឡាក់ (ដោយបាប) ទើបមិនយកនបុគ្គលបាបជាសំឡាញ់ឡើយ ។

ឥតិវុត្តកេ តិកនិបាតស្ស ទុតិយវគ្គស្ស អដ្ឋមសុត្តំ

បូតិមច្ឆំ កុសគ្គេន យោ នរោ ឧបនយ្ហតិ
កុសាបិ បូតិ វាយន្តិ ឯវំ ពាលូបសេវនា ។
តគ្គរញ្ច បលាសេន យោ នរោ ឧបនយ្ហតិ
បត្តាបិ សុរភិ វាយន្តិ ឯវំ ធីរូបសេវនា ។
តស្មា បត្តបុដស្សេវ[១] ញត្វា សម្បាកមត្តនោ
អសន្តេ នុបសេវេយ្យ សន្តេ សេវេយ្យ បណ្ឌិតោ ។
អសន្តោ និរយំ នេន្តិ សន្តោ បាបេន្តិ សុគ្គតិន្តិ ។
អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។
សត្តមំ[២] ។

(៧៧) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ភិជ្ជន្តាយំ[៣] ភិក្ខវេ កាយោ វិញ្ញាណំ វិរាគធម្មំ សព្ពេ ឧបធី អនិច្ចា ទុក្ខា វិបរិណាមធម្មាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

---

១ ឱ.ម. បលាសបុដស្សេវ ។ ២ ឱ.ម. សត្តមន្តិ នត្ថិ ។ ៣ អដ្ឋកថាយំ ភិទុរាយន្តិ ទិស្សតិ ។

នរជនណា ខ្ចប់ត្រីស្អុយ ដោយចុងស្បូវ ស្បូវក៏មានក្លិនស្អុយផ្សាយចេញទៅ យ៉ាងណាមិញ ការសេពគប់នឹងបុគ្គលពាលក៏យ៉ាងនោះដែរ ។ នរជនណា ខ្ចប់ខ្លឹមក្រស្នា ដោយស្លឹកឈើ ស្លឹកឈើ ក៏មានក្លិនក្រអូបផ្សាយទៅ យ៉ាងណាមិញ ការសេពនឹងអ្នកប្រាជ្ញក៏យ៉ាងនោះដែរ ។ ហេតុនោះ បណ្ឌិត ដឹងនូវការសម្រេចនៃផលរបស់ខ្លួន ដូចជាកញ្ចប់នៃស្លឹកឈើហើយ មិនគប្បីសេពគប់ នឹងពួកអសប្បុរសឡើយ គួរសេពគប់តែនឹងពួកសប្បុរស ។ ( ព្រោះ ) ពួកអសប្បុរស តែងនាំទៅកាន់នរក ពួកសប្បុរស តែងញុំាងសត្វឲ្យទៅកាន់ស្ថានសួគ៌ ។ ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ។ សូត្រទី ៧ ។

(៧៧) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ រូបកាយនេះ មានសេចក្តីបែកធ្លាយជាធម្មតា វិញ្ញាណមានការទៅប្រាសជាធម្មតា ឧបធិទាំងពួងជារបស់មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះក្នុងសូត្រនោះថា

កាយញ្ច ភិន្ទន្តំ ញត្វា វិញ្ញាណញ្ចបភង្គុណំ(១)
ឧបធីសុ ភយំ ទិស្វា ជាតិមរណមច្ចគា
សម្បត្វា បរមំ សន្តឹ(២) កាលំ កង្ខតិ ភាវិតត្តោតិ ។
អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

អដ្ឋមំ(៣) ។

(៧៨) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ ធាតុសោវ ភិក្ខវេ សត្តា សត្តេហិ សទ្ធឹ សំសន្ទន្តិ សមេន្តិ ហីនាធិមុត្តិកា សត្តា ហីនាធិមុត្តិកេហិ សត្តេហិ សទ្ធឹ សំសន្ទន្តិ សមេន្តិ កល្យាណាធិមុត្តិកា សត្តា កល្យាណាធិមុត្តិកេហិ សត្តេហិ សទ្ធឹ សំសន្ទន្តិ សមេន្តិ ។ អតីតម្បិ ភិក្ខវេ អទ្ធានំ ធាតុសោវ សត្តា សត្តេហិ សទ្ធឹ សំសន្ទឹសុ សមឹសុ ហីនាធិមុត្តិកា សត្តា ហីនាធិមុត្តិកេហិ សត្តេហិ សទ្ធឹ សំសន្ទឹសុ សមឹសុ កល្យាណាធិមុត្តិកា សត្តា កល្យាណាធិមុត្តិកេហិ សត្តេហិ សទ្ធឹ សំសន្ទឹសុ សមឹសុ ។

---

១ ឱ.ម. វិភង្គុណំ ។ ២ ម. សន្តំ ។ ៣ ឱ.ម. អដ្ឋមត្តិ ឧត្តិ ។

អ្នកប្រាជ្ញមានខ្លួនអប់រំហើយ ដឹងច្បាស់ នូវកាយដែលបែកធ្លាយផង ដឹងច្បាស់ នូវវិញ្ញាណដែលពុកផុយផង ឃើញភ័យ ក្នុងឧបធិទាំងឡាយផង ហើយកន្លងជាតិនិងមរណៈ បានដល់និព្វានជាទីរម្ងាប់សង្ខារទាំងពួង ដ៏ឧត្តម រមែងទ្រទ្រង់ រង់ចាំតែកាល (បរិនិព្វានខន្ធ) ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ។ សូត្រ ទី ៨ ។

(៧៨) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ រមែងប្រហែលគ្នា សេពគ្នា ជាមួយនឹងពួកសត្វ ដោយធាតុដូចគ្នា គឺសត្វដែលមានអធ្យាស្រ័យថោកទាប រមែងប្រហែលគ្នា សេពគ្នា ជាមួយនឹងពួកសត្វដែលមានអធ្យាស្រ័យថោកទាប សត្វដែលមានអធ្យាស្រ័យល្អ រមែងប្រហែលគ្នា សេពគ្នា ជាមួយនឹងពួកសត្វដែលមានអធ្យាស្រ័យល្អ ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ ប្រហែលគ្នា សេពគ្នា ជាមួយនឹងពួកសត្វ ដោយធាតុដូចគ្នា ក្នុងអតីតកាល គឺពួកសត្វ ដែលមានអធ្យាស្រ័យថោកទាប ប្រហែលគ្នា សេពគ្នា ជាមួយនឹងពួកសត្វ ដែលមានអធ្យាស្រ័យថោកទាប សត្វទាំងឡាយ ដែលមានអធ្យាស្រ័យល្អ ប្រហែលគ្នា សេពគ្នា ជាមួយនឹងពួកសត្វដែលមានអធ្យាស្រ័យល្អ ។

អនាគតម្បិ ភិក្ខវេ អទ្ធានំ ធាតុសោវ សត្តា សត្តេហិ សទ្ធឹ សំសន្ទិស្សន្តិ សមេស្សន្តិ ហីនាធិមុត្តិកា សត្តា ហីនាធិមុត្តិកេហិ សត្តេហិ សទ្ធឹ សំសន្ទិស្សន្តិ សមេស្សន្តិ កល្យាណាធិមុត្តិកា សត្តា កល្យាណាធិមុត្តិកេហិ សត្តេហិ សទ្ធឹ សំសន្ទិស្សន្តិ សមេស្សន្តិ ។ ឯតរហិ ភិក្ខវេ បច្ចុប្បន្នំ អទ្ធានំ ធាតុសោវ សត្តា សត្តេហិ សទ្ធឹ សំសន្ទន្តិ សមេន្តិ ហីនាធិមុត្តិកា សត្តា ហីនាធិមុត្តិកេហិ សត្តេហិ សទ្ធឹ សំសន្ទន្តិ សមេន្តិ កល្យាណាធិមុត្តិកា សត្តា កល្យាណាធិមុត្តិកេហិ សត្តេហិ សទ្ធឹ សំសន្ទន្តិ សមេន្តីតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

សំសគ្គា វនថោ(១) ជាតោ អសំសគ្គេន ឆិជ្ជតិ
បរិត្តំ ទារុមារុយ្ហ យថា សីទេ មហណ្ណវេ
ឯវំ កុសីតមាគម្ម សាធុជីវីបិ សីទតិ ។

---

១ ម. បនថោ ។

ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ គង់នឹងប្រហែលគ្នា នឹងស្មើគ្នា ជាមួយនឹងពួកសត្វ ដោយធាតុដូចគ្នា ក្នុងអនាគតកាល គឺពួកសត្វ ដែលមានអធ្យាស្រ័យថោកទាប នឹងប្រហែលគ្នា នឹងស្មើគ្នា ជាមួយនឹងពួកសត្វ ដែលមានអធ្យាស្រ័យថោកទាប ពួកសត្វដែលមានអធ្យាស្រ័យល្អ នឹងប្រហែលគ្នា នឹងស្មើគ្នា ជាមួយនឹងពួកសត្វដែលមានអធ្យាស្រ័យល្អ ៗ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ សត្វទាំងឡាយ រមែងប្រហែលគ្នា ស្មើគ្នា ជាមួយនឹងពួកសត្វ ដោយធាតុដូចគ្នា ក្នុងបច្ចុប្បន្នកាល គឺពួកសត្វ ដែលមានអធ្យាស្រ័យថោកទាប រមែងប្រហែលគ្នា ស្មើគ្នា ជាមួយនឹងពួកសត្វដែលមានអធ្យាស្រ័យថោកទាប ពួកសត្វដែលមានអធ្យាស្រ័យល្អ រមែងប្រហែលគ្នា ស្មើគ្នា ជាមួយនឹងពួកសត្វ ដែលមានអធ្យាស្រ័យល្អ ៗ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុះហើយ ៗ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ព្រៃគឺកិលេសកើតឡើងហើយ ព្រោះតែការជាប់ចំពាក់ ដែល
បុគ្គលនឹងកាត់ផ្តាច់បាន ដោយការមិនជាប់ចំពាក់ បុគ្គលអ្នក
មានប្រាជ្ញានឹងឆ្លងមហាសមុទ្រ ហើយលិចទៅក្នុងមហាសមុទ្រ
វិញ ព្រោះតែឡើងកាន់ក្បូនឈើដ៏តូច យ៉ាងណាមិញ ឯបុគ្គល
អ្នកចិញ្ចឹមជីវិតដោយប្រពៃ រមែងលិចចុះ ក្នុងមហាសមុទ្រគឺ
សង្សារ ព្រោះតែអាស្រ័យនឹងបុគ្គលខ្ជិលច្រអូស យ៉ាងនោះដែរ ៗ

តស្មា តំ បរិវជ្ជេយ្យ កុសីតំ ហីនវីរិយំ
បវិវិត្តេហិ អរិយេហិ បហិតត្តេហិ ឈាយិភិ
និច្ចំ អារទ្ធវីរិយេហិ បណ្ឌិតេហិ សហាវសេតិ ។
អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។
នវមំ[(១)] ។

(៧៩) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តយោមេ ភិក្ខវេ ធម្មា សេក្ខស្ស ភិក្ខុនោ បរិហានាយ សំវត្តន្តិ ។ កតមេ តយោ ។ ឥធ ភិក្ខវេ សេក្ខោ ភិក្ខុ កម្មារាមោ ហោតិ កម្មរតោ កម្មារាមតមនុយុត្តោ ភស្សារាមោ ហោតិ ភស្សរតោ ភស្សារាមតមនុយុត្តោ និទ្ទារាមោ ហោតិ និទ្ទារតោ និទ្ទារាមតមនុយុត្តោ ឥមេ ខោ ភិក្ខវេ តយោ ធម្មា សេក្ខស្ស ភិក្ខុនោ បរិហានាយ សំវត្តន្តិ ។ តយោមេ ភិក្ខវេ ធម្មា សេក្ខស្ស ភិក្ខុនោ អបរិហានាយ សំវត្តន្តិ ។ កតមេ តយោ ។

១ ឱ.ម. នវមន្តិ នត្ថិ ។

ព្រោះហេតុនោះ បុគ្គលគួរវៀរនូវបុគ្គលខ្ជិលនោះ ដែលមានព្យាយាមថោកទាប ហើយគួរនៅរួមដោយបណ្ឌិតទាំងឡាយ ដែលជាអ្នកស្ងាត់ ជាអ្នកឆ្ងាយចាកកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ជាអ្នកមានឈាន អ្នកប្រារព្ធព្យាយាមជានិច្ច ។

ខ្ញុំបានស្ដាប់មកហើយថា សេចក្ដីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៨ ។

(៧៩) ខ្ញុំបានស្ដាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ដ សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ នេះ រមែងប្រព្រឹត្ដទៅ ដើម្បីសេចក្ដីសាបសូន្យដល់សេក្ខភិក្ខុ ។ ធម៌ ៣ តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេក្ខភិក្ខុ ក្នុងសាសនានេះ ជាអ្នកមានការងារ(១) ជាទីត្រេកអរ ត្រេកអរក្នុងការងារ ប្រកបរឿយៗ នូវការងារជាទីត្រេកអរ១ ជាអ្នកមានតិរច្ឆានកថាជាទីត្រេកអរ ត្រេកអរក្នុងតិរច្ឆានកថា ប្រកបរឿយៗ នូវតិរច្ឆានកថាជាទីត្រេកអរ ១ ជាអ្នកមានការដេកលក់ជាទីត្រេកអរ ត្រេកអរក្នុងការដេកលក់ ប្រកបរឿយ ៗ នូវការដេកលក់ជាទីត្រេកអរ ១ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ នេះឯង រមែងប្រព្រឹត្ដទៅ ដើម្បីសេចក្ដីសាបសូន្យដល់សេក្ខភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ នេះ រមែងប្រព្រឹត្ដទៅ ដើម្បីមិនសាបសូន្យដល់សេក្ខភិក្ខុ ។ ធម៌ ៣ តើដូចម្ដេច ។

---

១ សំដៅយកការរវល់ ដេរចីវរ ស្មោកជាត្រជាដើម ។ អដ្ឋកថា ។

ឥធ ភិក្ខវេ សេក្ខោ ភិក្ខុ ន កម្មារាមោ ហោតិ ន កម្មរតោ ន កម្មារាមតមនុយុត្តោ ន ភស្សារាមោ ហោតិ ន ភស្សរតោ ន ភស្សារាមតមនុយុត្តោ ន និទ្ទារាមោ ហោតិ ន និទ្ទារតោ ន និទ្ទារាមតមនុយុត្តោ ឥមេ ខោ ភិក្ខវេ តយោ ធម្មា សេក្ខស្ស ភិក្ខុនោ អបរិហានាយ សំវត្តន្តីតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

កម្មារាមោ ភស្សរតោ និទ្ទារាមោ ច ឧទ្ធតោ
អភព្វោ តាទិសោ ភិក្ខុ ផុដ្ឋុំ សម្ពោធិមុត្តមំ ។
តស្មា ហិ អប្បកិច្ចស្ស[១] អប្បមិទ្ធោ អនុទ្ធតោ
ភព្វោ សោ តាទិសោ ភិក្ខុ ផុដ្ឋុំ សម្ពោធិមុត្តមន្តិ ។
អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ទសមំ[២] ។

តតិយវគ្គោ ។

---

១ ម. អនកិច្ចស្ស ។ ២ ឱ.ម. ទសមត្តិ ឧត្តិ ។

ម្នាលភិក្ខុទាំងឡាយ សេក្ខភិក្ខុ ក្នុងសាសនានេះ ជាអ្នកមិនមានការងារជាទីត្រេកអរ មិនត្រេកអរក្នុងការងារ មិនប្រកបរឿយ ៗ នូវការងារជាទីត្រេកអរ ១ ជាអ្នកមិនមានតិរច្ឆានកថាជាទីត្រេកអរ មិនត្រេកអរក្នុងតិរច្ឆានកថា មិនប្រកបរឿយៗនូវតិរច្ឆានកថា ជាទីត្រេកអរ១ ជាអ្នកមិនមានការដេកលក់ជាទីត្រេកអរ មិនត្រេកអរក្នុងការដេកលក់ មិនប្រកបរឿយៗនូវការដេកលក់ជាទីត្រេកអរ ១ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៣ នេះឯង រមែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់សេក្ខភិក្ខុ ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្ដីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ភិក្ខុអ្នកមានការងារជាទីត្រេកអរផង ត្រេកអរក្នុងតិរច្ឆានកថាផង
មានការដេកលក់ជាទីត្រេកអរផង មានចិត្តរវើរវាយប្រាកដដូច្នោះ
មិនគួរដើម្បីបានសម្ពោធិដ៏ប្រសើរឡើយ ។ ព្រោះហេតុនោះ ភិក្ខុ
នោះគួរជាអ្នកមានកិច្ចការតិច មានការដេកលក់តិច មានចិត្តមិន
រវើរវាយប្រាកដដូច្នោះ ទើបគួរនឹងបានសម្ពោធិដ៏ប្រសើរ ។

ខ្ញុំបានស្ដាប់មកហើយថា សេចក្ដីនេះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ។ សូត្រ ទី ១០ ។

ចប់ ទុតិយវគ្គ ។

## តស្សុទ្ទានំ

ទ្វេ ទិដ្ឋី និស្សរណំ រូបំ

បុត្តោ អវុដ្ឋិកេន ច

សុខា ច ភិន្ទនា ធាតុ

បរិហានេន តេ ទសាតិ ។

# ឧទ្ទាននៃតតិយវគ្គនោះគឺ

និយាយអំពីទិដ្ឋិ ២ លើក និស្សរណីយធាតុ ១ រូបជ្ឈាននឹងអរូបជ្ឈាន ១ បុត្ត ១ បុគ្គលប្រៀបដោយមេឃ មិនបង្អុរភ្លៀង ១ សេចក្តីសុខ ១ ការបែកធ្លាយ ១ ធាតុ ១ សេចក្តីសាបសូន្យ ១ រួមទាំងអស់ ត្រូវជា ១០ ។

# ឥតិវុត្តកេ តិកនិបាតស្ស បឋមវគ្គោ

(៨០) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តយោមេ ភិក្ខវេ អកុសលវិតក្កា ។ កតមេ តយោ ។ អនវញ្ញត្តិប្បដិសំយុត្តោ វិតក្កោ លាភសក្ការសិលោកប្បដិសំយុត្តោ វិតក្កោ បរានុទ្ទយតាបដិសំយុត្តោ វិតក្កោ ។ ឥមេ ខោ ភិក្ខវេ តយោ អកុសលវិតក្កាតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

អនវញ្ញត្តិសញ្ញុត្តោ លាភសក្ការគារវោ
សហនន្ទី អមច្ចេហិ អារា សំយោជនក្ខយា ។
យោ ច(១) បុត្តបសុំ(២) ហិត្វា វិភាហេ(៣) សង្ហរានិ ច
ភព្វោ សោ តាទិសោ ភិក្ខុ ផុដ្ឋុំ សម្ពោធិមុត្តមន្តិ ។

បឋមំ(៤) ។

(៨១) ទិដ្ឋា មយា ភិក្ខវេ សត្តា សក្ការេន អភិភូតា បរិយាទិន្នចិត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតិំ វិនិបាតំ និរយំ ឧបបន្នា

---

១ ឱ.ម យោ ប ។ ២ ម. បុត្តបសុំ ។ ៣ ម វិភាហេ សំហរានិ ច ។ អដ្ឋកថាយំបិ វិភាហេតិ ទិស្សតិ ។ ៤ ឱ.ប. បឋមន្តិ នត្ថិ ។

# ឥតិវុត្តកៈ តិកនិបាត បឋមវគ្គ

(៨០) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អកុសលវិតក្កៈនេះមាន ៣ ។ អកុសលវិតក្ក ៣ តើដូចម្តេចខ្លះ ។ គឺវិតក្កៈដែលប្រកបដោយសេចក្តីប្រាថ្នា មិនឲ្យអ្នកដទៃមើលងាយខ្លួន ១ វិតក្កៈដែលប្រកបដោយលាភសក្ការៈ នឹងសេចក្តីសរសើរ ១ វិតក្កៈដែលប្រកបដោយសេចក្តីអាណិតបគ្គលដទៃ ១ ។ ម្នាលភិក្ខុទាំងឡាយ អកុសលវិតក្កៈ មាន៣ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលណាមួយ ប្រកបដោយសេចក្តីប្រាថ្នា មិនឲ្យអ្នកដទៃមើលងាយខ្លួន ជាអ្នកធ្ងន់ក្នុងលាភ នឹងសក្ការៈ មានសេចក្តីរីករាយ ជាមួយនឹងពួកអមាត្យ បុគ្គលនោះឈ្មោះថា ឆ្ងាយអំពីការអស់ទៅនៃសំយោជនៈ ។ បុគ្គលណាមួយ ក្នុងលោកនេះ លះបង់បុត្តនឹងភរិយាផង លះបង់សត្វចិញ្ចឹមផង លះបង់សេចក្តីសង្គ្រោះ ក្នុងវិវាហៈផង ភិក្ខុប្រាកដដូច្នោះនោះ គួរដើម្បីបាននូវសម្ពោធិដ៏ឧត្តម ។ សូត្រទី ១ ។

(៨១) ម្នាលភិក្ខុទាំងឡាយ តថាគត បានឃើញពួកសត្វដែលត្រូវសក្ការៈ គ្របសង្កត់ហើយ រួបរឹតចិត្តហើយ លុះដល់បែកធ្លាយរាងកាយ ស្លាប់ទៅ បានទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក

ទិដ្ឋា មយា ភិក្ខវេ សត្តា អសក្ការេន អភិភូតា បរិយាទិន្នចិត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ទិដ្ឋា មយា ភិក្ខវេ សត្តា សក្ការេន ច អសក្ការេន ច តទុភយេន អភិភូតា បរិយាទិន្នចិត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ។ តំ ខោ បនាហំ ភិក្ខវេ នាញ្ញស្ស សមណស្ស វា ព្រាហ្មណស្ស វា សុត្វា វទាមិ(១) ទិដ្ឋា មយា ភិក្ខវេ សត្តា សក្ការេន អភិភូតា បរិយាទិន្នចិត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ទិដ្ឋា មយា ភិក្ខវេ សត្តា អសក្ការេន អភិភូតា បរិយាទិន្នចិត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ទិដ្ឋា មយា ភិក្ខវេ សត្តា សក្ការេន ច អសក្ការេន ច តទុភយេន អភិភូតា បរិយាទិន្នចិត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ។

---

១ ម. ឯត្ថន្តរេ អបិច ភិក្ខវេ យទេវ មេ សាមំ ញាតំ សាមំ ទិដ្ឋំ សាមំ វិទិតំ តមេវាហំ វទាមីតិ បាឋា ទិស្សន្តិ ។

ម្នាលភិក្ខុទាំងឡាយ តថាគត បានឃើញពួកសត្វ ដែលអសក្ការៈគ្របសង្កត់ហើយ រួបរឹតចិត្តហើយ លុះដល់បែកធ្លាយរាងកាយ ស្លាប់ទៅ បានទៅកើតហើយ ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ម្នាលភិក្ខុទាំងឡាយ តថាគត បានឃើញពួកសត្វ ដែលសក្ការៈនិងអសក្ការៈ ទាំងពីរយ៉ាងនោះ គ្របសង្កត់ហើយ រួបរឹតចិត្តហើយ លុះដល់បែកធ្លាយ រាងកាយស្លាប់ទៅ បានទៅកើតហើយ ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលភិក្ខុទាំងឡាយ តថាគត មិនមែនឮសេចក្តីនោះ (អំពីសំណាក់) នៃសមណៈ ឬព្រាហ្មណ៍ដទៃ ហើយពោលទេ ម្នាលភិក្ខុទាំងឡាយ តថាគត បានឃើញពួកសត្វ ដែលសក្ការៈគ្របសង្កត់ហើយ រួបរឹតចិត្តហើយ លុះដល់បែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតហើយ ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ម្នាលភិក្ខុទាំងឡាយ តថាគត បានឃើញពួកសត្វ ដែលអសក្ការៈគ្របសង្កត់ហើយ រួបរឹតចិត្តហើយ លុះដល់បែកធ្លាយរាងកាយ ស្លាប់ទៅ បានទៅកើតហើយ ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញពួកសត្វ ដែលសក្ការៈនិងអសក្ការៈ ទាំងពីរយ៉ាងនោះ គ្របសង្កត់ហើយ រួបរឹតចិត្តហើយ លុះដល់បែកធ្លាយរាងកាយ ស្លាប់ទៅ បានទៅកើតហើយ ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។

ឥតិវុត្តកេ តិកនិបាតស្ស ចតុត្ថវគ្គស្ស ទុតិយសុត្តំ

អបិ ច ភិក្ខវេ យទេវ មេ សាមំ ញាតំ សាមំ ទិដ្ឋំ សាមំ វិទិតំ តទេវាហំ វទាមិ ទិដ្ឋា មយា ភិក្ខវេ សត្តា សក្ការេន អភិភូតា បរិយាទិន្នចិត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ទិដ្ឋា មយា ភិក្ខវេ សត្តា អសក្ការេន អភិភូតា បរិយាទិន្នចិត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ទិដ្ឋា មយា ភិក្ខវេ សត្តា សក្ការេន ច អសក្ការេន ច តទុភយេន អភិភូតា បរិយាទិន្នចិត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នាតិ[១] ។

យស្ស សក្ការិយមានស្ស អសក្ការេន ចូភយំ
សមាធិ ន វិកម្បតិ អប្បមាទវិហារិនោ
តំ ឈាយិនំ សាតតិកំ សុខុមទិដ្ឋិវិបស្សកំ
ឧបាទានក្ខយារាមំ អាហុ សប្បុរិសោ ឥតីតិ ។

ទុតិយំ[២] ។

---

១ ម. អបិ ច ភិក្ខវេ យទេវ មេ សាមំ ញាតំ សាមំ ទិដ្ឋំ សាមំ វិទិតំ តទេវាហំ វទាមិ ទិដ្ឋា មយា ភិក្ខវេ សត្តា ។ល។ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នាតីតិ ឥមេ បាឋា ន ទិស្សន្តិ ។ ២ ឱ. ម. ទុតិយន្តិ នត្ថិ ។

ម្នាលភិក្ខុទាំងឡាយ លុះតែហេតុណា ដែលតថាគតដឹងខ្លួនឯង ឃើញខ្លួនឯង ជ្រាបច្បាស់ខ្លួនឯង ពិតមែន ទើបតថាគតពោលនូវហេតុនោះថា ម្នាលភិក្ខុទាំងឡាយ តថាគត បានឃើញពួកសត្វ ដែលសក្ការៈគ្របសង្កត់ហើយ រួបរឹតចិត្តហើយ លុះដល់បែកធ្លាយរាងកាយ ស្លាប់ទៅ បានទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ម្នាលភិក្ខុទាំងឡាយ តថាគត បានឃើញពួកសត្វ ដែលអសក្ការៈ គ្របសង្កត់ហើយ រួបរឹតចិត្តហើយ លុះដល់បែកធ្លាយ រាងកាយ ស្លាប់ទៅ បានទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ម្នាលភិក្ខុទាំងឡាយ តថាគត បានឃើញពួកសត្វ ដែលសក្ការៈនិងអសក្ការៈ ទាំងពីរនោះ គ្របសង្កត់ហើយ រួបរឹតចិត្តហើយ លុះដល់បែកធ្លាយ រាងកាយ ស្លាប់ទៅ បានទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។

បុគ្គលណា ដែលគេធ្វើសក្ការៈនិងអសក្ការៈទាំងពីរយ៉ាង ជាអ្នក
នៅដោយសេចក្តីមិនប្រមាទ មានសមាធិមិនញាប់ញ័រ អ្នកប្រាជ្ញ
តែងហៅបុគ្គល អ្នកមានឈាន មានព្យាយាមជាប់មិនដាច់
បានឃើញច្បាស់ ដោយទិដ្ឋិដ៏ល្អិត មានសេចក្តីត្រេកអរក្នុង
ការអស់ទៅនៃឧបាទាននោះ ថាជាសប្បុរស ។ សូត្រទី ២ ។

[៨២] តយោមេ ភិក្ខវេ ទេវេសុ ទេវសទ្ទា និច្ឆរន្តិ សមយា សមយំ ឧបាទាយ ។ កតមេ តយោ ។ យស្មឹ ភិក្ខវេ សមយេ អរិយសាវកោ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជ្ជាយ ចេតេតិ តស្មឹ ភិក្ខវេ សមយេ ទេវេសុ ទេវសទ្ទោ និច្ឆរតិ ឯសោ អរិយសាវកោ មារេន សទ្ធឹ សង្គាមាយ ចេតេតីតិ ។ អយំ ភិក្ខវេ បឋមោ ទេវេសុ ទេវសទ្ទោ និច្ឆរតិ សមយា សមយំ ឧបាទាយ ។ បុន ចបរំ ភិក្ខវេ យស្មឹ សមយេ អរិយសាវកោ សត្តន្នំ ពោធិបក្ខិយានំ ធម្មានំ ភាវនានុយោគមនុយុត្តោ វិហរតិ តស្មឹ ភិក្ខវេ សមយេ ទេវេសុ ទេវសទ្ទោ និច្ឆរតិ ឯសោ អរិយសាវកោ មារេន សទ្ធឹ សង្គាមេតីតិ ។ អយំ ភិក្ខវេ ទុតិយោ ទេវេសុ ទេវសទ្ទោ និច្ឆរតិ សមយា សមយំ ឧបាទាយ ។ បុន ចបរំ ភិក្ខវេ យស្មឹ សមយេ អរិយសាវកោ

(៨២) ម្នាលភិក្ខុទាំងឡាយ សំឡេងទេវតា[1] ៣ យ៉ាងនេះ តែងលាន់ឮ ក្នុងទេវលោក[2] ព្រោះអាស្រ័យសម័យនោះៗ ។ សំឡេង ៣ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវ័ក គិតដើម្បីកោរសក់ ពុកចង្កា ស្លៀកសំពត់កាសាយៈទាំងឡាយ ហើយចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ម្នាលភិក្ខុទាំងឡាយ សម័យនោះ សំឡេងទេវតា ក្នុងទេវលោកទាំងឡាយ តែងលាន់ឮឡើងថា អរិយសាវ័កនុ៎ះ គិតដើម្បីច្បាំងនឹងកិលេសមារ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសំឡេងទេវតាទី ១ ក្នុងទេវលោកទាំងឡាយ តែងលាន់ឮឡើង ព្រោះអាស្រ័យសម័យនោះៗ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សម័យណា អរិយសាវ័ក ប្រកបរឿយៗនូវព្យាយាម ដើម្បីចំរើននូវពោធិបក្ខិយធម៌ ៧ ពួក ម្នាលភិក្ខុទាំងឡាយ សម័យនោះ សំឡេងទេវតាក្នុងទេវលោកទាំងឡាយ តែងលាន់ឮឡើងថា អរិយសាវ័កនុ៎ះ កំពុងច្បាំងនឹងកិលេបមារ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសំឡេងទេវតាទី ២ ក្នុងទេវលោកទាំងឡាយ តែងលាន់ឮឡើង ព្រោះអាស្រ័យសម័យនោះៗ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត សម័យណា អរិយសាវ័ក

---

១ សំឡេងស្រែកហៅដោយសេចក្តីត្រេកអរនៃពួកទេវតា ។ ២ ក្នុងឧបបត្តិទេពទាំងពួង វៀរលែងតែអរូបាវចរទេវតានឹងអសញ្ញីទេវតា ។ អដ្ឋកថា ។

អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ តស្មឹ ភិក្ខវេ សមយេ ទេវេសុ ទេវសទ្ទោ និច្ឆរតិ ឯសោ អរិយសាវកោ វិជិតសង្គាមោ តមេវ សង្គាមសីសំ អភិវិជិយ អជ្ឈាវសតីតិ ។ អយំ ភិក្ខវេ តតិយោ ទេវេសុ ទេវសទ្ទោ និច្ឆរតិ សមយា សមយំ ឧបាទាយ ។ ឥមេ ខោ ភិក្ខវេ តយោ ទេវេសុ ទេវសទ្ទា និច្ឆរន្តិ សមយា សមយំ ឧបាទាយាតិ ។

ទិស្វា វិជិតសង្គាមំ សម្មាសម្ពុទ្ធសាវកំ
ទេវតាបិ នមស្សន្តិ មហន្តំ វីតសារទំ
នមោ តេ បុរិសាជញ្ញ យោ ត្វំ ទុជ្ជយមជ្ឈភូ
ជេត្វាន មច្ចុនោ សេនំ វិមោក្ខេន អនាវរំ
ឥតិ ហេតំ នមស្សន្តិ ទេវតា បត្តមានសំ
តញ្ហិ តស្ស ន បស្សន្តិ យេន មច្ចុវសំ វជេតិ ។

តតិយំ(១) ។

១ ឱម. តតិយន្តិ នត្ថិ ។

ធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅ ម្នាលភិក្ខុទាំងឡាយ សម័យនោះ សំឡេងទេវតាក្នុងទេវលោកទាំងឡាយ តែងលាន់ឮឡើងថា អរិយសាវកនុ៎ះ ឈ្នះសង្គ្រាមហើយ ឈ្នះពល គ្របសង្កត់នូវកំពូលនៃសង្គ្រាមនោះឯង ៗ ម្នាលភិក្ខុទាំងឡាយ នេះជាសំឡេងទេវតាទី ៣ ក្នុងទេវលោកទាំងឡាយ តែងលាន់ឮឡើង ព្រោះអាស្រ័យសម័យនោះ ៗ ។ ម្នាលភិក្ខុទាំងឡាយ សំឡេងនៃទេវតាក្នុងទេវលោកទាំងឡាយ មាន ៣ យ៉ាងនេះឯង តែងលាន់ឮឡើង ព្រោះអាស្រ័យសម័យនោះៗ ។

ពួកទេវតា បានឃើញសាវកនៃព្រះសម្មាសម្ពុទ្ធ ដែលឈ្នះសង្គ្រាមហើយ លោកមានគុណដ៏ធំប្រាសចាកសេចក្ដីកោតញញើត ទើបនមស្ការថា បពិត្របុរសអាជានេយ្យ អ្នកណា បានបង្ក្រាបសង្គ្រាម ដែលគេឈ្នះបានដោយកម្រ បានឈ្នះសេនានៃមច្ចុ ដែលបុគ្គលដទៃមិនអាចឃាត់ទាំងបាន ដោយវិមោក្ខ ខ្ញុំសូមនមស្ការអ្នកនោះ ព្រោះហេតុនោះ ពួកទេវតា តែងនមស្ការនូវសាវកនៃព្រះសម្មាសម្ពុទ្ធនុ៎ះ ដែលមានសេចក្ដីប្រាថ្នាសម្រេចហើយ សាវកនៃព្រះសម្មាសម្ពុទ្ធគប្បីដល់នូវអំណាចនៃមច្ចុទៀត ដោយហេតុណា ពួកទេវតាមិនឃើញហេតុនោះរបស់សាវកនៃព្រះសម្មាសម្ពុទ្ធនោះឡើយ ។ សូត្រទី ៣ ។

[៨៣] យទា ភិក្ខវេ ទេវោ ទេវកាយា ចវនធម្មោ ហោតិ បញ្ចស្ស បុព្វនិមិត្តានិ បាតុភវន្តិ មាលា មិលាយន្តិ វត្ថានិ កិលិស្សន្តិ កច្ឆេហិ សេទា មុច្ចន្តិ កាយេ[១] ទុព្វណ្ណិយំ ឱក្កមតិ សកេ ទេវោ ទេវាសនេ នាភិរមតីតិ ។ តមេនំ ភិក្ខវេ ទេវា ចវនធម្មោ អយំ ទេវបុត្តោតិ ឥតិ វិទិត្វា តីហិ វាចាហិ អនុមោទន្តិ ឥតោ ភោ សុគតឹ គច្ឆ សុគតឹ គន្ត្វា សុលទ្ធលាភំ លភ សុលទ្ធលាភំ លភិត្វា សុប្បតិដ្ឋិតោ ភវាហីតិ ។

[៨៤] ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច កិន្នុ ខោ ភន្តេ ទេវានំ សុគតិគមនសង្ខាតំ កិញ្ច ភន្តេ ទេវានំ សុលទ្ធលាភសង្ខាតំ កឹ បន ភន្តេ ទេវានំ សុប្បតិដ្ឋិតសង្ខាតន្តិ ។ មនុស្សត្តំ ខោ ភិក្ខវេ[២] ទេវានំ សុគតិគមនសង្ខាតំ យំ មនុស្សភូតោ សមានោ តថាគតប្បវេទិតេ ធម្មវិនយេ សទ្ធំ បដិលភតិ ឥទំ ខោ ភិក្ខវេ ទេវានំ សុលទ្ធលាភសង្ខាតំ

១ ម. កាយេន ។ ២ ម. ភិក្ខុ ។

(៨៣) ម្នាលភិក្ខុទាំងឡាយ ទេវតាមានការច្យុតិជាធម្មតា ចាកពួកទេវតា ក្នុងកាលណា បុព្វនិមិត្ត ៥ យ៉ាង តែងកើតឡើងប្រាកដ ដល់ទេវតានោះ (ក្នុងកាលនោះ) គឺកម្រងផ្កាទាំងឡាយ ស្វិតស្រពោន ១ សំពត់ទាំងឡាយសៅហ្មង ១ ញើសទាំងឡាយ តែងហូរចេញអំពីក្លៀក ១ សម្បុរមិនល្អតាំងឡើងក្នុងកាយ ១ ទេវតាមិនត្រេកអរក្នុងទេពាសនៈរបស់ខ្លួន ១ ។ ម្នាលភិក្ខុទាំងឡាយ ទេវតាទាំងឡាយ តែងដឹងនូវបុព្វនិមិត្តនោះថា ទេវបុត្តនេះ មានការច្យុតិជាធម្មតា ហើយក៏អនុមោទនាដោយវាចា ៣ បទថា ម្នាលអ្នកដ៏ចំរើន សូមអ្នកច្យុតអំពីទេវលោកនេះ ទៅកាន់សុគតិចុះ លុះអ្នកទៅកាន់សុគតិហើយ សូមឲ្យមានលាភ ដែលបានដោយងាយចុះ លុះមានលាភដែលបានដោយងាយហើយ សូមតាំងនៅដោយប្រពៃចុះ ។

(៨៤) កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុ ១ រូប ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ចុះអ្វីហៅថា ដំណើរទៅកាន់សុគតិរបស់ទេវតាទាំងឡាយ បពិត្រព្រះអង្គដ៏ចំរើន អ្វីហៅថាលាភដែលបានដោយងាយរបស់ទេវតាទាំងឡាយ បពិត្រព្រះអង្គដ៏ចំរើន អ្វីហៅថា ការតាំងនៅដោយប្រពៃនៃទេវតាទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភាពនៃមនុស្ស (នេះ) ឯង ដែលហៅថា ដំណើរទៅកាន់សុគតិ របស់ទេវតាទាំងឡាយ លុះបានកើតជាមនុស្សហើយ បានចំពោះនូវសទ្ធា ក្នុងធម្មវិន័យណា ដែលតថាគត សំដែងហើយ

សា ខោ បនស្ស សទ្ធា និវិដ្ឋា ហោតិ មូលជាតា បតិដ្ឋិតា ទឡ្ហា អសំហារិយា សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មឹ(១) ឥទំ ខោ ភិក្ខវេ ទេវានំ សុប្បតិដ្ឋិតសង្ខាតន្តិ ។

យទា ទេវោ ទេវកាយា ចវតិ អាយុសង្ខយា
តយោ សទ្ទា និច្ឆរន្តិ ទេវានំ អនុមោទតំ(២)
ឥតោ ភោ សុគតឹ គច្ឆ មនុស្សានំ សហព្យតំ
មនុស្សភូតោ សទ្ធម្មេ លភ សទ្ធំ អនុត្តរំ
សា តេ សទ្ធា និវិដ្ឋស្ស មូលជាតា បតិដ្ឋិតា
យាវជីវំ អសំហិរា សទ្ធម្មេ សុប្បវេទិតេ ។
កាយទុច្ចរិតំ ហិត្វា វចីទុច្ចរិតានិ ច
មនោទុច្ចរិតំ ហិត្វា យញ្ចញ្ញំ ទោសសញ្ហិតំ
កាយេន កុសលំ កត្វា វាចាយ កុសលំ ពហុំ
មនសា កុសលំ កត្វា អប្បមាណំ និរូបធឹ ។

---

១ ម. លោកស្មិន្តិ ។ ២ ម. អនុមោទយំ ។

ម្នាលភិក្ខុទាំងឡាយ ការបានទ្រព្យសទ្ធានេះឯង ហៅថា លាភដែលបានដោយងាយរបស់ទេវតាទាំងឡាយ ឯសទ្ធារបស់គេនោះ ជាសទ្ធាខ្ជាប់ខ្ជួន កើតជាឫសគល់តាំងនៅមាំមួន ដែលបុគ្គលណាមួយ ទោះជាសមណៈ ឬព្រាហ្មណ៍ ឬទេវតា ឬមារ ឬព្រហ្ម ក្នុងលោក មិនអាចនឹងនាំយកទៅបាន ម្នាលភិក្ខុទាំងឡាយ ការតាំងនៅមាំ នៃសទ្ធានេះឯង ហៅថា ការតាំងនៅដោយប្រពៃ របស់ទេវតាទាំងឡាយ ។

ទេវតាច្យុតចាកពួកទេវតា ព្រោះអស់ទៅនៃអាយុ ក្នុងកាលណា សំឡេង៣ យ៉ាង របស់ពួកទេវតា កាលអនុមោទនា តែងលាន់ឮឡើង (ក្នុងកាលនោះ) ថា ម្នាលអ្នកដ៏ចំរើន សូមអ្នកច្យុតអំពីទេវលោកនេះ ទៅកាន់សុគតិ ជាមួយនឹងពួកមនុស្សចុះ លុះអ្នកបានកើតជាមនុស្សហើយ សូមឲ្យបានទ្រព្យសទ្ធាដ៏ប្រសើរ ក្នុងព្រះសទ្ធម្មចុះ ក៏សទ្ធារបស់អ្នកនោះ ជាសទ្ធាខ្ជាប់ខ្ជួន ដែលបានជាឫសគល់ តាំងនៅមាំមួន ក្នុងព្រះសទ្ធម្ម ដែលតថាគតសំដែងហើយដោយប្រពៃ ដែលបុគ្គលណាមួយ មិនអាចនាំយកទៅបាន ដរាបអស់ជីវិត ។ អ្នកត្រូវលះកាយទុច្ចរិតផង លះវចីទុច្ចរិតផង លះមនោទុច្ចរិតផង លះអំពើដទៃ ដែលប្រកបដោយទោសផង ធ្វើកុសលដោយកាយ ធ្វើកុសលដោយវាចា ធ្វើកុសលដោយចិត្តឲ្យច្រើន ប្រមាណមិនបាន បរិសុទ្ធ មិនមានគ្រឿងសៅហ្មង ។

តតោ ឧបនិតំ បុញ្ញំ   កត្វា ទានេន តំ ពហុំ

អញ្ញោញ្ញិ មគ្គេ សទ្ធម្មេ   ព្រហ្មចរិយេ និវេសយេ(១)

ឥមាយ អនុកម្បាយ   ធេវា ធេវំ យសា វិន្ទុ

ចរន្តិ អនុមោទន្តិ   ឃរិ ធេវ បុនប្បុនន្តិ ។

ចតុត្ថំ(២) ។

(៨៤) តយោមេ ភិក្ខវេ បុគ្គលា លោកេ ឧប្បជ្ជមានា ឧប្បជ្ជន្តិ ពហុជនហិតាយ ពហុជន-សុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ កតមេ តយោ ។ ឥធ ភិក្ខវេ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោក-វិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ អយំ ភិក្ខវេ បឋមោ បុគ្គលោ

១ ឱ. និវេសយេ ។ ២ ឱ. ម. ចតុត្ថំ ឥតិ ។

លំដាប់នោះ អ្នកក្រែងត្រូវធ្វើបុណ្យ ដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្ន នោះ ឲ្យច្រើនដោយទាន ហើយញុំាងពួកសត្វដទៃ ឲ្យតាំងនៅក្នុង ព្រះសទ្ធម្ម ដែលជាព្រហ្មចរិយៈ ទេវតាទាំងឡាយ ដឹងច្បាស់នូវ ទេវតាកាលច្យុត ក្នុងកាលណា ក៏អនុមោទនា(ក្នុងកាលនោះ)ដោយ សេចក្តីអនុគ្រោះនេះថា ម្នាលទេវតា ចូរអ្នកមកឲ្យរឿយ ៗ ។ សូត្រទី ៤ ។

(៨៤) ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ កាលកើតឡើង ក្នុងលោក តែងកើតឡើង ដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ បុគ្គល ៣ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ មានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ ជានាយសារថីទូន្មាននូវបុរស ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ចធម៌ ទ្រង់ខ្ជាក់បោលនូវត្រៃភព ព្រះអង្គបានត្រាស់ឡើងក្នុងលោកនេះ ទ្រង់សំដែងធម៌ មានលំអបទដើម លំអបទកណ្តាល លំអបទចុង ប្រកបដោយអត្ថនិងព្យញ្ជនៈ ទ្រង់ប្រកាសព្រហ្មចរិយធម៌ ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ម្នាលភិក្ខុទាំងឡាយ នេះជាបុគ្គលទី ១

## ឥតិវុត្តកេ តិកនិបាតស្ស ចតុត្ថវគ្គស្ស បញ្ចមសុត្តំ

លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ បុន ចបរំ ភិក្ខវេ តស្សេវ សត្ថុ សាវកោ អរហំ ហោតិ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសំយោជនោ សម្មទញ្ញា វិមុត្តោ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ អយំ ភិក្ខវេ ទុតិយោ បុគ្គលោ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ បុន ចបរំ ភិក្ខវេ តស្សេវ សត្ថុ សាវកោ សេក្ខោ ហោតិ បាដិបទោ ពហុស្សុតោ សីលវតូបបន្នោ សោបិ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ

កាលកើតឡើងក្នុងលោក តែងកើតឡើង ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សាវ័ករបស់ព្រះសាស្តានោះ ជាអរហន្តខីណាស្រព មានព្រហ្មចរិយធម៌ប្រព្រឹត្តរួចហើយ មានសោឡសកិច្ច ធ្វើស្រេចហើយ មានភារៈ គឺខន្ធ ៥ ដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានកិលេសជាគ្រឿងប្រកបសត្វទុកក្នុងភពអស់រលីងហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ សាវ័កនោះ តែងសំដែងធម៌ មានលំអបទដើម មានលំអបទកណ្តាល មានលំអបទចុង ប្រកបដោយអត្ថនិងព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយធម៌ បរិសុទ្ធបរិបូណ៌ទាំងអស់ ម្នាលភិក្ខុទាំងឡាយ នេះបុគ្គលទី២ កាលកើតឡើងក្នុងលោកតែងកើតឡើង ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចំរើនដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត សាវ័ករបស់ព្រះសាស្តានោះ ជាសេក្ខបុគ្គល កំពុងប្រតិបត្តិ ជាពហុស្សូត បរិបូណ៌ដោយសីលនិងវត្ត សាវ័កនោះតែងសំដែងធម៌ មានលំអបទដើម មានលំអបទកណ្តាល មានលំអបទចុង ប្រកបដោយអត្ថនិងព្យញ្ជនៈ ប្រកាសព្រហ្មចរិយធម៌ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់

អយម្បិ ភិក្ខវេ តតិយោ បុគ្គលោ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ ឥមេ ខោ ភិក្ខវេ តយោ បុគ្គលា លោកេ ឧប្បជ្ជមានា ឧប្បជ្ជន្តិ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ ។

សត្ថា ហិ លោកេ បឋមោ មហេសិ
តស្សន្វយោ សាវកោ ភាវិតត្តោ
អថាបរោ បាដិបទោបិ សេក្ខោ
ពហុស្សុតោ សីលវតូបបន្នោ ។
ឯតេ តយោ ទេវមនុស្សសេដ្ឋា
បភង្ករា[១] ធម្មមុទីរយន្តា[២]
អបាបុរន្តិ[៣] អមតស្ស ទ្វារំ
យោគា បមោចេន្តិ[៤] ពហុជនំ តេ ។

---

១ ម. បភង្គា ។ ២ ឱ. ម ធម្មមុទីរយន្តា ។ ៣ ឱ អបារុណន្តិ ។ ម អបាបូរេន្តិ ។
៤ ឱ បមោចេន្តិ ។ ម. បមុញ្ចន្តិ ។

ម្នាលភិក្ខុទាំងឡាយ នេះបុគ្គលទី ៣ កាលកើតឡើង ក្នុងលោក ក៏កើតឡើង ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះឯង កាលកើតឡើង ក្នុងលោក តែងកើតឡើង ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។

ព្រះសាស្តា ព្រះអង្គស្វែងរកគុណដ៏ធំ ជាបុគ្គលទី ១ ក្នុងលោក សាវ័កអ្នកប្រព្រឹត្តតាមព្រះសាស្តានោះ មានខ្លួនអប់រំហើយ (ជាបុគ្គលទី ២) មួយទៀត សាវ័កដទៃជាសេក្ខបុគ្គល កំពុងប្រតិបត្តិ ជាពហុស្សូត បរិបូណ៌ដោយសីលនិងវត្ត (ជាបុគ្គលទី ៣) ។ បុគ្គល ៣ ពួកនេះ ប្រសើរជាងទេវតានិងមនុស្ស លោកជាអ្នកធ្វើពន្លឺគឺធម៌ សំដែងឡើងនូវធម៌គឺចតុរារិយសច្ច បានបើកទ្វារនៃព្រះអមតនិព្វាន លោកទាំងនោះ តែងញុំាងជនច្រើនឲ្យរួចចាកយោគៈបាន ។

យេ សត្ថវាហេន អនុត្តរេន
សុទេសិតំ មគ្គមនុក្កមន្តិ[1]
ឥធេវ ទុក្ខស្ស ករោន្តិ អន្តំ
យេ អប្បមត្តា សុគតស្ស សាសនេតិ ។

បញ្ចមំ[2] ។

(៨៦) អសុភានុបស្សី ភិក្ខវេ កាយស្មឹ វិហរថ អានាបានស្សតិ ច វោ អជ្ឈត្តំ បរិមុខំ សុបដ្ឋិតា ហោតុ[3] សព្វសង្ខារេសុ អនិច្ចានុបស្សិនោ វិហរថ ។ អសុភានុបស្សីនំ ភិក្ខវេ កាយស្មឹ វិហរតំ យោ សុភាយ ធាតុយា រាគានុសយោ សោ បហីយតិ ។ អានាបានស្សតិយា អជ្ឈត្តំ បរិមុខំ សុបដ្ឋិតាយ យេ ពាហិរា វិតក្កាសយា វិឃាតបក្ខិកា តេ ន ហោន្តិ ។ សព្វសង្ខារេសុ អនិច្ចានុបស្សីនំ វិហរតំ យា អវិជ្ជា សា បហីយតិ យា វិជ្ជា សា ឧប្បជ្ជតីតិ ។

១ ម. មគ្គមនុត្តមន្តិ ។ ២ ឱ. ម បញ្ចមន្តិ នត្ថិ ។ ៣ ម. ហោតិ ។

ពួកជនណា ឈានឡើងកាន់អរិយមគ្គ ដែលព្រះមានព្រះភាគដូចជានាយឈ្មួញដ៏ប្រសើរដោយសីលាទិគុណ ទ្រង់សំដែងហើយដោយប្រពៃ ពួកជនណា មិនប្រមាទក្នុងសាសនារបស់ព្រះសុគត ពួកជននោះ ៗ តែងធ្វើនូវទីបំផុតទុក្ខ ក្នុងអត្តភាពនេះបាន ។ សូត្រទី ៥ ។

(៨៦) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរពិចារណាឃើញរឿយ ៗ នូវអាការមិនស្អាតក្នុងកាយ ឯអានាបានស្សតិកម្មដ្ឋាន ក៏អ្នកទាំងឡាយ ចូរតាំងឡើងប្រាកដ ឲ្យមានមុខឆ្ពោះទៅកាន់អារម្មណ៍ខាងក្នុង អ្នកទាំងឡាយចូរពិចារណាឃើញរឿយៗ ក្នុងសង្ខារទាំងពួងថាមិនទៀងៗ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ ពិចារណាឃើញរឿយ ៗ នូវអាការមិនស្អាតក្នុងកាយហើយ រាគានុស្ស័យណា គួរដល់កិរិយាកើតឡើងក្នុងសុភធាតុ (កាន់យកនូវអារម្មណ៍ថាស្អាត) រាគានុស្ស័យនោះអ្នកទាំងឡាយ រមែងលះបង់បាន ។ កាលអានាបានស្សតិកម្មដ្ឋាន តាំងឡើងប្រាកដ មានមុខឆ្ពោះទៅកាន់ អារម្មណ៍ខាងក្នុងហើយ អាសយវិតក្កៈទាំងឡាយណាជាខាងក្រៅ ដែលជាចំណែកនៃសេចក្ដីចង្អៀតចង្អល់ អាសយ-វិតក្កៈទាំងនោះ មិនមានតទៅទៀតឡើយ ។ កាលបើអ្នកទាំងឡាយពិចារណាឃើញរឿយ ៗ ក្នុងសង្ខារទាំងពួងថា មិនទៀងហើយ អវិជ្ជាអ្នកទាំងឡាយ ក៏រមែងលះបង់បាន វិជ្ជាសោត ក៏រមែងកើតឡើង ។

អសុភានុបស្សី កាយស្មឹ អានាបានេ បដិស្សតោ
សព្វសង្ខារសមថំ បស្សំ អាតាបិ សព្វទា ។
ស វេ សម្មទ្ទសោ ភិក្ខុ យតោ តត្ថ វិមុច្ចតិ
អភិញ្ញាវោសិតោ សន្តោ ស វេ យោគាតិគោ មុនីតិ ។

ឆដ្ឋំ (១) ។

(៨៧) ធម្មានុធម្មប្បដិបន្នស្ស ភិក្ខុនោ អយមនុធម្មោ ហោតិ វេយ្យាករណាយ ធម្មានុធម្មប្បដិបន្នោយន្តិ ភាសមានោ ធម្មញ្ញេវ ភាសតិ នោ អធម្មំ វិតក្កយមានោ បន (២) ធម្មវិតក្កញ្ញេវ វិតក្កេតិ នោ អធម្មវិតក្កំ តទុភយំ អភិនិវជ្ជេត្វា ឧបេក្ខកោ វិហរតិ សតោ សម្បជានោតិ ។

ធម្មារាមោ ធម្មរតោ ធម្មំ អនុវិចិន្តយំ
ធម្មំ អនុស្សរំ ភិក្ខុ សទ្ធម្មា ន បរិហាយតិ ។
ចរំ វា យទិ វា តិដ្ឋំ និសិន្នោ ឧទ វា សយំ
អជ្ឈត្តំ សមយំ ចិត្តំ សន្តិមេវាធិគច្ឆតីតិ ។

សត្តមំ (៣) ។

---

១ ឱ. ម ឆដ្ឋន្តិ ឥត្ថិ ។ ២ ឱ. ម. វា ។ ៣ ឱ. ម. សត្តមន្តិ ឥត្ថិ ។

ភិក្ខុជាអ្នកពិចារណាឃើញរឿយៗ ក្នុងកាយថាមិនស្អាត មានសតិដំកល់ខ្ជាប់ក្នុងអានាបានស្សតិកម្មដ្ឋាន ពិចារណាឃើញព្រះនិព្វានជាទីរម្ងាប់សង្ខារទាំងពួងហើយ ជាអ្នកមានព្យាយាម ជាគ្រឿងផុតកំដៅកិលេសសព្វៗ កាល ។ ភិក្ខុនោះឯង ឈ្មោះថា ឃើញដោយប្រពៃ ជាអ្នកសង្រួម រមែងចុះចិត្តស៊ប់ក្នុងព្រះនិព្វានជាទីរម្ងាប់សង្ខារទាំងពួងនោះ ភិក្ខុនោះឯង ជាអ្នកមានព្រហ្មចរិយធម៌ ប្រព្រឹត្តរួចហើយ ជាអ្នកស្ងប់ព្រោះដឹងច្បាស់ ឈ្មោះថា អ្នកប្រាជ្ញប្រព្រឹត្តកន្លងយោគៈ ។ សូត្រទី ៦ ។

(៨៧) កាលបុគ្គលនិយាយថា ភិក្ខុអ្នកប្រតិបត្តិនូវធម៌សមគួរ ដល់ធម៌ដោយសភាពដ៏សមគួរណា សភាពដ៏សមគួរនេះ ជារបស់ភិក្ខុអ្នកប្រតិបត្តិធម៌សមគួរដល់ធម៌ ដោយសេចក្តីអធិប្បាយ ដូច្នេះឈ្មោះថា និយាយធម៌មែនពិត មិនឈ្មោះថា និយាយអធម៌ ឬឈ្មោះថា ត្រិះរិះធម៌មែនពិត មិនឈ្មោះថា ត្រិះរិះអធម៌ឡើយ លុះវៀរទាំងពីរនោះចេញ ទើបជាអ្នកព្រងើយ មានសតិសម្បជញ្ញៈ ។

ភិក្ខុមានធម៌ជាទីត្រេកអរ ត្រេកអរក្នុងធម៌ ត្រិះរិះរឿយៗ
នូវធម៌ រឭករឿយៗ នូវធម៌ រមែងមិនសាបសូន្យចាកព្រះ
សទ្ធម្មឡើយ ។ (ភិក្ខុនោះ) ទោះបីដើរ ឬឈរ ឬអង្គុយឬដេក
ក៏រម្ងាប់ចិត្ត (របស់ខ្លួន) ក្នុងកម្មដ្ឋានខាងក្នុង រមែងបានដល់
ព្រះនិព្វានជាទីស្ងប់រម្ងាប់ ពុំខានឡើយ ។ សូត្រទី ៧ ។

ឥតិវុត្តកេ តិកនិបាតស្ស ចតុត្ថវគ្គស្ស អដ្ឋមសុត្តំ

(៨៨) តយោមេ ភិក្ខវេ អកុសលវិតក្កា អន្ធករណា អចក្ខុករណា អញ្ញាណករណា បញ្ញានិរោធិកា វិឃាតបក្ខិកា អនិព្ពានសំវត្តនិកា ។ កតមេ តយោ ។ កាមវិតក្កោ ភិក្ខវេ អន្ធករណោ អចក្ខុករណោ អញ្ញាណករណោ បញ្ញានិរោធិកោ វិឃាតបក្ខិកោ អនិព្ពានសំវត្តនិកោ ។ ព្យាបាទវិតក្កោ ភិក្ខវេ អន្ធករណោ អចក្ខុករណោ អញ្ញាណករណោ បញ្ញានិរោធិកោ វិឃាតបក្ខិកោ អនិព្ពានសំវត្តនិកោ ។ វិហឹសាវិតក្កោ ភិក្ខវេ អន្ធករណោ អចក្ខុករណោ អញ្ញាណករណោ បញ្ញានិរោធិកោ វិឃាតបក្ខិកោ អនិព្ពានសំវត្តនិកោ ។ ឥមេ ខោ ភិក្ខវេ តយោ អកុសលា វិតក្កា[១] អន្ធករណា អចក្ខុករណា អញ្ញាណករណា បញ្ញានិរោធិកា វិឃាតបក្ខិកា អនិព្ពានសំវត្តនិកា ។

១ ឱ. ម. អកុសលវិតក្កា ។

ឥតិវុត្តកៈ តិកនិបាត ចតុត្ថវគ្គ សូត្រ ទី ៨

(៨៨) ម្នាលភិក្ខុទាំងឡាយ អកុសលវិតក្កៈ ៣ យ៉ាងនេះ ធ្វើឲ្យងងឹត ធ្វើមិនឲ្យមានបញ្ញាចក្ខុ ធ្វើមិនឲ្យមានញាណ ធ្វើបញ្ញាឲ្យរលត់ ជាចំណែកនៃសេចក្ដីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វានឡើយ ។ អកុសលវិតក្កៈ ៣ តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ គឺកាមវិតក្កៈ (សេចក្ដីត្រិះរិះប្រកបដោយកាម) ធ្វើឲ្យងងឹត ធ្វើមិនឲ្យមានបញ្ញាចក្ខុ ធ្វើមិនឲ្យមានញាណ ធ្វើបញ្ញាឲ្យរលត់ ជាចំណែកនៃសេចក្ដីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ១ ។ ម្នាលភិក្ខុទាំងឡាយ ព្យាបាទវិតក្កៈ (សេចក្ដីត្រិះរិះប្រកបដោយព្យាបាទ) ធ្វើឲ្យងងឹត ធ្វើមិនឲ្យមានបញ្ញាចក្ខុ ធ្វើមិនឲ្យមានញាណ ធ្វើបញ្ញាឲ្យរលត់ ជាចំណែកនៃសេចក្ដីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ១ ។ ម្នាលភិក្ខុទាំងឡាយ វិហឹសាវិតក្កៈ (សេចក្ដីត្រិះរិះប្រកបដោយការបៀតបៀន) ធ្វើឲ្យងងឹត ធ្វើមិនឲ្យមានបញ្ញាចក្ខុ ធ្វើមិនឲ្យមានញាណ ធ្វើបញ្ញាឲ្យរលត់ ជាចំណែកនៃសេចក្ដីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ១ ។ ម្នាលភិក្ខុទាំងឡាយ អកុសលវិតក្កៈ ៣ យ៉ាងនេះឯង ធ្វើឲ្យងងឹត ធ្វើមិនឲ្យមានបញ្ញាចក្ខុ ធ្វើមិនឲ្យមានញាណ ធ្វើបញ្ញាឲ្យរលត់ ជាចំណែកនៃសេចក្ដីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វានឡើយ ។

(៨៩) តយោមេ ភិក្ខវេ កុសលា វិតក្កា អនន្ធករណា ចក្ខុករណា ញាណករណា បញ្ញាវុទ្ធិកា អវិឃាតបក្ខិកា និព្វានសំវត្តនិកា ។ កតមេ តយោ ។ នេក្ខម្មវិតក្កោ ភិក្ខវេ អនន្ធករណោ ចក្ខុករណោ ញាណករណោ បញ្ញាវុទ្ធិកោ អវិឃាតបក្ខិកោ និព្វានសំវត្តនិកោ ។ អព្យាបាទវិតក្កោ ភិក្ខវេ អនន្ធករណោ ចក្ខុករណោ ញាណករណោ បញ្ញាវុទ្ធិកោ អវិឃាតបក្ខិកោ និព្វានសំវត្តនិកោ ។ អវិហឹសាវិតក្កោ ភិក្ខវេ អនន្ធករណោ ចក្ខុករណោ ញាណករណោ បញ្ញាវុទ្ធិកោ អវិឃាតបក្ខិកោ និព្វានសំវត្តនិកោ ។ ឥមេ ខោ ភិក្ខវេ តយោ កុសលា វិតក្កា អនន្ធករណា ចក្ខុករណា ញាណករណា បញ្ញាវុទ្ធិកា អវិឃាតបក្ខិកា និព្វានសំវត្តនិកាតិ ។

(៨៩) ម្នាលភិក្ខុទាំងឡាយ កុសលវិតក្កៈ ៣ យ៉ាងនេះ មិនធ្វើឲ្យងងឹត ធ្វើឲ្យមានបញ្ញាចក្ខុ ធ្វើឲ្យមានញាណ ធ្វើបញ្ញាឲ្យចំរើន មិនមែនជាចំណែកនៃសេចក្ដីចង្អៀតចង្អល់ ប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ។ កុសលវិតក្កៈ ៣ តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ គឺ នេក្ខម្មវិតក្កៈ (សេចក្ដីត្រិះរិះប្រកបដោយការចេញចាកកាម) មិនធ្វើឲ្យងងឹត ធ្វើឲ្យមានបញ្ញាចក្ខុ ធ្វើឲ្យមានញាណ ធ្វើបញ្ញាឲ្យចំរើន មិនមែនជាចំណែកនៃសេចក្ដីចង្អៀតចង្អល់ ប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ១ ។ ម្នាលភិក្ខុទាំងឡាយ អព្យាបាទវិតក្កៈ (សេចក្ដីត្រិះរិះមិនប្រកបដោយព្យាបាទ) មិនធ្វើឲ្យងងឹត ធ្វើឲ្យមានបញ្ញាចក្ខុ ធ្វើឲ្យមានញាណ ធ្វើបញ្ញាឲ្យចំរើន មិនមែនជាចំណែកនៃសេចក្ដីចង្អៀតចង្អល់ ប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ១ ។ ម្នាលភិក្ខុទាំងឡាយ អវិហឹសាវិតក្កៈ (សេចក្ដីត្រិះរិះមិនប្រកបដោយការបៀតបៀន) មិនធ្វើឲ្យងងឹត ធ្វើឲ្យមានបញ្ញាចក្ខុ ធ្វើឲ្យមានញាណ ធ្វើបញ្ញាឲ្យចំរើន មិនមែនជាចំណែកនៃសេចក្ដីចង្អៀតចង្អល់ ប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ១ ។ ម្នាលភិក្ខុទាំងឡាយ កុសលវិតក្កៈ ៣ យ៉ាងនេះឯង មិនធ្វើឲ្យងងឹត ធ្វើឲ្យមានបញ្ញាចក្ខុ ធ្វើឲ្យមានញាណ ធ្វើបញ្ញាឲ្យចំរើន មិនមែនជាចំណែកនៃសេចក្ដីចង្អៀតចង្អល់ ប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ។

ឥតិវុត្តកេ តិកនិបាតស្ស បឋមវគ្គស្ស នវមសុត្តំ

តយោ វិតក្កេ កុសលេ វិតក្កយេ
តយោ បន អកុសលេ និរាករេ
ស វេ វិតក្កានិ វិចារិតានិ
សមេតិ វុដ្ឋីវ រជំ សមូហតំ
ស វេ វិតក្កូបសមេន ចេតសា
ឥធេវ សោ សន្តិបទំ សមជ្ឈគាតិ ។

អដ្ឋមំ[១] ។

[៩០] តយោមេ ភិក្ខវេ អន្តរា មលា អន្តរា អមិត្តា អន្តរា សបត្តា អន្តរា វធកា អន្តរា បច្ចត្ថិកា ។ កតមេ តយោ ។ លោភោ ភិក្ខវេ អន្តរា មលោ អន្តរា អមិត្តោ អន្តរា សបត្តោ អន្តរា វធកោ អន្តរា បច្ចត្ថិកោ ។ ទោសោ ភិក្ខវេ អន្តរា មលោ អន្តរា អមិត្តោ អន្តរា សបត្តោ អន្តរា វធកោ អន្តរា បច្ចត្ថិ-កោ ។ មោហោ ភិក្ខវេ អន្តរា មលោ អន្តរា អមិត្តោ អន្តរា សបត្តោ អន្តរា វធកោ អន្តរា បច្ចត្ថិកោ ។ ឥមេ ខោ ភិក្ខវេ តយោ អន្តរា មលា អន្តរា អមិត្តា អន្តរា សបត្តា អន្តរា វធកា អន្តរា បច្ចត្ថិកាតិ ។

---

១ ឱ. ម. អដ្ឋិមត្តិ នត្ថិ ។

បុគ្គលគប្បីត្រិះរិះនូវកុសលវិតក្កៈទាំង ៣ យ៉ាងទៀត គប្បីលះបង់នូវអកុសលវិតក្កៈទាំង ៣ ចេញ បុគ្គលនោះឈ្មោះថារម្ងាប់នូវវិតក្កៈនិងវិចារៈបាន ដូចទឹកភ្លៀង កាលរម្ងាប់ធូលីដែលតាំងឡើងដូច្នោះដែរ បុគ្គលនោះមានចិត្តជាគ្រឿងរម្ងាប់វិតក្កៈ ឈ្មោះថា បានដល់ដោយប្រពៃនូវសន្តិបទគឺព្រះនិព្វានក្នុងបច្ចុប្បន្ននេះឯង ។ សូត្រទី ៨ ។

[៩០] ម្នាលភិក្ខុទាំងឡាយ ធម៌ជាមន្ទិលខាងក្នុង មិនមែនជាមិត្តខាងក្នុង ជាខ្មាំងខាងក្នុង ជាអ្នកសម្លាប់ខាងក្នុង ជាសឹកសត្រូវខាងក្នុង នេះមាន ៣ យ៉ាង ។ ធម៌ ៣ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ លោភៈ ជាមន្ទិលខាងក្នុង មិនមែនជាមិត្តខាងក្នុង ជាខ្មាំងខាងក្នុង ជាអ្នកសម្លាប់ខាងក្នុង ជាសឹកសត្រូវខាងក្នុង ១ ។ ម្នាលភិក្ខុទាំងឡាយ ទោសៈ ជាមន្ទិលខាងក្នុង មិនមែនជាមិត្តខាងក្នុង ជាខ្មាំងខាងក្នុង ជាអ្នកសម្លាប់ខាងក្នុង ជាសឹកសត្រូវខាងក្នុង ១ ។ ម្នាលភិក្ខុទាំងឡាយ មោហៈ ជាមន្ទិលខាងក្នុង មិនមែនជាមិត្តខាងក្នុង ជាខ្មាំងខាងក្នុង ជាអ្នកសម្លាប់ខាងក្នុង ជាសឹកសត្រូវខាងក្នុង ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាមន្ទិលខាងក្នុង មិនមែនជាមិត្តខាងក្នុង ជាអ្នកសម្លាប់ខាងក្នុង ជាសឹកសត្រូវខាងក្នុង មាន ៣ យ៉ាងនេះឯង ។

អនត្ថជននោ លោភោ លោភោ ចិត្តប្បកោបនោ

ភយមន្តរតោ ជាតំ តំ ជនោ នាវពុជ្ឈតិ ។

លុទ្ធោ អត្ថំ ន ជានាតិ លុទ្ធោ ធម្មំ ន បស្សតិ

អន្ធតមំ តទា ហោតិ យំ លោភោ សហតេ នរំ ។

យោ ច លោភំ បហន្ត្វាន លោភនេយ្យេ ន លុព្ភតិ

លោភោ បហិយ្យតេ តម្ហា (១) ឧទពិន្ទុវ បោក្ខរា ។

អនត្ថជននោ ទោសោ ទោសោ ចិត្តប្បកោបនោ

ភយមន្តរតោ ជាតំ តំ ជនោ នាវពុជ្ឈតិ ។

ទុដ្ឋោ អត្ថំ ន ជានាតិ ទុដ្ឋោ ធម្មំ ន បស្សតិ

អន្ធតមំ តទា ហោតិ យំ ទោសោ សហតេ នរំ ។

យោ ច ទោសំ បហន្ត្វាន ទោសនេយ្យេ ន ទុស្សតិ

ទោសោ បហិយ្យតេ តម្ហា តាលបក្កំវ ពន្ធនា ។

លោភៈ ជាធម៌ញ៉ាំងសេចក្ដីវិនាសឲ្យកើត លោភៈជាធម៌ញ៉ាំងចិត្តឲ្យកម្រើក ភ័យកើតហើយក្នុងចិត្ត ជនមិនដឹងនូវភ័យនោះឡើយ ។ បុគ្គលអ្នកលោភ រមែងមិនស្គាល់ប្រយោជន៍ បុគ្គលអ្នកលោភ រមែងមិនឃើញធម៌ សេចក្ដីលោភគ្របសង្កត់នរជន ក្នុងកាលណា សេចក្ដីងងឹតដ៏មានកំឡាំង ក៏កើតឡើងក្នុងកាលនោះ ។ លុះតែបុគ្គលណា បានលះបង់សេចក្ដីលោភហើយ ទើបមិនជាប់ចិត្ត ក្នុងអារម្មណ៍ ដែលគួរជាប់ចិត្ត សេចក្ដីលោភ ដែលអរិយមគ្គ កំចាត់បង់ចាកបុគ្គលនោះដូចដំណក់ទឹកដែលរមៀលចេញ អំពីស្លឹកឈូក ដូច្នោះឯង ។

ទោសៈ ជាធម៌ញ៉ាំងសេចក្ដីវិនាសឲ្យកើត ទោសៈជាធម៌ញ៉ាំងចិត្តឲ្យកម្រើក ភ័យកើតហើយក្នុងចិត្ត ជនមិនដឹងនូវភ័យនោះ ។ ជនអ្នកប្រទូស្ត រមែងមិនស្គាល់ប្រយោជន៍ ជនអ្នកប្រទូស្ត រមែងមិនឃើញធម៌ ទោសៈគ្របសង្កត់នរជន ក្នុងកាលណា សេចក្ដីងងឹតដ៏មានកំឡាំងក៏កើតឡើង ក្នុងកាលនោះ ។ លុះតែបុគ្គលណា បានលះបង់ទោសៈហើយ ទើបមិនប្រទូស្តក្នុងអារម្មណ៍ ដែលគួរប្រទូស្ត ទោសៈដែលអរិយមគ្គកំចាត់បង់ហើយ ចាកបុគ្គលនោះ ដូចជាផ្លែត្នោតទុំដែលជ្រុះចាកទង ដូច្នោះឯង ។

អនត្ថជននោ មោហោ   មោហោ ចិត្តប្បកោបនោ
ភយមន្តរតោ ជាតំ   តំ ជនោ នាវពុជ្ឈតិ ។
មូឡ្ហោ អត្ថំ ន ជានាតិ   មូឡ្ហោ ធម្មំ ន បស្សតិ
អន្ធតមំ តទា ហោតិ   យំ មោហោ សហតេ នរំ ។
យោ ច មោហំ បហត្វាន   មោហនេយ្យេ ន មុយ្ហតិ
មោហំ វិហន្តិ សោ សព្វំ   អាទិច្ចោវុទយំ តមន្តិ ។

នវមំ[១] ។

(៩១) [២] តីហិ ភិក្ខវេ អសទ្ធម្មេហិ អភិភូតោ បរិយាទិន្នចិត្តោ ទេវទត្តោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ កតមេហិ តីហិ ។ បាបិច្ឆតាយ ភិក្ខវេ អភិភូតោ បរិយាទិន្នចិត្តោ ទេវទត្តោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ បាបមិត្តតាយ ភិក្ខវេ អភិភូតោ បរិយាទិន្នចិត្តោ ទេវទត្តោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។

---

១ ឱ. ម. ទសមន្តិ អត្ថិ ។ ២ ឱ. ម. ឯត្ថ ឋានេ វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតន្តិ ទិស្សន្តិ ។

មោហៈជាធម៌ញុំាងសេចក្តីវិនាសឲ្យកើត មោហៈជាធម៌ញុំាងចិត្តឲ្យកម្រើក ភ័យកើតហើយខាងក្នុងចិត្ត ជនមិនដឹងនូវភ័យនោះ ៗ ជនអ្នកវង្វេង រមែងមិនស្គាល់ប្រយោជន៍ ជនអ្នកវង្វេង រមែងមិនឃើញធម៌ មោហៈគ្របសង្កត់នរជន ក្នុងកាលណា សេចក្តីងងឹតជាមានកំឡាំង ក៏កើតឡើងក្នុងកាលនោះៗ លុះតែបុគ្គលណា បានលះបង់មោហៈហើយ ទើបមិនវង្វេងក្នុងអារម្មណ៍ ដែលគួរវង្វេង បុគ្គលនោះ រមែងកំចាត់បង់នូវមោហៈទាំងពួង (ដោយមគ្គទី ៤) ដូចជាព្រះអាទិត្យកាលរះឡើង កំចាត់បង់ងងឹត ដូច្នោះឯង ៗ សូត្រទី ៩ ។

(៩១) ម្នាលភិក្ខុទាំងឡាយ ទេវទត្ត ត្រូវអសទ្ធម្ម ៣ យ៉ាង គ្របសង្កត់ រួបរឹតចិត្តហើយ ជាអ្នកទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់ ១ កប្ប រលែងកែបាន ៗ អសទ្ធម្ម ៣ គឺអ្វីខ្លះ ៗ ម្នាលភិក្ខុទាំងឡាយ ទេវទត្ត ត្រូវសេចក្តីប្រាថ្នាដ៏លាមក គ្របសង្កត់ រួបរឹតចិត្តហើយ ជាអ្នកទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់ ១ កប្ប រលែងកែបាន ១ ៗ ម្នាលភិក្ខុទាំងឡាយ ទេវទត្ត ត្រូវភាពនៃបាបមិត្តគ្របសង្កត់ រួបរឹតចិត្តហើយ ជាអ្នកទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់ ១ កប្ប រលែងកែបាន ១ ៗ

សតិ ខោ បន ឧត្តរឹ ករណីយេ ឱរមត្តកេន វិសេសាធិគមេន ច អន្តរា វោសានំ អាបាទិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ អសទ្ធម្មេហិ អភិភូតោ បរិយាទិន្នចិត្តោ ទេវទត្តោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោតិ ។[១]

មា ជាតុ កោចិ លោកស្មឹ បាបិច្ឆោ ឧបបជ្ជថ[២]
តទមិនាបិ ជានាថ បាបិច្ឆានំ យថាគតិ ។
បណ្ឌិតោតិ សមញ្ញាតោ ភាវិតត្តោតិ សម្មតោ
ជលំវ យសសា អដ្ឋា[៣] ទេវទត្តោតិ មេ សុតំ
សោ បមាទមនុចិណ្ណោ អាសជ្ជ[៤] នំ តថាគតំ
អវីចិនិរយំ បត្តោ ចតុទ្វារំ ភយានកំ ។
អទុដ្ឋស្ស ហិ យោ ទុព្ភេ បាបកម្មំ អកុព្វតោ
តមេវ បាបំ ផុសេតិ ទុដ្ឋចិត្តំ អនាទរំ ។

---

១ ឱ.ម. ឥតោ បរំ ឯកមត្ថំ ភគវា អវោច តត្ថេតំ ឥតិ វុច្ចតីតិ ទិស្សតិ ។
២ ម. ឧបបជ្ជិតិ ។ ៣ អដ្ឋកថាយំ អដ្ឋាតិ ទិស្សតិ ។ ៤ ឱ. អាបជ្ជ ។

មួយវិញទៀត កិច្ចដែលគួរធ្វើតទៅទៀតនៅមាន (ប៉ុន្តែ) ទេវទត្តដល់នូវសេចក្តីវិនាសក្នុងពាក់កណ្តាល ព្រោះឈានទទឹងអភិញ្ញាជាន់ទាបផង ព្រោះការត្រាស់ដឹងនូវគុណវិសេសជាន់ខ្ពស់ផង ១ ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្តដែលត្រូវអសទ្ធម្ម ៣ នេះឯង គ្របសង្កត់ រួបរឹតចិត្តហើយ ជាអ្នកទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់ ១ កប្ប លែងកែបាន ។

បុគ្គលទីមួយ ក្នុងលោក កុំមានសេចក្តីប្រាថ្នាដ៏លាមកដោយ
ជាប់ខាត គតិរបស់បុគ្គលទាំងឡាយ ដែលមានសេចក្តីប្រាថ្នា
ដ៏លាមក យ៉ាងណាមិញ អ្នកទាំងឡាយត្រូវដឹងនូវទេវទត្តនោះ
ដោយហេតុនេះ យ៉ាងនោះចុះ ។ តថាគត ឮថាទេវទត្តនេះ
គេដឹងថាជាបណ្ឌិត គេសរសើរថាជាអ្នកមានខ្លួនអប់រំហើយ
ហាក់ដូចជារុងរឿង ដោយយសបរិវារហើយឋិតនៅ ទេវទត្ត
នោះ ជាអ្នកសន្សំរឿយ ៗ នូវសេចក្តីប្រមាទ បៀតបៀន
តថាគតនោះ ហើយដល់នូវអវីចិនរក មានទ្វារ ៤ ជាទី
គួរខ្លាច ។ បុគ្គលណា ប្រទូស្តចំពោះបុគ្គល ដែលមិន
ប្រទូស្ត អ្នកមិនធ្វើបាបកម្ម ផលបាប រមែងប៉ះពាល់
ត្រូវបុគ្គល អ្នកមានចិត្តប្រទូស្ត មិនអើពើ នោះឯង ។

សមុទ្ទំ វិសកុម្ភេន យោ មញ្ញេយ្យ បទូសិតុំ
ន សោ តេន បទូសេយ្យ ភេស្មា ហិ ឧទធី មហា ។
ឯវមេតំ តថាគតំ យោ វាទេន វិហឹសតិ
សម្មគ្គតំ សន្តចិត្តំ វាទោ តម្ហិ ន រូហតិ ។
តាទិសំ មិត្តំ កុព្វេថ[១] តញ្ច សេវេយ្យ បណ្ឌិតោ
យស្ស មគ្គានុគោ ភិក្ខុ ខយំ ទុក្ខស្ស បាបុណេតិ ។
អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

ទសមំ[២] ។

ចតុត្ថវគ្គោ ។

តស្សុទ្ទានំ

វិតក្កសក្ការសទ្ទ- ចវមានំ លោកេ អសុភំ
ធម្មអន្ធការមលំ ទេវទត្តេន[៣] តេ ទសាតិ ។

---

១ ម. កុព្វេថ ។ ២ ឱ. ម. ទសមត្តំ ។ ៣ ម. ទេវទត្តោតិ ។

បុគ្គលណា សំគាល់ ដើម្បីនឹងប្រទូស្តនូវសមុទ្រ ដោយឆ្នាំង ដ៏ពេញដោយថ្នាំពិស បុគ្គលនោះ មិនគប្បីប្រទូស្ត ដោយឆ្នាំង ដ៏ពេញ ដោយថ្នាំពិសនោះបាន ព្រោះថា សមុទ្រ ជាសភាពធំ មហិមា យ៉ាងណាមិញ ។ បុគ្គលណា បៀតបៀនតថាគត នុ៎ះ ដែលកំពុងប្រតិបត្តិដោយប្រពៃ មានព្រះហឫទ័យស្ងប់រម្ងាប់ ដោយវាទៈជាទោស វាទៈ (របស់បុគ្គលនោះ) ក៏មិនដុះ ឡើងកន្លងព្រះតថាគតនោះ ក៏យ៉ាងនោះដែរ ។ ភិក្ខុជាអ្នក ប្រព្រឹត្តទៅតាមផ្លូវនៃបុគ្គលណា ហើយបានដល់ នូវការអស់ ទៅនៃសេចក្តីទុក្ខ បណ្ឌិត គប្បីធ្វើបុគ្គលមានសភាពដូច្នោះ ឲ្យជាមិត្តផង គប្បីសេពគប់ ចំពោះបុគ្គលនោះផង ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគទ្រង់ ត្រាស់ទុកហើយ ។ សូត្រ ទី ១០ ។

ចប់ ចតុត្ថវគ្គ ។

## ឧទ្ទាននៃចតុត្ថវគ្គ នោះគឺ

និយាយអំពីវិតក្កៈ១ សក្ការៈ១ សំឡេង ១ ទេពច្យុត ១ បុគ្គលក្នុងលោក ១ អសុភ ១ ធម៌ ១ ងងឹត១ មន្ទិល១ ទេវទត្ត១ ត្រូវជា១០ ។

## ឥតិវុត្តកេ តិកនិបាតស្ស បញ្ចមវគ្គោ

(៩២) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ តយោមេ ភិក្ខវេ អគ្គប្បសាទា ។ កតមេ តយោ ។ យាវតា ភិក្ខវេ សត្តា អបទា វា ទ្វិបទា(១) វា ចតុប្បទា វា ពហុប្បទា វា រូបិនោ វា អរូបិនោ វា សញ្ញិនោ វា អសញ្ញិនោ វា នេវសញ្ញីនាសញ្ញិនោ វា តថាគតោ តេសំ អគ្គមក្ខាយតិ អរហំ សម្មាសម្ពុទ្ធោ ។ យេ ភិក្ខវេ ពុទ្ធេ បសន្នា អគ្គេ តេ បសន្នា អគ្គេ ខោ បន បសន្នានំ អគ្គោ វិបាកោ ហោតិ ។ យាវតា ភិក្ខវេ ធម្មា សង្ខតា វា អសង្ខតា វា វិរាគោ តេសំ អគ្គមក្ខាយតិ យទិទំ មទនិម្មទនោ បិបាសវិនយោ អាលយសមុគ្ឃាតោ វដ្ដុបច្ឆេទោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ(២) ។

---

១ ឱ. ម. អបទា វា ទ្វិបទា វា ។ ២ ម. និព្វានន្តិ ។

# ឥតិវុត្តកៈ តិកនិបាត បញ្ចមវគ្គ

(៩២) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីជ្រះថ្លាចំពោះវត្ថុដ៏ប្រសើរនេះ មាន ៣ ។ សេចក្តីជ្រះថ្លាចំពោះវត្ថុដ៏ប្រសើរ ៣ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វទាំងប៉ុន្មាន ដែលជាសត្វមិនមានជើងក្តី មានជើងពីរក្តី មានជើងបួនក្តី មានជើងច្រើនក្តី មានរូបក្តី មិនមានរូបក្តី មានសញ្ញាក្តី មិនមានសញ្ញាក្តី មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន គឺមានសញ្ញាយ៉ាងល្អិតក្តី ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ប្រាកដជាប្រសើរ ជាងពួកសត្វទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វណា ជ្រះថ្លាក្នុងព្រះពុទ្ធ ពួកសត្វនោះឈ្មោះថា ជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរ កាលបើពួកសត្វជ្រះថ្លា ក្នុងវត្ថុដ៏ប្រសើរហើយ មានផលក៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងប៉ុន្មាន ដែលជាសង្ខតធម៌ (ធម៌ដែលមានបច្ច័យប្រជុំតាក់តែង) ក្តី ជាអសង្ខតធម៌ (ធម៌ដែលមិនមានបច្ច័យប្រជុំតាក់តែង) ក្តី វិរាគៈ (ការប្រាសចាកតម្រេក) ដែលជាគ្រឿងញាំញីនូវសេចក្តីស្រវឹង នាំចេញនូវសេចក្តីស្រេកឃ្លាន ដកឡើងនូវសេចក្តីអាល័យ កាត់ផ្តាច់នូវវដ្តៈ អស់តណ្ហា ប្រាសចាកតម្រេក រលត់មិនសេសសល់ មិនមានតណ្ហានេះ ប្រាកដជាប្រសើរជាងធម៌ទាំងនោះ ។

### ឥតិវុត្តកេ តិកនិបាតស្ស បញ្ចមវគ្គស្ស បឋមសុត្តំ

យេ ភិក្ខវេ វិរាគេ ធម្មេ បសន្នា អគ្គេ តេ បសន្នា អគ្គេ ខោ បន បសន្នានំ អគ្គោ វិបាកោ ហោតិ ។ យាវតា ភិក្ខវេ សង្ខតា ធម្មា អរិយោ អដ្ឋង្គិកោ មគ្គោ តេសំ អគ្គមក្ខាយតិ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ យេ ភិក្ខវេ អរិយេមគ្គធម្មេ បសន្នា អគ្គេ តេ បសន្នា អគ្គេ ខោ បន បសន្នានំ អគ្គោ វិបាកោ ហោតិ ។ យាវតា ភិក្ខវេ សង្ឃា វា គណា វា តថាគតសាវកសង្ឃោ តេសំ អគ្គមក្ខាយតិ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា(១) ។ យេ ភិក្ខវេ សង្ឃេ បសន្នា អគ្គេ តេ បសន្នា អគ្គេ ខោ បន បសន្នានំ អគ្គោ វិបាកោ ហោតិ ។ ឥមេ ខោ ភិក្ខវេ តយោ អគ្គប្បសាទាតិ ។ ឯតមត្ថំ ភគវា អវោច ។

---

១ ឱ. ម. ឥតោ បរំ ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ បាឋោ ទិស្សតិ ។

ម្នាលភិក្ខុទាំងឡាយ ពួកសត្វណា ជ្រះថ្លាក្នុងវិរាគធម៌ហើយ ពួកសត្វនោះ ឈ្មោះថា ជ្រះថ្លា ក្នុងវត្ថុដ៏ប្រសើរ កាលបើពួកសត្វជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរហើយ មានផលក៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងប៉ុន្មាន ដែលជាសង្ខតធម៌ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ គឺការឃើញត្រូវ ១ ការត្រិះរិះត្រូវ ១ វាចាត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ ព្យាយាមត្រូវ ១ រលឹកត្រូវ ១ តាំងចិត្តមាំត្រូវ ១ នេះប្រាកដជាប្រសើរជាងធម៌ទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វណា ជ្រះថ្លាក្នុងធម៌ គឺមគ្គដ៏ប្រសើរហើយ ពួកសត្វនោះ ឈ្មោះថាជ្រះថ្លា ក្នុងវត្ថុដ៏ប្រសើរ កាលបើពួកសត្វជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរហើយ មានផលក៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃក្តី គណៈក្តី ទាំងប៉ុន្មាន សង្ឃជាសាវក របស់ព្រះតថាគត ដែលចាត់ជាគូនៃបុរសមាន ៤ គូ ចាត់ជាបុរសបុគ្គល (រៀងគ្នា) មានប្រាំបី នេះប្រាកដជាប្រសើរជាងសង្ឃ និងគណៈទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វណា ជ្រះថ្លាក្នុងសង្ឃហើយ ពួកសត្វនោះ ឈ្មោះថា ជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរ កាលបើពួកសត្វជ្រះថ្លា ក្នុងវត្ថុដ៏ប្រសើរហើយ មានផលក៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរ មាន ៣ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។

តត្ថេតំ ឥតិ វុច្ចតិ

អគ្គតោ វេ បសន្នានំ អគ្គំ ធម្មំ វិជានតំ
អគ្គេ ពុទ្ធេ បសន្នានំ ទក្ខិណេយ្យេ អនុត្តរេ
អគ្គេ ធម្មេ បសន្នានំ វិរាគូបសមេ សុខេ
អគ្គេ សង្ឃេ បសន្នានំ បុញ្ញក្ខេត្តេ អនុត្តរេ
អគ្គស្មឹ ទានំ ទទតំ អគ្គំ បុញ្ញំ បវឌ្ឍតិ
អគ្គំ អាយុ ច វណ្ណោ ច យសោ កិត្តិ សុខំ ពលំ
អគ្គស្ស ទាតា មេធាវី អគ្គធម្មសមាហិតោ
ទេវភូតោ មនុស្សោ វា អគ្គប្បត្តោ បមោទតីតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

បឋមំ[១] ។

(៩៣) អន្តមិទំ ភិក្ខវេ ជីវិកានំ យទិទំ បិណ្ឌោល្យំ អភិសាបាយំ ភិក្ខវេ លោកស្មឹ បិណ្ឌោលោ វិចរសិ បត្តបាណីតិ ។ តញ្ច ខោ ឯតំ ភិក្ខវេ កុលបុត្តា ឧបេន្តិ

---

១ ឱ. ម. បឋមន្តិ នត្ថិ ។

ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

កាលបើពួកសត្វជ្រះថ្លាក្នុង ( ព្រះរត្នត្រ័យ ) ថាជារបស់ប្រសើរ ដឹងច្បាស់ថាជាសារៈប្រសើរ គឺជាជ្រះថ្លាក្នុងព្រះពុទ្ធដ៏ប្រសើរ ជាទក្ខិណេយ្យបុគ្គលដ៏ឧត្តម ជ្រះថ្លាក្នុងព្រះធម៌ ដ៏ប្រសើរ ជាគ្រឿងប្រាសចាកតម្រេកស្ងប់រម្ងាប់ ( កិលេស ) នាំមកនូវសេចក្តីសុខ ជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ជាបុញ្ញក្ខេត្តយ៉ាងខ្ពង់ខ្ពស់ ឲ្យនូវទានក្នុងវត្ថុដ៏ប្រសើរ បុណ្យដ៏ប្រសើរ ក៏រមែងចំរើន ទាំងអាយុ ពណ៌ យស កេរ្តិ៍ឈ្មោះ សេចក្តីសុខ និងកំឡាំងដ៏ប្រសើរ ក៏រមែងចំរើន អ្នកប្រាជ្ញ ជាអ្នកឲ្យ ( នូវទេយ្យធម៌ ) ចំពោះវត្ថុដ៏ប្រសើរ ហើយជាអ្នកមានចិត្តតាំងមាំ ក្នុងធម៌ដ៏ប្រសើរ លុះកើតជាទេវតា ឬកើតជាមនុស្ស សម្រេចនូវសម្បត្តិដ៏ប្រសើរ រមែងរីករាយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ។ សូត្រ ទី ១ ។

(៩៣) ម្នាលភិក្ខុទាំងឡាយ ការចិញ្ចឹមជីវិតដោយកិរិយាត្រាច់ទៅដើម្បីបិណ្ឌបាតនេះ លាមកជាងការចិញ្ចឹមជីវិតទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ព្រោះថាក្នុងលោករមែងមានពាក្យដ៏សាហាវថា អ្នកជាបុគ្គលប្រព្រឹត្តត្រាច់ទៅដើម្បីបិណ្ឌបាត មានតែបាត្រក្នុងដៃ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែពួកកុលបុត្រ ដែលចូលចិត្តចិញ្ចឹមជីវិតដោយកិរិយាត្រាច់ទៅ ដើម្បីបិណ្ឌបាតនោះ

អត្ថវសិកា អត្ថវសំ បដិច្ច នេវ រាជាភិនីតា ន ចោរាភិ-នីតា ន ឥណដ្ដា ន ភយដ្ដា ន អាជីវិកា បកតា[1] អបិ ច ខោ ឱតិណ្ណាម្ហា ជាតិយា ជរាមរណេន[2] សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ទុក្ខោតិណ្ណា[3] ទុក្ខបរេតា អប្បេវ នាម ឥមស្ស[4] កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ ឯវំ បព្វជិតោ ចាយំ ភិក្ខវេ កុលបុត្តោ[5] ហោតិ អភិជ្ឈាលុ កាមេសុ តិព្វសារាគោ ព្យាបន្នចិត្តោ បទុដ្ឋ-មនសង្កប្បោ មុដ្ឋស្សតិ អសម្បជានោ អសមាហិតោ វិព្ភន្តចិត្តោ បាកតិន្ទ្រិយោ ។ សេយ្យថាបិ ភិក្ខវេ ឆវាលាតំ ឧភតោ បទិត្តំ មជ្ឈេ គូថគតំ នេវ គាមេ កដ្ឋត្ថំ ផរតិ ន អរញ្ញេ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ គិហិភោគា ច បរិហីនោ សាមញ្ញត្ថញ្ច ន បរិបូរេតីតិ ។ ឯតមត្ថំ ភគវា អវោច ។

---

១ ម. អាជីវិកបកតា ។ ២ ឱ. ម. ជរាយ មរណេន ។ ៣ ឱ. ទុក្ខាភិតិណ្ណា ។ ៤ ម. អប្បេវ នាមស្ស ។ ៥ ឱ. ឯត្តូរេ សោជាតិ ទិស្សតិ ។

សុទ្ធតែ ជាអ្នកប្រព្រឹត្តទៅ ក្នុងអំណាចនៃប្រយោជន៍ ព្រោះអាស្រ័យប្រយោជន៍ មិនមែនព្រោះព្រះរាជាបៀតបៀន មិនមែន ព្រោះចោរបៀតបៀន មិនមែនព្រោះបំពាក់បំណុល មិនមែនព្រោះភ័យគ្របសង្កត់ មិនមែនព្រោះដុនដាប ដោយការចិញ្ចឹមជីវិតទេ ពិតជាព្រោះការត្រិះរិះថា ពួកយើងត្រូវជាតិ ជរា មរណៈ សេចក្តីសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត ទិងចង្អៀតចង្អល់ចិត្ត គ្របសង្កត់ហើយ ជាអ្នកត្រូវទុក្ខជាន់ ត្រូវទុក្ខគ្របសង្កត់ហើយ ធ្វើដូចម្តេចហ្ន៎ ការធ្វើនូវទីបំផុតនៃគំនរទុក្ខទាំងអស់នេះឲ្យប្រាកដបាន ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្រនេះបានបួសយ៉ាងនេះហើយ ក៏ជាអ្នកច្រើនដោយអភិជ្ឈា មានតម្រេកដ៏ក្លៀវក្លាក្នុងកាម មានចិត្តព្យាបាទ មានការត្រិះរិះក្នុងចិត្តដ៏អាក្រក់ ភ្លេចស្មារតី មិនដឹងខ្លួន មានចិត្តមិនមាំមួន មានចិត្តភ្ញាក់ផ្អើល មានឥន្ទ្រិយជាប្រក្រតីគឺមិនសង្រួម ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាអង្កត់ឧសសម្រាប់ដុតខ្មោច មានភ្លើងឆេះទាំងសងខាង ប្រឡាក់លាមកត្រង់កណ្តាល រមែងមិនផ្សព្វផ្សាយទៅដើម្បីជាឧសក្នុងស្រុក ក្នុងព្រៃបានឡើយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះថា សាបសូន្យចាកភោគៈ របស់គ្រហស្ថផង មិនបានញុំាងប្រយោជន៍ ជារបស់សមណៈឲ្យបរិបូណ៌ផង ក៏យ៉ាងនោះដែរ ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។

តត្ថេតំ ឥតិ វុច្ចតិ

គិហិភោគា ច បរិហីនោ សាមញ្ញត្ថញ្ច ទុព្ភតោ[១]
បរិធំសមានោ បកិរេតិ ឆវាលាតំវ នស្សតិ[២] ។
សេយ្យោ អយោគុឡោ ភុត្តោ តត្តោ អគ្គិសិខូបមោ
យញ្ចេ ភុញ្ជេយ្យ ទុស្សីលោ រដ្ឋបិណ្ឌំ អសញ្ញតោតិ ។

ទុតិយំ[៣] ។

(៩៦) សង្ឃាដិកណ្ណេ ចេបិ ភិក្ខវេ ភិក្ខុ គហេត្វា បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធោ អស្ស បាទេ បាទំ និក្ខិបន្តោ សោ ច ហោតិ អភិជ្ឈាលុ កាមេសុ តិព្វសារាគោ ព្យាបន្នចិត្តោ បទុដ្ឋមនសង្កប្បោ មុដ្ឋស្សតិ អសម្បជានោ អសមាហិតោ វិព្ភន្តចិត្តោ បាកតិន្ទ្រិយោ អថខោ សោ អារកាវ មយ្ហំ អហញ្ច តស្ស ។ តំ កិស្ស ហេតុ ។ ធម្មំ ហិ សោ ភិក្ខវេ ភិក្ខុ ន បស្សតិ ធម្មំ អបស្សន្តោ មំ ន បស្សតិ ។ យោជនសតេ ចេបិ សោ ភិក្ខវេ ភិក្ខុ វិហរេយ្យ

---

១ ម. ទុគ្គតោ ។ ២ ឱ. ម. ឆវាលាតំ វ នស្សតិ ។ ៣ ឱ. ម. ទុតិយន្តិ នត្ថិ ។

ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

(បុគ្គលទ្រុស្តសីល) រមែងសាបសូន្យចាកភោគៈ របស់គ្រហស្ថផង ចាកប្រយោជន៍ជារបស់សមណៈផង ជាបុគ្គលមានចំណែកអាក្រក់ តែងខ្ចាត់ខ្ចាយ ពេយពាយ វិនាសទៅ ដូចជាទុស្សដុតខ្មោច ។ បុគ្គល បរិភោគដុំដែកក្តៅ ដូចជាអណ្តាតភ្លើង ប្រសើរជាង បុគ្គលទ្រុស្តសីល មិនសង្រួមហើយ បរិភោគ នូវបិណ្ឌបាត របស់អ្នកដែន មិនប្រសើរ សោះឡើយ ។ សូត្រ ទី ២ ។

(៩៤) ម្នាលភិក្ខុទាំងឡាយ បើទុកជាភិក្ខុ ចាប់ជាយសង្ឃាដី (នៃតថាគត) ហើយដើរតាមអំពីខាងក្រោយៗ ដាក់ជើង (ខ្លួន) ត្រង់កន្លែងជើង (នៃតថាគត) តែថាភិក្ខុនោះ ជាអ្នកច្រើនដោយអភិជ្ឈា មានតម្រេកដ៏ក្លៀវក្លាក្នុងកាម មានចិត្តព្យាបាទ មានសេចក្តីត្រិះរិះ ក្នុងចិត្តដ៏អាក្រក់ ភ្លេចស្មារតី មិនដឹងខ្លួន មានចិត្តមិនមាំមួន មានចិត្តភ្ញាក់ផ្អើល មានឥន្ទ្រិយជាប្រក្រតី ភិក្ខុនោះ ឈ្មោះថា នៅឆ្ងាយអំពីតថាគត ដោយពិត ឯតថាគត ក៏ឈ្មោះថា នៅឆ្ងាយអំពីភិក្ខុនោះដែរ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុនោះ មិនឃើញធម៌ កាលបើ មិនឃើញធម៌ហើយ ឈ្មោះថា មិនឃើញតថាគត ។ ម្នាលភិក្ខុទាំងឡាយ បើទុកជាភិក្ខុនោះ នៅក្នុងទីមួយចំនួនរយយោជន៍

សោ ច ហោតិ អនភិជ្ឈាលុ កាមេសុ ន តិព្វសារាគោ អព្យាបន្នចិត្តោ អប្បទុដ្ឋមនសង្កប្បោ ឧបដ្ឋិតស្សតិ សម្បជានោ សមាហិតោ ឯកគ្គចិត្តោ សំវុតិន្ទ្រិយោ អថ ខោ សោ សន្តិកេវ មយ្ហំ អហញ្ច តស្ស ។ តំ កិស្ស ហេតុ ។ ធម្មំ ហិ សោ ភិក្ខវេ ភិក្ខុ បស្សតិ ធម្មំ បស្សន្តោ មំ បស្សតីតិ ។

អនុពន្ធោបិ ចេ អស្ស មហិច្ឆោ ច វិឃាតវា
ឯជានុគោ(១) អនេជស្ស និព្វុតស្ស អនិព្វុតោ
គិទ្ធោ សោ វីតគេធស្ស បស្ស យាវញ្ច អារកា ។
យោ ច ធម្មមភិញ្ញាយ ធម្មមញ្ញាយ បណ្ឌិតោ
រហទោវ និវាតោ ច(២) អនេជោ វូបសម្មតិ
អនេជោ សោ អនេជស្ស និព្វុតស្ស ច និព្វុតោ
អគិទ្ធោ(៣) វីតគេធស្ស បស្ស យាវញ្ច សន្តិកេតិ ។

តតិយំ(៤) ។

---

១ ម. ឯជាទាសោ ។ ២ ម. រហទោ វូបនិវាតោ ។ ៣ ម. ឯត្ថន្តរេ សោតិ អត្ថិ ។
៤ ឱ.ម. តតិយសុត្តំ នត្ថិ ។

តែភិក្ខុនោះ មិនជាអ្នកច្រើនដោយអភិជ្ឈា មិនមានតម្រេកដ៏ក្លៀវក្លាក្នុងកាម មិនមានចិត្តព្យាបាទ មិនមានសេចក្តីត្រិះរិះ ក្នុងចិត្តដ៏អាក្រក់ ប្រុងស្មារតី ដឹងខ្លួន មានចិត្តមាំមួន មានចិត្តមូលទឹងធឹង ក្នុងអារម្មណ៍តែមួយ សង្រួមឥន្ទ្រិយ ភិក្ខុនោះ ឈ្មោះថា នៅជិតតថាគតដោយពិត ទាំងតថាគត ក៏ឈ្មោះថា នៅជិតភិក្ខុនោះដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុនោះឃើញធម៌ កាលបើឃើញធម៌ហើយ ឈ្មោះថា ឃើញតថាគត ។

អ្នកចូរមើលចុះ ភិក្ខុណាដែលជាអ្នកប្រាថ្នាធំ បៀតបៀនគេ
លុះអំណាចតណ្ហាជាគ្រឿងញាប់ញ័រ មានចិត្តមិនត្រជាក់ ចំពាក់
នៅ (ក្នុងកាម) បើទុកជាភិក្ខុនោះ ជាប់កៀកនឹងព្រះពុទ្ធ ដែល
មិនមានតណ្ហាជាគ្រឿងញាប់ញ័រ មានចិត្តត្រជាក់ ឥតជាប់ចំពាក់
ក៏ឈ្មោះថា នៅឆ្ងាយជាដរាប ។ លុះតែភិក្ខុណា ជាបណ្ឌិត
បានដឹងច្បាស់នូវធម៌ (ដោយញាតបរិញ្ញា និងតីរណបរិញ្ញា) ដឹង
ច្បាស់នូវចតុសច្ចធម៌ (ដោយមគ្គញាណ) មិនមានតណ្ហាជាគ្រឿង
ញាប់ញ័រ ស្ងប់រម្ងាប់ ដូចជាអន្លង់ទឹកប្រាសចាកខ្យល់ មិនកំរើក
មានចិត្តត្រជាក់ មិនជាប់ចំពាក់ អ្នកចូរមើលចុះ ភិក្ខុនោះ
ឈ្មោះថា នៅជិតព្រះពុទ្ធ ដែលមិនមានតណ្ហាជាគ្រឿងញាប់ញ័រ
មានចិត្តត្រជាក់ មិនជាប់ចំពាក់ក្នុងកាមជាដរាប ។ សូត្រទី ៣ ។

(៩៥) តយោមេ ភិក្ខវេ អគ្គី ។ កតមេ តយោ ។ រាគគ្គិ ទោសគ្គិ មោហគ្គិ ។ ឥមេ ខោ ភិក្ខវេ តយោ អគ្គីតិ ។

រាគគ្គិ ទហតិ មច្ចេ    រត្តេ កាមេសុ មុច្ឆិតេ
ទោសគ្គិ បន ព្យាបន្នេ    នរេ បាណាតិបាតិនោ
មោហគ្គិ បន សម្មូឡ្ហេ    អរិយធម្មេ អកោវិទេ ។
ឯតេ អគ្គី អជានន្តា    សក្កាយាភិរតា បជា
តេ វឌ្ឍយន្តិ និរយំ    តិរច្ឆានញ្ច យោនិយោ
អសុរំ បិត្តិវិសយញ្ច    អមុត្តា មារពន្ធនា ។
យេ ច រត្តិន្ទិវា យុត្តា    សម្មាសម្ពុទ្ធសាសនេ
តេ និព្វាបេន្តិ រាគគ្គី    និច្ចំ អសុភសញ្ញិនោ
ទោសគ្គី បន មេត្តាយ    និព្វាបេន្តិ នរុត្តមា
មោហគ្គី បន បញ្ញាយ    យាយំ និព្វេធគាមិនី[1] ។

---

១ ម. និព្វេធគាមិនំ ។

(៩៩) ម្នាលភិក្ខុទាំងឡាយ ភ្លើងនេះ មាន ៣ យ៉ាង ៗ ភ្លើង ៣ យ៉ាង តើដូចម្តេច ៗ ភ្លើងគឺរាគៈ ១ ភ្លើងគឺទោសៈ ១ ភ្លើងគឺមោហៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ភ្លើងមាន ៣ យ៉ាងនេះឯង ៗ

ភ្លើងគឺរាគៈ រមែងដុតពួកសត្វដែលត្រេកត្រអាលជ្រប់នៅក្នុងកាម ចំណែកភ្លើងគឺទោសៈ រមែងដុតពួកជន ដែលមានចិត្តព្យាបាទ ជាអ្នកសម្លាប់សត្វ ឯភ្លើងគឺមោហៈ រមែងដុតពួកសត្វដែលវង្វេង មិនឈ្លាសវៃក្នុងអរិយធម៌ ៗ ពួកសត្វដែលមិនស្គាល់ភ្លើងទាំងនេះ ជាអ្នកត្រេកត្រអាលក្នុងសក្កាយ (ឧបាទានក្ខន្ធ ៥) រមែងញ៉ាំងភ្លើងទាំងនោះឲ្យចំរើន ទាំងញ៉ាំងនរក តិរច្ឆានកំណើត អសុរកាយ និងបិត្តិវិស័យឲ្យចំរើន មិនផុតចាកចំណងមារបាន ឡើយ ៗ លុះតែបុគ្គលទាំងឡាយណា ប្រកប (ដោយភាវនា) ក្នុងសាសនាព្រះសម្មាសម្ពុទ្ធ ទាំងយប់ទាំងថ្ងៃ បុគ្គលទាំងនោះ មានសេចក្តីសំគាល់ថា មិនស្អាតជានិច្ច ទើបញ៉ាំងភ្លើងគឺរាគៈ ឲ្យរលត់បាន ជាសត្វខ្ពង់ខ្ពស់ជាងជន ទើបញ៉ាំងភ្លើងគឺទោសៈ ឲ្យរលត់ ដោយមេត្តាភាវនាបាន ទាំងញ៉ាំងភ្លើងគឺមោហៈ ឲ្យរលត់ ដោយប្រាជ្ញាជាគ្រឿងទំលុះទំលាយកិលេស ៗ

តេ និព្វាបេត្វា និបកា   រត្តិន្ទិវមតន្ទិតា

អសេសំ បរិនិព្វន្តិ   អសេសំ ទុក្ខមច្ចគុំ ។

អរិយទ្ទសា វេទគុនោ   សម្មទញ្ញាយ បណ្ឌិតា

ជាតិក្ខយមភិញ្ញាយ   នាគច្ឆន្តិ បុនព្ភវន្តិ ។

ចតុត្ថំ[1] ។

(៩៦) តថា តថា ភិក្ខវេ ភិក្ខុ ឧបបរិក្ខេយ្យ យថា យថា[2] ឧបបរិក្ខតោ ពហិទ្ធា ចស្ស វិញ្ញាណំ អវិក្ខិត្តំ អវិសដំ អជ្ឈត្តំ អសណ្ឋិតំ អនុបាទាយ[3] អបរិតស្សតោ អាយតឹ ជាតិជរាមរណទុក្ខសមុទយសម្ភវោ ន ហោតីតិ ។

សត្តសង្គប្បហីនស្ស   នេត្តិច្ឆិន្នស្ស ភិក្ខុនោ

វិក្ខីណោ ជាតិសំសារោ   នត្ថិ អស្ស បុនព្ភវោតិ ។

បញ្ចមំ[4] ។

---

១ ឱ.ម. ចតុត្ថន្តិ នត្ថិ ។ ២ យថា យថាស្សាតិ បាឋោ អដ្ឋកថាយំ ទិស្សតិ ។ ៣ អនុបាទាយ ន បរិតស្សេយ្យាតិ បាឋោ អដ្ឋកថាយំ ទិស្សតិ ។ ៤ ឱ.ម. បញ្ចមន្តិ នត្ថិ ។

លុះភិក្ខុទាំងនោះ មានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មិនខ្ជិល
ប្រុងស ទាំងយប់ទាំងថ្ងៃ រំលត់គ្រឿងកិលេសបានហើយ
រមែងរលត់ទាំងខន្ធ មិនមានសេសសល់ កន្លងផុតនូវទុក្ខ
មិនមានសេសសល់ ។ អ្នកប្រាជ្ញទាំងឡាយ ជាអ្នក
ឃើញនូវអរិយធម៌ (និព្វាន និងសច្ចៈ ៤) ដល់នូវវេទ
ព្រោះដឹងដោយប្រពៃ ដឹងច្បាស់នូវធម៌ ជាគ្រឿងអស់ជាតិ
រមែងមិនវិលមកកាន់ភព ទៀតឡើយ ។ សូត្រ ទី ៤ ។

(៩៦) ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុពិចារណា យ៉ាងណា ៗ ហើយ វិញ្ញាណ មិនរាយមាយ មិនរើរាយទៅខាងក្រៅ ទាំងមិនឋិតនៅខាងក្នុង មិនតក់ស្លុត ព្រោះមិនប្រកាន់មាំ ភិក្ខុគួរពិចារណា យ៉ាងនោះ ៗ ទើបហេតុជាគ្រឿងបង្កឲ្យកើត នៃជាតិទុក្ខ ជរាទុក្ខ និងមរណទុក្ខ មិនមានតទៅ ។

ភិក្ខុដែលបានលះបង់ នូវគ្រឿងជាប់ចំពាក់ ៧ យ៉ាង កាត់ផ្តាច់
នូវតណ្ហាសម្រាប់នាំទៅកាន់ភព រមែងអស់ការត្រាច់ស្ទាត់ទៅកាន់
ជាតិ ភពថ្មីរបស់ភិក្ខុនោះ មិនមានទៀតឡើយ ។ សូត្រ ទី ៨ ។

(៩៧) តិស្សោ ឥមា ភិក្ខវេ កាមូបបត្តិយោ ។ កតមា តិស្សោ ។ បច្ចុបដ្ឋិតកាមា និម្មានរតិនោ បរនិម្មិតវសវត្តិនោ ។ ឥមា ខោ ភិក្ខវេ តិស្សោ កាមូបបត្តិយោតិ ។

បច្ចុបដ្ឋិតកាមា ច យេ ទេវា វសវត្តិនោ
និម្មានរតិនោ ទេវា យេ ចញ្ញេ កាមភោគិនោ
ឥត្ថភាវញ្ញថាភាវំ កាមភោគេសុ បណ្ឌិតា
សព្វេ បរិច្ចជេ កាមេ យេ ទិព្វា យេ ច មានុសា
បិយរូបសាតគធិតំ ឆេត្វា សោតំ ទុរច្ចយំ(១)
អសេសំ បរិនិព្វន្តិ អសេសំ ទុក្ខមច្ចគុំ
អរិយទ្ទសា វេទគុនោ សម្មទញ្ញាយ បណ្ឌិតា
ជាតិក្ខយមភិញ្ញាយ នាគច្ឆន្តិ បុនព្ភវន្តិ ។

ឆដ្ឋំ(២) ។

---

១ ម. ទុរច្ចយំ ។ ២ ឱ. ម. ឆដ្ឋិ ខត្តិ ។

(៩៧) ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃកាមនេះ មាន ៣ ។ ការកើតឡើងនៃកាម ៣ តើដូចម្តេច ។ គឺពួកសត្វដែលមានកាមតាំងឡើងចំពោះ ១ ពួកសត្វដែលកើត ក្នុងឋាននិម្មានរតី (ត្រេកអរចំពោះកាមដែលនិម្មិតដោយខ្លួនឯង) ១ ពួកសត្វដែលកើតក្នុងឋានបរ-និម្មិតវសវត្តិ (ប្រព្រឹត្តទៅក្នុងអំណាចនៃកាមដែលអ្នកដទៃនិម្មិតឲ្យ) ១ ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃកាម មាន ៣ នេះឯង ។

ពួកសត្វដែលមានកាមតាំងឡើងចំពោះក្តី ពួកទេវតាណាដែលកើតក្នុងឋានបរនិម្មិតវសវត្តិក្តី ពួកទេវតាណា ដែលកើតក្នុងឋាននិម្មានរតីក្តី នឹងពួកសត្វណាដទៃក្រៅអំពីនេះ ដែលជាអ្នកបរិភោគនូវកាមក្តី (ពួកសត្វទាំងអស់នោះ) មិនកន្លងនូវការបាននៃភពនេះហើយប្រែទៅជាដទៃ ព្រោះការបរិភោគកាមបានឡើយ (ព្រោះហេតុនោះ) កាមទាំងឡាយណា ជារបស់ទិព្វក្តី កាមទាំងឡាយណា ជារបស់មនុស្សក្តី អ្នកប្រាជ្ញលះបង់នូវកាមទាំងអស់នោះ កាត់ផ្តាច់នូវខ្សែគឺតណ្ហាជាគ្រឿងជាប់ចំពាក់ ដោយសេចក្តីកែពយក្នុងរូបជាទីស្រឡាញ់ ដែលពួកបុគ្គលឆ្លងបានដោយក្រ ហើយរលត់ មិនមានសេសសល់ កន្លងនូវទុក្ខ មិនមានសេសសល់ ពួកអ្នកប្រាជ្ញ ជាអ្នកឃើញនូវអរិយធម៌ ដល់នូវវេទ ព្រោះដឹងដោយប្រពៃ ដឹងច្បាស់នូវធម៌ជាគ្រឿងអស់ជាតិ រមែងមិនវិលមកកាន់ភពថ្មី ទៀតឡើយ ។ សូត្រទី ៦ ។

(៩៨) កាមយោគយុត្តោ ភិក្ខវេ ភវយោគយុត្តោ អាគាមី ហោតិ អាគន្ត្វា(១) ឥត្ថត្តំ ។ កាមយោគវិសំយុត្តោ ភិក្ខវេ ភវយោគយុត្តោ អនាគាមី ហោតិ អនាគន្ត្វា(២) ឥត្ថត្តំ ។ កាមយោគវិសំយុត្តោ ភិក្ខវេ ភវយោគវិសំយុត្តោ អរហំ(៣) ហោតិ ខីណាសវោតិ ។

កាមយោគេន សំយុត្តា ភវយោគេន ចូភយំ
សត្តា គច្ឆន្តិ សំសារំ ជាតិមរណគាមិនោ ។
យេ ច កាមេ បហន្ត្វាន អប្បត្តា អាសវក្ខយំ
ភវយោគេន សំយុត្តា អនាគាមីតិ វុច្ចរេ ។
យេ ច ខោ ឆិន្នសំសយា(៤) ខីណមានបុនព្ភវា
តេ វេ បារគតា លោកេ យេ បត្តា អាសវក្ខយន្តិ ។

សត្តមំ(៥) ។

---

១ ឱ. អាគន្តា ។ ២ ឱ. អនាគន្តា ។ ៣ ឱ.ម. អរហា ។ ៤ ម. ឆិន្នសំសាភ ។
៥ ឱ.ម. សត្តមន្តិ ឧត្តំ ។ តតិយភាណវារន្តិ ទិស្សតិ ។

(៩៨) ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រកបដោយកាមយោគៈ (កិលេសជាគ្រឿងប្រកបគឺតម្រេកក្នុងបញ្ចកាមគុណ) ប្រកបដោយភវយោគៈ (កិលេសជាគ្រឿងប្រកប គឺតម្រេកក្នុងរូបភពនិងអរូបភព) ឈ្មោះថា អាគាមិបុគ្គល ព្រោះនៅមកកាន់អត្តភាពជាមនុស្សនេះវិញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រាសចាកកាមយោគៈ តែប្រកបដោយភវយោគៈ ឈ្មោះថា អនាគាមិបុគ្គល ព្រោះមិនមកកាន់អត្តភាពជាមនុស្សទៀត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រាសចាកកាមយោគៈ ប្រាសចាកភវយោគៈ ឈ្មោះថា អរហន្ត អស់អាសវៈហើយ ។

ពួកសត្វ ដែលប្រកបដោយកាមយោគៈ និងភវយោគៈទាំងពីរ
ជាសត្វប្រព្រឹត្តទៅដើម្បីជាតិ និងមរណៈ រមែងអន្ទោលទៅ
កាន់សង្សារ ។ ចំណែកពួកសត្វណា បានលះបង់នូវកាម
ទាំងឡាយ តែមិនទាន់ដល់នូវការអស់ទៅនៃអាសវៈ នៅប្រកប
ដោយភវយោគៈនៅឡើយ ពួកសត្វនោះហៅថា អនាគាមិ-
បុគ្គល ។ លុះតែពួកសត្វណា បានកាត់នូវសេចក្តីសង្ស័យ
អស់សេចក្តីប្រកាន់ក្នុងភពថ្មីហើយ ឬពួកសត្វណា ដែល
បានដល់នូវការអស់ទៅនៃអាសវៈក្នុងលោក ពួកសត្វនោះឯង
ឈ្មោះថា បានដល់នូវត្រើយគឺព្រះនិព្វាន ។ សូត្រទី ៧ ។

(៩៧) កល្យាណសីលោ ភិក្ខវេ ភិក្ខុ កល្យាណធម្មោ កល្យាណបញ្ញោ ឥមស្មឹ ធម្មវិនយេ កេវលី វុសិតវា ឧត្តមបុរិសោតិ វុច្ចតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ កល្យាណសីលោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ឯវំ ខោ ភិក្ខវេ ភិក្ខុ កល្យាណសីលោ ហោតិ ។ ឥតិ កល្យាណសីលោ ។ កល្យាណធម្មោ ច កថំ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សត្តន្នំ ពោធិបក្ខិកានំ(១) ធម្មានំ ភាវនានុយោគមនុយុត្តោ វិហរតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ កល្យាណធម្មោ ហោតិ ។ ឥតិ កល្យាណសីលោ កល្យាណធម្មោ ។ កល្យាណបញ្ញោ ច កថំ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ កល្យាណបញ្ញោ ហោតិ ។

---

១ ឱ.ម. សត្តន្នំ ពោធិបក្ខិកានំ ។

(៩៩) ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសីលល្អ មានធម៌ល្អ មានប្រាជ្ញាល្អ បានប្រព្រឹត្តមគ្គព្រហ្មចរិយៈ ចប់សព្វគ្រប់ហើយ ហៅថាជាបុរសដ៏ខ្ពង់ខ្ពស់ ក្នុងធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសីលល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល បានសង្រួម ដោយការសង្រួមក្នុងបាតិមោក្ខ បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញភ័យក្នុងទោសបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសីលល្អ យ៉ាងនេះឯង ។ ដូច្នេះ ហៅថា ភិក្ខុមានសីលល្អ ។ ភិក្ខុមានធម៌ល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រកបរឿយៗ នូវការចំរើននូវពោធិបក្ខិយធម៌ ៣៧ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានធម៌ល្អយ៉ាងនេះឯង។ ដូច្នេះ ហៅថា ភិក្ខុមានសីលល្អ មានធម៌ល្អ ។ ភិក្ខុមានប្រាជ្ញាល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានប្រាជ្ញាល្អ យ៉ាងនេះឯង ។

ឥតិវុត្តកេ តិកនិបាតស្ស បញ្ចមវគ្គស្ស អដ្ឋមសុត្តំ

ឥតិ កល្យាណសីលោ កល្យាណធម្មោ កល្យាណ-
បញ្ញោ ឥមស្មឹ ធម្មវិនយេ កេវលី វុសិតវា ឧត្តម-
បុរិសោតិ វុច្ចតីតិ ។

យស្ស កាយេន វាចាយ មនសា នត្ថិ ទុក្កដំ
តំ វេ កល្យាណសីលោតិ អាហុ ភិក្ខុំ ហិរីមតំ[(១)] ។
យស្ស ធម្មា សុភាវិតា បត្តសម្ពោធិគាមិនោ
តំ វេ កល្យាណធម្មោតិ អាហុ ភិក្ខុំ អនុស្សទំ ។
យោ ទុក្ខស្ស បជានាតិ ឥធេវ ខយមត្តនោ
តំ វេ កល្យាណបញ្ញោតិ អាហុ ភិក្ខុំ អនាសវំ
តេហិ ធម្មេហិ សម្បន្នំ អនីឃំ ឆិន្នសំសយំ
អសិតំ សព្វលោកស្ស អាហុ សព្វប្បហាយិនន្តិ ។

អដ្ឋមំ[(២)] ។

---

១ ម. ហិរិមនំ ។ ២ ឱ.ម. អដ្ឋមន្តិ ឧត្តិ ។

ភិក្ខុដែលមានសីលល្អ មានធម៌ល្អ មានប្រាជ្ញាល្អ បានប្រព្រឹត្ត មគ្គព្រហ្មចរិយៈ ចប់សព្វគ្រប់ហើយ ហៅថាជាឧត្តមបុរស ក្នុងធម្មវិន័យនេះ ដូច្នេះឯង ។

ភិក្ខុណា មិនមានអំពើអាក្រក់ ដោយកាយ ដោយវាចា
ដោយចិត្ត អ្នកប្រាជ្ញ ហៅភិក្ខុនោះ ដែលមានសេចក្ដីខ្មាស
បាប ថាជាអ្នកមានសីលល្អ ដោយពិត ។ ធម៌ទាំងឡាយ
ប្រព្រឹត្តទៅ ដើម្បីសម្រេចសម្ពោធិញ្ញាណ ដែលភិក្ខុណា
បានចំរើនដោយល្អ ហើយ អ្នកប្រាជ្ញហៅភិក្ខុនោះ ដែលមិន
មានកិលេសក្រាស់ ថាជាអ្នកមានធម៌ល្អដោយពិត ។ ភិក្ខុណា
ដឹងច្បាស់នូវធម៌ជាគ្រឿងអស់ទៅនៃទុក្ខរបស់ខ្លួន ក្នុងលោក
នេះ អ្នកប្រាជ្ញ ហៅភិក្ខុនោះ ដែលមិនមានអាសវៈ ថាជាអ្នក
មានប្រាជ្ញាល្អ ដោយពិត អ្នកប្រាជ្ញ ពោលនូវភិក្ខុដែល
បរិបូណ៌ ដោយធម៌ទាំងឡាយនោះ ជាអ្នកមិនមានទុក្ខ អស់
សេចក្ដីសង្ស័យ លះបង់នូវកិលេសទាំងពួង ថាជាអ្នកមិន
អាស្រ័យដោយតណ្ហាទិដ្ឋិ ក្នុងលោកទាំងពួង ។ សូត្រ ទី ៨ ។

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ឥតិវុត្តកំ

[១០០] ទ្វេមានិ ភិក្ខវេ ទានានិ អាមិសទានំ ច ធម្មទានំ ច ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ ទានានំ យទិទំ ធម្មទានំ ។ ទ្វេមេ ភិក្ខវេ សំវិភាគា អាមិសសំវិភាគោ ច ធម្មសំវិភាគោ ច ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ សំវិភាគានំ យទិទំ ធម្មសំវិភាគោ ។ ទ្វេមេ ភិក្ខវេ អនុគ្គហា អាមិសានុគ្គហោ ច ធម្មានុគ្គហោ ច ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ អនុគ្គហានំ យទិទំ ធម្មានុគ្គហោតិ ។

យមាហុ ទានំ បរមំ អនុត្តរំ
យំ សំវិភាគំ ភគវា អវណ្ណយិ
អគ្គម្ហិ ខេត្តម្ហិ បសន្នចិត្តោ
វិញ្ញូ បជានំ កោ ន យជេថ កាលេ ។
យេ ចេវ ភាសន្តិ សុណន្តិ ចូភយំ
បសន្នចិត្តា សុគតស្ស សាសនេ
តេសំ សោ អត្ថោ បរមោ វិសុជ្ឈតិ
យេ អប្បមត្តា សុគតស្ស សាសនេតិ ។

ឆវិមំ[១] ។

---

១ ឱ.ម. ឥមេន្តិ នត្ថិ ។

(១០០) ម្នាលភិក្ខុទាំងឡាយ ទាននេះមាន ២ យ៉ាង គឺអាមិសទាន ១ ធម្មទាន ១ ម្នាលភិក្ខុទាំងឡាយ បណ្តាទានទាំង ២ យ៉ាងនេះ ធម្មទាន ប្រសើរជាង ។ ម្នាលភិក្ខុទាំងឡាយ ការចែកនេះ មាន ២ យ៉ាង គឺការចែកអាមិសៈ ១ ការចែកធម៌ ១ ម្នាលភិក្ខុទាំងឡាយ បណ្តាការចែកទាំង ២ នេះ ការចែកធម៌ ប្រសើរជាង ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីអនុគ្រោះនេះ មាន ២ យ៉ាង គឺសេចក្តីអនុគ្រោះ ដោយអាមិសៈ ១ សេចក្តីអនុគ្រោះ ដោយធម៌ ១ ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីអនុគ្រោះទាំង ២ យ៉ាងនេះ សេចក្តីអនុគ្រោះ ដោយធម៌ ប្រសើរជាង ។

ព្រះមានព្រះភាគ ពោលសរសើរ នូវទានណា ថាជាទាន
ឧត្តម ប្រសើរលើស ត្រាស់សរសើរ នូវការចែកណា
(ថាជារបស់ឧត្តម ប្រសើរលើស) អ្នកប្រាជ្ញ មានចិត្ត
ជ្រះថ្លា ចំពោះបុញ្ញក្ខេត្តដ៏ប្រសើរ កាលបើដឹងច្បាស់ហើយ
នរណា ទឹងមិនបូជា ក្នុងកាលដែលគួរ ។ ពួកសត្វណា
សំដែងផង ស្តាប់ផង ទាំងពីរពួក មានចិត្តជ្រះថ្លា ក្នុង
សាសនាព្រះសុគត (មួយទៀត) ពួកសត្វណា មិនធ្វេស
ប្រហែសក្នុងសាសនាព្រះសុគត ប្រយោជន៍ដ៏សំខាន់នោះ
របស់ពួកទាំងនោះ រមែងបរិសុទ្ធ ។ សូត្រទី ៩ ។

## ឥតិវុត្តកេ តិកនិបាតស្ស បញ្ចមវគ្គស្ស ទសមសុត្តំ

(១០១)[១] ធម្មេនាហំ ភិក្ខវេ តេវិជ្ជំ ព្រាហ្មណំ បញ្ញាបេមិ នាញ្ញំ លបិតលាបនមត្តេន ។ កថញ្ចាហំ ភិក្ខវេ ធម្មេន តេវិជ្ជំ ព្រាហ្មណំ បញ្ញាបេមិ នាញ្ញំ លបិតលាបនមត្តេន ។ ឥធ ភិក្ខវេ ភិក្ខុ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសម្បិ ជាតិយោ តឹសម្បិ ជាតិយោ ចត្តាឡីសម្បិ ជាតិយោ បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសតសហស្សម្បិ អនេកេបិ សំវដ្តកប្បេ អនេកេបិ វិវដ្តកប្បេ អនេកេបិ សំវដ្តវិវដ្តកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។

---

១ ម. យ. ឯត្ថ ឋានេ វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតន្តិ ឥមេ បាឋា ទិស្សន្តិ ។

(១០១) ម្នាលភិក្ខុទាំងឡាយ តថាគតបញ្ញត្តនូវបុគ្គលអ្នកបានត្រៃវិជ្ជា ដោយធម៌ ថាជាព្រាហ្មណ៍ មិនបញ្ញត្តនូវបុគ្គលដទៃថាជាព្រាហ្មណ៍ ដោយគ្រាន់តែពាក្យពោលនឹងបង្ហាញនូវមន្តប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតបញ្ញត្តនូវបុគ្គលអ្នកបានត្រៃវិជ្ជា ដោយធម៌ ថាជាព្រាហ្មណ៍ មិនបញ្ញត្តនូវបុគ្គលដទៃ ថាជាព្រាហ្មណ៍ ដោយគ្រាន់តែពាក្យពោល នឹងបង្ហាញនូវមន្តប៉ុណ្ណោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រលឹកជាតិដែលបានអាស្រ័យនៅក្នុងកាលមុនជាច្រើនប្រការ គឺ រលឹកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១០០០ ជាតិខ្លះ ១ សែនជាតិខ្លះ រលឹកបានច្រើនសំវដ្តកប្បខ្លះ ច្រើនវិវដ្តកប្បខ្លះ ច្រើនសំវដ្តវិវដ្តកប្បខ្លះ ថាអាត្មាអញបានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុងភពនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ ក៏បានមកកើតក្នុងភពនេះ ភិក្ខុនោះរលឹកតាមនូវជាតិដែលអាស្រ័យនៅក្នុងកាលមុនបានជាច្រើនប្រការ ព្រមទាំងអាការៈ ព្រមទាំងឧទ្ទេសយ៉ាងនេះ ។

អយមស្ស បឋមា វិជ្ជា អធិគតា ហោតិ អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន ។ បេ ។ យថាកម្មូបគេ សត្តេ បជានាតិ ។

នេះ ជាវិជ្ជាទី ១ ដែលភិក្ខុនោះបានហើយ អវិជ្ជាខ្ចាត់បាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតខ្ចាត់បាត់ទៅ ពន្លឺក៏កើតឡើង ដល់ភិក្ខុនោះ ដែលមិនប្រហែសធ្វេស ខំព្យាយាមដុតកំដៅកិលេស មានបហិតត្តមូលស្ងួន ( ឥតមាននឹកនា ដល់កាយនិងជីវិតឡើយ ) ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុ មានចក្ខុទិព្វ បរិសុទ្ធ កន្លងបង់ចក្ខុជារបស់មនុស្ស ពិចារណាឃើញនូវសត្វទាំងឡាយ ដែលកំពុងច្យុត កំពុងកើត ទាបថោកនិងឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្មថា អើហ្ន៎ សត្វទាំងអម្បាលនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលព្រះអរិយៈទាំងឡាយ ជាមិច្ឆាទិដ្ឋិ ប្រកាន់មាំនូវកម្មជាមិច្ឆាទិដ្ឋិ លុះសត្វទាំងនោះ បែកធ្លាយរាងកាយ ស្លាប់ទៅ បានទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក អើហ្ន៎ ចំណែកសត្វទាំងអម្បាលនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត មិនតិះដៀលព្រះអរិយៈទាំងឡាយ ជាសម្មាទិដ្ឋិ ប្រកាន់មាំនូវកម្មជាសម្មាទិដ្ឋិ លុះសត្វទាំងនោះ បែកធ្លាយរាងកាយ ស្លាប់ទៅ បានទៅកើត ឯសុគតិ សួគ៌ ទេវលោក ភិក្ខុនោះ មានចក្ខុទិព្វ បរិសុទ្ធ កន្លងបង់ចក្ខុជារបស់មនុស្សធម្មតា ។ បេ ។ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម ដោយប្រការៈ ដូច្នេះ ។

អយមស្ស ទុតិយា វិជ្ជា អធិគតា ហោតិ អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ អយមស្ស តតិយា វិជ្ជា អធិគតា ហោតិ អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បម-ត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។ ឯវំ ខោ អហំ ភិក្ខវេ ធម្មេន តេវិជ្ជំ ព្រាហ្មណំ បញ្ញាបេមិ នាញ្ញំ លបិតលាបនមត្តេនាតិ ។[១]

បុព្វេនិវាសំ យោ វេទិ[២] សគ្គាបាយញ្ច បស្សតិ
អថោ ជាតិក្ខយំ បត្តោ អភិញ្ញាវោសិតោ មុនិ ។
ឯតាហិ តីហិ វិជ្ជាហិ តេវិជ្ជោ ហោតិ ព្រាហ្មណោ

---

១ ឱ.ម. ឥតោ បរំ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតីតិ ឥមេ បាឋា ទិស្សន្តិ ។

២ ឱ. ឯត្ថ ហេដ្ឋា បុព្វេនិវាសំ យោ វេទិ សគ្គាបាយញ្ច ព្រាហ្មណំ បញ្ញាបេមិ ន ០ អញ្ញំ លបិតលាបនមត្តេនាតិ អយមេវ គាថា ទិស្សតិ ។

នេះជាវិជ្ជាទី ២ ដែលភិក្ខុនោះបានហើយ អវិជ្ជា ខ្ចាត់បាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតខ្ចាត់បាត់ទៅ ពន្លឺក៏កើតឡើង ដល់ភិក្ខុនោះ ដែលមិនប្រហែសធ្វេស ខំព្យាយាមដុតកំដៅកិលេស មានចិត្តមូលស្មឹង ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុបានធ្វើឲ្យជាក់ច្បាស់ សម្រេចដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ នឹងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។ នេះ ជាវិជ្ជាទី ៣ ដែលភិក្ខុនោះបានហើយ អវិជ្ជាខ្ចាត់បាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតខ្ចាត់បាត់ទៅ ពន្លឺក៏កើតឡើង ដល់ភិក្ខុនោះ ដែលមិនប្រហែសធ្វេស ខំព្យាយាមដុតកំដៅកិលេស មានចិត្តមូលស្មឹង ។ ម្នាលភិក្ខុទាំងឡាយ តថាគត បញ្ញត្តនូវបុគ្គលអ្នកបានត្រៃវិជ្ជា ដោយធម៌ ថាជាព្រាហ្មណ៍ មិនបញ្ញត្តនូវបុគ្គលដទៃ ថាជាព្រាហ្មណ៍ ដោយគ្រាន់តែពាក្យពោលនឹងបង្ហាញនូវមន្តប៉ុណ្ណោះទេ យ៉ាងនេះឯង ។

បុគ្គលណា បានដឹងនូវខន្ធសន្តាន ដែលអាស្រ័យនៅក្នុងកាល
មុន ទាំងឃើញនូវឋានសួគ៌និងអបាយ ទាំងបានដល់នូវការ
អស់ទៅនៃជាតិ ជាខាងក្រោយ បុគ្គលនោះ ឈ្មោះថាអ្នកប្រាជ្ញ
បានញុំាងកិច្ចឲ្យសម្រេច ព្រោះដឹងច្បាស់នូវចតុសច្ចធម៌ ។
ព្រាហ្មណ៍ (ណា) ជាអ្នកបានត្រៃវិជ្ជា ដោយវិជ្ជា ៣ នុ៎ះ

តមហំ វទាមិ តេវិជ្ជំ នាញ្ញំ លបិតលាបនន្តិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

នវមំ(១) ។

បញ្ចមវគ្គោ ។

## តស្សុទ្ទានំ

បសាទជីវិតសង្ឃាដិ អគ្គិ ឧបបរិក្ខយា

ឧបបត្តិកាមកល្យាណំ ធាតុំ ជម្មេន តេ ទសាតិ ។

តិកនិបាតោ និដ្ឋិតោ ។

---

១ ឱ. ម. ទសមត្តិ នត្ថិ ។

តថាគតហៅ នូវព្រាហ្មណ៍ អ្នកបានត្រៃវិជ្ជានោះ ថាជា

ព្រាហ្មណ៍ មិនហៅនូវបុគ្គលដទៃ ដែលជាអ្នកពោល

ទឹងបណ្ដាញនូវមន្ត ថាជាព្រាហ្មណ៍ឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ។ សូត្រទី ១០ ។

ចប់ បញ្ចមវគ្គ ។

## ឧទ្ទាននៃបញ្ចមវគ្គនោះគឺ

និយាយអំពី សេចក្តីជ្រះថ្លា ១ ការចិញ្ចឹមជីវិត ១ សង្ឃាដី ១ ភ្លើង ១ ការពិចារណា ១ ការកើតឡើងនៃកាម ១ កាមយោគៈ ១ សីលល្អ ១ ទាន ១ ព្រាហ្មណ៍ដោយធម៌ ១ ត្រូវជា ១០ ។

ចប់ តិកនិបាត ។

# ឥតិវុត្តកេ ចតុក្កនិបាតោ

(១០២) វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ អហមស្មិ ភិក្ខវេ ព្រាហ្មណោ យាចយោគោ សទា បយតបាណី អន្តិមទេហធរោ អនុត្តរោ ភិសក្កោ សល្លកត្តោ តស្ស មេ តុម្ហេ បុត្តា ឱរសា មុខតោ ជាតា ធម្មជា ធម្មនិម្មិតា ធម្មទាយាទា នោ អាមិសទាយាទា ។ ទ្វេមានិ ភិក្ខវេ ទានានិ អាមិសទានញ្ច ធម្មទានញ្ច ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ ទានានំ យទិទំ ធម្មទានំ ។ ទ្វេមេ ភិក្ខវេ សំវិភាគា អាមិសសំវិភាគោ ច ធម្មសំវិភាគោ ច ឯតទគ្គំ ភក្ខវេ ឥមេសំ ទ្វិន្នំ សំវិភាគានំ យទិទំ ធម្មសំវិភាគោ ។ ទ្វេមេ ភិក្ខវេ អនុគ្គហា អាមិសានុគ្គហោ ច ធម្មានុគ្គហោ ច ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ អនុគ្គហានំ យទិទំ ធម្មានុគ្គហោ ។ ទ្វេមេ ភិក្ខវេ យាគា អាមិសយាគោ ច ធម្មយាគោ ច ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ យាគានំ យទិទំ ធម្មយាគោតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

# ឥតិវុត្តកៈ ទុកនិបាត

(១០៦) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតជាព្រាហ្មណ៍ គួរគេសូមបាន មានដៃលាងស្អាតគ្រប់កាល ទ្រទ្រង់នូវអត្តភាពជាទីបំផុត ជាពេទ្យវះកាត់យ៉ាងប្រសើរ អ្នកទាំងឡាយ ជាបុត្តជាឱរស កើតអំពីមាត់តថាគត កើតអំពីធម៌ មានធម៌តាក់តែងហើយ មានធម៌ជាមត៌ក មិនមានអាមិសៈជាមត៌កឡើយ ។ ម្នាលភិក្ខុទាំងឡាយ ទាននេះមាន ២ គឺ អាមិសទាន ១ ធម្មទាន ១ ម្នាលភិក្ខុទាំងឡាយ បណ្តាទានទាំង ២ នេះ ធម្មទានប្រសើរជាង ។ ម្នាលភិក្ខុទាំងឡាយ ការចែកនេះមាន ២ គឺការចែកអាមិសៈ ១ ការចែកធម៌ ១ ម្នាលភិក្ខុទាំងឡាយ បណ្តាការចែកទាំង ២ នេះ ការចែកធម៌ប្រសើរជាង ។ ម្នាលភិក្ខុទាំងឡាយ ការអនុគ្រោះនេះ មាន ២ គឺការអនុគ្រោះដោយអាមិសៈ ១ ការអនុគ្រោះដោយធម៌ ១ ម្នាលភិក្ខុទាំងឡាយ បណ្តាការអនុគ្រោះ ទាំង ២ នេះ ការអនុគ្រោះដោយធម៌ប្រសើរជាង ។ ម្នាលភិក្ខុទាំងឡាយ ការបូជានេះមាន ២ គឺការបូជាដោយអាមិស ១ ការបូជាដោយធម៌ៈ ១ ម្នាលភិក្ខុទាំងឡាយ បណ្តាការបូជាទាំង ២ នេះ ការបូជាដោយធម៌ប្រសើរជាង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

យោ ធម្មយាគំ អយជី អមច្ឆរី

តថាគតោ សព្វសត្តានុកម្បី

តំ តាទិសំ ទេវមនុស្សសេដ្ឋំ

សត្តា នមស្សន្តិ ភវស្ស បារគុន្តិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

បឋមំ[១] ។

(១០៣) ចត្តារិមានិ ភិក្ខវេ អប្បានិ ចេវ សុលភានិ ច តានិ ច អនវជ្ជានិ ។ កតមានិ ចត្តារិ ។ បំសុកូលំ ភិក្ខវេ ចីវរានំ អប្បញ្ច សុលភញ្ច តញ្ច អនវជ្ជំ ។ បិណ្ឌិយាលោបោ ភិក្ខវេ ភោជនានំ អប្បញ្ច សុលភញ្ច តញ្ច អនវជ្ជំ ។ រុក្ខមូលំ ភិក្ខវេ សេនាសនានំ អប្បញ្ច សុលភញ្ច តញ្ច អនវជ្ជំ ។ បូតិមុត្តំ ភិក្ខវេ ភេសជ្ជានំ អប្បញ្ច សុលភញ្ច តញ្ច អនវជ្ជំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ អប្បានិ ចេវ

---

១ ឱម បឋមន្តិ នត្ថិ ។

ព្រះតថាគតអង្គណា មិនមានព្រះទ័យកំណាញ់ មានការអនុៈ
គ្រោះដល់សព្វសត្វ បានប្រោសប្រទានធម៌ សត្វទាំងឡាយ
តែងនមស្ការព្រះតថាគតនោះ ប្រាកដដូច្នោះ ព្រះអង្គ
ប្រសើរជាងទេវតានឹងមនុស្ស ទ្រង់ដល់នូវត្រើយនៃភព ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ។ សូត្រ ទី ១ ។

(១០៣) ម្នាលភិក្ខុទាំងឡាយ វត្ថុដែលតិចតួចផង ងាយបានផង វត្ថុទាំងនោះ មិនមានទោសផង នេះ មាន ៤ ។ វត្ថុទាំង ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បណ្តាចីវរទាំងឡាយ បំសុកូលចីវរ ជារបស់តិចតួចផង ងាយបានផង ចីវរនោះ ជារបស់មិនមានទោសផង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាភោជនទាំងឡាយ បិណ្ឌិយាលោបភោជន[១] ជារបស់តិចតួចផង ងាយបានផង ភោជននោះជារបស់មិនមានទោសផង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសេនាសនៈទាំងឡាយ រុក្ខមូលសេនាសនៈ ជារបស់តិចតួចផង ងាយបានផង សេនាសនៈនោះ ជារបស់មិនមានទោសផង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាភេសជ្ជៈទាំងឡាយ ទឹកមូត្រស្អុយ ជារបស់តិចតួចផង ងាយបានផង ទឹកមូត្រនោះ ជារបស់មិនមានទោសផង ។ ម្នាលភិក្ខុទាំងឡាយ វត្ថុ ៤ នេះឯង ជារបស់តិចតួចផង

---

១ ភោជនដែលបានដោយកំលាំងនៃស្លង ។

សុលភានិ ច តានិ ច អនវជ្ជានិ ។ យតោ ខោ ភិក្ខវេ ភិក្ខុ អប្បេន ច តុដ្ឋោ ហោតិ សុលភេន ច អនវជ្ជេន ច ឥទមស្សាហំ អញ្ញតរំ សាមញ្ញង្គន្តិ វទាមីតិ ។

អនវជ្ជេន តុដ្ឋស្ស អប្បេន សុលភេន ច
ន សេនាសនមារព្ភ ចីវរំ បានភោជនំ
វិឃាតោ ហោតិ ចិត្តស្ស ទិសា នប្បដិហញ្ញតិ ។
យេបស្ស(១) ធម្មា អក្ខាតា សាមញ្ញស្សានុលោមិកា
អធិគ្គហិតា តុដ្ឋស្ស អប្បមត្តស្ស ភិក្ខុនោតិ(២) ។
ទុតិយំ(៣) ។

(១០៤) ជានតោ អហំ ភិក្ខវេ បស្សតោ អាសវានំ ខយំ វទាមិ នោ អជានតោ នោ(៤) អបស្សតោ ។ កិញ្ច ភិក្ខវេ ជានតោ កឹ បស្សតោ អាសវានំ ខយោ ហោតិ ។ ឥទំ ទុក្ខន្តិ ភិក្ខវេ ជានតោ បស្សតោ អាសវានំ ខយោ ហោតិ ។

---

១ ឱ.ម. យេចស្ស ។ ២ ម. សិក្ខតោតិ ។ ៣ ឱ.ម. ទុតិយន្តិ នត្ថិ ។ ៤ ឱ.ម. នោតិ នត្ថិ ។

ងាយបានផង វត្ថុទាំងនោះ ជារបស់មិនមានទោសផង ។ ម្នាលភិក្ខុទាំងឡាយ វេលាណា ភិក្ខុត្រេកអរដោយរបស់តិចតួចផង ងាយបានផង មិនមានទោសផង តថាគតពោលនូវគុណណាមួយ របស់ភិក្ខុនេះ ថាជាអង្គនៃសមណភាព ។

កាលបើភិក្ខុត្រេកអរដោយវត្ថុមិនមានទោស ជារបស់តិចតួច ជារបស់ងាយបានហើយ រមែងមានចិត្តមិនចង្អៀតចង្អល់ ព្រោះប្រារព្ធនូវសេនាសនៈ ចីវរ ទឹកនិងភោជនឡើយ ភិក្ខុនោះ មិនទើសទាល់ក្នុងទិសទាំងឡាយឡើយ ។ ធម៌ទាំងឡាយណា ដែលតថាគតពោលទុកហើយ ថាជាធម៌សមគួរដល់សមណភាព ធម៌ទាំងនោះ ភិក្ខុអ្នកសន្តោស មិនប្រហែសធ្វេស បានហើយ ។ សូត្រ ទី ២ ។

(១០៤) ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈទាំងឡាយថា មានដល់ភិក្ខុអ្នកដឹង អ្នកឃើញ មិនពោលថា មានដល់ភិក្ខុ អ្នកមិនដឹង មិនឃើញឡើយ ។ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានដល់ភិក្ខុអ្នកដឹង តើដូចម្តេច អ្នកឃើញ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានដល់ភិក្ខុ អ្នកដឹង អ្នកឃើញថា នេះជាទុក្ខ ។

អយំ ទុក្ខសមុទយោតិ ភិក្ខវេ ជានតោ បស្សតោ អាសវានំ ខយោ ហោតិ ។ អយំ ទុក្ខនិរោធោតិ ភិក្ខវេ ជានតោ បស្សតោ អាសវានំ ខយោ ហោតិ ។ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ ភិក្ខវេ ជានតោ បស្សតោ អាសវានំ ខយោ ហោតិ ។ ឯវំ ខោ ភិក្ខវេ ជានតោ ឯវំ(១) បស្សតោ អាសវានំ ខយោ ហោតីតិ ។

សេក្ខស្ស សិក្ខមានស្ស ឧជុមគ្គានុសារិនោ
ខយស្មឹ បឋមំ ញាណំ តតោ អញ្ញា អនន្តរា(២) ។
តតោ អញ្ញាវិមុត្តស្ស វិមុត្តិញាណមុត្តមំ
ឧប្បជ្ជតិ ខយេ ញាណំ ខីណា សំយោជនា ឥតិ(៣)
ន ត្វេវិទំ កុសីតេន ពាលេនមវិជានតា
និព្វានំ អធិគន្តព្វំ សព្វគន្ថប្បមោចនន្តិ ។

ទុតិយំ(៤) ។

---

១ ឱ.ម. ឯវន្តិ នត្ថិ ។ ២ ម. អនន្តរាតិបិ បាឋោ ។ ៣ ម. ខីណំ សំយោជនំ ឥតិ ។

ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានដល់ភិក្ខុ អ្នកដឹង អ្នកឃើញថា នេះជាហេតុនាំឲ្យកើតទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានដល់ភិក្ខុ អ្នកដឹង អ្នកឃើញថា នេះជាការរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានដល់ភិក្ខុ អ្នកដឹង អ្នកឃើញថា នេះជាបដិបទាប្រព្រឹត្តទៅកាន់ទីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានដល់ភិក្ខុ អ្នកដឹងយ៉ាងនេះ អ្នកឃើញយ៉ាងនេះឯង ។

កាលបើសេក្ខបុគ្គល កំពុងសិក្សា ត្រាច់ទៅតាមផ្លូវដ៏ត្រង់
ញាណទី ១ គឺការអស់ទៅនៃអាសវៈ (ក៏កើតមាន) តអំពី
នោះទៅ អរហត្តមគ្គញាណដ៏ប្រសើរ (ក៏កើតឡើង) ។ កាលភិក្ខុ
មានចិត្តផុតស្រឡះចាកអាសវៈ ដោយសារអរហត្តមគ្គញាណ
នោះហើយ វិមុត្តិញាណដ៏ឧត្តម ក៏កើតឡើង សេចក្តីដឹងក្នុង
ការអស់ទៅថា សំយោជនៈទាំងឡាយ អស់ហើយ ដូច្នេះ
ឯព្រះនិព្វាន ជាគ្រឿងដោះចាកគ្រឿងចំពាក់ទាំងពួងនេះ បុគ្គល
ខ្ជិល ល្ងង់ មិនដឹងច្បាស់ មិនគប្បីបានឡើយ ។ សូត្រទី ៣ ។

### ឥតិវុត្តកេ ចតុក្កនិបាតស្ស ចតុត្ថសុត្តំ

(១០៨) យេ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥទំ ទុក្ខន្តិ យថាភូតំ នប្បជានន្តិ អយំ ទុក្ខសមុទយោតិ យថាភូតំ នប្បជានន្តិ អយំ ទុក្ខនិរោធោតិ យថាភូតំ នប្បជានន្តិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ នប្បជានន្តិ ។ ន មេ តេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ វា សមណសម្មតា ព្រាហ្មណេសុ វា ព្រាហ្មណសម្មតា ន ច បនេតេ អាយស្មន្តោ សាមញ្ញត្ថំ វា ព្រហ្មញ្ញត្ថំ វា ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។ យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥទំ ទុក្ខន្តិ យថាភូតំ បជានន្តិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានន្តិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានន្តិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានន្តិ ។ តេ ច ខោ មេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ ចេវ សមណសម្មតា ព្រាហ្មណេសុ ច ព្រាហ្មណសម្មតា តេ ច បនាយស្មន្តោ សាមញ្ញត្ថញ្ច ព្រហ្មញ្ញត្ថញ្ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។

[១០៨] ម្នាលភិក្ខុទាំងឡាយ ពួកសមណៈ ឬព្រាហ្មណ៍ណាមួយ មិនដឹងច្បាស់តាមពិតថា នេះជាទុក្ខ មិនដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ មិនដឹងច្បាស់តាមពិតថា នេះជាទីរលត់ទុក្ខ មិនដឹងច្បាស់តាមពិតថា នេះជាបដិបទា ប្រព្រឹត្តទៅកាន់ទីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ទាំងនោះ តថាគតមិនសន្មតថាជាសមណៈ ក្នុងពួកសមណៈ មិនសន្មតថាជាព្រាហ្មណ៍ ក្នុងពួកព្រាហ្មណ៍ឡើយ មួយទៀត លោកដ៏មានអាយុទាំងនោះ រមែងមិនធ្វើឲ្យជាក់ច្បាស់ សម្រេចដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវសាមញ្ញប្រយោជន៍ គឺអរិយមគ្គ ៤ នឹងព្រហ្មញ្ញប្រយោជន៍ គឺអរិយផល ៤ បានឡើយ ។ ម្នាលភិក្ខុទាំងឡាយ លុះតែពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះជាទីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាបដិបទាប្រព្រឹត្តទៅ កាន់ទីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ទាំងនោះ ទើបតថាគតសន្មតថាជាសមណៈ ក្នុងពួកសមណៈ សន្មតថាជាព្រាហ្មណ៍ ក្នុងពួកព្រាហ្មណ៍បាន មួយវិញទៀត លោកដ៏មានអាយុទាំងនោះ រមែងធ្វើឲ្យជាក់ច្បាស់ សម្រេចដោយប្រាជ្ញា ដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវសាមញ្ញប្រយោជន៍ នឹងព្រហ្មញ្ញប្រយោជន៍បាន ។

យេ ទុក្ខំ នប្បជានន្តិ អថោ ទុក្ខស្ស សម្ភវំ
យត្ថ ច សព្ពសោ ទុក្ខំ អសេសំ ឧបរុជ្ឈតិ
តញ្ច មគ្គំ ន ជានន្តិ ទុក្ខូបសមគាមិនំ
ចេតោវិមុត្តិហីនា តេ អថោ បញ្ញាវិមុត្តិយា
អភព្វា តេ អន្តកិរិយាយ តេ វេ ជាតិជរូបគា ។
យេ ច ទុក្ខំ បជានន្តិ អថោ ទុក្ខស្ស សម្ភវំ
យត្ថ ច សព្ពសោ ទុក្ខំ អសេសំ ឧបរុជ្ឈតិ
តញ្ច មគ្គំ បជានន្តិ ទុក្ខូបសមគាមិនំ
ចេតោវិមុត្តិសម្បន្នា អថោ បញ្ញាវិមុត្តិយា
ភព្វា តេ អន្តកិរិយាយ ន តេ ជាតិជរូបគាតិ ។

ចតុត្ថំ (១) ។

(១០៦) យេ តេ ភិក្ខវេ ភិក្ខូ សីលសម្បន្នា សមាធិសម្បន្នា បញ្ញាសម្បន្នា វិមុត្តិសម្បន្នា វិមុត្តិញាណទស្សនសម្បន្នា ឱវាទកា វិញ្ញាបកា សន្ទស្សកា សមាទបកា សមុត្តេជកា សម្បហំសកា អលំ សមក្ខាតារោ សទ្ធម្មស្ស ។

---

១ ឱ.ម. ចតុត្ថំ នត្ថិ ។

ពួកបុគ្គលណា មិនដឹងច្បាស់នូវទុក្ខផង នូវហេតុនាំឲ្យកើតទុក្ខផង នូវទីរលត់ទុក្ខ សព្វគ្រប់ ឥតមានសេសសល់ផង មិនដឹងច្បាស់ នូវផ្លូវប្រព្រឹត្តទៅ កាន់ទីស្ងប់រម្ងាប់ទុក្ខនោះផង ពួកបុគ្គលនោះ រមែងសាបសូន្យ ចាកចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ពួកបុគ្គលនោះ មិនគួរធ្វើនូវទីបំផុតនៃទុក្ខបានឡើយ ពួកបុគ្គលនោះ ចូលទៅកាន់ជាតិនិងជរាដោយពិត ៗ លុះតែពួកបុគ្គលណា ដឹងច្បាស់នូវទុក្ខផង នូវហេតុនាំឲ្យកើតទុក្ខផង នូវទីរលត់ទុក្ខ សព្វគ្រប់ ឥតមានសេសសល់ផង ដឹងច្បាស់ នូវផ្លូវប្រព្រឹត្តទៅ កាន់ទីស្ងប់រម្ងាប់ទុក្ខនោះផង ទើបបរិបូណ៌ ដោយចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ពួកបុគ្គលនោះ គួរធ្វើនូវទីបំផុតនៃទុក្ខបាន ពួកបុគ្គលនោះ មិនចូលទៅកាន់ជាតិនិងជរាឡើយ ។ សូត្រទី ៤ ។

(១០៦) ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា បរិបូណ៌ ដោយសីល បរិបូណ៌ ដោយសមាធិ បរិបូណ៌ ដោយបញ្ញា បរិបូណ៌ ដោយវិមុត្តិ បរិបូណ៌ ដោយវិមុត្តិញាណទស្សនៈ ជាអ្នកទូន្មានពន្យល់ឲ្យដឹង សំដែងបញ្ជាក់ឲ្យឃើញងាយ ណែនាំ ធ្វើឲ្យអង់អាច ធ្វើឲ្យរីករាយ (ក្នុងកុសលធម៌) អាចសំដែង នូវព្រះសទ្ធម្មបាន ។

ឥតិវុត្តកេ ចតុក្កនិបាតស្ស បញ្ចមសុត្តំ

ទស្សនម្បហំ ភិក្ខវេ តេសំ ភិក្ខូនំ ពហុការំ[១] វទាមិ សវនម្បហំ ភិក្ខវេ តេសំ ភិក្ខូនំ ពហុការំ វទាមិ ឧបសង្កមនម្បហំ ភិក្ខវេ តេសំ ភិក្ខូនំ ពហុការំ វទាមិ បយិរុបាសនម្បហំ ភិក្ខវេ តេសំ ភិក្ខូនំ ពហុការំ វទាមិ អនុស្សតិម្បហំ[២] ភិក្ខវេ តេសំ ភិក្ខូនំ ពហុការំ វទាមិ អនុបព្វជ្ជម្បហំ ភិក្ខវេ តេសំ ភិក្ខូនំ ពហុការំ វទាមិ ។ តំ កិស្ស ហេតុ ។ តថារូបេ ភិក្ខវេ ភិក្ខូ សេវតោ ភជតោ បយិរុបាសតោ អបរិបូរោបិ សីលក្ខន្ធោ ភាវនាបារិបូរឹ គច្ឆតិ អបរិបូរោបិ សមាធិក្ខន្ធោ ភាវនាបារិបូរឹ គច្ឆតិ អបរិបូរោបិ បញ្ញាក្ខន្ធោ ភាវនាបារិបូរឹ គច្ឆតិ អបរិបូរោបិ វិមុត្តិក្ខន្ធោ ភាវនាបារិបូរឹ គច្ឆតិ អបរិបូរោបិ វិមុត្តិញាណទស្សនក្ខន្ធោ ភាវនាបារិបូរឹ គច្ឆតិ ។

---

១ ឱ.ម. សព្វត្ថ ពហុបការន្តិ ទិស្សតិ ។ ២ ឱ. ម. អនុស្សរណម្បហំ ។

ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការជួបប្រទះ នូវភិក្ខុទាំងនោះ ថា មានឧបការៈច្រើនផង ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការស្តាប់ នូវភិក្ខុទាំងនោះថា មានឧបការៈច្រើនផង ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការចូលទៅរកភិក្ខុទាំងនោះថា មានឧបការៈច្រើនផង ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការចូលទៅអង្គុយជិតភិក្ខុទាំងនោះ ថាមានឧបការៈច្រើនផង ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការរលឹក នូវភិក្ខុទាំងនោះថា មានឧបការៈច្រើនផង ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការបួសតាមភិក្ខុទាំងនោះថា មានឧបការៈច្រើនផង ។ ដំណើរ នោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលសេពគប់ ចូលទៅអង្គុយជិតពួកភិក្ខុបែបនោះហើយ សីលក្ខន្ធដែលមិនទាន់បរិបូណ៌ រមែងដល់នូវការបរិបូណ៌ ដោយភាវនាផង សមាធិក្ខន្ធដែលមិនទាន់ បរិបូណ៌ រមែងដល់នូវការបរិបូណ៌ដោយភាវនាផង បញ្ញាខន្ធដែលមិនទាន់ បរិបូណ៌ រមែងដល់នូវការបរិបូណ៌ ដោយភាវនាផង វិមុត្តិក្ខន្ធដែលមិនទាន់ បរិបូណ៌ រមែងដល់នូវការបរិបូណ៌ ដោយភាវនាផង វិមុត្តិញាណទស្ស-នក្ខន្ធ ដែលមិនទាន់បរិបូណ៌ រមែងដល់នូវការបរិបូណ៌ ដោយភាវនាផង ។

ឯវរូបា ច តេ ភិក្ខវេ ភិក្ខូ សត្ថារោតិបិ វុច្ចន្តិ សត្ថ-វាហាតិបិ វុច្ចន្តិ រណញ្ជហាតិបិ វុច្ចន្តិ តមោនុទាតិបិ វុច្ចន្តិ អាលោកករាតិបិ វុច្ចន្តិ ឱភាសករាតិបិ វុច្ចន្តិ បជ្ជោតករាតិបិ វុច្ចន្តិ បភង្ករាតិបិ វុច្ចន្តិ ឧក្កាធារាតិបិ វុច្ចន្តិ អរិយាតិបិ វុច្ចន្តិ ចក្ខុមន្តោតិបិ វុច្ចន្តីតិ ។

បាមោជ្ជករណដ្ឋានំ ឯតំ(1) ហោតិ វិជានតំ
យទិទំ ភាវិតត្តានំ អរិយានំ ធម្មជីវិនំ ។
តេ ជោតយន្តិ សទ្ធម្មំ ភាសយន្តិ បភង្ករា
អាលោកករណា ធីរា ចក្ខុមន្តោ រណញ្ជហា ។
យេសំ វេ សាសនំ សុត្វា សម្មទញ្ញាយ បណ្ឌិតា
ជាតិក្ខយមភិញ្ញាយ នាគច្ឆន្តិ បុនព្ភវន្តិ ។

បញ្ចមំ(2) ។

(១០៧) ចត្តារោមេ ភិក្ខវេ តណ្ហុប្បាទា យត្ថ ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ។ កតមេ ចត្តារោ ។ ចីវរហេតុ វា ភិក្ខវេ ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ បិណ្ឌបាតហេតុ វា ភិក្ខវេ ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ

១ ឱ.ម. បាមុជ្ជករណំ ឋានំ ឯវំ ។ ២ ឱ.ម. បញ្ចមន្តិ នត្ថិ ។

ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុបែបនោះ ហៅថា សាស្តាក៏បាន ហៅថា អ្នកនាំទៅនូវពួកក៏បាន ហៅថា អ្នកលះបង់សត្រូវក៏បាន ហៅថា អ្នកបន្ទោបង់ងងឹតក៏បាន ហៅថា អ្នកធ្វើពន្លឺក៏បាន ហៅថា អ្នកធ្វើឲ្យភ្លឺស្វាងក៏បាន ហៅថា អ្នកធ្វើប្រទីបក៏បាន ហៅថា អ្នកធ្វើរស្មីក៏បាន ហៅថា អ្នកត្រោលបំភ្លឺដោយគប់ភ្លើងក៏បាន ហៅថាអរិយៈក៏បាន ហៅថាអ្នកមានចក្ខុក៏បាន ។

ការដែលបានជួបប្រទះជាដើម នូវពួកអរិយៈ ជាអ្នកដឹងច្បាស់
បានបំរើនចិត្ត ចិញ្ចឹមជីវិតតាមធម៌នុ៎ះឯង ជាហេតុធ្វើឲ្យមាន
បាមោជ្ជៈ ។ ពួកអរិយៈនោះ តែងបំភ្លឺ សំដែងនូវព្រះសទ្ធម្ម
អ្នកធ្វើរស្មី ធ្វើពន្លឺ អ្នកមានប្រាជ្ញា មានចក្ខុ លះបង់នូវ
សឹកសត្រូវគឺកិលេស ។ ពួកអ្នកប្រាជ្ញ បានស្តាប់នូវពាក្យ
ប្រដៅ របស់ពួកអរិយៈទាំងនោះហើយ រមែងដឹងច្បាស់
ដោយប្រពៃ ស្គាល់ច្បាស់ នូវធម៌ជាគ្រឿងអស់ទៅនៃជាតិ
ហើយមិនត្រឡប់មកកាន់ភពថ្មីទៀតឡើយ ។ សូត្រទី ៨ ។

(១០៧) ម្នាលភិក្ខុទាំងឡាយ តណ្ហាកាលកើតឡើង ដល់ភិក្ខុ រមែងកើតឡើង ព្រោះវត្ថុជាទីកើតនៃតណ្ហានេះ មាន ៤ ។ វត្ថុជាទីកើតនៃតណ្ហា ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តណ្ហាកាលកើតឡើង ដល់ភិក្ខុ រមែងកើតឡើង ព្រោះហេតុចីវរ ១ ម្នាលភិក្ខុទាំងឡាយ តណ្ហាកាលកើតឡើងដល់ភិក្ខុ រមែងកើតឡើង ព្រោះហេតុបិណ្ឌបាត ១

## ឥតិវុត្តកេ ចតុក្កនិបាតស្ស សត្តមសុត្តំ

សេនាសនហេតុ វា ភិក្ខវេ ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឥតិភវាភវហេតុ វា ភិក្ខវេ ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ តណ្ហុប្បាទា យត្ថ ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតីតិ ។

តណ្ហាទុតិយោ បុរិសោ ទីឃមទ្ធាន សំសរំ
ឥត្ថភាវញ្ញថាភាវំ សំសារំ នាតិវត្តតិ ។
ឯតមាទីនវំ[១] ញត្វា តណ្ហា[២] ទុក្ខស្ស សម្ភវំ
វីតតណ្ហោ អនាទានោ សតោ ភិក្ខុ បរិព្វជេតិ ។

ឆដ្ឋំ[៣] ។

(១០៨) សព្រហ្មកានិ ភិក្ខវេ តានិ កុលានិ យេសំ បុត្តានំ មាតាបិតរោ អជ្ឈាគារេ បូជិតា ហោន្តិ ។ សបុព្វទេវតានិ ភិក្ខវេ តានិ កុលានិ យេសំ បុត្តានំ មាតាបិតរោ អជ្ឈាគារេ បូជិតា ហោន្តិ ។ សបុព្វាចរិយានិ ភិក្ខវេ តានិ កុលានិ យេសំ បុត្តានំ មាតាបិតរោ អជ្ឈាគារេ បូជិតា ហោន្តិ ។

---

១ ឱ.ម. ឯវមាទីនវំ ។ ២ ម. តណ្ហំ ។ ៣ ឱ.ម. ឆដ្ឋន្តិ ឆដ្ឋំ ។

ម្នាលភិក្ខុទាំងឡាយ តណ្ហាកាលកើតឡើង ដល់ភិក្ខុ រមែងកើតឡើង ព្រោះសេនាសនៈ ១ ម្នាលភិក្ខុទាំងឡាយ តណ្ហាកាលកើតឡើង ដល់ភិក្ខុ រមែងកើតឡើង ព្រោះសេចក្តីចំរើនទីងវិនាស ១ ។ ម្នាលភិក្ខុទាំងឡាយ តណ្ហាកាលកើតឡើង ដល់ភិក្ខុ រមែងកើតឡើង ព្រោះវត្ថុជាទីកើតនៃតណ្ហា ៤ នេះឯង ។

បុរសដែលមានតណ្ហាជាគ្នា តែងវង្វេងអស់កាលជាយូរអង្វែង មិនប្រព្រឹត្តកន្លងនូវសង្សារ ដែលមានការប្រែប្រួលឥតឈប់បាន ។ ភិក្ខុបានដឹងច្បាស់ នូវតណ្ហាថាជាហេតុនាំឲ្យកើតទុក្ខ ថាមានទោសយ៉ាងនេះហើយ គួរជាអ្នកមិនមានតណ្ហា មិនមានការប្រកាន់ស្អិត មានស្មារតី ហើយគេចចេញ (ពាក់វន្ត) ។ សូត្រ ទី ៦ ។

(១០៨) ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយណា ដែលកូនបូជាមាតាបិតា ក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងឡាយនោះ ឈ្មោះថា នៅរួមជាមួយនឹងព្រហ្ម ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយណា ដែលកូនបូជាមាតាបិតា ក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងឡាយនោះ ឈ្មោះថា នៅរួមជាមួយនឹងបុព្វទេវតា (ទេវតាដើម) ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយណា ដែលកូនបូជាមាតាបិតាក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងឡាយនោះ ឈ្មោះថា នៅរួមជាមួយនឹងបុព្វាចារ្យ (អាចារ្យដើម) ។

សាហុនេយ្យានិ(១) ភិក្ខវេ តានិ កុលានិ យេសំ បុត្តានំ មាតាបិតរោ អជ្ឈាគារេ បូជិតា ហោន្តិ ។ ព្រហ្មាតិ ភិក្ខវេ មាតាបិតូនំ ឯតំ អធិវចនំ ។ បុព្វទេវតាតិ ភិក្ខវេ មាតាបិតូនំ ឯតំ អធិវចនំ ។ បុព្វាចរិយាតិ ភិក្ខវេ មាតាបិតូនំ ឯតំ អធិវចនំ ។ អាហុនេយ្យាតិ ភិក្ខវេ មាតាបិតូនំ ឯតំ អធិវចនំ ។ តំ កិស្ស ហេតុ ។ ពហុការា ភិក្ខវេ មាតាបិតរោ បុត្តានំ អាបាទកា បោសកា ឥមស្ស(២) ទស្សេតារោតិ ។

ព្រហ្មាតិ មាតាបិតរោ បុព្វាចរិយាតិ វុច្ចរេ
អាហុនេយ្យា ច បុត្តានំ បជាយ អនុកម្បកា ។
តស្មា ហិ នេ នមស្សេយ្យ សក្ករេយ្យ ច បណ្ឌិតោ
អន្នេន អថ បានេន វត្ថេន សយនេន ច
ឧច្ឆាទនេន ន្ហាបនេន(៣) បាទានំ ធោវនេន ច ។
តាយ នំ បារិចរិយាយ មាតាបិតូសុ បណ្ឌិតា(៤)
ឥធេវ នំ បសំសន្តិ បេច្ច សគ្គេ បមោទតីតិ ។

សត្តមំ(៥) ។

---

១ ឱ.ម. សាហុនេយ្យកានិ ។ ២ ឱ.ម. ឯត្តកំ លោកស្សាតិ អត្ថិ ។ ៣ ម. ន្ហាបនេន ។
៤ ឱ.ម. បណ្ឌិតោ ។ ៥ ឱ.ម. សត្តមន្តិ នត្ថិ ។

ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយណា ដែលកូនបូជាមាតាបិតា ក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងឡាយនោះ ឈ្មោះថា នៅរួមជាមួយនឹងអាហុនេយ្យបុគ្គល (បុគ្គលគួរបូជា) ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រហ្មនុ៎ះ ជាឈ្មោះរបស់មាតាបិតា ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា បុព្វទេវតានុ៎ះ ជាឈ្មោះរបស់មាតាបិតា ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា បុព្វាចារ្យនុ៎ះ ជាឈ្មោះរបស់មាតាបិតា ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា អាហុនេយ្យៈនុ៎ះ ជាឈ្មោះរបស់មាតាបិតា ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ (ព្រោះ) មាតាបិតា មានឧបការៈច្រើន ជាអ្នកបីបាច់ (ឲ្យគង់ជីវិត) ជាអ្នកចិញ្ចឹម (ឲ្យបៅទឹកដោះ) ទាំងជាអ្នកបង្ហាញនូវលោកនេះ ដល់កូនទាំងឡាយ ។

មាតាបិតាទាំងឡាយ ដែលហៅថា ព្រហ្មក្តី បុព្វាចារ្យក្តី អាហុនេយ្យៈក្តី (សុទ្ធតែ) ជាអ្នកអនុគ្រោះដល់ពួកសត្វ គឺកូន ។ ព្រោះហេតុនោះឯង អ្នកប្រាជ្ញ គួរនមស្ការ គួរធ្វើសក្ការៈដល់មាតាបិតាទាំងនោះ ដោយបាយ ទឹក សំពត់ គ្រឿងដេក គ្រឿងអប់ គ្រឿងផ្ងូតទឹក នឹងទឹកសម្រាប់លាងជើង ។ ព្រោះការដែលបានទំនុកបំរុងមាតាបិតានោះហើយ បានជាអ្នកប្រាជ្ញទាំងឡាយ សរសើរនូវបុគ្គលនោះ ក្នុងលោកនេះឯង បុគ្គលនោះ លុះលះលោកនេះទៅហើយ រមែងរីករាយ ក្នុងឋានសួគ៌ ។ សូត្រ ទី ៧ ។

(១០៧) ពហុការា ភិក្ខវេ ព្រាហ្មណគហបតិកា តុម្ហាកំ យេ តេ[១] បច្ចុបដ្ឋិតា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេហិ ។ តុម្ហេបិ ភិក្ខវេ ពហុការា ព្រាហ្មណគហបតិកានំ យំ នេសំ ធម្មំ ទេសេថ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេថ ។ ឯវមិទំ ភិក្ខវេ អញ្ញមញ្ញំ និស្សាយ ព្រហ្មចរិយំ វុស្សតិ ឱឃស្ស និត្ថរណត្ថាយ សម្មា ទុក្ខស្ស អន្តកិរិយាយាតិ ។

សាគារា អនគារា ច ឧភោ អញ្ញោញ្ញនិស្សិតា
អារាធយន្តិ សទ្ធម្មំ យោគក្ខេមំ អនុត្តរំ
សាគារេសុ ច ចីវរំ បច្ចយំ សយនាសនំ
អនគារា បដិច្ឆន្តិ បរិស្សយវិនោទនំ[២] ។

---

១ ឱ. តេ ។ ២ ម. បដិស្សយវិនោទនំ ។

(១០៩) ម្នាលភិក្ខុទាំងឡាយ ពួកព្រាហ្មណ៍និងគហបតីណា បានទំនុកបំរុងអ្នកទាំងឡាយ ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ ព្រាហ្មណ៍និងគហបតីទាំងនោះ ឈ្មោះថាមានឧបការៈច្រើន ដល់អ្នកទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ឯអ្នកទាំងឡាយ ក៏ឈ្មោះថាមានឧបការៈច្រើន ដល់ពួកព្រាហ្មណ៍និងគហបតីដែរ ព្រោះអ្នកទាំងឡាយ សំដែងធម៌ មានលំអបទដើម លំអបទកណ្តាល លំអបទចុង ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថនិងព្យញ្ជនៈ ដ៏បរិបូណ៌ បរិសុទ្ធទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយធម៌នេះ ដែលបុគ្គលប្រព្រឹត្ត ដើម្បីប្រយោជន៍រលាស់ចេញចាកឱឃៈ និងធ្វើឲ្យផុតទុក្ខដោយប្រពៃផង ក៏ព្រោះតែអាស្រ័យគ្នាទៅវិញទៅមក យ៉ាងនេះឯង ។

ពួកគ្រហស្ថ និងបព្វជិតទាំងពីរពួក អាស្រ័យគ្នាទៅវិញ
ទៅមក ទើបញុំាងព្រះសទ្ធម្ម ដែលជាទីក្សេមចាកយោគៈ
ដ៏ប្រសើរ ឲ្យសម្រេចបាន ឯពួកបព្វជិត តែងទទួល
ចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យ និងភេសជ្ជ-
ប្បច្ច័យ ជាគ្រឿងបន្ទោបង់សេចក្តីអន្តរាយ អំពីពួកគ្រហស្ថ ។

សុគតិំ បន និស្សាយ គហដ្ឋា ឃរមេសិនោ
សទ្ទហានា អរហតំ អរិយបញ្ញាយ ឈាយិនោ
ឥធ ធម្មំ ចរិត្វាន មគ្គំ សុគតិគាមិនំ
នន្ទិនោ ទេវលោកស្មឹ មោទន្តិ កាមកាមិនោតិ ។

អដ្ឋមំ[1] ។

(១១០) យេ កេចិ ភិក្ខវេ ភិក្ខូ កុហា ថទ្ធា លបា សិង្គី ឧន្នឡា អសមាហិតា ។ ន មេ តេ ភិក្ខវេ ភិក្ខូ មាមកា អបគតា ច តេ ភិក្ខវេ ភិក្ខូ ឥមស្មា ធម្មវិនយា ន ច តេ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជន្តិ ។ យេ ច ខោ ភិក្ខវេ ភិក្ខូ និក្កុហា និល្លបា ធីរា អត្ថទ្ធា សុសមាហិតា តេ ខោ មេ ភិក្ខវេ ភិក្ខូ មាមកា អនបគតា ច តេ ភិក្ខវេ ភិក្ខូ ឥមស្មា ធម្មវិនយា ឥមស្មឹ ច តេ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជន្តីតិ ។

១ ឱ ម. អដ្ឋមត្តិ ទត្តិ ។

ឯពួកគ្រហស្ថ អ្នកស្វែងរកប្រយោជន៍ក្នុងផ្ទះ បានអាស្រ័យសង្ឃជាសាវកនៃព្រះសុគតហើយ ជឿ (សេចក្ដីប្រតិបត្តិនិងពាក្យ) របស់ព្រះអរហន្តទាំងឡាយ ដោយប្រាជ្ញាដ៏ប្រសើរ ជាអ្នកពិនិត្យ បានប្រព្រឹត្តធម៌ ក្នុងសាសនានេះ ដែលជាផ្លូវប្រព្រឹត្តទៅកាន់សុគតិ រមែងជាអ្នកមានអំណរ រីករាយក្នុងទេវលោក បានសម្រេចតាមសេចក្ដីប្រាថ្នា ។ សូត្រ ទី ៨ ។

(១១០) ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាមួយ ជាអ្នកញ៉ាំងគេឲ្យស្ញើប រឹងរូស រាក់ទាក់ មានវាចាដូចស្នែង លើកកំពស់ មានចិត្តមិនទំនួល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថា មិនរាប់អានតថាគតផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថា ប្រាសចាកធម្មវិន័យនេះផង ភិក្ខុទាំងនោះ មិនដល់នូវសេចក្ដីចំរើន លូតលាស់ ទូលំទូលាយ ក្នុងធម្មវិន័យនេះផង ។ ម្នាលភិក្ខុទាំងឡាយ លុះតែពួកភិក្ខុណា មិនជាអ្នកញ៉ាំងគេឲ្យស្ញើប មិនរាក់ទាក់ មានប្រាជ្ញា មិនរឹងរូស មានចិត្តទំនួលល្អ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះឯង ទើបឈ្មោះថាជាអ្នករាប់អានតថាគតផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថា មិនប្រាសចាកធម្មវិន័យនេះផង ភិក្ខុទាំងនោះ រមែងដល់នូវសេចក្ដីចំរើនលូតលាស់ ទូលំទូលាយ ក្នុងធម្មវិន័យនេះផង ។

ឥតិវុត្តកេ ចតុក្កនិបាតស្ស ទសមសុត្តំ

កុហា ថទ្ធា លបា សិង្គី ឧន្នឡា អសមាហិតា
ន តេ ធម្មេ វិរូហន្តិ សម្មាសម្ពុទ្ធទេសិតេ ។
និក្កុហា និល្លបា ធីរា អត្ថទ្ធា សុសមាហិតា
តេ វេ ធម្មេ វិរូហន្តិ សម្មាសម្ពុទ្ធទេសិតេតិ ។

នវមំ[១] ។

(១១១) សេយ្យថាបិ ភិក្ខវេ បុរិសោ នទិយា សោតេន ឱវុយ្ហេយ្យ បិយរូបសាតរូបេន តមេនំ ចក្ខុមា បុរិសោ តីរេ ឋិតោ ទិស្វា ឯវំ វទេយ្យ កិញ្ចាបិ ខោ ត្វំ អម្ភោ បុរិស នទិយា សោតេន ឱវុយ្ហសិ[២] បិយរូបសាតរូបេន អត្ថិ ចេត្ថ ហេដ្ឋា រហទោ សឩមិ[៣] សាវដ្ដោ សគ្គហោ សរក្ខសោ យំ ត្វំ អម្ភោ បុរិស រហទំ បាបុណិត្វា មរណំ វា និគច្ឆសិ មរណមត្តំ វា ទុក្ខន្តិ ។ អថ ខោ សោ ភិក្ខវេ បុរិសោ តស្ស បុរិសស្ស សទ្ទំ សុត្វា ហត្ថេហិ ច បាទេហិ ច បដិសោតំ វាយមេយ្យ ។ ឧបមា ខោ មេ អយំ ភិក្ខវេ កតា អត្ថស្ស វិញ្ញាបនាយ ។

---

១ ឱ.ម. នវមន្តិ នត្ថិ ។ ២ ម ទហសេ ។ ៣ ឱ. សឩម្មិ ។ ម. សឩមិ ។

ពួកភិក្ខុណា ដែលជាអ្នកញុំាងគេឲ្យស្ញើច រឹងរូស រាក់ទាក់ មានកាយដូចស្នែង លើកកំពស់ មានចិត្តមិននឹងនួន ភិក្ខុទាំងនោះ មិនលូតលាស់ក្នុងធម៌ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងឡើយ ។ លុះតែពួកភិក្ខុណា មិនជាអ្នកញុំាងគេឲ្យស្ញើច មិនរាក់ទាក់ មានប្រាជ្ញា មិនរឹងរូស មានចិត្តនឹងនួន ភិក្ខុទាំងនោះ ទើបលូតលាស់ក្នុងធម៌ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងបាន ។ សូត្រ ទី ៩ ។

(១១១) ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសត្រូវខ្សែទឹកស្ទឹង បន្សាត់ទៅ ដោយទាំងវត្ថុជាទីស្រឡាញ់ ទាំងវត្ថុជាទីត្រេកអរ[១] បុរសមានចក្ខុ ឈរនៅទៀបត្រើយ បានឃើញបុរសនោះហើយ ក៏និយាយយ៉ាងនេះថា នែបុរសដ៏ចំរើន អ្នកត្រូវខ្សែទឹកស្ទឹងបន្សាត់ទៅ ដោយទាំងវត្ថុជាទីស្រឡាញ់ទាំងវត្ថុជាទីត្រេកអរ ក៏ពិតមែនហើយ តែថាក្នុងស្ទឹងនេះ មានអន្លង់នៅខាងក្រោមដ៏ប្រកបដោយរលកនិងទឹកគួចវិល មានសត្វសាហាវនិងអារក្សទឹក (នៅចាំ) នែបុរសដ៏ចំរើន លុះអ្នកអណ្តែតដល់អន្លង់នោះហើយ មុខជាដល់នូវសេចក្តីស្លាប់ឬនូវទុក្ខស្មើស្លាប់មិនខាន ។ ម្នាលភិក្ខុទាំងឡាយ លុះបុរសនោះ បានឮសំឡេងបុរសនោះហើយ ក៏ព្យាយាមហែលដោយដៃ ដោយជើង ច្រាសទឹកមកវិញ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីឧបមានេះឯង តថាគតធ្វើ ដើម្បីឲ្យអ្នកទាំងឡាយ ដឹងច្បាស់នូវសេចក្តី ។

---

១ វត្ថុផ្សេងៗ មានមាសប្រាក់ជាដើម ដែលជាទីស្រឡាញ់-ត្រេកអររបស់ជន ហៅថា បិយរូប សាតរូប ។

អយញ្ចេវេត្ថ[១] អត្ថោ នទិយា សោតេនាតិ[២] ខោ ភិក្ខវេ តណ្ហាយេតំ អធិវចនំ បិយរូបសាតរូបេនាតិ[៣] ខោ ភិក្ខវេ ឆន្នេតំ អជ្ឈត្តិកានំ អាយតនានំ អធិវចនំ ហេដ្ឋា រហទោតិ ខោ ភិក្ខវេ បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ អធិវចនំ សឩម្មីតិ ខោ ភិក្ខវេ កោធុបាយាសស្សេតំ អធិវចនំ សាវដ្ដោតិ ខោ ភិក្ខវេ បញ្ចន្នេតំ កាមគុណានំ អធិវចនំ សគ្គហោ សរក្ខសោតិ ខោ ភិក្ខវេ មាតុគ្គាមស្សេតំ អធិវចនំ បដិសោតន្តិ[៤] ខោ ភិក្ខវេ នេក្ខម្មស្សេតំ អធិវចនំ ហត្ថេហិ ច បាទេហិ ច វាយាមោតិ ខោ ភិក្ខវេ វីរិយារម្ភស្សេតំ អធិវចនំ ចក្ខុមា បុរិសោ តីរេ ឋិតោតិ ខោ ភិក្ខវេ តថាគតស្សេតំ អធិវចនំ អរហតោ សម្មាសម្ពុទ្ធស្សាតិ ។

សហាបិ ទុក្ខេន ជហេយ្យ កាមេ
យោគក្ខេមំ អាយតឹ បត្ថយានោ
សម្មប្បជានោ សុវិមុត្តចិត្តោ

---

១ ឱ.ម. អយំ បេត្ថ ។ ២ ឱ.ម. សោតោតិ ។ ៣ ឱ. បិយរូបសាតរូបន្តិ ។ ម. បិយរូបំ សាតរូបន្តិ ។ ៤ ឱ ម. បដិសោតោតិ ។

សេចក្តីអធិប្បាយនេះ ក្នុងពាក្យឧបមានុះថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា ខ្សែទឹកស្ទឹងនេះ ជាឈ្មោះនៃតណ្ហា ម្នាលភិក្ខុទាំងឡាយ ពាក្យថា រូបជាទីស្រឡាញ់ និងរូបជាទីត្រេកអរនេះ ជាឈ្មោះនៃអាយតនៈខាងក្នុង ៦ ម្នាលភិក្ខុទាំងឡាយ ពាក្យថា អន្លង់នៅខាងក្រោមនេះ ជាឈ្មោះនៃសំយោជនៈជាចំណែកខាងក្រោម ៥ ម្នាលភិក្ខុទាំងឡាយ ពាក្យថាប្រកបដោយរលកនេះ ជាឈ្មោះនៃសេចក្តីក្រោធ និងសេចក្តីចង្អៀតចង្អល់ចិត្ត ម្នាលភិក្ខុទាំងឡាយ ពាក្យថា ប្រកបដោយទឹកក្តួចវិលនេះ ជាឈ្មោះនៃកាមគុណ ៥ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ប្រកបដោយសត្វសាហាវនិងអារក្សទឹកនេះ ជាឈ្មោះនៃមាតុគ្រាម ម្នាលភិក្ខុទាំងឡាយ ពាក្យថា ហែលច្រាសទឹកនេះ ជាឈ្មោះនៃនេក្ខម្មៈ(១) ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្យាយាមហែលដោយដៃ ដោយជើងនេះ ជាឈ្មោះនៃការប្រារព្ធព្យាយាម ម្នាលភិក្ខុទាំងឡាយ ពាក្យថា បុរសមានចក្ខុឈរនៅទៀបច្នេរនេះ ជាឈ្មោះនៃព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។

បុគ្គលណា កាលប្រាថ្នា នូវការក្សេមចាកយោគៈ ទៅខាងមុខ
ត្រូវលះបង់នូវកាមទាំងឡាយ ព្រមទាំងសេចក្តីទុក្ខ ជាអ្នក
មានសេចក្តីដឹងខ្លួន មានចិត្តផុតស្រឡះ ដោយប្រពៃហើយ

---

១ ចិត្តដែលថយចេញចាកកាម ដោយសេចក្តីនឿយណាយ ឬការលះរាជសម្បត្តិចេញបួស ហៅថា នេក្ខម្មៈ ។

វិមុត្តិយា ផស្សយេ តត្ថ តត្ថ
ស វេទគូ វុសិតព្រហ្មចរិយោ
លោកន្តគូ បារគតោតិ វុច្ចតីតិ ។

ទសមំ (១) ។

[១១២] ចរតោ ចេបិ ភិក្ខវេ ភិក្ខុនោ ឧប្បជ្ជតិ កាមវិតក្កោ វា ព្យាបាទវិតក្កោ វា វិហឹសាវិតក្កោ វា តញ្ចេ (២) ភិក្ខុ អធិវាសេតិ នប្បជហតិ ន វិនោទេតិ ន ព្យន្តីករោតិ (៣) ន អនភាវំ គមេតិ ចរម្បិ ភិក្ខវេ ភិក្ខុ ឯវំភូតោ អនាតាបី អនោត្តប្បី សតតំ សមិតំ កុសីតោ ហីនវីរិយោតិ វុច្ចតិ ។ ឋិតស្ស ចេបិ ភិក្ខវេ ភិក្ខុនោ ឧប្បជ្ជតិ កាមវិតក្កោ វា ព្យាបាទវិតក្កោ វា វិហឹសាវិតក្កោ វា តញ្ចេ (៤) ភិក្ខុ អធិវាសេតិ នប្បជហតិ ន វិនោទេតិ ន ព្យន្តីករោតិ ន អនភាវំ គមេតិ ឋិតោបិ ភិក្ខវេ ភិក្ខុ ឯវំភូតោ អនាតាបី អនោត្តប្បី សតតំ សមិតំ កុសីតោ ហីនវីរិយោតិ វុច្ចតិ ។

---

១ ម. ទសមត្តំ នត្ថិ ។ ២ ឱ.ម. ឯត្ថន្តរេ ភិក្ខវេតិ អត្ថិ ។ ៣ ម. ព្យន្តី ករោតិ ។
៤ ឱ.ម. ឯត្ថន្តរេ ភិក្ខវេតិ អត្ថិ ។

បាននូវវិមុត្តិ ក្នុងអារម្មណ៍នោះៗ បុគ្គលនោះ តថាគតហៅថា អ្នកដល់នូវវេទគឺមគ្គញាណ ហៅថា អ្នកមានព្រហ្មចរិយធម៌ប្រព្រឹត្តរួចហើយ ហៅថា អ្នកដល់នូវទីបំផុតនៃលោក ហៅថា អ្នកដល់នូវត្រើយគឺព្រះនិព្វាន ។ សូត្រ ទី ១០ ។

(១១៤) ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុកំពុងដើរទៅ បើមានកាមវិតក្កៈក្តី ព្យាបាទវិតក្កៈក្តី វិហឹសាវិតក្កៈក្តី កើតឡើង បើភិក្ខុទទួលនូវវិតក្កៈនោះ មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យវិនាស មិនធ្វើឲ្យដល់នូវការសាបសូន្យទេ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុកំពុងដើរក៏ដោយ តែមានសភាពយ៉ាងនេះហើយ ហៅថា ជាអ្នកមិនមានព្យាយាមដុតកំដៅកិលេស មិនជាអ្នកក្តៅនឹងបាប ជាអ្នកខ្ជិលច្រអូសជានិច្ចកាល មិនមានព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុកំពុងឈរ បើមានកាមវិតក្កៈក្តី ព្យាបាទវិតក្កៈក្តី វិហឹសាវិតក្កៈក្តី កើតឡើង បើភិក្ខុទទួលនូវវិតក្កៈនោះ មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យវិនាស មិនធ្វើឲ្យដល់នូវការសាបសូន្យទេ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុ កំពុងឈរក៏ដោយ តែមានសភាពយ៉ាងនេះហើយ ហៅថាជាអ្នកមិនមានព្យាយាមដុតកំដៅកិលេស មិនជាអ្នកក្តៅនឹងបាប ជាអ្នកខ្ជិលច្រអូសជានិច្ចកាល មិនមានព្យាយាម ។

និសិន្នស្ស ចេបិ ភិក្ខវេ ភិក្ខុនោ ឧប្បជ្ជតិ កាមវិតក្កោ វា ព្យាបាទវិតក្កោ វា វិហឹសាវិតក្កោ វា តញ្ចេ[១] ភិក្ខុ អធិវាសេតិ នប្បជហាតិ ន វិនោទេតិ ន ព្យន្តីករោតិ ន អនភាវំ គមេតិ និសិន្នោបិ ភិក្ខវេ ភិក្ខុ ឯវំភូតោ អនាតាបី អនោត្តប្បី សតតំ សមិតំ កុសីតោ ហីនវីរិយោតិ វុច្ចតិ ។ សយានស្ស ចេបិ ភិក្ខវេ ភិក្ខុនោ ជាគរស្ស ឧប្បជ្ជតិ កាម-វិតក្កោ វា ព្យាបាទវិតក្កោ វា វិហឹសាវិតក្កោ វា តញ្ចេ ភិក្ខុ អធិវាសេតិ នប្បជហាតិ ន វិនោទេតិ ន ព្យន្តីករោតិ ន អនភាវំ គមេតិ សយានោបិ ភិក្ខវេ ភិក្ខុ ជាគរោ ឯវំភូតោ អនាតាបី អនោត្តប្បី សតតំ សមិតំ កុសីតោ ហីនវីរិយោតិ វុច្ចតិ ។

(១១៣) ចរតោ ចេបិ ភិក្ខវេ ភិក្ខុនោ ឧប្បជ្ជតិ កាមវិតក្កោ វា ព្យាបាទវិតក្កោ វា វិហឹសាវិតក្កោ វា តញ្ចេ ភិក្ខុ ន អធិវាសេតិ[២] បជហាតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ ចរម្បិ ភិក្ខវេ ភិក្ខុ

១ ឱ ម. ឯត្ថន្តរេ ភិក្ខវេតិ អត្ថិ ។ ២ ឱ.ម. នាធិវាសេតិ ។

ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុកំពុងអង្គុយ បើមានកាមវិតក្កៈក្តី ព្យាបាទវិតក្កៈក្តី វិហឹសាវិតក្កៈក្តី កើតឡើង បើភិក្ខុទទួលនូវវិតក្កៈនោះ មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យវិនាស មិនធ្វើឲ្យដល់នូវការសាបសូន្យទេ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុកំពុងអង្គុយក៏ដោយ តែមានសភាព យ៉ាងនេះហើយ ហៅថាជាអ្នកមិនមានព្យាយាមដុតកំដៅកិលេស មិនជាអ្នកខ្លាចនឹងបាប ជាអ្នកខ្ជិលច្រអូសជានិច្ចកាល មិនមានព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុកំពុងដេក កំពុងភ្ញាក់ (ដឹងខ្លួន) បើមានកាមវិតក្កៈក្តី ព្យាបាទវិតក្កៈក្តី វិហឹសាវិតក្កៈក្តី កើតឡើង បើភិក្ខុទទួល នូវវិតក្កៈនោះ មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យវិនាស មិនធ្វើឲ្យដល់នូវការសាបសូន្យទេ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុ កំពុងដេក ភ្ញាក់ ក៏ដោយ តែមានសភាពយ៉ាងនេះហើយ ហៅថាជាអ្នកមិនមានព្យាយាមដុតកំដៅកិលេស មិនជាអ្នកខ្លាចនឹងបាប ជាអ្នកខ្ជិលច្រអូសជានិច្ចកាល មិនមានព្យាយាម ។

(១១៣) ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុកំពុងដើរទៅ បើមានកាមវិតក្កៈក្តី ព្យាបាទវិតក្កៈក្តី វិហឹសាវិតក្កៈក្តី កើតឡើងហើយ បើភិក្ខុមិនទទួលនូវវិតក្កៈនោះទេ បានលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យដល់នូវការសាបសូន្យហើយ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុកំពុងដើរទៅក៏ដោយ

ឥតិវុត្តកេ ចតុក្កនិបាតស្ស ឯកាទសមសុត្តំ

ឯវំភូតោ អាតាបី ឱត្តប្បី សតតំ សមិតំ អារទ្ធវីរិយោ បហិតត្តោតិ វុច្ចតិ ។ ឋិតស្ស ចេបិ ភិក្ខវេ ភិក្ខុនោ ឧប្បជ្ជតិ កាមវិតក្កោ វា ព្យាបាទវិតក្កោ វា វិហឹសាវិតក្កោ វា តញ្ចេ ភិក្ខុ នាធិវាសេតិ បជហាតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ ឋិតោបិ ភិក្ខវេ ភិក្ខុ ឯវំភូតោ អាតាបី ឱត្តប្បី សតតំ សមិតំ អារទ្ធវីរិយោ បហិតត្តោតិ វុច្ចតិ ។ និសិន្នស្ស ចេបិ ភិក្ខវេ ភិក្ខុនោ ឧប្បជ្ជតិ កាមវិតក្កោ វា ព្យាបាទវិតក្កោ វា វិហឹសាវិតក្កោ វា តញ្ចេ ភិក្ខវេ ភិក្ខុ នាធិវាសេតិ បជហាតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ និសិន្នោបិ ភិក្ខវេ ភិក្ខុ ឯវំភូតោ អាតាបី ឱត្តប្បី សតតំ សមិតំ អារទ្ធវីរិយោ បហិតត្តោតិ វុច្ចតិ ។ សយានស្ស ចេបិ ភិក្ខវេ ភិក្ខុនោ ជាគរស្ស ឧប្បជ្ជតិ កាមវិតក្កោ វា ព្យាបាទវិតក្កោ វា វិហឹសាវិតក្កោ វា តញ្ចេ ភិក្ខុ នាធិវាសេតិ បជហាតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ

តែមានសភាព យ៉ាងនេះហើយ ហៅថាជាអ្នកមានព្យាយាមដុតកំដៅកិលេស ជាអ្នកក្តៅនឹងបាប ជាអ្នកប្រារព្ធព្យាយាមជានិច្ចកាល មានចិត្តស្ងប់ទៅកាន់ព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុកំពុងឈរ បើមានកាមវិតក្កៈក្តី ព្យាបាទវិតក្កៈក្តី វិហឹសាវិតក្កៈក្តី កើតឡើងហើយ បើភិក្ខុមិនទទួលនូវវិតក្កៈនោះទេ បានលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យដល់នូវការសាបសូន្យហើយ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុកំពុងឈរក៏ដោយ តែមានសភាពយ៉ាងនេះហើយ ហៅថាជាអ្នកមានព្យាយាមដុតកំដៅកិលេស ជាអ្នកក្តៅនឹងបាប ជាអ្នកប្រារព្ធព្យាយាមជានិច្ចកាល មានចិត្តស្ងប់ទៅកាន់ព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុកំពុងអង្គុយ បើមានកាមវិតក្កៈក្តី ព្យាបាទវិតក្កៈក្តី វិហឹសាវិតក្កៈក្តី កើតឡើង ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនទទួល នូវវិតក្កៈនោះទេ បានលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យដល់នូវការសាបសូន្យហើយ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុកំពុងអង្គុយក៏ដោយ តែមានសភាពយ៉ាងនេះហើយ ហៅថាជាអ្នកមានព្យាយាមដុតកំដៅកិលេស ជាអ្នកក្តៅនឹងបាប ជាអ្នកប្រារព្ធព្យាយាមជានិច្ចកាល មានចិត្តស្ងប់ទៅកាន់ព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុកំពុងដេក ភ្ញាក់ បើមានកាមវិតក្កៈក្តី ព្យាបាទវិតក្កៈក្តី វិហឹសាវិតក្កៈក្តី កើតឡើងហើយ បើភិក្ខុមិនទទួលនូវវិតក្កៈនោះទេ បានលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យដល់នូវការសាបសូន្យហើយ

សយានោបិ ភិក្ខវេ ភិក្ខុ ជាគរោ ឯវំភូតោ អាតាបី ឱត្តប្បី សតតំ សមិតំ អារទ្ធវីរិយោ បហិតត្តោតិ វុច្ចតិ ។

ចរំ វា យទិ វា តិដ្ឋំ និសិន្នោ ឧទ វា សយំ
យោ វិតក្កំ វិតក្កេតិ បាបកំ គេហនិស្សិតំ
កុម្មគ្គំ បដិបន្នោ សោ មោហនេយ្យេសុ មុច្ឆិតោ
អភព្វោ តាទិសោ ភិក្ខុ ផុដ្ឋុំ សម្ពោធិមុត្តមំ ។
យោ ចរំ វា យទិ វា តិដ្ឋំ និសិន្នោ ឧទ វា សយំ
វិតក្កំ សមយិត្វាន វិតក្កូបសមេ រតោ
ភព្វោ សោ តាទិសោ ភិក្ខុ ផុដ្ឋុំ សម្ពោធិមុត្តមន្តិ ។

ឯកាទសមំ ។

(១១៤) សម្បន្នសីលា ភិក្ខវេ ហោថ[១] សម្បន្នបាតិមោក្ខា បាតិមោក្ខសំវរសំវុតា វិហរថ អាចារគោចរសម្បន្នា អណុមត្តេសុ វជ្ជេសុ ភយ-ទស្សាវិនោ[២] សមាទាយ សិក្ខថ សិក្ខាបទេសុ ។

---

១ ឱ.ម. វិហរថ ។ ២ ឱ.ម. ភយទស្សាវី ។

ម្នាលភិក្ខុទាំងឡាយ ចុះជាភិក្ខុកំពុងដេក កំពុងភ្ញាក់ក៏ដោយ តែមានសភាព យ៉ាងនេះហើយ ហៅថាជាអ្នកមានព្យាយាមដុតកំដៅកិលេស ជាអ្នកខ្លាចនឹងបាប ជាអ្នកប្រារព្ធពកយាមជានិច្ចកាល មានចិត្តស្ងប់ទៅកាន់ព្រះនិព្វាន ។

ភិក្ខុណា កំពុងដើរក្តី ឈរក្តី អង្គុយក្តី ដេកក្តី ត្រិះរិះនូវវិតក្កៈដ៏លាមក ដែលអាស្រ័យនូវផ្ទះគឺតណ្ហា ភិក្ខុបែបនោះឯង ហៅថា ដើរទៅរកផ្លូវខុស ជ្រប់នៅក្នុង (អារម្មណ៍មានរូបជាដើម) ជាទីតាំងនៃសេចក្តីប្រព្រឹត្តទៅនៃមោហៈ មិនគួរបាននូវសម្ពោធិញាណដ៏ឧត្តមឡើយ ។ ភិក្ខុណា កំពុងដើរក្តី ឈរក្តី អង្គុយក្តី ដេកក្តី បានញុំាងអកុសលវិតក្កៈឲ្យស្ងប់រម្ងាប់ ត្រេកអរក្នុងកិរិយារម្ងាប់នូវវិតក្កៈ ភិក្ខុបែបនោះឯង គួរបាននូវសម្ពោធិញាណដ៏ឧត្តម ។ សូត្រទី ១១ ។

(១១៤) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរជាបុគ្គលបរិបូណ៌ដោយសីល បរិបូណ៌ដោយបាតិមោក្ខ សង្រួមដោយការសង្រួមក្នុងបាតិមោក្ខ បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ។

សម្បន្នសីលានំ ភិក្ខវេ ភវតំ(១) សម្បន្នបាតិមោក្ខានំ បាតិមោក្ខសំវរសំវុតានំ វិហរតំ អាចារគោចរសម្បន្នានំ អណុមត្តេសុ វជ្ជេសុ ភយទស្សាវីនំ សមាទាយ សិក្ខតំ សិក្ខាបទេសុ កិមស្ស(២) ភិក្ខវេ ឧត្តរឹ ករណីយំ ចរតោ ចេបិ ភិក្ខវេ ភិក្ខុនោ អភិជ្ឈា វិគតា ហោតិ ព្យាបាទោ វិគតោ ហោតិ ថីនមិទ្ធំ វិគតំ ហោតិ ឧទ្ធច្ចកុក្កុច្ចំ វិគតំ ហោតិ វិចិកិច្ឆា បហីនា ហោតិ អារទ្ធវីរិយំ ហោតិ(៣) អសល្លីនំ ឧបដ្ឋិតា សតិ អប្បមុដ្ឋា(៤) បស្សទ្ធោ កាយោ អសារទ្ធោ សមាហិតំ ចិត្តំ ឯកគ្គំ ចរំបិ ភិក្ខវេ ភិក្ខុ ឯវំភូតោ អាតាបី ឱត្តប្បី សតតំ សមិតំ អារទ្ធវីរិយោ បហិតត្តោតិ វុច្ចតិ ។ ឋិតស្ស ចេបិ ភិក្ខវេ ភិក្ខុនោ អភិជ្ឈា វិគតា ហោតិ ព្យាបាទោ វិគតោ ហោតិ ថីនមិទ្ធំ វិគតំ ហោតិ ឧទ្ធច្ចកុក្កុច្ចំ វិគតំ ហោតិ វិចិកិច្ឆា បហីនា ហោតិ អារទ្ធំ ហោតិ វីរិយំ អសល្លីនំ ឧបដ្ឋិតា សតិ អប្បមុដ្ឋា បស្សទ្ធោ កាយោ អសារទ្ធោ សមាហិតំ ចិត្តំ ឯកគ្គំ

---

១ ឱ.ម. វិហរតំ ។ ២ ឱ. កិញ្ចស្ស ។ ម. កិស្ស ។ ៣ ឱ.ម. អារទ្ធំ ហោតិ វីរិយំ ។
៤ ឱ. អសម្មុដ្ឋា ។ ម. អសំមុដ្ឋា ។

ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ ជាបុគ្គលបរិបូណ៌ដោយសីល បរិបូណ៌ដោយបាតិមោក្ខ សង្រួមដោយការសង្រួមក្នុងបាតិមោក្ខ បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរធ្វើដូចម្តេចតទៅទៀត ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុកំពុងដើរទៅក្តី បើប្រាសចាកអភិជ្ឈា ប្រាសចាកព្យាបាទ ប្រាសចាកថីនមិទ្ធៈ ប្រាសចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់វិចិកិច្ឆា ប្រារព្ធព្យាយាមមិនធូរថយ ប្រុងស្មារតីមិនភ្លេចភ្លាំង មានកាយស្ងប់រម្ងាប់ មិនក្រវល់ក្រវាយ មានចិត្តតាំងមាំ មូលទឹងនួន ក្នុងអារម្មណ៍តែ ១ ហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបើទុកជាកំពុងដើរទៅ តែមានសភាព យ៉ាងនេះហើយ ហៅថាជាអ្នកមានព្យាយាម ដុតកំដៅកិលេស ក្តៅទឹងបាប ប្រារព្ធព្យាយាមជានិច្ចកាល មានចិត្តស្ទុងទៅកាន់ព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុកំពុងឈរក្តី បើប្រាសចាកអភិជ្ឈា ប្រាសចាកព្យាបាទ ប្រាសចាកថីនមិទ្ធៈ ប្រាសចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់វិចិកិច្ឆា ប្រារព្ធព្យាយាមមិនធូរថយ ប្រុងស្មារតីមិនភ្លេចភ្លាំង មានកាយស្ងប់រម្ងាប់ មិនក្រវល់ក្រវាយ មានចិត្តតាំងមាំ មូលទឹងនួនក្នុងអារម្មណ៍តែ ១ ហើយ

ឋិតោបិ ភិក្ខវេ ភិក្ខុ ឯវំភូតោ អាតាបី ឱត្តប្បី សតតំ សមិតំ អារទ្ធវិរិយោ បហិតត្តោតិ វុច្ចតិ ។ និសិន្នស្ស ចេបិ ភិក្ខវេ ភិក្ខុនោ អភិជ្ឈា វិគតា ហោតិ ព្យាបាទោ វិគតោ ហោតិ ថីនមិទ្ធំ វិគតំ ហោតិ ឧទ្ធច្ចកុក្កុច្ចំ វិគតំ ហោតិ វិចិកិច្ឆា បហីនា ហោតិ អារទ្ធំ ហោតិ វិរិយំ អសល្លីនំ ឧបដ្ឋិតា សតិ អសម្មុដ្ឋា បស្សទ្ធោ កាយោ អសារទ្ធោ សមាហិតំ ចិត្តំ ឯកគ្គំ និសិន្នោបិ ភិក្ខវេ ភិក្ខុ ឯវំភូតោ អាតាបី ឱត្តប្បី សតតំ សមិតំ អារទ្ធវិរិយោ បហិតត្តោតិ វុច្ចតិ ។ សយានស្ស ចេបិ ភិក្ខវេ ភិក្ខុនោ ជាគរស្ស អភិជ្ឈា វិគតា ហោតិ ព្យាបាទោ វិគតោ ហោតិ ថីនមិទ្ធំ វិគតំ ហោតិ ឧទ្ធច្ចកុក្កុច្ចំ វិគតំ ហោតិ វិចិកិច្ឆា បហីនា ហោតិ អារទ្ធំ ហោតិ វិរិយំ អសល្លីនំ ឧបដ្ឋិតា សតិ អសម្មុដ្ឋា បស្សទ្ធោ កាយោ អសារទ្ធោ សមាហិតំ ចិត្តំ ឯកគ្គំ សយានោបិ ភិក្ខវេ ភិក្ខុ ជាគរោ ឯវំភូតោ អាតាបី ឱត្តប្បី សតតំ សមិតំ អារទ្ធវិរិយោ បហិតត្តោតិ វុច្ចតីតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុទុកជាកំពុងឈរ តែមានសភាពយ៉ាងនេះហើយ ហៅថាជាអ្នកមានព្យាយាមដុតកំដៅកិលេស ក្តៅនឹងបាប ប្រារព្ធព្យាយាមជានិច្ចកាល មានចិត្តស្ទុងទៅកាន់ព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុកំពុងអង្គុយក្តី បើប្រាសចាកអភិជ្ឈា ប្រាសចាកព្យាបាទ ប្រាសចាកថីនមិទ្ធៈ ប្រាសចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់វិចិកិច្ឆា ប្រារព្ធព្យាយាមមិនធូរថយ ប្រុងស្មារតីមិនភ្លេចភ្លាំង មានកាយស្ងប់រម្ងាប់មិនក្រវល់ក្រវាយ មានចិត្តតាំងមាំមួន នឹងនួនក្នុងអារម្មណ៍តែមួយហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទុកជាកំពុងអង្គុយ តែមានសភាព យ៉ាងនេះហើយ ហៅថាជាអ្នកមានព្យាយាមដុតកំដៅកិលេស ក្តៅនឹងបាប ប្រារព្ធព្យាយាមជានិច្ចកាល មានចិត្តស្ទុងទៅកាន់ព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុកំពុងដេកក្តី កំពុងភ្ញាក់ក្តី បើប្រាសចាកអភិជ្ឈា ប្រាសចាកព្យាបាទ ប្រាសចាកថីនមិទ្ធៈ ប្រាសចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់វិចិកិច្ឆា ប្រារព្ធព្យាយាមមិនធូរថយ ប្រុងស្មារតីមិនភ្លេចភ្លាំង មានកាយស្ងប់រម្ងាប់ មិនក្រវល់ក្រវាយ មានចិត្តតាំងមាំ មូលនឹងនួន ក្នុងអារម្មណ៍តែមួយហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទុកជាកំពុងដេក កំពុងភ្ញាក់ តែមានសភាព យ៉ាងនេះហើយ ហៅថាជាអ្នកមានព្យាយាម ដុតកំដៅកិលេស ក្តៅនឹងបាប ប្រារព្ធព្យាយាមជានិច្ចកាល មានចិត្តស្ទុងទៅកាន់ព្រះនិព្វាន ។

ឥតិវុត្តកេ ចតុក្កនិបាតស្ស តេរសមសុត្តំ

យតំ ចរេ យតំ តិដ្ឋេ យតំ អច្ឆេ យតំ សយេ
យតំ សម្មិញ្ជយេ ភិក្ខុ យតមេនំ បសារយេ
ឧទ្ធំ តិរិយំ អបាចីនំ យាវតា ជគតោ គតិ
សមវេក្ខិតា ច(១) ធម្មានំ ខន្ធានំ ឧទយព្វយំ
ឯវំវិហារិមាតាបី សន្តវុត្តិ អនុទ្ធតំ
ចេតោសមថសាមីចី សិក្ខមានំ សទា សតំ
សតតំ បហិតត្តោតិ អាហុ ភិក្ខុំ តថាវិធន្តិ ។

ទ្វាទសមំ(២) ។

[១១៥] វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ ។ លោកោ ភិក្ខវេ តថាគតេន អភិសម្ពុទ្ធោ លោកស្មា តថាគតោ វិសំយុត្តោ(៣) លោកសមុទយោ ភិក្ខវេ តថាគតេន អភិ-សម្ពុទ្ធោ លោកសមុទយោ តថាគតស្ស បហីនោ

---

១ ឱ. វ ។ ២ ឱ.ម. ទ្វាទសមន្តិ ឥត្ថិ ។ ៣ ឱ.ម វិសញ្ញុត្តោ ។

ឥតិវុត្តកៈ ចតុក្កនិបាត សូត្រ ទី ១៣

ភិក្ខុ គួរដើរទៅឲ្យមានព្យាយាម (កំចាត់បាប) គួរឈរឲ្យមានព្យាយាម គួរអង្គុយឲ្យមានព្យាយាម គួរដេកឲ្យមានព្យាយាម គួរបត់ចូល (នូវអវយវៈ) ឲ្យមានព្យាយាម គួរលាចេញ (នូវអវយវៈ) ឲ្យមានព្យាយាម ការប្រព្រឹត្តទៅនៃលោក ក្នុងខាងលើ ក្នុងទីជុំវិញ ក្នុងទិសខាងក្រោមត្រឹមណា ភិក្ខុគួរជាអ្នកពិចារណា នូវការកើតឡើងការរលត់នៃខន្ធទាំងឡាយ ដែលមានការសោបសូន្យជាធម្មតា ត្រឹមណោះ អ្នកប្រាជ្ញទាំងឡាយ បានសរសើរ នូវភិក្ខុអ្នកសម្រេចសម្រាន្តនៅយ៉ាងនេះ មានព្យាយាមដុតកំដៅកិលេស មានការប្រព្រឹត្តិស្ងប់រម្ងាប់ មានចិត្តមិនរាយមាយ សិក្សាឲ្យសមគួរដល់ធម៌ជាគ្រឿងស្ងប់ចិត្ត មានស្មារតីគ្រប់កាល បែបនោះថាជាបុគ្គលមានចិត្តស្ងុនទៅកាន់ព្រះនិព្វាន ។ សូត្រ ទី ១២ ។

(១១៤) ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សំដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ លោក (ទាំងមូល) តថាគត បានត្រាស់ដឹង ច្បាស់ហើយ តថាគតជាបុគ្គល ប្រាសចាកលោក ម្នាលភិក្ខុទាំងឡាយ ធម៌ជាគ្រឿងបណ្តាលឲ្យកើតលោក តថាគត បានត្រាស់ដឹង ច្បាស់ហើយ ធម៌ជាគ្រឿងបណ្តាល ឲ្យកើតលោក តថាគត បានលះបង់ហើយ

លោកនិរោធោ ភិក្ខវេ តថាគតេន អភិសម្ពុទ្ធោ លោកនិរោធោ តថាគតស្ស សច្ឆិកតោ លោកនិរោធគាមិនី បដិបទា ភិក្ខវេ តថាគតេន អភិសម្ពុទ្ធា លោកនិរោធគាមិនី បដិបទា តថាគតស្ស ភាវិតា ។ យំ ភិក្ខវេ សទេវកស្ស លោកស្ស សមារកស្ស សព្រហ្មកស្ស សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា យស្មា តំ តថាគតេន អភិសម្ពុទ្ធំ តស្មា តថាគតោតិ វុច្ចតិ ។ យញ្ច ភិក្ខវេ រត្តឹ តថាគតោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុជ្ឈតិ យញ្ច រត្តឹ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វាយតិ យមេតស្មឹ អន្តរេ ភាសតិ លបតិ និទ្ទិសតិ សព្វំ តថេវ ហោតិ នោ អញ្ញថា តស្មា តថាគតោតិ វុច្ចតិ ។ យថាវាទី ភិក្ខវេ តថាគតោ តថាការី យថាការី តថាវាទី ឥតិ យថាវាទី តថាការី យថាការី តថាវាទី តស្មា តថាគតោតិ វុច្ចតិ ។

ម្នាលភិក្ខុទាំងឡាយ ធម៌ជាគ្រឿងរលត់ទៅនៃលោក តថាគត បានត្រាស់ដឹងច្បាស់ហើយ ធម៌ជាគ្រឿងរលត់ទៅនៃលោក តថាគត បានធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលភិក្ខុទាំងឡាយ បដិបទាប្រព្រឹត្តទៅកាន់ទីរលត់ទៅនៃលោក តថាគត បានត្រាស់ដឹងច្បាស់ហើយ បដិបទាប្រព្រឹត្តទៅកាន់ទីរលត់ទៅនៃលោក តថាគត បានអប់រំហើយ ។ ម្នាលភិក្ខុទាំងឡាយ របស់ណា ដែលលោកព្រមទាំងទេវតា មារ ទាំងព្រហ្ម ពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនឹងមនុស្សដ៏សេស បានឃើញ បានឮ បានប៉ះពាល់ បានដឹង បានដល់ បានស្វះស្វែងរក បានពារក ដោយចិត្តហើយ របស់នោះតថាគត បានត្រាស់ដឹងច្បាស់ហើយ ព្រោះហេតុណា ហេតុនោះបានជាហៅថា ព្រះតថាគត ។ ម្នាលភិក្ខុទាំងឡាយ តថាគត ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញាណ ក្នុងរាត្រីណាផង បរិនិព្វានទៅដោយអនុបាទិសេសនិព្វានធាតុ ក្នុងរាត្រីណាផង សំដែងពោលពន្យល់នូវសុត្តសាសនាណា ក្នុងចន្លោះរាត្រីទាំងពីរនុ៎ះ សុត្តសាសនាទាំងអស់នោះ ក៏ទៅជាយ៉ាងនោះដដែល មិនប្រែទៅជាយ៉ាងដទៃឡើយ ព្រោះហេតុនោះបានជា ហៅថា ព្រះតថាគត ។ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ពោលយ៉ាងនោះ ព្រោះតែពោលយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ពោលយ៉ាងនោះឯង ព្រោះហេតុនោះបានជា ហៅថា ព្រះតថាគត ។

ឥតិវុត្តកេ ចតុក្កនិបាតស្ស តេរសមសុត្តំ

សទេវកេ ភិក្ខវេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ តថាគតោ អភិភូ អនភិភូតោ អញ្ញទត្ថុទសោ វសវត្តី តស្មា តថាគតោតិ វុច្ចតីតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ ឥតិ វុច្ចតិ

សព្វលោកំ អភិញ្ញាយ សព្វលោកេ យថាតថំ
សព្វលោកវិសំយុត្តោ សព្វលោកេ អនូបយោ[1]
សព្វេ សព្វាភិភូ ធីរោ សព្វគន្ថប្បមោចនោ
ផុដ្ឋស្ស បរមា សន្តិ[2] និព្វានំ អកុតោភយំ
ឯស ខីណាសវោ ពុទ្ធោ អនីឃោ ឆិន្នសំសយោ
សព្វកម្មក្ខយំ បត្តោ វិមុត្តោ[3] ឧបធិសង្ខយេ

---

១ ម. អនុបយោ ។ អដ្ឋកថាយំ អនុសយោតិ ទិស្សតិ ។ ២ ម. បរមំ សន្តិ ។ ៣ ម. វិមុត្តោ

ម្នាលភិក្ខុទាំងឡាយ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្ម-លោក ក្នុងពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស តថាគត ជាអ្នកគ្របសង្កត់លើសត្វឯទៀត (ដោយគុណ) សត្វឯទៀតគ្របសង្កត់ (តថាគតវិញ) មិនបាន ជាអ្នកឃើញហេតុសព្វគ្រប់ ធ្វើអំណាចឲ្យប្រព្រឹត្តទៅ ព្រោះហេតុនោះ បានជា ហៅថា ព្រះតថាគត ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

អ្នកប្រាជ្ញ បានដឹងច្បាស់ នូវលោកទាំងពួង ក្នុងលោក
ទាំងពួង ដោយពិត ជាអ្នកប្រាសចាកលោកទាំងពួង ក្នុង
លោកទាំងពួង មិនមាននរណា(១) ប្រៀបបាន ជាអ្នកគ្រប
សង្កត់លោកទាំងអស់ (ដោយគុណ) ជាអ្នកញុំាងលោក
ទាំងអស់ ឲ្យផុតចាកគ្រឿងចំពាក់ទាំងពួង ព្រះនិព្វានជាទី
ស្ងប់រម្ងាប់យ៉ាងក្រៃលែង មិនមានភ័យអំពីទីណាៗ ដល់
អ្នកប្រាជ្ញដែលបានហើយ អ្នកប្រាជ្ញនុ៎ះ ជាព្រះខីណាស្រព
ត្រាស់ដឹងនូវសច្ចៈ ៤ ជាបុគ្គលមិនមានទុក្ខ បានកាត់
ផ្តាច់នូវសេចក្តីសង្ស័យ ដល់នូវការអស់ទៅនៃកម្មទាំងពួង
មានចិត្តផុតស្រឡះ ក្នុងធម៌ជាគ្រឿងអស់ទៅ នៃកិលេស

១ ក្នុងអដ្ឋកថាថា មិនមានឧគឺនរគឺតណ្ហានិងទិដ្ឋិ (អត្តសយោ) ។

ឯស សោ ភគវា ពុទ្ធោ ឯស សីហោ អនុត្តរោ

សទេវកស្ស លោកស្ស ព្រហ្មចក្កំ បវត្តយិ ។

ឥតិ នេតំ មនុស្សា ច យេ ពុទ្ធំ សរណំ គតា

សង្គម្ម តំ នមស្សន្តិ មហន្តំ វីតសារទំ ។

ទន្តោ ទមយតំ សេដ្ឋោ សន្តោ សមយតំ ឥសី

មុត្តោ មោចយតំ អគ្គោ តិណ្ណោ តារយតំ វរោ ។

ឥតិ ហេតំ នមស្សន្តិ មហន្តំ វីតសារទំ ។

សទេវកស្មឹ លោកស្មឹ នត្ថិ តេ បដិបុគ្គលោតិ ។

អយម្បិ អត្ថោ វុត្តោ ភគវតា ឥតិ មេ សុតន្តិ ។

តេរសមំ(១) ។

ចតុក្កនិបាតោ និដ្ឋិតោ ។

---

១ ខ ម. តេរសមត្ថិ ទត្ថិ ។

អ្នកប្រាជ្ញនុ៎ះ ជាព្រះពុទ្ធ លែងវិលមកកាន់ភពថ្មីទៀត អ្នកប្រាជ្ញនុ៎ះ ជាសីហៈ (អ្នកកំចាត់នូវកិលេស) ដ៏ប្រសើរ ញុំាងចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ដល់លោក ព្រមទាំងទេវលោក ។ ពួកទេវតា និងមនុស្សណា បានដល់ព្រះពុទ្ធជាទីរលឹក ទេវតា និងមនុស្សទាំងនោះ ក៏មកប្រជុំនមស្ការចំពោះព្រះពុទ្ធដែលមានព្រះទ័យក្លៀវក្លាដ៏ប្រសើរនោះ ។ ព្រះពុទ្ធ ព្រះអង្គទូន្មានខ្លួនដ៏ប្រសើរ ជាងពួកជនអ្នកទូន្មានខ្លួន ព្រះអង្គស្ងប់រម្ងាប់ដ៏ប្រសើរ ជាងពួកជនអ្នកស្ងប់រម្ងាប់ ព្រះអង្គស្វែងរកនូវគុណមានសីលគុណជាដើម ព្រះអង្គមានចិត្តរួចស្រឡះ ដ៏ប្រសើរជាងពួកជនអ្នកមានចិត្តរួចស្រឡះ ព្រះអង្គឆ្លងផុតដ៏ប្រសើរជាងជនអ្នកឆ្លងទាំងឡាយ ។ ព្រោះហេតុនោះឯង ទើបពួកទេវតា និងមនុស្ស តែងនមស្ការចំពោះព្រះពុទ្ធ ដែលមានព្រះទ័យក្លៀវក្លាដ៏ប្រសើរ អង្គនុ៎ះ ។ ក្នុងលោក ព្រមទាំងទេវលោក ឥតមានបុគ្គលណា ប្រៀបផ្ទឹមនឹងព្រះអង្គបានឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ១៣ ។

ចប់ ចតុក្កនិបាត ។

ឥតិវុត្តកេ ចតុក្កនិបាតស្ស ឧទ្ទានំ

តស្សុទ្ទានំ

ព្រាហ្មណា ចត្តារិ ជានំ សមណាសីលា តណ្ហា ព្រហ្មា

ពហុការា(១) កុហនា បុរិសា ចរំ សម្បន្នលោកេន តេរសាតិ ។

ឥតិវុត្តកេ ទ្វាទសាធិកសតសុត្តន្តិ ។

ឥតិវុត្តកំ និដ្ឋិតំ ។

---

សត្តវីសេកនិបាតំ

ទុក្កំ ពាវីសសុត្តសង្គហិតំ

សមបញ្ញាសមេវ តិកំ

តេរស ចតុក្កញ្ច ឥតិ យមិទំ

ទ្វិទសុត្តរសុត្តសតេ

សង្គាយិត្វា សមានយិំសុ បុរា

អរហន្តោ ចិរដ្ឋិតិយា

តមាហុ នាមេន ឥតិវុត្តន្តិ ។

ឥតិវុត្តកបាលិ និដ្ឋិតា ។

ឥទំ មរម្មបោត្ថកេ អាគតំ ។

---

១ ឱ. ពហុបការា ។

ឥតិវុត្តកៈ ចតុក្កនិបាត ឧទ្ទាន

## ឧទ្ទាននៃចតុក្កនិបាតនោះគឺ

និយាយអំពីព្រះមានព្រះភាគជាព្រាហ្មណ៍ ១ វត្ថុងាយបាន ៤ យ៉ាង ១ ការអស់ទៅនៃអាសវៈ របស់បុគ្គលអ្នកដឹង ១ ពួកសមណព្រាហ្មណ៍ ១ ពួកភិក្ខុមានសីល ១ តណ្ហា ១ ត្រកូលដែលនៅរួម នឹងព្រហ្មជាដើម ១ ពួកព្រាហ្មណ៍ នឹងគហបតីមានឧបការៈច្រើន ១ ពួកភិក្ខុអ្នកធ្វើឲ្យគេស្ញើប ជាដើម ១ បុរសត្រូវទឹកស្ទឹងកួច ១ អកុសលវិតក្កៈកើតដល់ ភិក្ខុកំពុងដើរទៅជាដើម ១ ភិក្ខុមានសីលបរិបូណ៌ជាដើម ១ ព្រះតថាគតត្រាស់ដឹងនូវលោក ១ រួមជា ១៣ រឿង ។

ក្នុងឥតិវុត្តកៈ មានសូត្រ ១១២ ។

ចប់ ឥតិវុត្តកៈ ។

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | បន្តិលេខាយំ |
|---|---|---|---|
| វុត្តបរហាតា | វុត្តមរហាតា | ៣ | ១២ |
| អប្បត្តមានស្ស | អប្បត្តមានសស្ស | ១៤ | ៣ |
| អប្បត្តមានស្ស (១) | អប្បត្តមានសស្ស | ១៩ | ៣ |
| ឃានញ្ញុ | ឃានញ្ញុ | ៣២ | ” |
| នទ្ធិ | នត្ថិ | ៣៦ | ១៤ |
| ភរសមុទិតា | ភរសម្មុទិតា | ៤៧ | ៩ |
| ភក្ខុ | ភិក្ខុ | ៤៨ | ៣ |
| អយម្ប | អយម្បិ | ៦៦ | ១២ |
| ទោសោ ច អវិជ្ជា | ទោសោ ច អវិជ្ជា | ៧៨ | ២ |
| រមសុត្តំ | នរមសុត្តំ | ៩៣ | ១ |
| ភាវយីតិ | ភាវយីតិ | ១០២ | ១០ |
| តម្ហា (១) | តម្ហា | ១១២ | ៧ |
| ភដ្ឋត្តំ | ភដ្ឋត្ថំ | ១១៩ | ១៣ |
| ឥត្ថការញ្ញត្ថាការំ | ឥត្ថការញ្ញថាការំ | ១២៤ | ៨ |
| ភក្ខុវេ | ភិក្ខុវេ | ១៣៣ | ១១ |
| អនោត្តប្ប | អនោត្តប្បី | ១៤៧ | ១៦ |

១ ឱ. ម. អប្បត្តមានសស្ស ” ១៤

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ដើម្ប | ដើម្បី | ២ | ៨ |
| អស | អស់ | ១០ | ៧ |
| នៈ | នេះ | ១៦ | ១៣ |
| តថាគតអាច | តថាគតឃើញហេតុសព្វគ្រប់ អាច | ២១ | ១៤ |
| សងត្ក់ | សង្កត់ | ២៧ | ៨ |
| ពីទ្ធ | ពទ្ធី | ២៩ | ១៧ |
| ដូចជាឫស្សីមានផ្លែ | ដូចជាផ្លែឫស្សី | ៦០ | ៩ |
| ព្រះអហន្ត | ព្រះអរហន្ត | ៦៤ | ១៤ |
| ទីប្រកបដោយមរណៈ | ទីប្រកបនៃមរណៈ | ៧២ | ៦ |
| មិនយកនបុគ្គលជាប | មិនយកបុគ្គលជាប | ៩០ | ១៩ |
| អកុសលវិតក្ក | អកុសលវិតក្កៈ | ៩៧ | ៤ |
| ដែលតថាគត | ដែលព្រះតថាគត | ១០២ | ១៩ |
| ប | ▪ | ១០៣ | ១៤ |
| របស | របស់ | ១២៣ | ១៦ |
| អស់ទោ | អស់ទៅ | ១២៦ | ១៥ |
| ដាយល្អ | ដោយល្អ | ១២៧ | ៩ |
| ដាធិល | ដាធិល់ | ១៤៥ | ១៤ |
| គួរវិតក្កៈ | គួរវិតក្កៈ | ១៤៨ | ១០ |

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស ឥតិវុត្តកស្ស

# ទុតិយោ ភាគោ

## មាតិកា


| | | | |
|---|---|---|---|
| | | | អង្គ |
| ឯកនិបាតស្ស | បឋមវគ្គស្ស | បឋមសុត្តំ ........ | ១ |
| | | ទុតិយសុត្តំ ........ | ២ |
| | | តតិយសុត្តំ ........ | ៣ |
| | | ចតុត្ថសុត្តំ ........ | " |
| | | បញ្ចមសុត្តំ ........ | ៤ |
| | | ឆដ្ឋសុត្តំ ........ | ៥ |
| | | សត្តមសុត្តំ ........ | ៦ |
| | | អដ្ឋមសុត្តំ ........ | ៧ |
| | | នវមសុត្តំ ........ | ៨ |
| | | ទសមសុត្តំ ........ | ៩ |
| | ទុតិយវគ្គស្ស | បឋមសុត្តំ ........ | ១០ |
| | | ទុតិយសុត្តំ ........ | " |

# សុត្តន្តបិដក

# ខុទ្ទកនិកាយ ឥតិវុត្តកៈ

## ទុតិយភាគ

## មាតិកា

ទំព័រ


ឯកនិបាត បឋមវគ្គ សូត្រទី ១ . . . . . . . . . . . . . ១

សូត្រទី ២ . . . . . . . . . . . . . ២

សូត្រទី ៣ . . . . . . . . . . . . . ៣

សូត្រទី ៤ . . . . . . . . . . . . . ״

សូត្រទី ៥ . . . . . . . . . . . . . ៤

សូត្រទី ៦ . . . . . . . . . . . . . ៥

សូត្រទី ៧ . . . . . . . . . . . . . ៦

សូត្រទី ៨ . . . . . . . . . . . . . ៧

សូត្រទី ៩ . . . . . . . . . . . . . ៨

សូត្រទី ១០ . . . . . . . . . . . . . ៩

ទុតិយវគ្គ សូត្រទី ១ . . . . . . . . . . . . . ១០

សូត្រទី ២ . . . . . . . . . . . . . ״

មាតិកាបត្តានិ

# មាតិកា


| | | | អង្កេ |
|---|---|---|---|
| ឯកនិបាតស្ស | ទុតិយវគ្គស្ស | តតិយសុត្តំ . . . . . | ១១ |
| | | ចតុត្ថសុត្តំ . . . . . | ១២ |
| | | បញ្ចមសុត្តំ . . . . . | ១៣ |
| | | ឆដ្ឋសុត្តំ . . . . . | ១៤ |
| | | សត្តមសុត្តំ . . . . . | ១៥ |
| | | អដ្ឋមសុត្តំ . . . . . | ១៦ |
| | | នវមសុត្តំ . . . . . | ១៧ |
| | | ទសមសុត្តំ . . . . . | ១៨ |
| | តតិយវគ្គស្ស | បឋមសុត្តំ . . . . . | ២០ |
| | | ទុតិយសុត្តំ . . . . . | ២១ |
| | | តតិយសុត្តំ . . . . . | ២៣ |
| | | ចតុត្ថសុត្តំ . . . . . | ២៤ |
| | | បញ្ចមសុត្តំ . . . . . | ២៥ |
| | | ឆដ្ឋសុត្តំ . . . . . | . |
| | | សត្តមសុត្តំ . . . . . | ២៧ |

# សន្លឹកប្រាប់មាតិកា


| មាតិកា | | | ទំព័រ |
|---|---|---|---|
| ឯកនិបាត | ទុតិយវគ្គ | សូត្រទី ៣ | ១១ |
| | | សូត្រទី ៤ | ១២ |
| | | សូត្រទី ៥ | ១៣ |
| | | សូត្រទី ៦ | ១៤ |
| | | សូត្រទី ៧ | ១៥ |
| | | សូត្រទី ៨ | ១៦ |
| | | សូត្រទី ៩ | ១៧ |
| | | សូត្រទី ១០ | ១៨ |
| | តតិយវគ្គ | សូត្រទី ១ | ២០ |
| | | សូត្រទី ២ | ២១ |
| | | សូត្រទី ៣ | ២៣ |
| | | សូត្រទី ៤ | ២៤ |
| | | សូត្រទី ៥ | ២៥ |
| | | សូត្រទី ៦ | 〃 |
| | | សូត្រទី ៧ | ២៧ |

# មាតិកាបដ្ឋានំ

## មាតិកា


| | | | អង្ក |
|---|---|---|---|
| ទុកនិបាតស្ស | បឋមវគ្គស្ស | បឋមសុត្តំ . . . . . . | ៣១ |
| | | ទុតិយសុត្តំ . . . . . . | ៣២ |
| | | តតិយសុត្តំ . . . . . . | ៣៣ |
| | | ចតុត្ថសុត្តំ . . . . . . | ៣៤ |
| | | បញ្ចមសុត្តំ . . . . . . | ៣៥ |
| | | ឆដ្ឋសុត្តំ . . . . . . | ៣៦ |
| | | សត្តមសុត្តំ . . . . . . | ៣៧ |
| | | អដ្ឋមសុត្តំ . . . . . . | ៣៨ |
| | | នវមសុត្តំ . . . . . . | ៣៩ |
| | | ទសមសុត្តំ . . . . . . | ៤០ |
| | ទុតិយវគ្គស្ស | បឋមសុត្តំ . . . . . . | ៤២ |
| | | ទុតិយសុត្ត . . . . . . | ៤៤ |
| | | តតិយសុត្តំ . . . . . . | ៤៥ |
| | | ចតុត្ថសុត្តំ . . . . . . | ៤៦ |
| | | បញ្ចមសុត្តំ . . . . . . | ៤៨ |

# សន្លឹកប្រាប់មាតិកា

## មាតិកា

| | | | |
|---|---|---|---|
| ទុកនិបាត បឋមវគ្គ | សូត្រទី | ១ | ៣១ |
| | សូត្រទី | ២ | ៣២ |
| | សូត្រទី | ៣ | ៣៣ |
| | សូត្រទី | ៤ | ៣៤ |
| | សូត្រទី | ៥ | ៣៥ |
| | សូត្រទី | ៦ | ៣៦ |
| | សូត្រទី | ៧ | ៣៧ |
| | សូត្រទី | ៨ | ៣៨ |
| | សូត្រទី | ៩ | ៣៩ |
| | សូត្រទី | ១០ | ៤០ |
| ទុតិយវគ្គ | សូត្រទី | ១ | ៤២ |
| | សូត្រទី | ២ | ៤៤ |
| | សូត្រទី | ៣ | ៤៥ |
| | សូត្រទី | ៤ | ៤៦ |
| | សូត្រទី | ៥ | ៤៨ |

# មាតិកាបត្តានិ


| មាតិកា | | | អង្កេ |
|---|---|---|---|
| ទុកនិបាតស្ស | ទុតិយវគ្គស្ស | ឆដ្ឋសុត្តំ . . . . . . | ៤៩ |
| | | សត្តមសុត្តំ . . . . . | ៥០ |
| | | អដ្ឋមសុត្តំ . . . . . . | ៥២ |
| | | នវមសុត្តំ . . . . . | ៥៣ |
| | | ទសមសុត្តំ . . . . . | ៥៤ |
| | | ឯកាទសមសុត្តំ . . . . | ៥៦ |
| | | ទ្វាទសមសុត្តំ . . . . . | ៥៧ |
| តិកនិបាតស្ស | បឋមវគ្គស្ស | បឋមសុត្តំ . . . . . . | ៦០ |
| | | ទុតិយសុត្តំ . . . . . . | " |
| | | តតិយសុត្តំ . . . . . . | ៦១ |
| | | ចតុត្ថសុត្តំ . . . . . . | ៦២ |
| | | បញ្ចមសុត្តំ . . . . . . | ៦៣ |
| | | ឆដ្ឋសុត្តំ . . . . . . | " |
| | | សត្តមសុត្តំ . . . . . . | ៦៤ |
| | | អដ្ឋមសុត្តំ . . . . . . | ៦៥ |

# សន្លឹកប្រាប់មាតិកា

## មាតិកា ទំព័រ


ទុកនិបាត ទុតិយវគ្គ សូត្រទី ៦ .......... ៤៩
សូត្រទី ៧ .......... ៥០
សូត្រទី ៨ .......... ៥២
សូត្រទី ៩ .......... ៥៣
សូត្រទី ១០ .......... ៥៤
សូត្រទី ១១ .......... ៥៦
សូត្រទី ១២ .......... ៥៧
តិកនិបាត បឋមវគ្គ សូត្រទី ១ .......... ៦០
សូត្រទី ២ .......... ״
សូត្រទី ៣ .......... ៦១
សូត្រទី ៤ .......... ៦២
សូត្រទី ៥ .......... ៦៣
សូត្រទី ៦ .......... ״
សូត្រទី ៧ .......... ៦៤
សូត្រទី ៨ .......... ៦៥

# មាតិកាបត្តានំ


| មាតិកា | | | អង្កេ |
|---|---|---|---|
| តិកនិបាតស្ស | បឋមវគ្គស្ស | នវមសុត្តំ | ៦៦ |
| | | ទសមសុត្តំ | ៦៧ |
| | ទុតិយវគ្គស្ស | បឋមសុត្តំ | ៦៩ |
| | | ទុតិយសុត្តំ | " |
| | | តតិយសុត្តំ | ៧០ |
| | | ចតុត្ថសុត្តំ | ៧១ |
| | | បញ្ចមសុត្តំ | ៧២ |
| | | ឆដ្ឋសុត្តំ | ៧៣ |
| | | សត្តមសុត្តំ | ៧៤ |
| | | អដ្ឋមសុត្តំ | " |
| | | នវមសុត្តំ | ៧៦ |
| | | ទសមសុត្តំ | ៧៧ |
| | តតិយវគ្គស្ស | បឋមសុត្តំ | ៧៩ |
| | | ទុតិយសុត្តំ | ៨០ |
| | | តតិយសុត្តំ | ៨២ |

# សន្លឹកប្រាប់មាតិកា

## មាតិកា ទំព័រ


| | | | | |
|---|---|---|---|---|
| តិកនិបាត | បឋមវគ្គ | សូត្រទី | ៩ | ៦៦ |
| | | សូត្រទី | ១០ | ៦៧ |
| | ទុតិយវគ្គ | សូត្រទី | ១ | ៦៩ |
| | | សូត្រទី | ២ | " |
| | | សូត្រទី | ៣ | ៧០ |
| | | សូត្រទី | ៤ | ៧១ |
| | | សូត្រទី | ៥ | ៧២ |
| | | សូត្រទី | ៦ | ៧៣ |
| | | សូត្រទី | ៧ | ៧៤ |
| | | សូត្រទី | ៨ | " |
| | | សូត្រទី | ៩ | ៧៦ |
| | | សូត្រទី | ១០ | ៧៧ |
| | តតិយវគ្គ | សូត្រទី | ១ | ៧៩ |
| | | សូត្រទី | ២ | ៨០ |
| | | សូត្រទី | ៣ | ៨២ |

# មាតិកា

| | | | អង្គ |
|---|---|---|---|
| តិកនិបាតស្ស | តតិយវគ្គស្ស | ចតុត្ថសុត្តំ . . . . . . | ៨៣ |
| | | បញ្ចមសុត្តំ . . . . . . | ៨៤ |
| | | ឆដ្ឋសុត្តំ . . . . . . | ៨៧ |
| | | សត្តមសុត្តំ . . . . . . | ៨៩ |
| | | អដ្ឋមសុត្តំ . . . . . . | ៩១ |
| | | នវមសុត្តំ . . . . . . | ៩២ |
| | | ទសមសុត្តំ . . . . . . | ៩៤ |
| | ចតុត្ថវគ្គស្ស | បឋមសុត្តំ . . . . . . | ៩៧ |
| | | ទុតិយសុត្តំ . . . . . . | " |
| | | តតិយសុត្តំ . . . . . . | ១០០ |
| | | ចតុត្ថសុត្តំ . . . . . . | ១០២ |
| | | បញ្ចមសុត្តំ . . . . . . | ១០៤ |
| | | ឆដ្ឋសុត្តំ . . . . . . | ១០៧ |
| | | សត្តមសុត្តំ . . . . . . | ១០៨ |
| | | អដ្ឋមសុត្តំ . . . . . . | ១០៩ |

# សន្លឹកប្រាប់មាតិកា

## មាតិកា ទំព័រ


តិកនិបាត តតិយវគ្គ សូត្រទី ៤ . . . . . . . . . . . . ៨៣

សូត្រទី ៥ . . . . . . . . . . . . ៨៤

សូត្រទី ៦ . . . . . . . . . . . . ៨៧

សូត្រទី ៧ . . . . . . . . . . ៨៩

សូត្រទី ៨ . . . . . . . . . . ៩១

សូត្រទី ៩ . . . . . . . . . . ៩២

សូត្រទី ១០ . . . . . . . . . . ៩៤

ចតុត្ថវគ្គ សូត្រទី ១ . . . . . . . . . . ៩៧

សូត្រទី ២ . . . . . . . . . . .

សូត្រទី ៣ . . . . . . . . . . ១០០

សូត្រទី ៤ . . . . . . . . . . ១០២

សូត្រទី ៥ . . . . . . . . . . ១០៤

សូត្រទី ៦ . . . . . . . . . . ១០៧

សូត្រទី ៧ . . . . . . . . . . ១០៨

សូត្រទី ៨ . . . . . . . . . . ១០៩

# មាតិកាបន្ទាប់

## មាតិកា


| មាតិកា | | | អង្គ |
|---|---|---|---|
| តិកនិបាតស្ស | ចតុត្ថវគ្គស្ស | នវមសុត្តំ | ១១១ |
| | | ទសមសុត្តំ | ១១៣ |
| | បញ្ចមវគ្គស្ស | បឋមសុត្តំ | ១១៦ |
| | | ទុតិយសុត្តំ | ១១៨ |
| | | តតិយសុត្តំ | ១២០ |
| | | ចតុត្ថសុត្តំ | ១២២ |
| | | បញ្ចមសុត្តំ | ១២៣ |
| | | ឆដ្ឋសុត្តំ | ១២៤ |
| | | សត្តមសុត្តំ | ១២៥ |
| | | អដ្ឋមសុត្តំ | ១២៦ |
| | | នវមសុត្តំ | ១២៨ |
| | | ទសមសុត្តំ | ១២៩ |
| ចតុក្កនិបាតស្ស | | បឋមសុត្តំ | ១៣៣ |
| | | ទុតិយសុត្តំ | ១៣៤ |
| | | តតិយសុត្តំ | ១៣៥ |

# សន្លឹកប្រាប់មាតិកា


| មាតិកា | | | ទំព័រ |
|---|---|---|---|
| តិកនិបាត | ចតុត្ថវគ្គ | សូត្រទី ៩ | ១១១ |
| | | សូត្រទី ១០ | ១១៣ |
| | បញ្ចមវគ្គ | សូត្រទី ១ | ១១៦ |
| | | សូត្រទី ២ | ១១៨ |
| | | សូត្រទី ៣ | ១២០ |
| | | សូត្រទី ៤ | ១២២ |
| | | សូត្រទី ៥ | ១២៣ |
| | | សូត្រទី ៦ | ១២៤ |
| | | សូត្រទី ៧ | ១២៥ |
| | | សូត្រទី ៨ | ១២៦ |
| | | សូត្រទី ៩ | ១២៨ |
| | | សូត្រទី ១០ | ១២៩ |
| | ចតុក្កនិបាត | សូត្រទី ១ | ១៣៣ |
| | | សូត្រទី ២ | ១៣៤ |
| | | សូត្រទី ៣ | ១៣៥ |

# មាតិកាបត្តានិ

## មាតិកា

អង្ក


| | | |
|---|---|---|
| ចតុក្កនិបាតស្ស | ចតុត្ថសុត្តំ . . . . . . | ១៣៧ |
| | បញ្ចមសុត្តំ . . . . . . | ១៣៨ |
| | ឆដ្ឋសុត្តំ . . . . . . | ១៤០ |
| | សត្តមសុត្តំ . . . . . . | ១៤១ |
| | អដ្ឋមសុត្តំ . . . . . . | ១៤៣ |
| | នវមសុត្តំ . . . . . . | ១៤៤ |
| | ទសមសុត្តំ . . . . . . | ១៤៥ |
| | ឯកាទសមសុត្តំ . . . . . | ១៤៧ |
| | ទ្វាទសមសុត្តំ . . . . . . | ១៥០ |
| | តេរសមសុត្តំ . . . . . . | ១៥៣ |

# សន្ទឹកក្រាប់មាតិកា


| មាតិកា | | ទំព័រ |
|---|---|---|
| ចតុក្កនិបាត | សូត្រទី ៤ . . . . . . . . . . . . . | ១៣៧ |
| | សូត្រទី ៥ . . . . . . . . . . . . . | ១៣៨ |
| | សូត្រទី ៦ . . . . . . . . . . . . . | ១៤០ |
| | សូត្រទី ៧ . . . . . . . . . . . . . | ១៤១ |
| | សូត្រទី ៨ . . . . . . . . . . . . . | ១៤៣ |
| | សូត្រទី ៩ . . . . . . . . . . . . . | ១៤៤ |
| | សូត្រទី ១០ . . . . . . . . . . . . . | ១៤៥ |
| | សូត្រទី ១១ . . . . . . . . . . . . . | ១៤៧ |
| | សូត្រទី ១២ . . . . . . . . . . . . . | ១៥០ |
| | សូត្រទី ១៣ . . . . . . . . . . . . . | ១៥៣ |

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយប្រាក់អំណោយនៃ
អ្នកខាងក្រោមនេះ :

Printing costs were met through the gift of

**Wat. Sotoshu Jinnouin Temple**
The Rev. Shoushun Nishimura
2-1-16 Shimizu, Kure-shi, Hiroshima-ken 737 Japan

この本は次の方によって復刻されました。

宗教法人 曹洞宗 神応院 住職　西村正俊
〒737　広島県呉市清水２丁目1-26
☎0823-21-4491

ព្រះត្រៃបិដក ភាគទី ១១០ " អភិធម្មបិដក "
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ
ការបោះពុម្ពជាថ្មីឡើងវិញ របស់សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ
បោះពុម្ព ថ្ងៃទី ១០ កក្កដា ឆ្នាំ ១៩៩៤
សហប្រតិបត្តិការរៀបរៀង និងបោះពុម្ពនៅប្រទេសជប៉ុន

TRIPITAKA VOL. 53 (of 110 volumes total)
"SUTTANTA PITAKA"
Published by the Buddhist Institute, Phnom Penh
Reproduced with the kind cooperation of the
TRIPITAKA PUBLISHING COMMITTEE
First edition December 8, 1994
Printed in Japan by Hirosaki Sogo Printing Ltd.

トリピタカ（南伝大蔵経）全110巻・第53巻スッタンタピタカ（経部）

発　行：プノンペン仏教研究所
復刻救援：カンボジア版トリピタカ(南伝大蔵経)復刻救援委員会
発　行：1994年12月8日

印刷・製本／弘前相互印刷株式会社
製作にあたり弘前相互印刷株式会社の多大な協力を得ました。

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE